ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត




◆ ការបាត់បង់ភាពយន្តឯកសាររបបកម្ពុជាប្រជាធិបតេយ្យ

◆ ប្រវត្តិសាលាក្ដីកាត់ទោសមេដឹកនាំខ្មែរក្រហម

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ ៨៤ ខែធ្នូ ឆ្នាំ២០០៦

ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត

លេខ៨៤ ខែធ្នូ ឆ្នាំ២០០៦

## មាតិកា

◆ សំបុត្រ ៖ ការបាត់បង់ភាពយន្តឯកសាររបបកម្ពុជាប្រជាធិបតេយ្យ ........១

**ផ្នែកឯកសារ**

◆ ហ៊ុន ចំរើន ៖ វិស្វករមកពីប្រទេសបារាំង ........................................១៥

◆ បញ្ជីឈ្មោះជនរងគ្រោះដែលកម្ទេចនៅមន្ទីរ ស-២១ ..........................១៨

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ គុកខ្មែរក្រហម..........................................................................២០

◆ ព្រាត់ស្លាប់..............................................................................២៥

◆ ចំណាត់ឧក្រិដ្ឋកម្មមន្ទីរសន្តិសុខភូមិភាគនិរតី ....................................២៨

◆ វាសនាកូនស្រីខ្ញុំ .........................................................................៣៥

◆ ការចូលរួមរបស់ជនរងគ្រោះ ........................................................៣៧

**ផ្នែកច្បាប់**

◆ ឧក្រិដ្ឋកម្មដែលវិនិច្ឆ័យដោយអង្គជំនុំជម្រះវិសាមញ្ញ ..........................៤២

**វេទិកាពិភាក្សាសាធារណៈ**

◆ ប្រវត្តិសាលាក្ដីកាត់ទោសមេដឹកនាំខ្មែរក្រហម ..............................៥១

**ជំពូកស្រាវជ្រាវរកគ្រួសារ**

◆ ឪពុកម្ដាយរបស់ខ្ញុំក្នុងរបបខ្មែរក្រហម.............................................៦០



ប្រជាជនសួរសំណួរទៅមន្ត្រីតុលាការក្នុងអង្គជំនុំជម្រះវិសាមញ្ញ ក្នុងតុលាការកម្ពុជា



ប្រជាជនដើរទស្សនាអគារគុកនៅមន្ទីរស-២១

**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ

ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា

ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន

លេខ ០២៩១ពម/៩៩

ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

រូបថតឯកសារ ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

**ស្នេរលេខនេះ** ៖ ដេង ពង្សរ៉ាស៊ី, សូ ហ្វារីណា, អៀ ម៉េងទ្រី, កែវ ដាស៊ីល, អូប្រី អាដេម៉ា, ខែលី វ៉ាយលី, ជុំ ចរិយា **អ្នកនិពន្ធនិងស្រាវជ្រាវ** ៖ លី សុផល, ណយ សុផារី, ឌី ខាំបូលី **អ្នកបកប្រែ** ៖ បាន់ ចំរើន, ប៉ាន់ ស៊ីម៉ាឡា **និពន្ធនាយកទូទៅ** ៖ ឆាំង យុ **ក្រាហ្វិកកុំព្យូទ័រ** ៖ គីម សុវណ្ណដានី **គ្រប់គ្រងការចែកផ្សាយ** ៖ វ័ត្ន គាវរាពិដោវ

Email: dccam@online.com.kh, Homepage: www.dccam.org

*សំបុត្រ ៖*

# ការបាត់បង់ភាពយន្តឯកសាររបបកម្ពុជាប្រជាធិបតេយ្យ

ប្រជាជនកម្ពុជាជាងមួយលាននាក់ត្រូវបានជម្លៀសចេញពីទីក្រុងភ្នំពេញនិងទីរួមខេត្តជាច្រើនទៀត នៅពេលដែលខ្មែរក្រហមចូលកាន់អំណាចនៅក្នុងប្រទេសកម្ពុជានៅឆ្នាំ១៩៧៥ ។ ប្រជាជនកម្ពុជាជាច្រើនលាននាក់សុទ្ធតែទទួលការបង្ខំឲ្យធ្វើការ ការឃោសនារបស់ខ្មែរក្រហម និងការតស៊ូប្រយុទ្ធឥតឈប់ឈរប្រឆាំងនឹងវៀតណាម ។ ក៏ប៉ុន្តែ ប្រជាជនកម្ពុជាអាយុក្រោម ៣៥ឆ្នាំ ដែលរស់នៅប្រទេសកម្ពុជាមិនបានឆ្លងកាត់របបខ្មែរក្រហម ហើយក៏មិនជឿថាប្រជាជនកម្ពុជាធ្លាប់រស់នៅដោយវេទនាក្នុងរបបនោះដែរ ព្រោះថា ភាគច្រើននៃអ្នកទាំងនោះគិតថា «ទាល់តែឃើញផ្ទាល់ភ្នែក ទើបជឿ» ។

ដោយសារតែខ្មែរក្រហមមានជំនឿថាខ្លួននឹងកាន់អំណាចជារៀងរហូត ខ្មែរក្រហមបានថតជាខ្សែភាពយន្តនូវសកម្មភាពការងាររបស់ប្រជាជននៅជនបទ ការប្រជុំថ្នាក់កម្មាភិបាលនិងថ្នាក់លើ និងព្រឹត្តិការណ៍ផ្សេងៗទុកសម្រាប់មនុស្សជំនាន់ក្រោយ ។ ក្នុងគោលបំណងឃោសនាផ្សព្វផ្សាយ ខ្មែរក្រហមក៏បានថតសកម្មភាពតស៊ូប្រយុទ្ធជាមួយទាហាន លន់ នល់ និងសកម្មភាពជ័យជម្នះរបស់យោធាផ្សេងៗទៀត ។ បន្ទាប់ពីរបបកម្ពុជាប្រជាធិបតេយ្យត្រូវបានផ្តួលរំលំ ភាពយន្តឯកសារទាំងនេះត្រូវបានយកមករក្សាទុកនៅនាយកដ្ឋានភាពយន្តនៃក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ។

ភាពយន្តឯកសារនេះ គឺជាឯកសារដ៏មានតម្លៃដែលមិនអាចកាត់ថ្លៃបានសម្រាប់ប្រទេសកម្ពុជា ជាពិសេសសម្រាប់ដំណើរការកាត់ទោសមេដឹកនាំខ្មែរក្រហមដែលគ្រោងនឹងចាប់ផ្តើមនៅពាក់កណ្តាលឆ្នាំ២០០៧ ។ ភាពយន្តឯកសារទាំងនេះ ក៏ជាឯកសារដែលអាចជួយដល់ការចោទប្រកាន់មេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម ដូចជា នួន ជា, ខៀវ សំផន, និងអៀង សារី ។ ភាពយន្តឯកសារទាំងនេះ គឺជាផ្នែកដ៏សំខាន់មួយនៃប្រវត្តិសាស្ត្រកម្ពុជាសម័យទំនើបស្តីពីអំពើប្រល័យពូជសាសន៍ និងអាចប្រើប្រាស់ជាឯកសារសម្រាប់ការអប់រំកូនខ្មែរជំនាន់ក្រោយ ។ ក៏ប៉ុន្តែគួរឲ្យសោកស្តាយ ឯកសារទាំងនេះបានបាត់បង់នៅដើមឆ្នាំ១៩៩៨ ហើយសព្វថ្ងៃយើងនៅមិនទាន់ដឹងច្បាស់ពីទីកន្លែងនៃភាពយន្តឯកសារទាំងនេះនៅកន្លែងណាទេ ។

មជ្ឈមណ្ឌលឯកសារកម្ពុជានិងអង្គការផ្សេងៗទៀតបាននិងកំពុងតែស្វះស្វែងរកភាពយន្តឯកសារនៃរបបកម្ពុជាប្រជាធិបតេយ្យនៅទូទាំងពិភពលោកអស់រយៈពេលជិត៩ឆ្នាំមកហើយ ដើម្បីនាំយកភាពយន្តឯកសារទាំងនេះជូនប្រជាជនកម្ពុជាវិញ ។ ក៏ប៉ុន្តែភាពយន្តឯកសារទាំងនេះចល័តគ្រប់ទីកន្លែងដោយសម្ងាត់ ហើយប្រហែលជាមានមនុស្សជាច្រើនបានទទួលផលចំណេញពីភាពយន្តឯកសារនេះផងក៏មិនដឹង ។

## ឆ្នាំ១៩៩៨ ៖ ភាពយន្តឯកសាររបបកម្ពុជាប្រជាធិបតេយ្យចេញពីប្រទេសកម្ពុជាទៅកាន់ប្រទេសបារាំង

នៅខែឧសភា ឆ្នាំ១៩៩៨ មជ្ឈមណ្ឌលឯកសារកម្ពុជាបានស្នើសុំនាយកដ្ឋានភាពយន្តនៃក្រសួងវប្បធម៌និងវិចិត្រសិល្បៈនូវបញ្ជីឈ្មោះភាពយន្តឯកសារដែលធ្វើឡើងនៅក្នុងរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ ក្រសួងវប្បធម៌និងវិចិត្រសិល្បៈបានផ្ញើបញ្ជីឈ្មោះភាពយន្តឯកសារមកឲ្យមជ្ឈមណ្ឌល ដោយបានបញ្ជាក់ថា ក្រសួងបានរក្សាទុកភាពយន្តឯកសារដែលមានរយៈពេលជាង១ពាន់ម៉ោងដែលបង្ហាញពីព្រឹត្តិការណ៍របបកម្ពុជាប្រជាធិបតេយ្យ ។

បញ្ជីឈ្មោះភាពយន្តឯកសារនៃក្រសួងវប្បធម៌និងវិចិត្រសិល្បៈ មានចំនួន១៨៧ដុំ ដែលក្នុងនោះមាន៣៦ដុំជាភាពយន្តឯកសារនៅសម័យសង្គមរាស្ត្រនិយម (១៩៥៤-១៩៧០) ២៦ដុំជាភាពយន្តឯកសារនៅរបបសាធារណរដ្ឋខ្មែរ (១៩៧០-១៩៧៥) ១០១ដុំជាភាពយន្តឯកសារក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និង២៤ដុំជាភាពយន្តឯកសារក្នុងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា(១៩៧៩-១៩៩២) ។

បញ្ជីឈ្មោះភាពយន្តឯកសារនេះចុះហត្ថលេខាដោយប្រធាននាយកដ្ឋានភាពយន្ត ប៊ុន ណារ៉ុទ្ធិ និងអ្នកអភិរក្សបណ្ណសារដ្ឋាន សុខ សុង និងត្រូវបានឯកភាពនិងអនុម័តដោយរដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ នុត ណារ៉ាង នៅថ្ងៃទី៤ ខែមីនា ឆ្នាំ១៩៩៨ ។

ភាពយន្តឯកសារចំនួន១០១ស្តីអំពីកម្ពុជាប្រជាធិបតេយ្យ បង្ហាញពីប្រធានបទផ្សេងៗគ្នា រួមមាន ÷

- ជីវភាពប្រចាំថ្ងៃនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដូចជាការដាំដំណាំនិងការប្រមូលផលតម្បាញ វែកដី ការជីកទំនប់ និងប្រឡាយ និងកុលសម្ព័ន្ធព្រៃភ្នំ ។
- ដំណើរទស្សនកិច្ចរបស់ថ្នាក់ដឹកនាំអន្តរជាតិដែលមានសមានចិត្តចំពោះ របបកម្ពុជាប្រជាធិបតេយ្យ (ដូចជា កូរ៉េ ឡាវ ជាដើម) ។
- ផ្នែកយោធា ៖ កងទ័ពខ្មែរក្រហមតស៊ូប្រយុទ្ធជាមួយនឹងទាហាន លន់ នល់ និងកងទ័ពវៀតណាម ការចូលកាន់កាប់ទីក្រុងភ្នំពេញ និងយុទ្ធនារី ។
- ផ្នែកនយោបាយ ៖ សម័យប្រជុំមហាសន្និបាតកម្ពុជាប្រជាធិបតេយ្យនៅពហុកីឡដ្ឋានអូឡាំពិក ការប្រោរព្ធខួបអនុស្សាវរីយ៍ នៃលទ្ធិកម្មុយនិស្តកម្ពុជា សកម្មភាពពិនិត្យទំនប់ទឹករបស់ ប៉ុល ពត ។

ជាងនេះទៅទៀតភាពយន្តឃើញមាននូវរូបភាពឬសកម្មភាពខ្លីៗរបស់សម្តេច សីហនុ និងសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ។

បន្ទាប់មក មជ្ឈមណ្ឌលឯកសារកម្ពុជាបានសរសេរសំបុត្រផ្ញើជូនឯកឧត្តម នុត ណារ៉ាង រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ស្នើសុំមើលភាពយន្តឯកសារទាំងនេះ ។ ក៏ប៉ុន្តែ នៅពេលដែលយើងទទួលបានការអនុញ្ញាតពីក្រសួងយើងបានទៅឃើញត្រឹមតែបន្ទប់ទទេនិងគ្មានភាពយន្តឯកសារឡើយ ។ បុគ្គលិកនៃក្រសួងវប្បធម៌និងវិចិត្រសិល្បៈ បានប្រាប់យើងថាភាពយន្តឯកសារទាំងនេះត្រូវបានបញ្ជូនទៅកាន់ប្រទេសបារាំងដើម្បី "ធ្វើការជួសជុលឡើងវិញ" និងបាននិយាយថា ភាពយន្តឯកសារទាំងនេះនឹងមិនប្រគល់មកឲ្យប្រទេសកម្ពុជាវិញទេ ប្រសិនបើរាជរដ្ឋាភិបាលកម្ពុជាមិនចំណាយថវិកាដើម្បីដោះដូរភាពយន្តទាំងនេះមកវិញ ។

## ឆ្នាំ១៩៩៩-២០០២ ៖ ការរកឃើញទីកន្លែងរក្សាទុកភាពយន្តឯកសារ តែនៅមានភាពអាថ៌កំបាំង

នៅខែមករា ឆ្នាំ១៩៩៩ ដោយសុំមិនបញ្ចេញឈ្មោះ អ្នកសារព័ត៌មានរបស់ទីភ្នាក់ងារសារព័ត៌មាន រ៉យទ័រ ម្នាក់បានសួរលោក ដានីញែល រឺនូហ្វ ប្រធានក្រុមហ៊ុនទូរទស្សន៍ ស៊ីស្តែមធីវី នៅក្នុងទីក្រុងប៉ូឡូញ (ដែលជាក្រុមហ៊ុនទូរទស្សន៍បារាំងធំបំផុតទី៦) អំពីភាពយន្តឯកសារដែលបាត់បង់ទាំងនេះ ។ លោក ដានីញែល រឺនូហ្វ បានអះអាងថា ក្រុមហ៊ុនស៊ីស្តែមធីវី មានភាពយន្តទាំងនេះ ហើយភាពយន្តនេះត្រូវបានជួសជុលរួចអស់ហើយ ។ ប្រការនេះបានធ្វើឲ្យយើងមានក្តីសង្ឃឹមថា ភាពយន្តឯកសារទាំងនេះនឹងប្រគល់ជូនប្រទេសកម្ពុជាវិញក្នុងពេលឆាប់ៗ ជាពិសេសនៅពេលលោក រឺនូហ្វ ទទួលស្គាល់ថា ឯកសារទាំងនេះជារបស់រាជរដ្ឋាភិបាលកម្ពុជា ។

ប៉ុន្តែក្រោយមកក្រុមហ៊ុនកែប្រែពាក្យសម្តី ។ ជាដំបូង ក្រុមហ៊ុនបានអះអាងថា ខ្លួនមានភាពយន្តឯកសារស្តីអំពីប្រវត្តិសាស្ត្រកម្ពុជាដែលមានរយៈពេលតែ៤០ម៉ោង ហើយក្នុងនោះភាពយន្តឯកសារស្តីអំពីរបបកម្ពុជាប្រជាធិបតេយ្យមានរយៈពេលតែ១០ម៉ោងប៉ុណ្ណោះ ។ លោក រឺនូហ្វ ក៏បាននិយាយថា ភាពយន្តឯកសារទាំងនេះនឹង"ទំនងជាមិនអាចប្រើប្រាស់ជាភស្តុតាង"បានទេ ហើយភាពយន្តឯកសារសំខាន់ៗជាច្រើនទៀតអាចមាននៅប្រទេសវៀតណាម ឬអឺរ៉ុបខាងកើត ឯកសារដើមរក្សាទុកនៅទីនោះ ។ ទីពីរ លោក រឺនូហ្វ បានបញ្ជាក់ថា ក្រុមហ៊ុនរបស់លោកនឹងធ្វើការជួសជុលហ្វីលក្នុង"រយៈពេលបួនទៅប្រាំខែ" ។

លោក រឺនូហ្វ មានប្រសាសន៍ថាក្រុមហ៊ុនទូរទស្សន៍ស៊ីស្តែមធីវី នឹងជួសជុលភាពយន្តឯកសារឡើងវិញដោយមិនគិតថ្លៃក្នុងរយៈពេលបីឆ្នាំខាងមុខ ប៉ុន្តែក្រុមហ៊ុនបានផ្លាស់ប្តូរនូវគោលជំហររបស់ខ្លួនជាថ្មីម្តងទៀត ។ ក្រុមហ៊ុនទូរទស្សន៍ ស៊ីស្តែមធីវី បានប្រកាសជាសាធារណៈថា ប្រជាជនកម្ពុជាត្រូវតែទិញភាពយន្តឯកសារទាំងនេះ ប្រសិនបើចង់បានភាពយន្តឯកសារទាំងនេះត្រឡប់មកវិញ ។ ម្យ៉ាងវិញទៀតនៅក្នុងកិច្ចសន្ទនាជាឯកជន លោក រឺនូហ្វ បានមានប្រសាសន៍ប្រាប់ខ្ញុំថា ក្រុមហ៊ុនទូរទស្សន៍ ស៊ីស្តែមធីវី មិនមានរក្សាទុកនូវភាពយន្តឯកសារទាំងនេះទេ ។

បញ្ហាដែលត្រូវបានដឹងជាសាធារណៈនោះ គឺត្រង់ចំណុចដែលថាឯកឧត្តម នុត ណារ៉ាង បានចុះហត្ថលេខាលើកិច្ចសន្យាមួយទំព័រជាមួយលោក រីនូហ្វ ក្នុងការប្រគល់ភាពយន្តឯកសារទាំងនេះទៅឲ្យក្រុមហ៊ុនទូរទស្សន៍ ស៊ីស្ដែមធីវី ។ ក៏ប៉ុន្តែ នៅក្នុងកិច្ចសន្យានេះមិនបានបញ្ជាក់ពីចំនួនទឹកប្រាក់ដែលក្រុមហ៊ុនបារាំងនេះបានចំណាយទិញភាពយន្តឯកសារទាំងនេះ និងថែមទាំងមិនបានបញ្ជាក់នូវកាលបរិច្ឆេទដែលភាពយន្តឯកសារនេះត្រូវប្រគល់មកឲ្យប្រទេសកម្ពុជាវិញនៅពេលណាផងទេ ។

ខ្ញុំបានព្យាយាមសរសេរសំបុត្រទាក់ទងឯកឧត្តម នុត ណារ៉ាង ជាច្រើនលើក ក៏ប៉ុន្តែខ្ញុំពុំដែលទទួលបានចម្លើយតបវិញឡើយ ។ ជាងនេះទៅទៀត ទោះបីជាខ្ញុំបានធ្វើការទាក់ទងជាមួយនឹងមន្ត្រីរាជរដ្ឋាភិបាលផ្សេងៗជាច្រើនទៀតក៏ដោយ ក៏មន្ត្រីទាំងនេះជាទូទៅបានបដិសេធមិនទទួលខុសត្រូវចំពោះការទាមទារភាពយន្តឯកសារត្រឡប់មកវិញដែរ ឬបាននិយាយថាខ្លួន "រវល់ពេក" មិនមានពេលវេលាដោះស្រាយបញ្ហានេះទេ ។

ដូចគ្នានេះដែរ ក្រុមហ៊ុនទូរទស្សន៍បារាំងហាក់ដូចជាមិនចង់ផ្ដល់ព័ត៌មានស្ដីអំពីភាពយន្តឯកសារនេះទាល់តែសោះ ។ មន្ត្រីស្ថានទូតបារាំងបានបដិសេធមិនលូកដៃចូលទៅក្នុងរឿងនេះទេ ពីព្រោះភាពយន្តឯកសារទាំងនេះ ជាប្រយោជន៍ឯកជន ។ ម្យ៉ាងវិញទៀត លោក រីនូហ្វ បានបញ្ជាក់ថា កិច្ចព្រមព្រៀងឆ្នាំ ១៩៩៨ ហាមគាត់មិនឲ្យបេញផ្សាយភាពយន្តឯកសារនេះដរាបណាគ្មានសេចក្ដីណែនាំពីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ។ លោក រីនូហ្វ បានបន្ថែមទៀតថា គាត់ពុំដែលបានទទួលនូវសំណើណាមួយជាផ្លូវការពីក្រសួងវប្បធម៌និងវិចិត្រសិល្បៈឡើយ ។ លោក រីនូហ្វ បានមានប្រសាសន៍ថា "យើងកំពុងតែថែរក្សាភាពយន្តឯកសារទាំងនេះក្នុងទីកន្លែងដែលមានសុវត្ថិភាព និងត្រឹមត្រូវ ។ ប្រសិនបើរាជរដ្ឋាភិបាលកម្ពុជាចង់បានឯកសារនេះត្រឡប់ទៅវិញ រាជរដ្ឋាភិបាលកម្ពុជាត្រូវតែធ្វើសំណើសុំជាមុនសិន" ។

នៅចន្លោះពេលនេះ ផ្នែកជាច្រើននៃភាពយន្តឯកសារទាំងនេះបានចាប់ផ្ដើមចាក់បញ្ចាំងនៅក្នុងកម្មវិធីភាពយន្តតែស្ដាប់មិនបាន ដែលធ្វើឲ្យមជ្ឈមណ្ឌលធ្វើការសន្និដ្ឋានថា កិច្ចការជួសជុលភាពយន្តឯកសារឡើងវិញត្រូវបានធ្វើចប់សព្វគ្រប់រួចទៅហើយ ។ ក្រុមហ៊ុនទូរទស្សន៍នេះទំនងជាអ្នកដែលកាន់កាប់ភាពយន្តទាំងនេះតែម្នាក់គត់ ហើយភាពយន្តទាំងនេះក៏ទំនងជាសម្រាប់ដាក់លក់ទៀតផង ។

## ឆ្នាំ២០០២-២០០៦ ៖ គេហទំព័រមិនច្បាស់លាស់នៅបន្ត

នៅពាក់កណ្ដាលឆ្នាំ២០០២ រឿងនេះខ្ញុំបានសុំទៅឲ្យអង្គភាពប្រឆាំងអំពើពុករលួយនៃទីស្ដីការគណៈរដ្ឋមន្ត្រីជាអ្នកដោះ-ស្រាយ ។ លោក សំ សុខុន ប្រធាននាយកដ្ឋានភាពយន្តនៃក្រសួងវប្បធម៌និងវិចិត្រសិល្បៈ បានមានប្រសាសន៍ជាសាធារណៈថា រាជរដ្ឋាភិបាលកម្ពុជាបានស្នើសុំឲ្យមានការប្រគល់ភាពយន្តឯកសារទាំងនេះត្រឡប់មកឲ្យកម្ពុជាវិញ ។ លោក សំ សុខុន បានប្រមែប្រមូលភាពយន្តឯកសារជាច្រើនដែលចាប់ផ្ដើមនៅក្នុងឆ្នាំ១៩៧៩ នៅពេលដែលឯកសារខ្មែរក្រហមជាច្រើនត្រូវបានបោះបង់និងដុតបំផ្លាញចោលបន្ទាប់ពីរបបកម្ពុជាប្រជាធិបតេយ្យត្រូវបានផ្ដួលរំលំ ។

បញ្ហានេះបានកើតឡើងជាថ្មីនិងជាសាធារណៈ នៅពេលដែលអត្ថបទមួយដែលមានចំណងជើងថា "ភាពយន្តឯកសារប្រវត្តិ-សាស្ត្រដ៏កម្សត់នៅក្នុងប្រទេសបារាំង"ចុះផ្សាយជាភាសាអង់គ្លេសនៅក្នុងកាសែតក្នុងស្រុកមួយឈ្មោះ ភ្នំពេញប៉ុស្តិ៍ ចុះថ្ងៃទី២៥ ខែមេសា - ថ្ងៃទី៨ ខែឧសភា ឆ្នាំ២០០៣ ។ នៅក្នុងអត្ថបទនេះ ឯកឧត្តម នុត ណារ៉ាង ពេលនោះ ជាសមាជិកសភាត្រូវបានដកស្រង់សម្ដីដោយមានប្រសាសន៍ថា ឯកឧត្តមធ្លាប់បានឃើញភាពយន្តឯកសារនេះនៅក្នុងឆ្នាំ១៩៩៩ និងមានអារម្មណ៍ភ្ញាក់ផ្អើលយ៉ាងខ្លាំងចំពោះស្ថានភាពនៃភាពយន្តឯកសារទាំងនេះដោយសារតែចំនួនពាក់កណ្ដាលត្រូវបានលួច ឬខូចខាត ។ ឯកឧត្តម នុត ណារ៉ាង ក៏បានបដិសេធចំពោះការលក់ភាពយន្តឯកសារទាំងនេះដោយបញ្ជាក់ថាភាពយន្តឯកសារទាំងនេះត្រូវបានបញ្ជូនទៅកាន់ប្រទេសបារាំងដើម្បីជួសជុលនិងថែរក្សា ។ ឯកឧត្តម បានមានប្រសាសន៍ថា "ព័ត៌មានដែលសារព័ត៌មានបានចុះផ្សាយថា ខ្ញុំបានលក់ភាពយន្តប្រវត្តិសាស្ត្រនេះមិនពិតនោះទេ ។ អ្វីដែលខ្ញុំធ្វើ គឺដើម្បីថែរក្សាវប្បធម៌តែប៉ុណ្ណោះ" ។

ឯកឧត្តម ស៊ាន វិសុទ្ធ ប្រធានអង្គភាពប្រឆាំងអំពើពុករលួយ

បានធ្វើឲ្យការវែកគំនិតគ្នានេះកាន់តែធំឡើង នៅពេលដែលឯកឧត្តមត្រូវបានដកស្រង់សម្តីដោយមានប្រសាសន៍ថា "លោក ឆាំង យុ ប្រធានមជ្ឈមណ្ឌលឯកសារកម្ពុជា ពុំមានភ័ស្តុតាងគ្រប់គ្រាន់ដើម្បីចង្អុលបញ្ហានេះ ។ ខ្ញុំនឹងពិនិត្យមើលបញ្ហានេះ ប្រសិនបើក្រសួងវប្បធម៌និងវិចិត្រសិល្បៈដាក់សំណើទៅដល់ទីស្តីការគណៈរដ្ឋមន្ត្រីនោះ ។ ប្រសិនបើពុំមានបណ្តឹងណាមួយពីជនរងគ្រោះទេនោះ ប៉ុន្តែសក៏មិនអាចធ្វើអ្វីបានដែរ" ។

លោកស្រី អីដវីង ឡាហ្វរ៉ែត ដែលជាអ្នកស្រាវជ្រាវភាពយន្តជនជាតិបារាំងបាននិយាយបន្ថែមទៅលើបញ្ហាអាថ៌កំបាំងនៃទីកន្លែងរក្សាទុកភាពយន្តឯកសារទាំងនេះ ។ លោកស្រីបានមានប្រសាសន៍ថា ភាពយន្តឯកសារទាំងនេះត្រូវបានលាក់ទុកនៅក្នុងបណ្ណសារដ្ឋានធំមួយរបស់បារាំង គឺបណ្ណាល័យ ប៉ាថេ (Pathé Library) ។ លោកស្រីបានអះអាងថា "វាហាក់ដូចជាកិច្ចព្រមព្រៀងរវាងក្រុមហ៊ុនទូរទស្សន៍ ស៊ីស្តែមធីវី និងបណ្ណាល័យ ប៉ាថេ ជាដំបូងធ្វើឡើងដើម្បីជួសជុល និងបន្ទាប់មកឈានទៅដល់ការព្រមព្រៀងគ្នាស្តីពីការចែកចាយភាពយន្តឯកសារទាំងនេះ ដែលនឹងជាការលួចបន្លំដ៏ធំមួយ" ។ កាសែតភ្នំពេញប៉ុស្តិ៍ បានស្រាវជ្រាវរកឃើញគេហទំព័ររបស់បណ្ណាល័យ ប៉ាថេ ដែលគេហទំព័រនេះ មិនមាននូវរូបភាពណាមួយស្តីពីរបបកម្ពុជាប្រជាធិបតេយ្យនោះទេ ។ បណ្ណាល័យនេះមិនបានឆ្លើយតបទៅនឹងសំណើសុំរបស់កាសែតភ្នំពេញប៉ុស្តិ៍ នូវព័ត៌មានបន្ថែមឡើយ ។

នៅក្នុងបទសម្ភាសន៍ជាមួយ ដានីញែល រីនួហ្វ ដែលចុះផ្សាយនៅក្នុងអត្ថបទនេះ លោកបានអះអាងថា ភាពយន្តឯកសារស្តីអំពីរបបកម្ពុជាប្រជាធិបតេយ្យរក្សាទុកនៅក្រុមហ៊ុនទូរទស្សន៍ ស៊ីស្តែមធីវី នៅក្នុងបន្ទប់សុវត្ថិភាព ។ ក៏ប៉ុន្តែ លោក រីនួហ្វ បាននិយាយខុសពីពេលមុនទាក់ទិននឹងការជួសជុលភាពយន្តឯកសារឡើងវិញ ដោយលោកបានមានប្រសាសន៍ថា កិច្ចការនេះត្រូវការថវិកាចំនួន៦ម៉ឺន៥ពាន់ដុល្លារសហរដ្ឋអាមេរិក ។ លោក រីនួហ្វ សន្យាថា ប្រសិនបើលោកអាចទទួលបាននូវថវិកាជាថ្លៃការ លោកនឹងប្រគល់ភាពយន្តទាំងនេះជូនក្រសួងវប្បធម៌និងវិចិត្រសិល្បៈវិញ ដែលនៅពេលនោះព្រះអង្គម្ចាស់ក្សត្រី បុប្ផា ទេវី ជាព្រះប្រធាន ។

លោក រីនួហ្វ បានបញ្ជាក់ជាថ្មីថា ប្រសិនបើក្រសួងវប្បធម៌និងវិចិត្រសិល្បៈចង់បានភាពយន្តទាំងនេះត្រឡប់ទៅវិញនោះ ក្រសួងត្រូវតែធ្វើសំណើសុំត្រឡប់ទៅវិញ ។ ឆ្លើយតបទៅនឹងការចោទសួររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា លោក រីនួហ្វ បានបន្ថែមទៀតថា "ប្រសិនបើ លោក ឆាំង យុ ចង់ពិនិត្យមើលភាពយន្តទាំងនេះ លោក ឆាំង យុ គួរតែជួបពិភាក្សាជាមួយប្រធាននាយកដ្ឋាននៃក្រសួងវប្បធម៌និងវិចិត្រសិល្បៈ" ។

មជ្ឈមណ្ឌលឯកសារកម្ពុជាបានផ្តល់ចម្លើយទៅវិញតាមរយៈការសរសេរសំបុត្រផ្ញើជូនកាសែតភ្នំពេញប៉ុស្តិ៍ ដោយបានដកស្រង់នូវប្រសាសន៍របស់ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី សុខ អាន ថា ÷

*រដ្ឋាភិបាលកម្ពុជាបានឯកភាពអនុញ្ញាតឲ្យលោកធ្វើការស្រាវជ្រាវឯកសារនានា ដែលពាក់ព័ន្ធនឹងអំពើប្រល័យពូជសាសន៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា និងនៅក្នុងបណ្តាប្រទេសទាំងឡាយដែលពាក់ព័ន្ធដល់ឯកសាររបបប្រល័យពូជសាសន៍នៅកម្ពុជា តាមរយៈអង្គការក្រៅរដ្ឋាភិបាលរបស់លោកដែលមានឈ្មោះថា មជ្ឈមណ្ឌលឯកសារកម្ពុជា ។*

ក៏ប៉ុន្តែ ពុំមានចម្លើយតបបន្ថែមពីលោក រីនួហ្វ ទេ ។

បន្ទាប់មកទៀត អ្នកដែលទាក់ទិននឹងការវែកគំនិតគ្នានេះ គឺផលិតករភាពយន្តកម្ពុជារស់នៅប្រទេសបារាំងឈ្មោះ ប៉ាន់ ឫទ្ធី ។ លោក ប៉ាន់ ឫទ្ធី ក៏មានបំណងពិនិត្យឡើងវិញនូវភាពយន្តឯកសារទាំងនេះដែរ ក៏ប៉ុន្តែត្រូវក្រុមហ៊ុនទូរទស្សន៍ ស៊ីស្តែម ធីវី បដិសេធដោយបាននិយាយថាលោក ប៉ាន់ ឫទ្ធី ត្រូវតែមានការអនុញ្ញាតពីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ។ ប្រភពផ្សេងៗទៀត ដូចជាក្រុមហ៊ុនទូរទស្សន៍អាមេរិកកម្មវិធី ៦០នាទី ក៏បានព្យាយាមសាកល្បងដែរ ក៏ប៉ុន្តែក្រុមហ៊ុនទូរទស្សន៍ ស៊ីស្តែមធីវី បាននិយាយថា អ្នកទាំងនោះពុំមានសិទ្ធិពិនិត្យភាពយន្តឯកសារទាំងនេះទេ ។

## ក្រុមហ៊ុនឯកជនមួយព្យាយាមស្វែងរកភាពយន្តឯកសារនេះ

ស្ថានភាពដ៏ចម្រូងចម្រាសនេះបានអូសបន្លាយរហូតដល់ចុងខែមីនា ឆ្នាំ២០០៦ នៅពេលដែលការទាក់ទងគ្នាបានចាប់ផ្តើមរវាងលោក ដេម លីនណើ នៃក្រុមហ៊ុន មីឌា មេធី (ដែលជាក្រុមហ៊ុនមួយមានមូលដ្ឋាននៅទីក្រុងញូវយ៉កដែលមានជំនាញខាង

ផ្នែកឯកសារសោតទស្សន៍) និងបណ្ណសារដ្ឋានជាតិកម្ពុជា ។ លីនណឺ បានធ្វើការជាមួយបណ្ណសារដ្ឋានជាតិកម្ពុជា និងមានការព្រួយបារម្ភជាខ្លាំងអំពីបញ្ហាបាត់បង់នូវភាពយន្តឯកសារនេះ ។ ដោយហេតុនេះ លោកបានខិតខំស្វះស្វែងរកឲ្យឃើញទីកន្លែងរក្សាទុកភាពយន្តឯកសារទាំងនេះ ។ លោក លីនណឺ បានទំនាក់ទំនងទៅវិទ្យាស្ថានសោតទស្សន៍បារាំង (INA) នៅក្នុងទីក្រុងប៉ារីសនៃប្រទេសបារាំង ដែលបានបញ្ជាក់ថា វិទ្យាស្ថាននឹងពិនិត្យស្ថានភាពនៃភាពយន្តឯកសារទាំងនេះ ។ លោក បានចាត់ទុកបញ្ហានេះជាការបង្ហាញជាវិជ្ជមានមួយដែលថា វិទ្យាស្ថានជាតិមានរក្សាទុកភាពយន្តឯកសារស្តីអំពីរបបកម្ពុជាប្រជាធិបតេយ្យមួយចំនួនធំទាំងអស់ ។

ក្រោយមកលោក លីនណឺ បានសរសេរសំបុត្រផ្ញើជូនឯកឧត្តម ជា សោភ័ណ រដ្ឋលេខាធិការនៃទីស្តីការគណៈរដ្ឋមន្ត្រី ដោយស្នើសុំឲ្យឯកឧត្តមសរសេរសំបុត្រក្រៅផ្លូវការផ្ញើជូនវិទ្យា-ស្ថានសោតទស្សន៍បារាំង ដើម្បីស្នើសុំជំនួយពីវិទ្យាស្ថានក្នុងការស្វែងរកទីកន្លែងរក្សាភាពយន្តឯកសារនេះ និងការប្រគល់ឯកសារនេះមកឲ្យកម្ពុជាវិញ ។ បើទោះបីជាពុំមានចម្លើយតបពីវិទ្យាស្ថាននេះក៏ដោយ នៅខែមេសា លោក លីនណឺ បានទទួលការអះអាងបញ្ជាក់ក្រៅផ្លូវការពីវិទ្យាស្ថានបារាំងថាខ្លួនបានរក្សាទុកឯកសារទាំងនេះ ។

មួយខែក្រោយមកទៀត លោក អេមមេនញូអែល ហ៊ូក នៃវិទ្យាស្ថានសោតទស្សន៍បារាំង បានសរសេរសំបុត្រផ្ញើជូនលោក លីនណឺ ដោយបញ្ជាក់ថា អង្គការរបស់លោកបានបញ្ចប់កិច្ចព្រមព្រៀងជាមួយក្រសួងវប្បធម៌កម្ពុជា ។ កិច្ចព្រមព្រៀងនេះ បានប្រគល់ឲ្យវិទ្យាស្ថានសោតទស្សន៍បារាំង ធ្វើការជួសជុលនិងអភិរក្សភាពយន្តឯកសារទាំងនេះ ។ លោក លីនណឺ ក៏បានបញ្ជាក់ទៀតថា វិទ្យាស្ថានសោតទស្សន៍បារាំងនឹងរក្សាទុកឯកសារដើម ហើយបញ្ជូនឯកសារថតចម្លងជូនអាជ្ញាធរកម្ពុជា ។ អ្វីដែលមាននៅក្នុងកិច្ចព្រមព្រៀងនោះពុំត្រូវបានប្រកាសឲ្យដឹងជាសាធារណៈឡើយ ។

លោក លីនណឺ បានឆ្លើយតបទៅលោក ហ៊ូក ដោយចម្លងជូនលោកស្រី លឹម គី អនុប្រធានបណ្ណសារជាតិកម្ពុជា និងឯក-ឧត្តម ជា សោភ័ណ ។ លោក លីនណឺ បានប្រាប់លោក ហ៊ូក ថា បណ្ណសារដ្ឋានជាតិនិងទីស្តីការគណៈរដ្ឋមន្ត្រីមិនមានកិច្ចព្រមព្រៀងរវាងក្រសួងវប្បធម៌និងវិចិត្រសិល្បៈនិងវិទ្យាស្ថានសោតទស្សន៍បារាំងនោះទេ ហើយលោក លីនណឺ បានស្នើសុំព័ត៌មានបន្ថែម ។ លោក លីនណឺ ក៏បានស្នើឲ្យលោក ហ៊ូក បញ្ជាក់ឲ្យបានច្បាស់នូវស្ថានភាពបច្ចុប្បន្ននៃកិច្ចខិតខំប្រឹងប្រែងជួសជុលភាពយន្តឯកសារឡើងវិញរបស់វិទ្យាស្ថានសោតទស្សន៍បារាំង និងពេលវេលាដែលការជួសជុលនេះនឹងត្រូវបញ្ចប់ ។ ជាចុងក្រោយ លោក លីនណឺ បានសុំឲ្យវិទ្យាស្ថានសោតទស្សន៍បារាំងផ្តល់ឲ្យបណ្ណសារឯកសារថតចម្លងឌីជីថល ដើម្បីឲ្យបណ្ណសារជាតិនិងទីស្តីការគណៈរដ្ឋមន្ត្រី អាចយល់ដឹងពីខ្លឹមសារភាពយន្តឯកសារដែលវិទ្យាស្ថានរក្សាទុក ។

លោក ហ៊ូក បានផ្ញើសំបុត្រមួយនៅក្នុងខែឧសភា ដែលមិនបានឆ្លើយតបទៅនឹងគ្រប់សំណួរទាំងអស់របស់លោក លីនណឺ ។ ខ្លឹមសារនៃសំបុត្របានបញ្ជាក់ថា អង្គការរបស់លោកធ្វើការទាក់ទងតែជាមួយរដ្ឋមន្ត្រីថ្មីនៃក្រសួងវប្បធម៌តែប៉ុណ្ណោះ គឺអ្នកអគ្គម្ចាស់ ស៊ីសុវត្ថិ ប៉ាណារ៉ាសិរីវុឌ្ឍ ដែលបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះ ។ ប្រហែលជាដោយសារតែលោក ហ៊ូក យល់ថា លោកកំពុងតែដើរនៅក្នុងផ្លូវនយោបាយគ្រោះថ្នាក់មួយ លោក ហ៊ូក នៅតែប្រកាន់ខ្ជាប់ថា បណ្ណសារដ្ឋានជាតិត្រូវតែដោះស្រាយបញ្ហានេះជាមួយអ្នកអគ្គម្ចាស់ស៊ីសុវត្ថិ ប៉ាណារ៉ាសិរីវុឌ្ឍ ។

បណ្ណសារដ្ឋានជាតិបានឆ្លើយតបថា ខ្លួនបាន“ពិភាក្សា”អំពីការត្រៀមរៀបចំសរសេរសំបុត្រផ្ញើជូនលោក លីនណឺ ជាមួយនឹងអគ្គលេខាធិការនៃសមាគមបណ្ណសារសោតទស្សន៍អាស៊ីអាគ្នេយ៍ប៉ាស៊ីហ្វិក *(SEAPAVAA)* គឺលោក ដេមី លាន ។ តំណាងនៃបណ្ណសារដ្ឋានជាតិកម្ពុជាបានមានប្រសាសន៍ថា បណ្ណសារដ្ឋានជាតិកម្ពុជាបានសហការជាមួយគណៈកម្មាធិការនៃសមាគមនេះទៅលើគម្រោងបញ្ជូនឯកសារត្រឡប់មកវិញ ។

នៅខែឧសភា បណ្ណសារដ្ឋានជាតិបានជូនដំណឹងទៅលោក លីនណឺ ថា អគ្គលេខាធិការនៃសមាគមបណ្ណសារសោតទស្សន៍អាស៊ីអាគ្នេយ៍ប៉ាស៊ីហ្វិក *(SEAPAVAA)* បានផ្តល់ចម្លើយតបបណ្ណ-សារដ្ឋានជាតិក្រៅផ្លូវការ ។ លោកបានបញ្ជាក់ថា លោកមានអារម្មណ៍សប្បាយរីករាយជាខ្លាំងចំពោះការផ្លូវស្រាលថ្មីៗ ក្នុង

*ការស្រាវជ្រាវរកមកវិញនូវភាពយន្តឯកសារទាំងនេះ និងបានបញ្ជាក់ថា លោកនឹងពិភាក្សាជាមួយអ្នកអគ្គម្ចាស់ ស៊ីសុវត្ថិ ប៉ាណារ៉ាសីរីវុឌ្ឍ អំពីបញ្ហាទាំងនេះ ។ អ្នកអគ្គម្ចាស់បានសន្យាថា នឹងផ្តល់ព័ត៌មានឲ្យលោក លីនណឺ នៅពេលដែលអ្នកអគ្គម្ចាស់មានព័ត៌មានគ្រប់គ្រាន់ស្តីអំពីស្ថានភាពភាពយន្តឯកសារទាំងនេះ ។*

*បណ្ណសារដ្ឋានជាតិក៏បានជូនដំណឹងទៅដល់លោក លីនណឺ អំពីគម្រោងថ្មីមួយរបស់ស្ថានទូតបារាំងហៅថាមជ្ឈមណ្ឌលធនធានសោតទស្សន៍ហនុមានកម្ពុជា ដែលកំពុងធ្វើការពីបញ្ហាភាពយន្តឯកសារទាំងនេះជាមួយនាយកដ្ឋានភាពយន្តនៃក្រសួងវប្បធម៌និងវិចិត្រសិល្បៈ (មិនមែនជាមួយបណ្ណសារដ្ឋានជាតិទេ) ។ បណ្ណសារដ្ឋានជាតិបានសង្កត់ធ្ងន់ថា ទោះបីជាមជ្ឈមណ្ឌលហនុមានអាចប្រមែប្រមូលភាពយន្តឯកសារទាំងនេះក៏ដោយ ក៏មជ្ឈមណ្ឌលនេះមិនអាចរក្សាទុកភាពយន្តឯកសារនេះដោយស្របច្បាប់បានទេ ។ បណ្ណសារដ្ឋានជាតិបានលើកឡើងពីច្បាប់បណ្ណសារដ្ឋានកម្ពុជាដែលចែងថា ក្រសួងទាំងអស់ត្រូវតែបញ្ជូនបណ្ណសារទៅឲ្យបណ្ណសារដ្ឋានជាតិ ហើយអង្គការក្រៅរដ្ឋាភិបាលទាំងអស់ដែលកំពុងតែបំពេញការងារនៅក្នុងប្រទេសកម្ពុជាត្រូវតែថតចម្លងគម្រោងរបស់ខ្លួនផ្ញើជូនបណ្ណសារដ្ឋានជាតិ ។*

*លោក លីនណឺ បានសរសេរសំបុត្រផ្ញើជូនទៅមជ្ឈមណ្ឌលហនុមាន ដោយចោទសួរអំពីតួនាទីរបស់មជ្ឈមណ្ឌល ។ ការឆ្លើយតបរបស់មជ្ឈមណ្ឌលហនុមាន គឺមានសភាពស្រពេចស្រពិលថាតើមជ្ឈមណ្ឌលបានប្រមែប្រមូលឯកសារចម្លងឌីជីថលជាសំឡេងនិងរូបភាពស្តីពីប្រវត្តិសាស្ត្រកម្ពុជា ប្រពៃណី ឬវប្បធម៌ ។ ដោយកត់សម្គាល់ឃើញថាខ្លួនពុំមានអាណត្តិត្រឹមត្រូវតាមច្បាប់ មជ្ឈមណ្ឌលហនុមានបានអះអាងជាថ្មីថា ខ្លួនមានបំណងប្រមែប្រមូលឯកសារភាពយន្តថតចម្លងឌីជីថលទាំងអស់ដែលមាននៅក្នុងប្រទេសកម្ពុជានិងក្រៅប្រទេស ។*

*ដោយចង់ដឹងពីភាពយន្តឯកសារស្តីអំពីរបបកម្ពុជាប្រជាធិបតេយ្យ លោក លីនណឺ បានសរសេរសំបុត្រផ្ញើទៅមជ្ឈមណ្ឌលហនុមានជាថ្មីម្តងទៀត ដោយបានសួរថាតើមជ្ឈមណ្ឌលបានដឹងអ្វីខ្លះអំពីស្ថានភាពនៃភាពយន្តឯកសារដែលរក្សាទុកនៅវិទ្យាស្ថានសោតទស្សន៍បារាំង អំពីស្ថានភាពឯកសារទាំងនេះ អំពីការជួសជុលឡើងវិញ និងពេលវេលាដែលបណ្ណសារដ្ឋានជាតិនឹងទទួលបានឯកសារចម្លងឌីជីថល ។ លោក លីនណឺ បានសួរជាច្រើនសំណួរផ្សេងៗទៀត ដូចជាថាតើមជ្ឈមណ្ឌលហនុមានបានឃើញកិច្ចសន្យាជាមួយនឹងវិទ្យាស្ថានសោតទស្សន៍បារាំងដែរឬទេ និងថាតើមជ្ឈមណ្ឌលនឹងសហការជាមួយបណ្ណសារដ្ឋានជាតិដែរឬទេ ។ នៅត្រឹមខែវិច្ឆិកា ឆ្នាំ២០០៦ លោក លីនណឺ មិនទាន់បានទទួលចម្លើយតបអ្វីនៅឡើយទេ ហើយការតាមដាននេះហាក់ដូចជាមិនទៅមុខសោះ ។*

### ការពិតចាំបាច់ត្រូវតែបង្ហាញ

*មជ្ឈមណ្ឌលឯកសារកម្ពុជាមានឯកសារដែលបង្ហាញអំពីទីកន្លែងដែលរក្សាទុកភាពយន្តឯកសារដែលបាត់បង់ បើទោះបីជាមជ្ឈមណ្ឌលពុំមានលទ្ធភាពក្នុងការបង្ហាញយ៉ាងច្បាស់លាស់នូវទីកន្លែងរក្សាទុកឯកសារពិតប្រាកដក៏ដោយ ។ គេហទំព័ររបស់មជ្ឈមណ្ឌលបុប្ផាណាបង្ហាញថា ខ្លួនកំពុងតែសហការគ្នារវាងវិទ្យាស្ថានសោតទស្សន៍បារាំងនិងក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ។ គេហទំព័រនេះក៏បានបញ្ជាក់ថា ក្រសួងវប្បធម៌និងវិចិត្រសិល្បៈបានប្រគល់ឲ្យមជ្ឈមណ្ឌលធនធានសោតទស្សន៍ នូវភាពយន្តឯកសារមួយចំនួនធំដើម្បីធ្វើការជួសជុលឡើងវិញ និងថតចម្លងជារូបភាពឌីជីថល ។*

*តើមជ្ឈមណ្ឌលបុប្ផាណាមានរក្សាទុកនូវភាពយន្តឯកសារដែលបាត់បង់នេះដែរឬទេ?*

*នៅចុងបញ្ចប់ មិនសំខាន់ថាតើភាពយន្តឯកសារទាំងនេះនៅទីណា ថាតើទឹកប្រាក់ចំនួនប៉ុន្មាន ត្រូវបានប្រគល់ទៅឲ្យអ្នកណានោះទេ និងថាតើនរណាខ្លះបាននិយាយរឿងពិតនោះទេ ។ អ្វីដែលសំខាន់នោះ គឺការប្រគល់ភាពយន្តឯកសារទាំងនេះមកឲ្យប្រទេសកម្ពុជាវិញដែលជាម្ចាស់កម្មសិទ្ធិស្របច្បាប់ ។*

**ឆាំង យុ**

## ពាក្យស្លោកខ្មែរក្រហម

- **ស្លាប់ក្នុងសង្គ្រាមប្រសើរជាងរស់។**

*(សៀវភៅកំណត់ហេតុលេខ១០ ៧/៧)*

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ**
នាយកដ្ឋានសិល្បៈភាពយន្តនិងផ្សព្វផ្សាយវប្បធម៌
ការិយាល័យឯកសារដ្ឋាន

## បញ្ជីខ្សែភាពយន្តឯកសារ
## ដែលយកទៅប្រទេសបារាំងដើម្បីឆ្លងចម្លងធ្វើឱ្យថ្មីឡើងវិញ

| លរ | ចំណងជើងឯកសារ | ជំនាន់ផលិត | ប្រភេទ | ខ្នាត | ប្រវែង ជាម៉ែត្រ | ពណ៌ ស-ខ្មៅ | លេខ សំគាល់ |
|---|---|---|---|---|---|---|---|
| | I ខ្សែភាពយន្តឯកសារជំនាន់សង្គមរាស្ត្រនិយម | | | | | | |
| 01 | សម្តេចទាមទារឯករាជ្យ | សង្គមរាស្ត្រនិយម | Positif | 16mm | 321 | ស-ខ្មៅ | ស-១ |
| 02 | សោភ័ណ្ឌភាពនៅពេលកវិល | សង្គមរាស្ត្រនិយម | Négatif | 16mm | 194 | ពណ៌ | ស-២ |
| 03 | របាំប្រជាប្រិយខ្មែរ | សង្គមរាស្ត្រនិយម | Positif | 16mm | 198 | ស-ខ្មៅ | ស-៣ |
| 04 | ស្ពានផ្លូវរថភ្លើង-សម្ពោធស្ថានីយរថភ្លើង | សង្គមរាស្ត្រនិយម | Négatif | 16mm | 212 | ស-ខ្មៅ | ស-៤ |
| 05 | ទស្សនកិច្ច-ប្រជុំកាងារ-ចែកអំណោយ | សង្គមរាស្ត្រនិយម | Négatif | 16mm | 206 | ស-ខ្មៅ | ស-៥ |
| 06 | ទស្សនកិច្ចឧត្តមនាវី ហ៊ែលគី | សង្គមរាស្ត្រនិយម | Positif | 16mm | 110 | ស-ខ្មៅ | ស-៦ |
| 07 | បច្ចុប្បន្នភាព | សង្គមរាស្ត្រនិយម | Négatif | 16mm | 231 | ស-ខ្មៅ | ស-៧ |
| 08 | រឿងវែង La joie de vivre | សង្គមរាស្ត្រនិយម | Négatif | 16mm | 148 | ស-ខ្មៅ | ស-៨ |
| 09 | ពិធីច្រត់ព្រះនង្គ័ល | សង្គមរាស្ត្រនិយម | Négatif | 16mm | 240 | ស-ខ្មៅ | ស-៩ |
| 10 | កឋិនទាន ប្រគល់ចង់ផ្កាលា | សង្គមរាស្ត្រនិយម | Négatif | 16mm | 220 | ស-ខ្មៅ | ស-១០ |
| 11 | ប្រជុំការងារ-សម្ភាសន៍-ចែកអំណោយ | សង្គមរាស្ត្រនិយម | Négatif | 16mm | 215.5 | ស-ខ្មៅ | ស-១១ |
| 12 | បដិសណ្ឋារកិច្ចភ្ញៀវរដ្ឋ លីក្វាងយូ | សង្គមរាស្ត្រនិយម | Négatif | 16mm | 215.4 | ស-ខ្មៅ | ស-១២ |
| 13 | សន្និសីទសារពត៌មាន វេជ្ជសាស្ត្រ | សង្គមរាស្ត្រនិយម | Négatif | 16mm | 241.6 | ស-ខ្មៅ | ស-១៣ |
| 14 | ស្រមោលអង្គរវត្ត | សង្គមរាស្ត្រនិយម | Négatif | 16mm | 397 | ស-ខ្មៅ | ស-១៤ |
| 15 | ហែព្រះពុទ្ធរូបមានបដា-ដង្ហែរក្បួនស្តេច( ធំ ) | សង្គមរាស្ត្រនិយម | Négatif | 16mm | 102 | ស-ខ្មៅ | ស-១៥ |
| 16 | ជប់លៀងដោយសម្តេច •នៅប្រាសាទខេមរិន្ទ សម្តេចទទួលទាហាន•ប្រជុំ ( ញ៉ក ជួម៉ុង ) រៀបចំក្រុមកុន | សង្គមរាស្ត្រនិយម | Négatif | 16mm | 137 | ស-ខ្មៅ | ស-១៦ |
| 17 | សម្តេចចែកអំណោយដោយផ្ទាល់ •សិល្បៈ ថ្វាយសម្តេចមហាក្សត្រីយានី ( ស៊ុត ) | សង្គមរាស្ត្រនិយម | Négatif | 16mm | 141.6 | ស-ខ្មៅ | ស ១៧ |
| 18 | និវេសនដ្ឋាន ៤ស.ទ ( សម្តេចសម្ពោធ ) | សង្គមរាស្ត្រនិយម | Négatif | 16mm | 46.5 | ស-ខ្មៅ | ស-១៨ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| 19 | សម្តេចយាងសម្ពោធ ចាប់ដៃប្រជាជន | សង្គមរាស្ត្រនិយម | Négatif | 16mm | 98.4 | ស_ខ្មៅ | ស_១៩ |
| 20 | សម្តេចជាយុវជន_យុវនារី_សម្តេចទទួលភ្ញៀវនៅចំការមន អ៊ុន តាំ ចែកអំណោយ | សង្គមរាស្ត្រនិយម | Négatif | 16mm | 108 | ស_ខ្មៅ | ស_២០ |
| 21 | សម្តេចប្រជុំនៅចំការមន | សង្គមរាស្ត្រនិយម | Négatif | 16mm | 51.4 | ស_ខ្មៅ | ស_២១ |
| 22 | សវនាការសម្តេចនៅចំការមន សម្តេចជួនប្រជាជន ព្រះសង្ឃទស្សនារោងចក្រនៅកំពង់សោម | សង្គមរាស្ត្រនិយម | Négatif | 16mm | 103.7 | ស_ខ្មៅ | ស_២២ |
| 23 | សម្ពោធស្ពាន ថ្វាយផ្កានៅវិហារព្រះកែវ | សង្គមរាស្ត្រនិយម | Négatif | 16mm | 43.1 | ស_ខ្មៅ | ស_២៣ |
| 24 | លោក យឹម នីត យុវជនប្លង់ស្លុងនៅភ្នំឧត្តុង្គ | សង្គមរាស្ត្រនិយម | Négatif | 16mm | 58.1 | ស_ខ្មៅ | ស_២៤ |
| 25 | ពិធីបុណ្យអុំទូកឃើញពីខាងកើត សម្តេចកាប់ដីជាមួយប្រជាជន | សង្គមរាស្ត្រនិយម | Négatif | 16mm | 43 | ស_ខ្មៅ | ស_២៥ |
| 26 | មាតុភូមិនិវត្តន៍ពីប្រទេសបារាំង ជាមួយអ្នកម្នាងម៉ូនិក | សង្គមរាស្ត្រនិយម | Négatif | 16mm | 67.7 | ស_ខ្មៅ | ស_២៦ |
| 27 | សម្តេចសីហនុសម្ពោធសាលារៀនអង្គតាសោម និង ជួសជុលប្រាសាទបុរាណ | សង្គមរាស្ត្រនិយម | Positif | 16mm | 110 | ពណ៌ | ស_២៧ |
| 28 | ពិធីភ្ជាប់ពាក្យព្រះអង្គម្ចាស់ចាំង | សង្គមរាស្ត្រនិយម | Positif | 16mm | 113.3 | ស_ខ្មៅ | ស_២៨ |
| 29 | សៀកចិន _ ទស្សនកិច្ចសម្តេចសីហនុនៅប៉េកាំង • អុំទូកនៅកម្ពុជា | សង្គមរាស្ត្រនិយម | Négatif | 16mm | 29.2 | ស_ខ្មៅ | ស_២៩ |
| 30 | ពិធីថ្វាយព្រះសុគន្ធវារី _ការចេញដំណើររបស់នាយករដ្ឋមន្ត្រី លន់ ណុល _ព្រះរាជពិធីចំរើនព្រះជន្ម ពិធីប្រគល់ឈើយៀកកុង ពិធីផ្ទេរដំណែង _ទស្សនកិច្ចឯកឧត្តមនីយ៉ូនីហាម៉ានី _ពិធីខួបឆ្នាំទី១៦បុណ្យឯករាជ្យ | សង្គមរាស្ត្រនិយម | Positif | 16mm | 316.9 | ស_ខ្មៅ | ស_១៤៥ |
| | <u>II ខ្សែភាពយន្តឯកសារជំនាន់ លន់ ណុល</u> | | | | | | |
| 31 | លោក រិល តិនសុន ទស្សនាចំការកៅស៊ូ | លន់ ណុល | Négatif | 16mm | 130.9 | ស_ខ្មៅ | ល_៣០ |
| 32 | ប្រតិបត្តិការសឹក_មហាសន្និបាត | លន់ ណុល | Négatif | 16mm | 104.8 | ស_ខ្មៅ | ល_៣១ |
| 33 | កុម្មង់ដូនារីហាត់បាញ់កាំភ្លើង_បោះឆ្នោតចំហរនៅសភាប្រតិបត្តិការសុរិយា_បំពាក់សក្តិសិស្សនាយទាហាន | លន់ ណុល | Négatif | 16mm | 202.7 | ស_ខ្មៅ | ល_៣២ |
| 34 | ការហ្វឹកហាត់យុទ្ធជនស្ម័គ្រចិត្ត | លន់ ណុល | Négatif | 16mm | 177.9 | ស_ខ្មៅ | ល_៣៣ |
| 35 | ពិធីបុណ្យនៃកិច្ចប្រតិបត្តិការអគ្គីនេត្រ | លន់ ណុល | Négatif | 16mm | 192.3 | ស_ខ្មៅ | ល_៣៤ |
| 36 | ពិធីប្រគល់អំណោយដល់ជនភៀសខ្លួន | លន់ ណុល | Négatif | 16mm | 257.6 | ស_ខ្មៅ | ល_៣៥ |
| 37 | សម័យប្រជុំសភាលើកទី២៤ នៅចំការមន | លន់ ណុល | Positif | 16mm | 83.2 | ស_ខ្មៅ | ល_៣៦ |
| 38 | ទស្សនកិច្ចប្រធានាធិបតីនៅតាខ្មៅ | លន់ ណុល | Négatif | 16mm | 281.9 | ស_ខ្មៅ | ល_៣៧ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| 39 | បច្ចុប្បន្នភាព ‐ ទស្សនកិច្ច លន់ ណុល ក្នុងក្រុងភ្នំពេញ | លន់ ណុល | Négatif | 16mm | 281.8 | ស‐ខ្មៅ | ល‐៣៨ |
| 40 | ព្យុហយាត្រាឥតុលានៅមុខវាំងសិល្ប និស្សិត កងទ័ព អ្នកធ្វើការ លើកបដា ស្រែកជ័យ ឃោសតាមទីផ្សារ តាមផ្លូវឆ្នាំ១៩៧០ | លន់ ណុល | Négatif | 16mm | 154.9 | ស‐ខ្មៅ | ល‐៣៩ |
| 41 | ឈាបនកិច្ច លោក ស៊ុំ សាវុធ | លន់ ណុល | Négatif | 16mm | 30 | ស‐ខ្មៅ | ល‐៤០ |
| 42 | សង្គ្រាមបំផ្លាញខ្មោចខ្មីផ្ទះទឹកទាហ៊ាន | លន់ ណុល | Positif | 35mm | 111.1 | ស‐ខ្មៅ | ល‐៤១ |
| 43 | បាតុកម្មដេញយៀកកុងពីស្រុក‐មានបាតុករ‐បដា‐ទ័ពប្រយុទ្ធ ‐ M113 ‧ សវនាការ លន់ ណុល | លន់ ណុល | Négatif | 16mm | 404.2 | ស‐ខ្មៅ | ល‐៤២ |
| 44 | ជនភៀសខ្លួនពីតំបន់ខ្មាំង | លន់ ណុល | Négatif | 16mm | 320 | ស‐ខ្មៅ | ល‐៤៣ |
| 45 | ប្រគល់ទង់ថ្នាលានៅស្វាយរៀង | លន់ ណុល | Négatif | 16mm | 133.1 | ស‐ខ្មៅ | ល‐៤៤ |
| 46 | ចំបាំងរថក្រោះ 7BI ( M113ឆេះ + M113 បាញ់) | លន់ ណុល | Négatif | 16mm | 19.4 | ស‐ខ្មៅ | ល‐៤៥ |
| 47 | កងទ័ពចេនឡាគោកធ្លក | លន់ ណុល | Négatif | 16mm · | 39.9 | ស‐ខ្មៅ | ល‐៤៦ |
| 48 | ប្រគេនទេយ្យទានព្រះសង្ឃរងគ្រោះ‧ការបង្ហាញ ខ្លួនទាហានយៀកកុង ‧ ព្យុហយាត្រានៅ Stade Olympique | លន់ ណុល | Négatif | 16mm | 142.6 | ស‐ខ្មៅ | ល‐៤៧ |
| 49 | ទស្សនកិច្ច ឡុង បូរ៉េត នៅបាត់ដំបង ‐ ប៉ៃលិន‐ឧត្តរមានជ័យ‐កំពង់ធំ‧កំពង់ឆ្នាំង | លន់ ណុល | Négatif | 16mm | 144.7 | ស‐ខ្មៅ | ល‐៤៨ |
| | **<u>III ខ្សែភាពយន្តឯកសារជំនាន់ ប៉ុល ពត</u>** | | | | | | |
| 50 | សិល្បៈកងទ័ពប្រឆាំងរបប លន់ ណុល | ប៉ុល ពត | Négatif | 16mm | 324.5 | ស‐ខ្មៅ | ប‐៤៩ |
| 51 | ពិធីបុណ្យរួម ពាកង | ប៉ុល ពត | Négatif | 16mm | 294.7 | ស‐ខ្មៅ | ប‐៥០ |
| 52 | ឧស្សាហកម្មចុនស្រោល | ប៉ុល ពត | Négatif | 16mm | 565.2 | ស‐ខ្មៅ | ប‐៥១ |
| 53 | ទស្សនាព្រែកជីក ១មករា | ប៉ុល ពត | Positif | 35mm | 104.6 | ស‐ខ្មៅ | ប‐៥២ |
| 54 | សិប្បកម្មតម្បាញ ‧ រោងចក្រតម្បាញ | ប៉ុល ពត | Positif | 35mm | 130 | ស‐ខ្មៅ | ប‐៥៣ |
| 55 | វែកដីច្រុងកាំបិតស្ទូងស្រូវផែនទីវាយលុក កងទ័ពប៉ុលពតប្រយុទ្ធជាមួយទាហ៊ានលន់ ណុល | ប៉ុល ពត | Positif | 35mm | 134 | ស‐ខ្មៅ | ប‐៥៤ |
| 56 | ទស្សនកិច្ចថ្នាក់ដឹកនាំគូរ៉េប្រគល់ត្រាក់ទ័រ | ប៉ុល ពត | Positif | 16mm | 307.1 | ស‐ខ្មៅ | ប‐៥៥ |
| 57 | ស្រែល្វឹងល្វើយ ‧ ច្រូតបោកបែន ‧ ស្ទូងមនុស្សច្រើន ‧ ធ្វើបង្គីវែកដី ‧ ធ្វើទំនប់ទឹក មនុស្សច្រើន | ប៉ុល ពត | Négatif | 16mm | 203 | ស‐ខ្មៅ | ប‐៥៦ |
| 58 | កងទ័ពប៉ុលពតវាយសំរុកចូលទីក្រុងភ្នំពេញ ‧ ឆេះកញ្ចាល់សាំង | ប៉ុល ពត | Positif | 16mm | 156.3 | ស‐ខ្មៅ | ប‐៥៧ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| 59 | ធ្វើស្រូវប្រាំង • ជាន់រហាត់ទឹក | ប៉ុល ពត | Positif | 35mm | 72.6 | ស_ខ្មៅ | ប_៥៨ |
| 60 | សមរភូមិក្រោយវាយសំរុកដើម្បីសមរភូមិមុខ | ប៉ុល ពត | Positif | 35mm | 37.8 | ស_ខ្មៅ | ប_៥៩ |
| 61 | នារីស្រែអំបិល • ចិញ្ចឹមសត្វ • ដាំដំណាំ | ប៉ុល ពត | Positif | 35mm | 80.7 | ស_ខ្មៅ | ប_៦០ |
| 62 | បុណ្យចាត់តាំងកងទ័ព ( ថតសំរាប់ធ្វើជាឯកសារ របៀបប្រយុទ្ធនៅវៀតណាម_ស្មា_ចំរោងទ័ពលន់ ណុល ) | ប៉ុល ពត | Négatif | 16mm | 111.2 | ស_ខ្មៅ | ប_៦១ |
| 63 | មិទ្ទិញនៅស្ពាត ( ពណ៌ល្អ ) | ប៉ុល ពត | Positif | 35mm | 262.4 | ស_ខ្មៅ | ប_៦២ |
| 64 | ប្តេជ្ញាវាយសំរុកជីកអាងទឹក១៧មេសា( ភូមិភាគឧត្តរ ) | ប៉ុល ពត | Positif | 35mm | 140.5 | ស_ខ្មៅ | ប_៦៣ |
| 65 | កសិកម្ម • បាចជី • ពោចស្មៅ • ត្បាញ | ប៉ុល ពត | Négatif | 16mm | 165.8 | ស_ខ្មៅ | ប_៦៤ |
| 66 | ច្រូតកាត់ពោតបែន ( ប្តូពើ ) | ប៉ុល ពត | Positif | 35mm | 291.6 | ស_ខ្មៅ | ប_៦៥ |
| 67 | ប្រព័ន្ធប្រឡាយ | ប៉ុល ពត | Négatif | 35mm | 106.8 | ស_ខ្មៅ | ប_៦៦ |
| 68 | វាយសំរុកកសិកម្ម | ប៉ុល ពត | Négatif | 35mm | 58.6 | ស_ខ្មៅ | ប_៦៧ |
| 69 | កសិកម្ម | ប៉ុល ពត | Négatif | 16mm | 72.2 | ស_ខ្មៅ | ប_៦៨ |
| 70 | ផ្សាភ្ជាប់សមរភូមិក្រោយ និង សមរភូមិមុខ | ប៉ុល ពត | Négatif | 16mm | 303.1 | ស_ខ្មៅ | ប_៦៩ |
| 71 | ផ្ទុលផុលកចាល់ទឹក • ផលិតទឹកដោះគោ | ប៉ុល ពត | Positif | 16mm | 360.3 | ស_ខ្មៅ | ប_៧០ |
| 72 | ពេទ្យជ្រោយចង្វារ | ប៉ុល ពត | Positif | 35mm | 240.8 | ស_ខ្មៅ | ប_៧១ |
| 73 | យុទ្ធជន _ នារីឆ្វេងទន្លេមេគង្គ | ប៉ុល ពត | Positif | 35mm | 79.1 | ស_ខ្មៅ | ប_៧២ |
| 74 | ភូមិភាគនិរតី | ប៉ុល ពត | Positif | 35mm | 144.8 | ស_ខ្មៅ | ប_៧៣ |
| 75 | សង្គ្រាមចំរូងឫស្សី | ប៉ុល ពត | Positif | 35mm | 213 | ស_ខ្មៅ | ប_៧៤ |
| 76 | ផ្ទុលផុលផ្លូវដែក ( មានអៀងសារី ) សង់ផ្ទះ ប្រជុំក្នុងសហករណ៍ | ប៉ុល ពត | Positif | 35mm | 231.1 | ស_ខ្មៅ | ប_៧៥ |
| 77 | ជីកប្រឡាយលើកទំនប់ភូមិភាគបស្ចឹម | ប៉ុល ពត | Positif | 35mm | 84.5 | ស_ខ្មៅ | ប_៧៦ |
| 78 | ប្រព័ន្ធប្រឡាយ _ ទំនប់ ( មនុស្សច្រើន ) | ប៉ុល ពត | Positif | 35mm | 136.4 | ស_ខ្មៅ | ប_៧៧ |
| 79 | មិទ្ទិញនៅស្ពាតល្បហយាត្រា M113 - មានកាណុង និងមានរូបប៉ុល ពត | ប៉ុល ពត | Négatif | 35mm | 219.2 | ស_ខ្មៅ | ប_៧៨ |
| 80 | កងទ័ពការពារនៅភូមិភាគបស្ចិម ( Pol Pot នៅស្ពាត ) ៉ទ្វី៉ | ប៉ុល ពត | Négatif | 35mm | 115.8 | ស_ខ្មៅ | ប_៧៩ |
| 81 | តំបន់កោះកុង | ប៉ុល ពត | Positif | 35mm | 83 | ស_ខ្មៅ | ប_៨០ |
| 82 | សុជានុវង្សទស្សនាកម្ពុជាប្រជាធិបតេយ្យ(២ម៉ឺ) | ប៉ុល ពត | Négatif | 16mm | 337.9 | ស_ខ្មៅ | ប_៨១ |
| 83 | ក្រុមសាធារណការប៉ុល ពត | ប៉ុល ពត | Négatif | 16mm | 117.3 | ស_ខ្មៅ | ប_៨២ |
| 84 | ធ្វើស្រូវវស្សា | ប៉ុល ពត | Négatif | 16mm | 166 | ស_ខ្មៅ | ប_៨៣ |
| 85 | បណ្តុះបណ្តាលវិជ្ជាបច្ចេកទេស | ប៉ុល ពត | Positif | 35mm | 237.4 | ពណ៌ | ប_៨៤ |
| 86 | ប្រព័ន្ធភ្លើស្រែ | ប៉ុល ពត | Positif | 35mm | 196.4 | ស_ខ្មៅ | ប_៨៥ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| 87 | ភូមិភាគឧត្តរ ( ជីកប្រឡាយ•បំបែកថ្ម ) | ប៉ុល ពត | Positif | 35mm | 58.2 | ស_ខ្មៅ | ប_៨៦ |
| 88 | រែកគ្រាប់ • សមរភូមិប្រយុទ្ធ • ខ្មោចស្លាប់ •រថក្រោះឆេះខ្ទេចខាតទៅនឹងកន្លែង •ឃើញ មួកកងទ័ពវៀតណាម ( វាយជាមួយកងទ័ពវៀតណាម ប្រហែលជាឆ្នាំ1978 )(Coupie de travail) | ប៉ុល ពត | Positif | 16mm | 332 | ស_ខ្មៅ | ប_៨៧ |
| 89 | សង្គ្រាមព្រួញ_ ចំរុងឫស្សី | ប៉ុល ពត | Positif | 35mm | 298.9 | ស_ខ្មៅ | ប_៨៨ |
| 90 | ពេទ្យស់ត្វ _ ផ្សិនិសថ | ប៉ុល ពត | Positif | 35mm | 241.3 | ស_ខ្មៅ | ប_៨៩ |
| 91 | ច្រូតកាត់បោកបែននៅភូមិភាគពាយ័ព្យ | ប៉ុល ពត | Positif | 35mm | 113.9 | ស_ខ្មៅ | ប_៩០ |
| 92 | កងកាំភ្លើងធំ B40 | ប៉ុល ពត | Négatif | 16mm | 144 | ស_ខ្មៅ | ប_៩១ |
| 93 | បុណ្យចាត់តាំងទ័ព | ប៉ុល ពត | Positif | 16mm | 237.5 | ស_ខ្មៅ | ប_៩២ |
| 94 | ភូមិភាគឧត្តរ ( កាប់ដី •រែកដី ) | ប៉ុល ពត | Positif | 35mm | 95.4 | ស_ខ្មៅ | ប_៩៣ |
| 95 | ឆាកល្ខោនខ្មីៗ | ប៉ុល ពត | Négatif | 16mm | 346 | ស_ខ្មៅ | ប_៩៤ |
| 96 | ការធ្វើឧបករណ៍បំរើកសិកម្ម | ប៉ុល ពត | Négatif | 16mm | 112 | ស_ខ្មៅ | ប_៩៥ |
| 97 | ប្រព័ន្ធភ្លឺស្រែថ្មី ( ឧត្តរ ) | ប៉ុល ពត | Positif | 35mm | 136 | ស_ខ្មៅ | ប_៩៦ |
| 98 | ធ្វើស្រែប្រាំង_សមរភូមិក្រោយនិងសមរភូមិមុខ | ប៉ុល ពត | Négatit | 16mm | 188.2 | ស_ខ្មៅ | ប_៩៧ |
| 99 | ធយោបាយទឹក • វារីអគ្គិសនី | ប៉ុល ពត | Négatif | 16mm | 349 | ស_ខ្មៅ | ប_៩៨ |
| 100 | ស្នាដៃបនឧក្រិដ្ឋយួនឈ្លានពានទឹកដីខ្មែរធ្វើស្រែ •ផ្ទះឆេះស្វាយរៀង •ផ្លូវជាតិលេខ៧•ផ្ទះបាក់ បែក• PolPot ប្រជុំ•ផ្ទះឆេះ | ប៉ុល ពត | Négatif | 16mm | 223.4 | ស_ខ្មៅ | ប_៩៩ |
| 101 | ធ្វើថ្នល់ . ឃ្លាំងដាក់ស្រូវ | ប៉ុល ពត | Négatif | 16mm | 174.1 | ស_ខ្មៅ | ប_១០០ |
| 102 | ស្នាដៃយួនឈ្លានពានលេបទឹកដី | ប៉ុល ពត | Négatif | 16mm | 292.9 | ស_ខ្មៅ | ប_១០១ |
| 103 | រែកដី ( ងងឹត ) | ប៉ុល ពត | D.Nég | 16mm | 236 | ស_ខ្មៅ | ប_១០២ |
| 104 | វត្តមហាវាយសំរុក ១មករា៧៥ | ប៉ុល ពត | Négatif | 16mm | 155.5 | ស_ខ្មៅ | ប_១០៣ |
| 105 | ទស្សនកិច្ចភូរ៉េ • លាវ នៅកម្ពុជា | ប៉ុល ពត | Négatif | 16mm | 306.8 | ស_ខ្មៅ | ប_១០៤ |
| 106 | ស្នាដៃយួនឈ្លានពានលេបទឹកដី•បាញ់ថ្នាំស្រូវ • សង្គ្រាមឆេះផ្ទះសំបែង | ប៉ុល ពត | Positif | 16mm | 286 | ស_ខ្មៅ | ប_១០៥ |
| 107 | តំបន់សៀមរាបអង្គរ | ប៉ុល ពត | Négatif | 35mm | 119 | ស_ខ្មៅ | ប_១០៦ |
| 108 | ច្រូតស្រូវ ( ងងឹត ) | ប៉ុល ពត | Positif | 35mm | 181 | ស_ខ្មៅ | ប_១០៧ |
| 109 | ច្រូត . ជីកកណ្តាប់ . ទូលកញ្ជើស្រូវ ប្រឡាយ . បន្លែ ទូលកញ្ជើបន្លែ | ប៉ុល ពត | Négatif | 16mm | 231.6 | ស_ខ្មៅ | ប_១០៨ |
| 110 | ទំនប់វារីអគ្គិសនី . ស្ទូង . ច្រូតស្រូវ សមរភូមិស្វាយរៀង សមរភូមិផ្លូវជាតិលេខ៧ ភូមិភាគនិរតី | ប៉ុល ពត | Positif | 16mm | 279.5 | ស_ខ្មៅ | ប_១០៩ |
| 111 | រោងចក្រធ្វើបារី . ច្រូត . ត្បាញ | ប៉ុល ពត | Négatif | 16mm | 251.1 | ស_ខ្មៅ | ប_១១០ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| 112 | ការរីកចំរើនខាងរោងចក្រពីសិប្បកម្មទៅឧស្សាហកម្ម | ប៉ុល ពត | D.Nég | 16mm | 130.7 | ស_ខ្មៅ | ប_១១១ |
| 113 | សង្គ្រាមយោធា ប៉ុល ពត | ប៉ុល ពត | Négatif | 16mm | 133.2 | ស_ខ្មៅ | ប_១១២ |
| 114 | ធ្លាក់យន្តហោះ , វះត្រីធ្វើដៀត | ប៉ុល ពត | Négatif | 16mm | 91.4 | ស_ខ្មៅ | ប_១១៣ |
| 115 | សង់ទំនប់អាងទឹក , ប្រមូលផលស្រូវ | ប៉ុល ពត | Positif | 16mm | 109 | ស_ខ្មៅ | ប_១១៤ |
| 116 | បោកស្រូវ , រហាត់ទឹក | ប៉ុល ពត | Négatif | 16mm | 70.3 | ស_ខ្មៅ | ប_១១៥ |
| 117 | សំណង់បេតុង | ប៉ុល ពត | Négatif | 16mm | 153 | ស_ខ្មៅ | ប_១១៦ |
| 118 | ផ្ទះឆេះចាក់បែកទល់ដែនវៀតណាម | ប៉ុល ពត | Négatif | 16mm | 62.1 | ស_ខ្មៅ | ប_១១៧ |
| 119 | ធ្វើស្រែជុំវិញទន្លេសាប | ប៉ុល ពត | Négatif | 16mm | 81 | ស_ខ្មៅ | ប_១១៨ |
| 120 | ខួបទី៩ កងទ័ពប៉ុល ពត ( ស្អិត ) | ប៉ុល ពត | Négatif | 35mm | 112.5 | ស_ខ្មៅ | ប_១១៩ |
| 121 | កម្មករធ្វើស្រែអំបិល | ប៉ុល ពត | D.Nég | 16mm | 85 | ស_ខ្មៅ | ប_១២០ |
| 122 | កាប់ដី , ច្រូតស្រូវ , ដឹកជញ្ជូន | ប៉ុល ពត | Négatif | 16mm | 89 | ស_ខ្មៅ | ប_១២១ |
| 123 | ប្រតិបត្តិការលើកភូមិភាគបូព៌ា | ប៉ុល ពត | Négatif | 16mm | 65.9 | ស_ខ្មៅ | ប_១២២ |
| 124 | ធ្វើថ្នល់ | ប៉ុល ពត | Négatif | 16mm | 96.4 | ស_ខ្មៅ | ប_១២៣ |
| 125 | ទិវាបុណ្យខួបទី១៧នៃរបបកុម្មុយនិស្ត មាន ប៉ុល ពត | ប៉ុល ពត | Positif | 16mm | 47.7 | ស_ខ្មៅ | ប_១២៤ |
| 126 | របាំនៅជនបទ | ប៉ុល ពត | Négatif | 35mm | 153 | ស_ខ្មៅ | ប_១២៥ |
| 127 | កងទ័ព ប៉ុល ពត ធ្វើដំណើរទៅសមរភូមិ | ប៉ុល ពត | Négatif | 16mm | 80.5 | ស_ខ្មៅ | ប_១២៦ |
| 128 | ភូមិភាគ ពាយ័ព្យ | ប៉ុល ពត | D.Nég | 16mm | 90 | ស_ខ្មៅ | ប_១២៧ |
| 129 | កងទ័ពប៉ុលពតបាញ់ផ្លោងទៅទន្លេមេកុង | ប៉ុល ពត | Négatif | 16mm | 148.6 | ស_ខ្មៅ | ប_១២៨ |
| 130 | ផ្ទះឆេះក្រោយពេលសង្គ្រាមជាមួយវៀតណាម | ប៉ុល ពត | Négatif | 16mm | 113.8 | ស_ខ្មៅ | ប_១២៩ |
| 131 | ស្មារតីប្រយុទ្ធរបស់យុទ្ធនារីផលិតអំបិល (យកឡាន៤០៤ទៅធ្វើជាកំលាំងបូមទឹកសមុទ្រ ) | ប៉ុល ពត | Positif | 16mm | 88.8 | ស_ខ្មៅ | ប_១៣០ |
| 132 | ផ្ទះឆេះចាក់បែកលិចទឹក | ប៉ុល ពត | Négatif | 16mm | 50.5 | ស_ខ្មៅ | ប_១៣១ |
| 133 | ភូមិភាគពាយ័ព្យ(សម្ភោធទំនប់ទឹក មានកម្មករច្រើនប្រជុំធំ បេះក្រូច , បាញ់ធ្លាក់យន្តហោះវៀតណាម ) | ប៉ុល ពត | Négatif | 16mm | 83.3 | ស_ខ្មៅ | ប_១៣២ |
| 134 | ស្ទូងស្រូវ | ប៉ុល ពត | Positif | 35mm | 60 | ស_ខ្មៅ | ប_១៣៣ |
| 135 | រោងចក្រកៅស៊ូកង់ឡាន | ប៉ុល ពត | Négatif | 16mm | 81 | ស_ខ្មៅ | ប_១៣៤ |
| 136 | ស្នាដៃឧក្រិដ្ឋរបស់ខ្មាំងយួនឈ្លានពានទឹកដី | ប៉ុល ពត | Négatif | 16mm | 122.1 | ស_ខ្មៅ | ប_១៣៥ |
| 137 | ប៉ុលពត ខៀវសំផន អៀងសារី ទទួលគណៈប្រតិភូមកកាន់ប្រទេស កម្ពុជា | ប៉ុល ពត | Positif | 16mm | 120.2 | ស_ខ្មៅ | ប_១៣៦ |
| 138 | យោធា ប៉ុលពត រែកជញ្ជូនគ្រាប់ដឹកដោយរទេះគោ | ប៉ុល ពត | Négatif | 16mm | 20.2 | ស_ខ្មៅ | ប_១៣៧ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| 139 | ភូមិភាគ ពាយ័ព្យ | ប៉ុល ពត | Négatif | 35mm | 65.5 | ស_ខ្មៅ | ប_១៣៨ |
| 140 | សំណង់រោងចក្រអគ្គិសនី ៨៣ | ប៉ុល ពត | Négatif | 16mm | 143.8 | ស_ខ្មៅ | ប_១៣៩ |
| 141 | វីរភាពកងទ័ព ប៉ុលពត នៅសមរភូមិមុខ " មានកប់មីន " | ប៉ុល ពត | Négatif | 16mm | 147.6 | ស_ខ្មៅ | ប_១៤០ |
| 142 | សំណង់ទ្វារទឹក , ភាយថ្ម , ដកស្ទូង | ប៉ុល ពត | Négatif | 16mm | 108.4 | ស_ខ្មៅ | ប_១៤១ |
| 143 | ខ្មោចទាហានពាក់ទ័ព លន់ណុល ពេលពាក់ ស្ពានជ្រោយចង្វា | ប៉ុល ពត | Négatif | 16mm | 44.7 | ស_ខ្មៅ | ប_១៤៣ |
| 144 | ជនជាតិនៅភូមិភាគឦសាន្ត មានប្រពៃណី បុកអីដាំស្រូវ . ពោត | ប៉ុល ពត | Négatif | 16mm | 22.5 | ស_ខ្មៅ | ប_១៤៤ |

| លរ | IV ខ្សែភាពយន្តឯកសារផលិតក្រោយឆ្នាំ ១៩៧៩ | ចំនួនថុំ | ចំនួនចំឡង | ខ្នាត | ប្រភេទ | ពណ៌ | ប្រទេសផលិត | លេខចំឡង |
|---|---|---|---|---|---|---|---|---|
| 145 | កម្ពុជាឆ្នាំទី៥ | 6 | 1 | 35mm | Positif | ពណ៌ | កម្ពុជា | ឯក 7 |
| 146 | រដូវផ្កាភ្លោតផ្កា | 3 | 1 | 35mm | Positif | ពណ៌ | កម្ពុជា | ឯក 1 |
| 147 | កម្រងផ្កាជូនពរ | 3 | 1 | 35mm | Positif | ពណ៌ | កម្ពុជា | ឯក 4 |
| 148 | វិលមកទន្លេសាប | 3 | 1 | 35mm | Positif | ពណ៌ | កម្ពុជា | ឯក 14 |
| 149 | ចលនាបំបាត់គ្រោះមិនចេះអក្សរ | 3 | 1 | 35mm | Positif | ស ខ្មៅ | កម្ពុជា | ឯក 50 |
| 150 | កម្ពុជាមិនឯកកោ | 2 | 1 | 35mm | Positif | ស ខ្មៅ | កម្ពុជា | ឯក 30 |
| 151 | ដើម្បីសុខភាពកូនយើង | 2 | 1 | 35mm | Positif | ពណ៌ | កម្ពុជា | ឯក 48 |
| 152 | សំឡេងនៃក្តីសង្ឃឹម | 2 | 1 | 35mm | Positif | ស ខ្មៅ | កម្ពុជា | ឯក 51 |
| 153 | រស់នៅជានិច្ច | 3 | 1 | 35mm | Positif | ពណ៌ | កម្ពុជា | ឯក 45 |
| 154 | អប្សរា | 2 | 1 | 35mm | Positif | ពណ៌ | កម្ពុជា | ឯក 47 |
| 155 | ឆមាសទី ១ ឆ្នាំ ១៩៨៤ | 1 | 1 | 35mm | Positif | ស ខ្មៅ | កម្ពុជា | ឯក 33 |
| 156 | ទស្សនកិច្ចទ្រៀងជិញ | 1 | 1 | 35mm | Positif | ស ខ្មៅ | កម្ពុជា | ឯក 41 |
| 157 | មហោស្រពយុវជនពិភពលោកទី១២ | 3 | 1 | 35mm | Positif | ស ខ្មៅ | កម្ពុជា | ឯក 39 |
| 158 | អង្គរ | 3 | 1 | 35mm | Positif | ពណ៌ | កម្ពុជា | ឯក 59 |
| 159 | កម្ពុជាកសាងជីវិតថ្មី | 4 | 1 | 35mm | Positif | ពណ៌ | កម្ពុជា | ឯក 35 |
| 160 | ពូជស្រូវ IR | 2 | 1 | 35mm | Positif | ពណ៌ | កម្ពុជា | ឯក 37 |
| 161 | ជ័យជំនះ ៧មករា ឆ្នាំ ១៩៨៤ | 4 | 1 | 35mm | Positif | ពណ៌ | កម្ពុជា | ឯក 26 |
| 162 | មួយឆ្នាំក្រោយរំដោះ | 4 | 1 | 35mm | Positif | ស ខ្មៅ | កម្ពុជា | A1 |
| 163 | កុមារកម្ពុជា | 2 | 1 | 35mm | Positif | ស ខ្មៅ | កម្ពុជា | ឯក 2 |
| 164 | ឆមាសទី ២ | 1 | 1 | 35mm | Positif | ស ខ្មៅ | កម្ពុជា | ឯក 40 |
| 165 | បោះឆ្នោត | 4 | 1 | 35mm | Positif | ស ខ្មៅ | កម្ពុជា | A1 |
| 166 | ចងចាំជានិច្ច | 1 | 1 | 35mm | Positif | ពណ៌ | កម្ពុជា | ឯក 43 |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| 167 | ទស្សនកិច្ចផាន់ វ៉ាន់ដុង | 1 | 1 | 35mm | Positif | ពណ៌ | កម្ពុជា | 5 |
| 168 | កម្ពុជាមរណៈភាពជីវិតថ្មី | 5 | 1 | 35mm | Positif | ពណ៌ | អាល្លឺម៉ង់ | |

**សរុបចំនួនម៉ែត្រខ្សែភាពយន្តឯកសារខ្នាត៣៥ម.ម** : ២៣ ២៧៩,៨០ ម៉ែត្រ

**សម័យសង្គមរាស្ត្រនិយម** : ទំងន់ ចំនួន ១៧,២០ គក្រ ចំនួនបូប៊ីន ៣៦ ដុំ

**សម័យ លន់ ណល់** : ទំងន់ ចំនួន ១២,២៥ គក្រ ចំនួនបូប៊ីន ២៦ ដុំ

**សម័យ ប៉ុល ពត** : ទំងន់ ចំនួន ៧៣,២៧ គក្រ ចំនួនបូប៊ីន ១០១ ដុំ

សរុប **: ទំងន់ចំនួន ១០២,៧២គក្រ ចំនួនបូប៊ីន ១៦៣ដុំ**

**ខ្សែភាពយន្តឯកសារផលិតក្រោយឆ្នាំ ១៩៧៩ សរុប: ទំងន់ ១០២,២០គក្រ ចំនួនបូប៊ីន ៧០ដុំ ២៤ ចំណងជើង**

រាជធានីភ្នំពេញ,ថ្ងៃទី 03 ខែ មីនា ឆ្នាំ១៩៩៨

បានឃើញ និង ពិនិត្យ

ប្រធាននាយកដ្ឋាន

ម៉ុន.ណារិទ្ធ

អ្នកទទួលខុសត្រូវឯកសារដ្ឋាន

សុក សុខ

រាជធានីភ្នំពេញ,ថ្ងៃទី ខែ ឆ្នាំ១៩៩៨

ភាគីទទួល

រាជធានីភ្នំពេញ,ថ្ងៃទី 04 ខែ មីនា ឆ្នាំ១៩៩៨

បានឃើញ និង យល់ព្រម

រដ្ឋមន្ត្រី ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

នុត-ណារ៉ាំង

*(អត្ថបទសង្ខេបចេញពីចម្លើយសារភាព)*

# ហ៊ិន ចំរើន : វិស្វករមកពីប្រទេសបារាំង

ហ៊ិន ចំរើន កើតនៅឆ្នាំ១៩៣៧ នៅទីក្រុងសៀមរាប អង្គរ ។ ឪពុករបស់ ហ៊ិន ចំរើន ស្លាប់ដោយជំងឺនៅឆ្នាំ១៩៤៧ ។ ចំរើនរស់នៅជាមួយម្តាយ អ៊ុយ ឡែម ប្រកបរបរជាកសិករ ។ ចំរើន បានទទួលការអប់រំនៅសាលាបឋមសិក្សាក្រុងសៀមរាប ។ ក្រោយពីប្រលងជាប់សញ្ញាប័ត្របឋមសិក្សា ចំរើន បានបន្តការសិក្សានៅអនុវិទ្យាល័យយុត្តិវង្សនៅក្រុងបាត់ដំបង ។ នៅចុងឆ្នាំ ១៩៥៧ ចំរើន បានប្រលងជាប់សញ្ញាប័ត្រមធ្យមសិក្សាកម្រិត ២នៅវិទ្យាល័យព្រះស៊ីសុវត្ថិ និងបានទទួលអាហារូបករណ៍ទៅសិក្សានៅបរទេសជាមួយសិស្ស៧នាក់ទៀត ។ ចំរើន និងមិត្តភក្តិបួននាក់ដែលរួមមាន ហេង គិមអ៊ី, សេង ប៊ុនគន, ជា លីមស៊ិន, និង ហេង គិកលី បានទៅសិក្សានៅប្រទេសបារាំង ចំណែកសិស្សបីនាក់ទៀតបានទៅសិក្សានៅប្រទេសកាណាដា ។

ចំរើន និងមិត្តភក្តិ បានចាកចេញពីកម្ពុជាទៅសិក្សានៅប្រទេសបារាំងនៅខែកញ្ញា ឆ្នាំ១៩៥៨ ។ ចំរើន ស្នាក់នៅជាមួយនិស្សិតកម្ពុជានាបុរីអន្តរជាតិនៃសាកលវិទ្យាល័យក្រុងប៉ារីស ។ ដោយមានការណែនាំពីនិស្សិតរៀមច្បង ថាម សំអាច, ចំរើន និង ហេង គិកលី បានចុះឈ្មោះចូលរៀននៅសាលាសាធារណការផ្នែក "គណិតសាស្ត្រជាន់ខ្ពស់" ។ នៅខែមិថុនា ឆ្នាំ១៩៥៩ ដោយមានការអនុញ្ញាតពីក្រសួងអប់រំជាតិ និងរដ្ឋមន្ត្រីក្រសួងសាធារណការ ផ្នែក ឆាត និង ហ៊ិន ចំរើន បានចូលរៀន"សាលាវិស្វករសាធារណការរដ្ឋ" ។

ក្នុងរយៈពេលសិក្សានៅប្រទេសបារាំង ចំរើន មានទំនាក់ទំនងជាមួយនិស្សិតកម្ពុជាច្រើន ជាពិសេស តូច ខាំឌឿន ដែលបានណែនាំឲ្យ ចំរើន ចូលជាសមាជិក"សមាគមសហភាពនិស្សិតខ្មែរ" ដែលមាន តូច ខាំឌឿន ជាប្រធាន ។ ចំរើន មានមុខងារជាអគ្គលេខាធិការសមាគមនេះ ។ ចន្លោះខែកក្កដា និងខែសីហា ឆ្នាំ ១៩៥៩ ចំរើន និង អ៊ិន សូផាន់ ត្រូវបានចាត់តាំងជាតំណាងសមាគមសហភាពនិស្សិតខ្មែរឲ្យទៅចូលរួម"មហាសមោសរសាកលលោកសម្រាប់យុវជន មិត្តភាព និងសន្តិភាព" ដែលប្រព្រឹត្តទៅនៅទីក្រុងវីយេន ប្រទេសអូទ្រីស ក្រោមជំនួយឧបត្ថម្ភពីសហភាពសូវៀត ។ គោលបំណងនៃការជួបជុំគ្នានេះគឺ ដើម្បីផ្សព្វផ្សាយពីការរីកចម្រើនផ្នែកសេដ្ឋកិច្ច សង្គមកិច្ច សុខាភិបាល និងវប្បធម៌នៃប្រទេសសង្គមនិយមខាងកើតដែលមានសហភាពសូវៀតជាគំរូ ។

នៅខែមិថុនាឆ្នាំ១៩៦១ ចំរើន ប្រលងចេញពីសាលាសាធារណការរដ្ឋ ហើយទទួលបានសញ្ញាប័ត្រជាវិស្វករសាធារណការ ។ ចំរើន ទទួលបានការអនុញ្ញាតពីក្រសួងអប់រំជាតិឲ្យទៅធ្វើកម្មសិក្សាបន្ថែមនៅ"មជ្ឈមណ្ឌលសិក្សាស្រាវជ្រាវសម្រាប់ឧស្សាហកម្មស៊ីម៉ង់ត៍" ។ ចំរើន និងនិស្សិតបរទេសដទៃទៀត បានធ្វើទស្សនកិច្ចរោងចក្រឧស្សាហកម្មនិងសហគ្រិនឯកជនជាច្រើនដែលមាននៅប្រទេសបារាំង ។

ចន្លោះខែកក្កដានិងខែសីហាឆ្នាំ១៩៦២ ចំរើន បានរួមដំណើរជាមួយគណៈប្រតិភូសហភាពនិស្សិតខ្មែរទៅចូលរួម"មហាសមោសរសាកលលោកសម្រាប់យុវជន មិត្តភាព និងសន្តិភាព" នៅទីក្រុងហែលស៊ិនគី ប្រទេសហ្វាំងឡង់ ។ ក្រោយទស្សនកិច្ចនេះ សហភាពនិស្សិតខ្មែរបានចាត់តាំងឲ្យ ចំរើន និង សួង ស៊ីគឿន ធ្វើជាតំណាងដើម្បីចូលរួមមហាសន្និបាតប្រចាំឆ្នាំរបស់អង្គការនិស្សិតអន្តរជាតិនៅប្រទេសប៉ូឡូញ ។

នៅខែតុលាឆ្នាំ១៩៦២ ចំរើន បានបញ្ចប់ការសិក្សានៅប្រទេសបារាំង ហើយបានវិលត្រឡប់ចូលមកប្រទេសកម្ពុជាវិញ បម្រើការនៅក្រសួងសាធារណការ ។ គាត ឈន់ ដែលជាអគ្គនាយកមន្ទីរស្ថាបនាដោយគ្រឿងចក្រ បានស្នើសុំ ភាន់ មូលីភាន់ រដ្ឋមន្ត្រីក្រសួងសាធារណការឲ្យផ្លាស់ប្តូរ ចំរើន មកធ្វើការជាមួយដោយមាននាទីជានាយកបច្ចេកទេសមន្ទីរ ។ មន្ទីរនេះទ្រទ្រង់ដោយសហរដ្ឋអាមេរិក សម្រាប់សាងសង់ផ្លូវជាតិលេខ៤ពីភ្នំពេញទៅក្រុងកំពង់សោម ។ គាត ឈន់ បានណែនាំ ចំរើន ឲ្យស្គាល់ ញឹក ជូឡុង នៅក្នុងពិធីជប់លៀងមួយនៅបុរីគីរីរម្យ ដែលមានការចូលរួមពី អ៊ីង គៀត ។ នៅទីនោះ ញឹក ជូឡុង បានប្រកាសទទួលស្គាល់ ចំរើន នៅមុខទង់ជាតិអាមេរិកាំងអមទៅដោយទង់ជាតិកម្ពុជានិង

ទង់ជាតិយោធា ។ ចំរើន បានសន្និដ្ឋានថា នេះគឺជាការប្រកាសទទួលសមាជិកសេ.អ៊ី.អា ដែលមាន ញ៉ឹក ជូឡុង ជាអ្នកទទួលខុសត្រូវ ។ បន្ទាប់មក ញ៉ឹក ជូឡុង បានបន្តធ្វើការប្រជុំអនុវត្តគម្រោងធ្វើផ្លូវកាត់ភ្នំក្រវាញ រៀបចំមូលដ្ឋានសឹកបង្អែកលើខ្ពង់រាបគិរីរម្យ និងធ្វើផ្លូវភ្ជាប់ពីគិរីរម្យមកផ្លូវជាតិលេខ៤ ។ គោលបំណងនៃគម្រោងនេះគឺដើម្បីកម្ទេចមូលដ្ឋានខ្មែរក្រហមនៅភូមិភាគភ្នំក្រវាញ និងផ្តាច់ការទាក់ទងរវាងខ្មែរក្រហមនិងអ្នកភូមិ ។

ក្រៅពីការងារទាំងនេះ ចំរើន មានភារកិច្ចប្រមូលនិងពង្រឹងកម្លាំងសម្រាប់បម្រើនយោបាយចក្រពត្តិអាមេរិក ។ កិច្ចការដែលត្រូវធ្វើរួមមាន ÷ ១) បំផុសគោលជំហរគាំទ្រនយោបាយរបស់អាមេរិកក្នុងការផ្តល់ជំនួយមកកម្ពុជា ២) ផ្សព្វផ្សាយនូវគុណសម្បត្តិរបស់ជំនួយនេះក្នុងការកសាងប្រទេសដូចមានឧទាហរណ៍ប្រទេសថៃស្រាប់ ៣) ក្តាប់អ្នកធ្វើការនៅក្នុងការដ្ឋានកុំឲ្យមានការតវ៉ាឬប្រឆាំង ៤) ត្រៀមចាំទទួលការងារ ហើយអនុវត្តឲ្យទាន់ពេលវេលា និង៥) រក្សាការសម្ងាត់ ។

នៅឆ្នាំ១៩៦៤ អ៊ីង គៀត បន្ទាប់ពីត្រូវបានតែងតាំងជារដ្ឋមន្ត្រីក្រសួងសាធារណការ បានចេញលិខិតបង្គាប់ការផ្ទាស់ចំរើន ចេញពីមន្ទីរស្ថាបនាដោយគ្រឿងចក្រឲ្យមកនៅក្នុងក្រសួងវិញ ។ នៅដើមឆ្នាំ១៩៦៥ ចំរើន ត្រូវបានតែងតាំងជានាយក្រុមបច្ចេកទេសនៃនាយកដ្ឋានសាធារណការ ត្រួតពិនិត្យមើលផ្លូវជាតិនិងវាលយន្តហោះទូទាំងប្រទេស ។ ក្រៅពីកិច្ចការនេះ អ៊ីង គៀត បានប្រគល់ភារកិច្ចឲ្យ ចំរើន ត្រួតពិនិត្យការស្ថាបនាស្ពាននៅក្បាលថ្នល់ភ្នំពេញរបស់ក្រុមហ៊ុនឯកជនបារាំងនិងបង្រៀននិស្សិតនៅសាធារណការ ។ ចំរើន បានអប់រំ អ៊ុក ថែន នាយកសាធារណការទទួលខុសត្រូវការដ្ឋានវាលយន្តហោះរាមកំពង់សោម សរ ឆង និង ឆន សុភាព ឲ្យស្រលាញ់របបលោកសេរី គាំទ្រឲ្យមានជំនួយអាមេរិកាំងតទៅមុខទៀត និងប្រឆាំងដាច់ខាតនឹងចលនាខ្មែរក្រហម ។ នៅពេលមានព្រឹត្តិការណ៍ វាយស្ថានទូតអាមេរិកនៅឆ្នាំ១៩៦៤ ចំរើន បានណែនាំបុគ្គលិកសាធារណការកុំឲ្យចូលរួមក្នុងបាតុកម្មនេះ ។

នៅដើមខែកញ្ញាឆ្នាំ១៩៦៦ ចំរើន បានទៅបន្តការសិក្សានៅប្រទេសបារាំងជាលើកទីពីរ ដោយទទួលបានអាហារូបករណ៍ពីអង្គការបារាំងមួយឈ្មោះ «មជ្ឈមណ្ឌលស្ទង់កាល់វ៉ាំងគ្រូស» ហើយទទួលបានអាហារូបករណ៍៧០០ត្រណោត(១ត្រណោតស្មើ១០រៀល) ក្នុងមួយខែក្នុងការសិក្សានៅមជ្ឈមណ្ឌលនេះ ។ នៅទីនោះ ចំរើន បានទាក់ទងមិត្តភក្តិចាស់ៗនិងនិស្សិតខ្មែរឲ្យគាំទ្រនយោបាយអាមេរិកនៅកម្ពុជា ដោយលើកយកបញ្ហាជំនួយអាមេរិកាំងមកពិភាក្សា ។ នៅដើមឆ្នាំ១៩៦៧ ចំរើន បានទទួលសញ្ញាប័ត្រជាវិស្វករសំណង់បេតុងដែកថែប និងបេតុងប្រេកុងត្រាំង ។ ចំរើន បានវិលត្រឡប់មកកម្ពុជាវិញ ហើយចូលបម្រើការងារនៅក្រសួងសាធារណការដដែល ។ ប៉ុន្តែ រដ្ឋមន្ត្រីក្រសួងសាធារណការនៅពេលនោះ គឺ ផ្ទែក គឿន ចំណែក អ៊ីង គៀត ទៅធ្វើការជាមួយ ញ៉ឹក ជូឡុង នៅអគ្គអធិការដ្ឋានយោធា ។

គាត ឈន់ ដែលនៅពេលនោះជារដ្ឋមន្ត្រីក្រសួងឧស្សាហកម្មបានស្នើ ផ្ទែក គឿន ឲ្យធ្វើលិខិតបង្គាប់ការផ្ទាស់ ចំរើន ឲ្យមកធ្វើការនៅក្រសួងឧស្សាហកម្មដែរ ដោយធ្វើជាប្រធានបច្ចេកទេសក្រុមហ៊ុនជាតិស្ថាបនា ។ ក្រុមហ៊ុននេះមានភារកិច្ចទទួលធ្វើសំណង់ផ្ទះឬរោងចក្រសម្រាប់រដ្ឋ និងក្រុមហ៊ុនជាតិនានា ដែលមាន ឈាងសេង ជាអគ្គនាយក ។ ក្រៅពីនេះ ចំរើន នៅបន្តបង្រៀននិស្សិតនៅសាលាជាតិសាធារណការ ។ ក្រៅពីការអប់រំ ចំរើន ឆ្លៀតពេលពិភាក្សាជាមួយនិស្សិតអំពីភាពអត់ការងារធ្វើបន្ទាប់ពីបញ្ចប់ការសិក្សាដោយសារវិបត្តិសេដ្ឋកិច្ចនៅក្នុងប្រទេស ។ នៅក្នុងក្រុមហ៊ុនជាតិស្ថាបនា(សំណង់) ចំរើន មានភារកិច្ចឃោសនាឲ្យបុគ្គលិកទាំងអស់ជ្រួតជ្រាបអំពីសភាពការណ៍ធុនដាបនៃសេដ្ឋកិច្ចប្រទេសដែលចាំបាច់ត្រូវតែប្តូររបបគ្រប់គ្រង ហើយទាំងអស់គ្នាត្រូវគាំទ្ររបបថ្មីរបស់លោកសេរី ។

នៅខែមេសាឆ្នាំ១៩៦៨ ចំរើន បានចូលរួមប្រជុំជាមួយ ញ៉ឹក ជូឡុង ដើម្បីអនុវត្តវិធានការថ្មីចំពោះខ្មែរក្រហមឲ្យបានម៉ឺងម៉ាត់ ។ ផែនការទីមួយគឺបញ្ឈប់មិនឲ្យក្រុមខ្មែរក្រហមចូលមកធ្វើជាសមាជិករដ្ឋាភិបាល ។ ផែនការទីពីរគឺដកតំណែងខ្មែរក្រហមទាំងអស់ដែលមានភារកិច្ចនៅក្នុងក្រសួងនិងឯកោក្រុមនេះ ។ ក្នុងឆ្នាំ១៩៦៩ ចំរើន បានបន្តសកម្មភាពអប់រំបុគ្គលិកសាធារណការនៅតាមការដ្ឋានផ្សេងៗទៀតដូចជា ការដ្ឋានសាងសង់សណ្ឋាគារនៅមុខប្រាសាទអង្គរ ។ ចំរើន ក៏បានទទួលផែនការបំផុសកម្មករឲ្យត្រៀមរៀបចំបាតុកម្មគាំទ្ររដ្ឋប្រហារទម្លាក់សម្តេច សីហនុ ។

ក្រោយរដ្ឋប្រហារខែមីនាឆ្នាំ១៩៧០ ហ៊ិន ចំរើន បានឃោសនាអប់រំកម្មករឲ្យគាំទ្រនយោបាយរបស់រដ្ឋាភិបាល លន់ នល់ ។ ចំរើន បានចូលរួមប្រជុំជាមួយ អ៊ីង គៀត និងបុគ្គលិក

អាមេរិកាំងជាញឹកញាប់ដើម្បីពិភាក្សាពីគម្រោងជំនួយសម្ភារ សាងសង់ទំនប់ពីរធ្វើជាខ្សែក្រវាត់ការពារទីក្រុងភ្នំពេញ ។ នៅខែមេសា ឆ្នាំ១៩៧១ ចំរើន បានចូលរួមក្នុងកិច្ចប្រជុំមួយតាមការអញ្ជើញរបស់អាមេរិកាំង ។ អ្នកចូលរួមក្នុងអង្គប្រជុំរួមមាន ស៊ីង ង៉ុកថាញ់ រដ្ឋមន្ត្រីទី១, អ៊ិត ឌុយ រដ្ឋមន្ត្រីហិរញ្ញវត្ថុ, ឃី តាំងលឹម រដ្ឋមន្ត្រីក្រសួងសាធារណការ ចៅ ស៊ុន, អ៊ីង គៀត, ថាប្បនា ឆិន្ទ ឧត្តមសេនីយ៍, ត្រាន់ ឡាំ និងឯកអគ្គរដ្ឋទូតអាមេរិកនិងសហការី ។ ខ្លឹមសារនៃអង្គប្រជុំគឺដើម្បីសាងសង់កំពង់ផែយោធាមួយទៀតនៅភ្នំពេញ ដើម្បីទទួលជំនួយយោធានិងគ្រាប់រំសេវពីអាមេរិក ។ នៅខែមេសា ឆ្នាំ១៩៧២ ចំរើន បានចូលរួមប្រជុំជាមួយ ឃី តាំងលឹម, អ៊ីង គៀត និងទាហានអាមេរិកាំងបីនាក់ទៀតដើម្បីពង្រីកមូលដ្ឋានយន្តហោះយោធានៅពោធិចិនតុង ត្រៀមចាំទទួលជំនួយយន្តហោះពីអាមេរិក ពង្រីកវាលយន្តហោះនៅរាមសំដៅការពារផ្លូវជាតិលេខ៤ និងពង្រីកវាលយន្តហោះនៅខេត្តបាត់ដំបងសម្រាប់ដាក់ធ្នែងសំចតយន្តហោះមកពីភ្នំពេញ ។

នៅខែមេសា ឆ្នាំ១៩៧៣ ចំរើន និងប្រពន្ធបានទទួលការចាត់តាំងពី ឃី តាំងលឹម រដ្ឋមន្ត្រីក្រសួងសាធារណការ ឲ្យទៅធ្វើកម្មសិក្សារយៈពេល៦ខែនៅប្រទេសប៊ែលហ្ស៊ិកនិងប្រទេសបារាំង ។ ចំរើន មានភារកិច្ចចូលទៅបង្កប់ខ្លួនក្នុងជួររណសិរ្សរួបរួមជាតិកម្ពុជានៅប្រទេសបារាំង ដើម្បីបំបែកកម្លាំងរណសិរ្សមិនឲ្យធ្វើសកម្មភាព ។ ទៅដល់ប្រទេសបារាំង ចំរើន បានសរសេរសំបុត្រមួយច្បាប់ផ្ញើ គាត ឈន់ ដើម្បីសុំយោបល់ពីបញ្ហាដែលគាត់ចង់ចូលជាសមាជិករណសិរ្ស ។ គាត់ ឈន់ បានឲ្យ ចំរើន ទៅជួប អ៊ិន សូកាន និង ញឹក ជូឡុង ចំពោះបញ្ហាចូលរណសិរ្សនេះ ។ ចំរើន និងមិត្តភក្តិដែលទើបមកដល់ប្រទេសបារាំងបីបួននាក់ទៀត ត្រូវបានបញ្ចូលជាសមាជិករណសិរ្សក្នុងពិធីមីទ្ទិងមួយក្រោមអធិបតីភាពរបស់ ឌិក សាគុណ និង ចៅ សេង ។ ក្នុងរយៈពេលឆ្នាំ១៩៧៤ ចំរើន បានបញ្ចូលសមាជិកសេ.អ៊ី.អាទៅក្នុងជួររណសិរ្សបានចំនួន៣នាក់ឈ្មោះ អ៊ុក សាមេត, មាន គីមលី និង អ៊ុំ សូមេថា និងធ្វើឲ្យសមាជិករណសិរ្ស១០នាក់លែងមានសកម្មភាព ។

ក្រោយថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ញឹក ជូឡុង បានហៅ ចំរើន និង អ៊ីង គៀត មកប្រជុំដើម្បីបញ្ជូនសមាជិករណសិរ្សមួយចំនួនមកកម្ពុជា ។ អ៊ិន សូផាន់, អ៊ិន សូកាន និង ឌិក សាគុណ បានត្រឡប់មកកម្ពុជាមុនគេ ។ ចំរើន នៅបន្តអប់រំអណិកជនខ្មែរដែលសម្រេចចិត្តចូលមកកម្ពុជា ឲ្យតស៊ូដើម្បីដណ្តើមយករដ្ឋអំណាចពីអង្គការបដិវត្តន៍ ។ មុនត្រឡប់ចូលមកកម្ពុជា ចំរើន បានទទួលផែនការពី ញឹក ជូឡុង ដូចតទៅ ÷ ១) ទាក់ទង គាត ឈន់ ដើម្បីរៀបចំខ្សែសេ.អ៊ី.អាឡើងវិញ ២) ត្រូវរកមធ្យោបាយផ្ញើសំបុត្រឬសេចក្តីរាយការណ៍មកឲ្យ អ៊ីង គៀត ៣) ត្រូវរកអង្គការបដិវត្តន៍ឲ្យឃើញ ៤) ចូលរួមរៀបចំចលនាបញ្ញវ័ន្តទូទាំងប្រទេស និង៥) ស៊ើបការណ៍ឲ្យដឹងពីពេលវេលាដែលអង្គការបដិវត្តន៍សម្រេចចាយលុយឡើងវិញ ។

នៅថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ១៩៧៦ ចំរើន និងគ្រួសារព្រមទាំងខ្មែរ៧នាក់ទៀតបានចេញដំណើរជាមួយគ្នាពីប្រទេសបារាំងមកប្រទេសចិន មុននឹងបន្តដំណើរមកកម្ពុជាជាមួយខ្មែរ១០នាក់ទៀតដែលរង់ចាំនៅវាលយន្តហោះនៅទីក្រុងប៉េកាំង ។ អ្នកទាំងអស់គ្នាបានមកដល់កម្ពុជានៅថ្ងៃទី១ ខែតុលា ឆ្នាំ១៩៧៦ ហើយបានមករស់នៅមន្ទីរក-១៥ ។ មួយសប្តាហ៍ក្រោយមក ចំរើន និងខ្មែរទាំងអស់ដែលទើបមកពីបរទេសបានចូលរៀនវគ្គសិក្សាដែលរៀបចំដោយមន្ទីរអស់រយៈពេល១៨ថ្ងៃ ។ មួយថ្ងៃក្រោយការបិទវគ្គសិក្សា ចំរើន និងសិក្ខាកាមទាំងអស់ត្រូវបានបញ្ជូនមកមន្ទីរក-៦នៅបឹងត្របែក ។ នៅទីនេះ ចំរើន មាននាទីជាប្រធានពួកដែលមានសមាជិកពីរនាក់ ។ ក្រៅពីការងារធ្វើពលកម្ម ចំរើន និងមិត្តឯទៀតត្រូវចូលរួមប្រជុំជីវភាពជារៀងរាល់ថ្ងៃ ។ នៅដើមខែធ្នូ ឆ្នាំ១៩៧៦ ចំរើន បានចូលរៀនវគ្គសិក្សាលើកទីពីររយៈពេល៥ថ្ងៃទៀតនៅមន្ទីរក-៦ ។ ចំរើន ត្រូវបានចាប់ខ្លួនបញ្ជូនមកមន្ទីរស-២១នៅពេលកំពុងរៀន ។

នៅក្នុងចម្លើយសារភាពដែលមានចំនួន១២៩ទំព័រ ចំរើន បានសារភាពថាបានធ្វើសកម្មភាពប្រឆាំងនឹងបដិវត្តន៍ ដោយបានធ្វើការឃោសនាអប់រំសមាជិកនៅក-៦ សោកស្តាយដល់ការរស់នៅឯបរទេស និងចិញ្ចឹមចិត្តអំពីការរស់នៅរបៀបលោកសេរីនៅថ្ងៃអនាគត ។ ហ៊ិន ចំរើន បានបញ្ចប់ចម្លើយសារភាពរបស់ខ្លួននៅថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៧៧ ដោយមានចុះហត្ថលេខានិងផ្តិតមេដៃ ។ នៅក្នុងចម្លើយសារភាពរបស់ ហ៊ិន ចំរើន មានចុះហត្ថលេខារបស់អ្នកសួរឈ្មោះ ស្រ៊ឹម ។ មិនមានឯកសារបញ្ជាក់ថា ហ៊ិន ចំរើន ត្រូវបានសម្លាប់នៅថ្ងៃខែឆ្នាំណាទេ ។

**ឌីខាំ បូលី**

# បញ្ជីឈ្មោះជនរងគ្រោះដែលបានកម្ទេចនៅមន្ទីរស-២១ (គុកទួលស្លែង)

## រៀបចំនិងចងក្រងដោយ : យិន នាន

(តពីលេខមុន)

| ល.រ | នាម-គោត្តនាម | មុខងារ | កន្លែងយក | ថ្ងៃចូល | ថ្ងៃកម្ទេច |
|---|---|---|---|---|---|
| ៣០៦៥ | ស៊ិន ធឿន ហៅ ភក្តិ | មេពួក | ឃ្លាំងរដ្ឋ | ១៥-៥-៧៧ | ២០-៦-៧៧ |
| ៣០៦៦ | ស៊ិន ធីម ហៅ គីម | យុទ្ធជន | ឃ្លាំងរដ្ឋ | ៥-៥-៧៧ | ២០-៦-៧៧ |
| ៣០៦៧ | ព្រុំ ឌុន ហៅ ឌឿន | អនុក្រុម | ឃ្លាំងរដ្ឋ | ៥-២-៧៧ | ២០-៦-៧៧ |
| ៣០៦៨ | ហួន ឌឿន ហៅ ដី | កាន់បញ្ជី | ឃ្លាំងរដ្ឋ | ២២-៣-៧៧ | ២០-៦-៧៧ |
| ៣០៦៩ | ជាម សាយ | កាន់បញ្ជី | ឃ្លាំងរដ្ឋ | ៦-៥-៧៧ | ២០-៦-៧៧ |
| ៣០៧០ | នង តេន | នយោបាយកងតូច | ឃ្លាំងរដ្ឋ | ៦-៥-៧៧ | ២០-៦-៧៧ |
| ៣០៧១ | សយ សារី ហៅ ធា | នយោបាយកងតូច | ឃ្លាំងរដ្ឋ | ៦-៥-៧៧ | ២០-៦-៧៧ |
| ៣០៧២ | ជាប សែន ហៅ រុន | អនុកងតូច | ឃ្លាំងរដ្ឋ | ៦-៥-៧៧ | ២០-៦-៧៧ |
| ៣០៧៣ | លឿង ហ៊ាន់ | យុទ្ធជន | ឃ្លាំងរដ្ឋ | ៦-៥-៧៧ | ២០-៦-៧៧ |
| ៣០៧៤ | នួន លី ហៅ វ៉េន | ប្រធានកង | ឃ្លាំងរដ្ឋ | ៦-៥-៧៧ | ២០-៦-៧៧ |
| ៣០៧៥ | ម៉ាន់ ហេង ហៅ ហ៊ាន់ | យោធាកងតូច | ឃ្លាំងរដ្ឋ | ២៨-៥-៧៧ | ២០-៦-៧៧ |
| ៣០៧៦ | ស៊ុន សឹម ហៅ វ៉ាត | មេក្រុម | ឃ្លាំងរដ្ឋ | ២៣-៣-៧៧ | ២០-៦-៧៧ |
| ៣០៧៧ | អ៊ុក ឆាន ហៅ ដាន់ | យុទ្ធជន | ឃ្លាំងរដ្ឋ | ១៦-៤-៧៧ | ២០-៦-៧៧ |
| ៣០៧៨ | សោម ជាវ ហៅ សាញ់ | យុទ្ធជន | ឃ្លាំងរដ្ឋ | ១០-៥-៧៧ | ២០-៦-៧៧ |
| ៣០៧៩ | ប៉ោ ញ៉ | បង្ហាត់ធ្វើទូក | ពាណិជ្ជកម្មរដ្ឋ | ២៩-៥-៧៧ | ២០-៦-៧៧ |
| ៣០៨០ | ដាន់ យ៉ន | ជាងទូក | ពាណិជ្ជកម្មរដ្ឋ | ២៩-៥-៧៧ | ២០-៦-៧៧ |
| ៣០៨១ | សូ សៅ ហៅ សែន | មេក្រុម | ពាណិជ្ជកម្មរដ្ឋ | ២១-៣-៧៧ | ២០-៦-៧៧ |
| ៣០៨២ | កង ធួន ហៅ ផែន | មេក្រុម | ពាណិជ្ជកម្មរដ្ឋ | ២១-៣-៧៧ | ២០-៦-៧៧ |
| ៣០៨៣ | មិន សូត្រ ហៅ សេង | ប្រធានពេទ្យ | ពាណិជ្ជកម្មរដ្ឋ | ៩-៥-៧៧ | ២០-៦-៧៧ |
| ៣០៨៤ | ហំ សំណាង ហៅ សុក | យុទ្ធជន | ពាណិជ្ជកម្មរដ្ឋ | ២២-៣-៧៧ | ២០-៦-៧៧ |
| ៣០៨៥ | ស្ងួន ម៉ុក ហៅ ខុំ | អនុក្រុម | ដឹកជញ្ជូនជើងទឹក | ២៧-៥-៧៧ | ២០-៦-៧៧ |
| ៣០៨៦ | ងិន សាន | កម្មករ | ពាណិជ្ជកម្ម | ២០-៥-៧៧ | ២០-៦-៧៧ |
| ៣០៨៧ | សៅ ឈួន | ជាងទូក | ពាណិជ្ជកម្ម | ២៩-៥-៧៧ | ២០-៦-៧៧ |
| ៣០៨៨ | ប៉ុល ប៉ុន | ជាងទូក | ពាណិជ្ជកម្ម | ២៩-៥-៧៧ | ២០-៦-៧៧ |
| ៣០៨៩ | ញ៉ែម សំ | ជាងទូក | ពាណិជ្ជកម្ម | ២៩-៥-៧៧ | ២០-៦-៧៧ |
| ៣០៩០ | ព្រុំ នន | យុទ្ធជន | ពាណិជ្ជកម្ម | ២៩-៥-៧៧ | ២០-៦-៧៧ |
| ៣០៩១ | ដៃ ប៉ក់ | អនុក្រុម | ពាណិជ្ជកម្ម | ១៩-៥-៧៧ | ២០-៦-៧៧ |

| | | | | | |
|---|---|---|---|---|---|
| ៣០៩២ | ទឹម សុគាង ហៅ ស៊ីម | យុទ្ធជន | ពាណិជ្ជកម្ម | ១៥-៥-៧៧ | ២០-៦-៧៧ |
| ៣០៩៣ | ឆុំ គា ហៅ សេន | មេក្រុម | ពាណិជ្ជកម្ម | ១៥-៥-៧៧ | ២០-៦-៧៧ |
| ៣០៩៤ | វ៉ូយ ថៃ ហៅ ថេន | ប្រធានមន្ទីរ | ពាណិជ្ជកម្ម | ១៥-៤-៧៧ | ២០-៦-៧៧ |
| ៣០៩៥ | ងិន ហៀង ហៅ ភ័ណ | យុទ្ធជន | ពាណិជ្ជកម្ម | ១៥-៥-៧៧ | ២០-៦-៧៧ |
| ៣០៩៦ | ម៉េង ហួ ហៅ ហ៊ាង | យុទ្ធជន | ពាណិជ្ជកម្ម | ១៥-៥-៧៧ | ២០-៦-៧៧ |
| ៣០៩៧ | ព្រុំ សាំង ហៅ ញ៉ី | មេក្រុម | ពាណិជ្ជកម្ម | ១៩-៥-៧៧ | ២០-៦-៧៧ |
| ៣០៩៨ | ដាង ឡេង ហៅ សួត | យុទ្ធជន | ពាណិជ្ជកម្ម | ១៥-៥-៧៧ | ២០-៦-៧៧ |
| ៣០៩៩ | ប៉ែន សៀន | យុទ្ធជន | ពាណិជ្ជកម្ម | ១៥-៥-៧៧ | ២០-៦-៧៧ |
| ៣១០០ | លី ស្រេង | កងតូច | ពាណិជ្ជកម្ម | ១៥-៥-៧៧ | ២០-៦-៧៧ |
| ៣១០១ | ម៉ែន ឆាន | យុទ្ធជន | ពាណិជ្ជកម្ម | ១៥-៥-៧៧ | ២០-៦-៧៧ |
| ៣១០២ | អឿ ហំ ហៅ ដា | ? | ពាណិជ្ជកម្ម | ១៥-៤-៧៧ | ២០-៦-៧៧ |
| ៣១០៣ | លាង គង់ ហៅ ស៊ន | មេក្រុម | ពាណិជ្ជកម្ម | ១៤-៥-៧៧ | ២០-៦-៧៧ |
| ៣១០៤ | អេង សេង ហៅ ស៊ឹម | ពេទ្យ | ពាណិជ្ជកម្ម | ៧-៥-៧៧ | ២០-៦-៧៧ |
| ៣១០៥ | អ៊ាន ប៉េងគុត ហៅ ចេក | មេក្រុម | ពាណិជ្ជកម្ម | ៥-៤-៧៧ | ២០-៦-៧៧ |
| ៣១០៦ | កែវ សាត | ប្រធានក្រុម | ពាណិជ្ជកម្ម | ២៣-៣-៧៧ | ២០-៦-៧៧ |
| ៣១០៧ | ពូច ជន ហៅ ជិន | មេពួក | ពាណិជ្ជកម្មរដ្ឋ | ២១-៣-៧៧ | ២០-៦-៧៧ |
| ៣១០៨ | គង់ វឿន | យុទ្ធជន | ពាណិជ្ជកម្មរដ្ឋ | ២១-៣-៧៧ | ២០-៦-៧៧ |
| ៣១០៩ | ហាំង ឈីម ហៅ ឡាយ | ប្រធានកង | ពាណិជ្ជកម្មរដ្ឋ | ១៦-៥-៧៧ | ២០-៦-៧៧ |
| ៣១១០ | អ៊ុម គយ ហៅ សៃ | យុទ្ធជន | ពាណិជ្ជកម្មរដ្ឋ | ២១-៣-៧៧ | ២០-៦-៧៧ |
| ៣១១១ | ជាម ឆេង ហៅ សេង | ធ្វើបញ្ជី | ពាណិជ្ជកម្មរដ្ឋ | ៣០-៤-៧៧ | ២០-៦-៧៧ |
| ៣១១២ | មាស វន ហៅ វ៉ន | មេក្រុម | ពាណិជ្ជកម្មរដ្ឋ | ៧-៥-៧៧ | ២០-៦-៧៧ |
| ៣១១៣ | នួន ខន ហៅ ដា | កម្មករថ្មី | ពាណិជ្ជកម្មរដ្ឋ | ២៣-៣-៧៧ | ២០-៦-៧៧ |
| ៣១១៤ | ចាយ ចន | មេក្រុម | ពាណិជ្ជកម្មរដ្ឋ | ២១-៣-៧៧ | ២០-៦-៧៧ |
| ៣១១៥ | សៀង ស្រេង ហៅ ស្រួច | ពេទ្យ | ពាណិជ្ជកម្មរដ្ឋ | ៦-៤-៧៧ | ២០-៦-៧៧ |
| ៣១១៦ | សែ នឿ ហៅ ដាន | មេក្រុម | ពាណិជ្ជកម្មរដ្ឋ | ២១-៣-៧៧ | ២០-៦-៧៧ |
| ៣១១៧ | ប៉ែន រិន ហៅ តែម | មេក្រុម | ពាណិជ្ជកម្មរដ្ឋ | ?-៥-៧៧ | ២០-៦-៧៧ |
| ៣១១៨ | ជុំ ឡឿន | យុទ្ធជន | ពាណិជ្ជកម្មរដ្ឋ | ២១-៣-៧៧ | ២០-៦-៧៧ |
| ៣១១៩ | ជឹម ឡឿន | យុទ្ធជន | ពាណិជ្ជកម្មរដ្ឋ | ២៣-៣-៧៧ | ២០-៦-៧៧ |
| ៣១២០ | ឈួន ដាត | សមាជិក | កងពល៣១០ | ២១-៦-៧៧ | ២៥-៦-៧៧ |
| ៣១២១ | ឈា សុង ហៅ សេង | យុទ្ធជន | កងពល៣១០ | ២១-៦-៧៧ | ២៥-៦-៧៧ |
| ៣១២២ | ធឹម គីមហុង ហៅ ស្នាក់ | យុទ្ធជន | សេនាធិការ | ២១-៦-៧៧ | ២៥-៦-៧៧ |

(នៅមានត)

# គុកខ្មែរក្រហម

## ខេត្តកំពត

## ស្រុកអង្គរជ័យ

### ១) មន្ទីរសន្តិសុខតាម៉ន

មន្ទីរសន្តិសុខតាម៉នជាមន្ទីរសន្តិសុខប្រចាំតំបន់១៣ដោយមានតាម៉ុកជាអ្នកគ្រប់គ្រង ។ មន្ទីរនេះស្ថិតនៅភូមិឫស្សីជុំ ឃុំប្រភ្នំ ស្រុកអង្គរជ័យ ខេត្តកំពត ។ ប៉ុល ផាន ប្រធានវប្បធម៌និងព័ត៌មានស្រុកបាននិយាយថា គាត់ធ្លាប់ឃើញ តាម៉ុក ជិះរថយន្តហ្ស៊ីប (Jeep) តាមបណ្តោយផ្លូវពីឃុំតានី ស្រុកអង្គរជ័យ ឆ្ពោះទៅកាន់មន្ទីរសន្តិសុខតាម៉ន ។ មន្ទីរសន្តិសុខនេះមានរបងលួសបន្លាហ៊ុមពទ្ធ័៧ជាន់ និងអគារ៣សម្រាប់ឃុំឃាំងអ្នកទោសគឺ ១)អគារឃុំឃាំងអ្នកទោសស្ត្រី ២) អគារឃុំឃាំងអ្នកទោសបុរស និង៣) អគារផ្ទាល់ដីសម្រាប់ឃុំឃាំងតែអ្នកទោសធ្ងន់ដែលត្រូវកម្ទេចចោលក្នុងពេលឆាប់ៗ ។


មន្ទីរសន្តិសុខតាម៉ន ភូមិឫស្សីជុំ ឃុំប្រភ្នំ ស្រុកអង្គរជ័យ ខេត្តកំពត

ចាប់ពីឆ្នាំ១៩៧៣ដល់មុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ជនរងគ្រោះស្ទើរតែទាំងអស់ជាប្រជាជនមូលដ្ឋានដែលធ្លាប់ចូលបម្រើបដិវត្តន៍និងអ្នកមានបងប្អូនធ្វើការនៅទីក្រុង ហើយត្រូវចោទថាជាគិញប្កខ្មាំងបង្កប់ ។ ប៉ុន្តែបន្ទាប់ពីថ្ងៃជ័យជម្នះឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៧ ជនរងគ្រោះភាគច្រើនជាប្រជាជន ១៧មេសា ដែលជម្លៀសចេញពីទីក្រុងភ្នំពេញ អ្នកជាប់ខ្សែចិន ចាម វៀតណាម ព្រមទាំងខ្មែរកម្ពុជាក្រោមផង ។

នៅឆ្នាំ១៩៧៨ កងសន្តិសុខប្រចាំមន្ទីរសន្តិសុខតាម៉ន បានសម្លាប់អ្នកទោសអស់ច្រើនជាងឆ្នាំមុនៗ ។ ជនរងគ្រោះត្រូវកងសន្តិសុខអារផ្តាច់បំពង់-ក សម្រក់ឈាមដាក់ក្នុងរណ្តៅធ្វើពីបេតុងដែលនៅជិតអគារជាន់ផ្ទាល់ដី ។ ឈាមរបស់អ្នកទោសត្រូវខ្មែរក្រហមយកទៅលាយជាមួយទឹកធ្វើជីស្រោចដំណាំនៅក្បែរនោះ ។ ក្រៅពីសម្លាប់នៅក្បែរអគារជាន់ផ្ទាល់ដី អ្នកទោសខ្លះទៀតត្រូវបាននាំយកទៅសម្លាប់នៅព្រៃតាគុយដែលមានទីតាំងស្ថិតនៅចម្ងាយប្រហែល៣គីឡូម៉ែត្រពីមន្ទីរសន្តិសុខតាម៉ន ។

អ៊ិង សាភឿន ជាអតីតអ្នកទោសស្ត្រីនៅមន្ទីរសន្តិសុខតាម៉ន ក្នុងអំឡុងឆ្នាំ១៩៧៧ បច្ចុប្បន្នរស់នៅក្នុងឃុំតានី ស្រុកអង្គរជ័យ ។ សាភឿន និយាយថា គាត់ត្រូវកងសន្តិសុខចាប់ខ្លួននៅខែកក្កដា ឆ្នាំ១៩៧៧ ពេលដែលគាត់កំពុងមានផ្ទៃពោះ៣ខែ ដោយសារគាត់ជាភរិយាមន្ត្រីតូចតាចម្នាក់នៅក្រុងភ្នំពេញកាលពីជំនាន់លន់នល់ ។ សាភឿន ត្រូវកងឈ្លបបញ្ជូនមកមន្ទីរសន្តិសុខតាម៉ន ជាមួយនឹងអ្នកទោសជាច្រើននាក់ទៀត ។ សាភឿន និងអ្នកទោសផ្សេងទៀតត្រូវបានបញ្ជាឲ្យធ្វើការជាទម្ងន់ ។ ក្នុងពេលធ្វើការ សាភឿន ដឹងថាមានអ្នកទោសចំនួន៣០០នាក់ ត្រូវកងសន្តិសុខនាំយកទៅសម្លាប់ក្នុងរយៈពេល៣ថ្ងៃ ។ នៅឆ្នាំ១៩៧៨ សាភឿន បានសម្រាលកូននៅក្នុងមន្ទីរឃុំឃាំងទាំងលំបាកលំបិន ។ សាភឿន និយាយដូច្នេះថា «កងឈ្លបគ្រាន់តែប្រគល់ទឹកមួយធុង និងកន្ត្រៃមួយសម្រាប់កាត់ទងផ្ចិតឲ្យខ្ញុំប៉ុណ្ណោះ» ។

នៅឆ្នាំ១៩៧៩ ខ្មែរក្រហមបានបង្ខំឲ្យអ្នកទោសស្រីចំនួន ១២៥នាក់ដើរឆ្ពោះទៅខេត្តកំពង់ស្ពឺ ។ អ្នកទោសស្ត្រី៨៥នាក់

ត្រូវខ្មែរក្រហមសម្លាប់នៅខេត្តកំពង់ស្ពឺ ហើយនៅសល់តែ៤០នាក់ត្រូវបង្ខំឲ្យធ្វើដំណើរទៅកាន់ភ្នំព្រះខេត្តពោធិសាត់ទៀត ។ សាភឿន ក៏ស្ថិតនៅក្នុងចំណោមអ្នកទាំង៤០នេះដែរ ។ ប៉ុន្តែទីបំផុតនៅរស់តែ១៨នាក់ប៉ុណ្ណោះ ។ សាភឿន និយាយថា “ទីបំផុតពួកយើងដែលសល់១៨នាក់បានសម្រេចចិត្តរត់ឡើងលើភ្នំ ។ កូនរបស់ខ្ញុំនៅមានជីវិតនៅឡើយ ហើយឥឡូវនេះវាមានអាយុ១៧ឆ្នាំហើយ ។ វាមានឈ្មោះថា សេង មនោ” ។

## ទិន្នន័យសង្ខេប

**ទីតាំង** : មន្ទីរសន្តិសុខតាម៉ន ស្ថិតនៅភូមិឫស្សីជុំ ឃុំប្រភ្នំ ស្រុកអង្គរជ័យ ខេត្តកំពត ។

**ស្ថិតិ** : មន្ទីរសន្តិសុខតាម៉ន ជាមន្ទីរសន្តិសុខប្រចាំតំបន់១៣ និងជាមន្ទីរធំជាងគេនៅក្នុងខេត្តកំពត ។ ខ្មែរក្រហមបានសង់ផ្ទះ៣ខ្នងដើម្បីឃុំឃាំងមនុស្ស ។ មួយខ្នងសម្រាប់ឃុំឃាំងអ្នកទោសស្ត្រី មួយខ្នងទៀតឃុំឃាំងអ្នកទោសបុរស និងមួយខ្នងទៀតឃុំឃាំងអ្នកទោសធ្ងន់មិនថាបុរស ឬស្ត្រីឡើយ ។ អ្នកទោសត្រូវកងឈ្លបនាំយកទៅសម្លាប់នៅព្រៃតាគុយ ។

## ២) មន្ទីរសន្តិសុខស្រែជា

នៅឆ្នាំ១៩៧៥ នៅឃុំចំប៉ីខ្មែរក្រហមបានបង្កើតមន្ទីរសន្តិសុខមួយដែលមានទីតាំងក្នុងវត្តស្រែជាភូមិស្រែជា ឃុំចំប៉ី ស្រុកអង្គរជ័យ ខេត្តកំពត ។ កុដិសម្រាប់ព្រះសង្ឃគង់នៅត្រូវខ្មែរក្រហមយកធ្វើជាមន្ទីរឃុំឃាំងនិងកន្លែងសួរចម្លើយ ។ ចំណែកព្រះវិហារជាកន្លែងស្នាក់នៅរបស់កម្មាភិបាលខ្មែរក្រហមដែលមើលការខុសត្រូវនៅក្នុងមន្ទីរសន្តិសុខនេះ ។ ចេង គឺជាប្រធានសន្តិសុខប្រចាំវត្តស្រែជា សព្វថ្ងៃគាត់រស់នៅភូមិទន្លេនាម ឃុំចំប៉ី ។ ម្នាក់ទៀតឈ្មោះ រឿន ជាអនុប្រធាន ។ រឿន ត្រូវចាប់ខ្លួនពីបទប្លន់ទ្រព្យសម្បត្តិប្រជាជនកាលពីពេលថ្មីៗនេះ ។

ក្នុងនាមជាអ្នកគ្រប់គ្រងមន្ទីរសន្តិសុខវត្តស្រែជា ចេង និង រឿន បានចាប់ប្រជាជនជាច្រើននាក់មកដាក់ឃុំឃាំងដើម្បីសួរចម្លើយនិងសម្លាប់ចោល ។ អ្នកទោសស្ត្រីត្រូវកងឈ្លបរំលោភមុនទើបសម្លាប់ចោលជាក្រោយ ។ ជួនកាលក៏យកទៅសម្លាប់ភ្លាមៗដែរ ។ ហ៊ុន អ៊ុំ អាយុ៥៥ឆ្នាំ រស់នៅភូមិស្រែជា ឃុំចំប៉ី ស្រុកអង្គរជ័យបានរៀបរាប់ថា គាត់ឃើញខ្មែរក្រហមចងដៃអ្នកទោសស្ត្រីភ្ជាប់នឹងសេះដែលពួកវាជិះធ្វើការ ហើយជិះបំផាយទៅមុខ ដោយឲ្យអ្នកទោសរត់តាមពីក្រោយរហូតដល់ដួលស្លាប់ ឬយកទៅសម្លាប់នៅពេលដែលរត់មិនរួច ។ បងប្រុសរបស់ អ៊ុំ ឈុត បានឃើញហេតុការណ៍ចាប់រំលោភនេះដោយផ្ទាល់ភ្នែកខណៈពេលដែលគាត់ចេញពីកន្លែងធ្វើការត្រឡប់មកផ្ទះរបស់គាត់ ។ ចំណែកអ្នកទោសបុរសត្រូវកងឈ្លបធ្វើទារុណកម្មនិងបង្អត់បាយរហូតដល់ស្លាប់ ។ អ៊ុំ ឈុត អាយុ៦១ឆ្នាំ រស់នៅក្នុងភូមិស្រែជា ឃុំចំប៉ី ស្រុកអង្គរជ័យ ខេត្តកំពត បាននិយាយថា អ្នកខុសសីលធម៌ក៏ត្រូវកងឈ្លបចាប់យកមកដាក់ឃុំឃាំងនៅមន្ទីរសន្តិសុខវត្តស្រែជានេះដែរ ។ អ្នកទោសភាគច្រើន គឺមកពីភូមិដើមដូង ឃុំដើមដូង ។ អ្នកទោសត្រូវបាននាំយកទៅសម្លាប់នៅទីតាំងមួយស្ថិតនៅចម្ងាយប្រហែល១០០ម៉ែត្រពីមន្ទីរសន្តិសុខ ។ រណ្តៅចំនួន២៥ និងសាកសពជនរងគ្រោះប្រមាណ ៤០០នាក់ ត្រូវកងឈ្លបសម្លាប់នៅទីតាំងនោះ ។


មន្ទីរសន្តិសុខស្រែជា ភូមិស្រែជា ឃុំចំប៉ី ស្រុកអង្គរជ័យ ខេត្តកំពត

ក្រោយឆ្នាំ១៩៧៩ រណ្តៅសាកសពទាំងប៉ុន្មានត្រូវប្រជាជនគាស់កកាយដើម្បីរកវត្ថុមានតម្លៃផ្សេងៗដែលនៅជាប់នឹងខ្លួនសាកសព ។ បច្ចុប្បន្នអតីត

មន្ទីរសន្តិសុខវត្តស្រែជាត្រូវបានរុះរើចេញទាំងស្រុងដោយសារតែភាពពុកផុយ ។

**ទិន្នន័យសង្ខេប**

**ទីតាំង** ៖ មន្ទីរសន្តិសុខស្រែជា ស្ថិតនៅភូមិស្រែជា ឃុំចំប៉ី ស្រុកអង្គរជ័យ ខេត្តកំពត ។

**ស្ថិតិ** ៖ មន្ទីរសន្តិសុខស្រែជា ត្រូវបានបង្កើតឡើងនៅក្នុងបរិវេណវត្តស្រែជាកាលពីអំឡុងឆ្នាំ១៩៧៥ ក្នុងគោលបំណងឃុំឃាំងជនរងគ្រោះជាប្រជាជនជម្លៀសមកពីទីក្រុងភ្នំពេញ និងប្រជាជនមូលដ្ឋានដែលរស់នៅក្នុងភូមិដើមដូង ឃុំដើមដូង ស្រុកអង្គរជ័យ ។ ជនរងគ្រោះត្រូវបានសម្លាប់ដាក់នៅក្នុងរណ្តៅចំនួន២៥ ។

## ស្រុកបន្ទាយមាស

### ៣) មន្ទីរសន្តិសុខទ្វារខៀវ (គុកទ្វារខៀវ)

បន្ទាប់ពីរំដោះទូទាំងប្រទេសនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ផ្ទះប្រជាជននៅជុំវិញបរិវេណទីផ្សារស្រុកបន្ទាយមាស ត្រូវអង្គការបដិវត្តន៍ប្រមូលយកធ្វើជាសម្បត្តិរួមនិងធ្វើជាមន្ទីរសន្តិសុខប្រចាំស្រុក៧៥ ឬមន្ទីរសន្តិសុខទ្វារខៀវ ឬគុកទ្វារខៀវ ។ ម្ចាស់ផ្ទះត្រូវបានបណ្តេញឲ្យទៅរស់នៅតាមជនបទដាច់ស្រយាល ម្ចាស់ផ្ទះខ្លះទៀតត្រូវសម្លាប់ចោលដោយសារតែរឹងទទឹងមិនស្តាប់តាមបញ្ជា ។ ប្រដាប់ប្រដាទាំងអស់ដែលមាននៅតាមផ្ទះនីមួយៗត្រូវអង្គការដឹកជញ្ជូនយកទៅដាក់ក្នុងឃ្លាំងសម្រាប់យកទៅប្រើប្រាស់នៅតាមសហករណ៍ក្នុងស្រុក ។ ផ្ទះល្វែងដែលមានបន្ទប់ជាប់ៗគ្នា ស្ថិតនៅកាច់ជ្រុងអតីតផ្សារស្រុកបន្ទាយមាសត្រូវខ្មែរក្រហមយកធ្វើជាមន្ទីរឃុំឃាំងនិងកន្លែងសួរចម្លើយ ។

ង៉ែត ម៉ៅ ហៅ ព្រាប វុធ ជាបុគ្គលិកនគរបាលស្រុកបន្ទាយមាស បាននិយាយថា ជនរងគ្រោះដែលខ្មែរក្រហមចាប់មកដាក់នៅក្នុងមន្ទីរសន្តិសុខទ្វារខៀវ ជាប្រជាជនមូលដ្ឋានដែលកងឈ្លបចាប់មកពីសហករណ៍នានាក្នុងស្រុក៧៥ ប្រជាជន១៧មេសា និងអ្នកជាប់និន្នាការនយោបាយពីសង្គមចាស់ ។ អ្នកទោសភាគច្រើនត្រូវកងឈ្លបនាំយកទៅសម្លាប់នៅទីតាំងជិតមន្ទីរសន្តិសុខទ្វារខៀវនេះ ។ តាមការប៉ាន់ស្មានរបស់ ង៉ែត ម៉ៅ ថា ជនរងគ្រោះប្រហែលជា២០០០នាក់ ត្រូវបានសម្លាប់ដាក់ក្នុងរណ្តៅជាច្រើននៅទីតាំងព្រៃចេកដែលសព្វថ្ងៃនេះគឺជាវាលស្រែល្ហឹងល្ហើយ ។

រហូតមកដល់បច្ចុប្បន្ន អតីតមន្ទីរសន្តិសុខទ្វារខៀវនៅតែមានទ្រង់ទ្រាយដូចដើម ប៉ុន្តែមិនមែនជាផ្ទះសម្រាប់ប្រជាជនស្នាក់នៅទៀតទេ ព្រោះត្រូវរដ្ឋអំណាចយកធ្វើជាការិយាល័យភូមិបាល មន្ទីរវប្បធម៌និងវិចិត្រសិល្បៈ និងមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍របស់ស្រុកវិញ ។

**ទិន្នន័យសង្ខេប**

**ទីតាំង** ៖ មន្ទីរសន្តិសុខទ្វារខៀវ ស្ថិតនៅក្នុងភូមិព្រៃក្រឡាខាងលិច ឃុំទូកមាសខាងលិច ស្រុកបន្ទាយមាស ខេត្តកំពត ។

**ស្ថិតិ** ៖ អតីតទីផ្សារប្រចាំស្រុកបន្ទាយមាស ធ្លាប់ត្រូវខ្មែរក្រហមយកធ្វើជាមន្ទីរសន្តិសុខប្រចាំស្រុក៧៥ ឬ គុកទ្វារខៀវ ។ អ្នកទោសគ្រប់ប្រភេទដែលជាប់នៅក្នុងមន្ទីរសន្តិសុខនេះ ត្រូវកងសន្តិសុខយកទៅសម្លាប់នៅទីតាំងព្រៃចេក ។ បច្ចុប្បន្ន មន្ទីរសន្តិសុខនេះ ត្រូវអាជ្ញាធរស្រុកបង្កើតជាការិយាល័យផ្សេងៗចំណុះសាលាស្រុកបន្ទាយមាសវិញ ។



មន្ទីរសន្តិសុខទ្វារខៀវ ភូមិព្រៃក្រឡាខាងលិច ឃុំទូកមាសខាងលិច ស្រុកបន្ទាយមាស ខេត្តកំពត

### ៤) មន្ទីរសន្តិសុខគៀនជុំ

មន្ទីរសន្តិសុខប្រចាំស្រុក៧៥ជាអតីតផ្សារប្រចាំស្រុកបន្ទាយមាស ហើយត្រូវបានផ្លាស់ប្តូរទីតាំងទៅនៅភ្នំគៀនជុំ ដែលមានឈ្មោះថាមន្ទីរសន្តិសុខគៀនជុំ ។ មន្ទីរសន្តិសុខនេះ បានត្រូវបង្កើតឡើងនៅឆ្នាំ១៩៧៧ ។ អគារទាំងអស់ប្រក់ដំបូលស្បូវ ហើយអគារតូចៗខ្លះទៀតត្រូវបានប្រើប្រាស់ធ្វើជាកន្លែងស្នាក់នៅរបស់កម្មាភិបាលខ្មែរក្រហមដែលធ្វើការនៅក្នុងមន្ទីរសន្តិសុខនេះ ។ នៅឆ្នាំ១៩៧៩ កម្មាភិបាលគ្រប់គ្រងមួយចំនួនត្រូវបានសម្លាប់និងមួយចំនួនទៀតបានរត់ទៅកាន់ព្រំដែន ។ ចំណែកអគារទាំងប៉ុន្មាននៅក្នុងមន្ទីរនេះត្រូវប្រជាជនរុះរើគ្មានសល់ ។



មន្ទីរសន្តិសុខគៀនជុំ ភូមិព្រៃតាព្រិត ឃុំស្តេចគង់ខាងលិច ស្រុកបន្ទាយមាស ខេត្តកំពត

### ទិន្នន័យសង្ខេប

**ទីតាំង** : មន្ទីរសន្តិសុខគៀនជុំ ស្ថិតនៅក្នុងភូមិព្រៃតាព្រិត ឃុំស្តេចគង់ខាងលិច ស្រុកបន្ទាយមាស ខេត្តកំពត ។

**ស្ថិតិ** : មន្ទីរសន្តិសុខប្រចាំស្រុកបន្ទាយមាសបានផ្លាស់ប្តូរទីតាំងមកកាន់ភ្នំគៀនជុំនៅឆ្នាំ១៩៧៧ ។ អ្នកទោសទាំងអស់ដែលធ្លាប់ជាប់គុកក្នុងមន្ទីរសន្តិសុខប្រចាំស្រុកបន្ទាយមាសត្រូវបន្តមកជាប់គុកនៅមន្ទីរសន្តិសុខគៀនជុំដដែល ។ នៅដើមឆ្នាំ១៩៧៩ មន្ទីរសន្តិសុខនេះត្រូវបានរំលាយចោល ។ ចំណែកអគារសម្រាប់ឃុំឃាំងអ្នកទោសត្រូវបានប្រជាជនដែលមានទីលំនៅក្បែរៗនោះរុះរើគ្មានសល់ ។

## ស្រុកដងទង់

### ៥) មន្ទីរសន្តិសុខភ្នំល្អាង

មន្ទីរសន្តិសុខភ្នំល្អាងមានទីតាំងស្ថិតនៅភាគខាងលិចភ្នំវល្លិ៍ ។ នៅរដូវទឹកឡើងផ្លូវចូលទៅកាន់ភ្នំល្អាងត្រូវទឹកជន់លិចល្ហល្ហាច ។ ខ្មែរក្រហមប្រើប្រាស់ល្អាងភ្នំនេះធ្វើជាមន្ទីរសន្តិសុខសម្រាប់ឃុំឃាំងអ្នកទោសជាប្រជាជនថ្មី និងទាហាន ឬប៉ូលិសនៃរបបសាធារណរដ្ឋខ្មែរ ។ ហ៊ិន ដែលជាប្រធានមន្ទីរសន្តិសុខភ្នំល្អាងត្រូវប្រជាជនសម្លាប់នៅថ្ងៃរំដោះខែមករា ឆ្នាំ១៩៧៩ ។

អ្នកទោសទាំងអស់ដែលជាប់នៅក្នុងមន្ទីរឃុំឃាំងភ្នំល្អាងត្រូវខ្មែរក្រហមនាំយកទៅសម្លាប់ចោលនៅកន្លែងមួយដែលមានចម្ងាយប្រហែល១គីឡូម៉ែត្រកន្លះពីភ្នំល្អាង តាមផ្លូវលំមួយឆ្ពោះទៅកាន់ផ្លូវជាតិលេខ៣ ។ នៅទីនោះមានរណ្តៅសាកសពយ៉ាងច្រើន ប៉ុន្តែរណ្តៅទាំងនោះត្រូវរលុបបាត់អស់ដោយសារទឹកភ្លៀងនិងទឹកជំនន់ ហើយខ្លះទៀតត្រូវប្រជាជនចាក់ដីលុបដើម្បីធ្វើស្រែ ។



មន្ទីរសន្តិសុខភ្នំល្អាង ស្ថិតនៅក្នុងភូមិល្អាង ឃុំល្អាង ស្រុកដងទង់ ខេត្តកំពត

### ទិន្នន័យសង្ខេប

**ទីតាំង** : មន្ទីរសន្តិសុខភ្នំល្អាង ស្ថិតនៅក្នុងភូមិល្អាង ឃុំល្អាង ស្រុកដងទង់ ខេត្តកំពត ។

**ស្ថិតិ** : ប្រជាជនជាច្រើននាក់ដែលជម្លៀសចេញពីទីក្រុងភ្នំពេញត្រូវខ្មែរក្រហមចាប់បញ្ជូនទៅដាក់ឃុំឃាំងនៅក្នុងមន្ទីរសន្តិសុខភ្នំល្អាង ហើយត្រូវកងឈ្លបនាំយកទៅសម្លាប់នៅទីតាំងមួយចម្ងាយប្រហែល១គីឡូម៉ែត្រកន្លះពីមន្ទីរសន្តិសុខ ។

## ស្រុកកំពង់ត្រាច

### ៦) មន្ទីរសន្តិសុខភូមិចិនមាន

ភូមិចិនមាន ជាឈ្មោះដែលប្រជាជននិយមហៅតៗគ្នា

វហូតក្លាយជាទម្លាប់ និងបានដឹងគ្រប់ថា មន្ទីរនេះស្ថិតនៅក្នុងភូមិអូរស្វែង ឃុំដំណាក់កន្ទួតខាងជើង ស្រុកកំពង់ត្រាច ខេត្តកំពត ។ មន្ទីរសន្តិសុខភូមិចិនមានត្រូវខ្មែរក្រហមសាងសង់ឡើងក្រោយថ្ងៃជ័យជម្នះ១៧មេសា១៩៧៥ ។ អ្នកទោសដែលបញ្ជូនមកដាក់ឃុំឃាំង នៅទីនោះត្រូវកងឈ្លបសួរចម្លើយនៅពេលយប់



មន្ទីរសន្តិសុខភូមិចិនមាន ភូមិអូរស្វែង ឃុំដំណាក់កន្ទួតខាងជើង ស្រុកកំពង់ត្រាច ខេត្តកំពត

និងនាំយកទៅសម្លាប់ចោលបន្ទាប់ពីសួរចម្លើយ ។ ហង់ ភន អាយុ៥២ឆ្នាំ ជាប្រធានភូមិអូរស្វែងបាននិយាយថា អ្នកទោសភាគច្រើនជាប្រជាជនមូលដ្ឋាននិងប្រជាជនថ្មី ។ នៅចុងឆ្នាំ១៩៧៨ និងដើមខែមករា ឆ្នាំ១៩៧៩ អ្នកទោសទាំងអស់ត្រូវកងសន្តិសុខនាំយកទៅសម្លាប់ចោល ។ ហង់ ភន សន្និដ្ឋានថា ទំនងជាខ្មែរក្រហមទើបតែសម្លាប់មនុស្សនៅចុងឆ្នាំ១៩៧៨ប៉ុណ្ណោះ ពីព្រោះប្រមាត់ខ្លះហាលមិនទាន់ស្ងួតនៅឡើយ ។

នៅក្រោយឆ្នាំ១៩៧៩ ប្រជាជនមួយចំនួនបានឃើញប្រមាត់មនុស្សយ៉ាងច្រើនដាក់ហាលពាសពេញនៅក្នុងបរិវេណមន្ទីរឃុំឃាំងភូមិចិនមាន ។

**ទិន្នន័យសង្ខេប**

**ទីតាំង** ៖ មន្ទីរសន្តិសុខភូមិចិនមាន ស្ថិតនៅក្នុងភូមិអូរស្វែង ឃុំដំណាក់កន្ទួតខាងជើង ស្រុកកំពង់ត្រាច ខេត្តកំពត ។

**ស្ថិតិ** ៖ មន្ទីរសន្តិសុខភូមិចិនមាន ជាមន្ទីរសន្តិសុខមួយដែលឃុំឃាំងអ្នកទោសជាប្រជាជនថ្មីនិងប្រជាជនមូលដ្ឋាន ។ អ្នកទោសត្រូវបានសម្លាប់ចោលទាំងអស់នៅពេលយប់បន្ទាប់ពីបានសួរចម្លើយរួច ។

## ស្រុកកំពត

### ៧) មន្ទីរសន្តិសុខវត្តកំពង់ត្រឡាច

ព្រះវិហារវត្តកំពង់ត្រឡាច ត្រូវខ្មែរក្រហមយកធ្វើជាមន្ទីរសន្តិសុខ ហើយបរិវេណខាងក្រៅប្រើជាកន្លែងសម្លាប់មនុស្ស ។ ណាត កែវ ជាអនុប្រធានឃុំបាននិយាយថា អ្នកទោសដែលជាប់នៅមន្ទីរសន្តិសុខវត្តកំពង់ត្រឡាច ត្រូវបានយកទៅសម្លាប់នៅព្រៃ ត្រពាំងស្តោរ ចម្ងាយប្រហែល២គីឡូម៉ែត្រពីវត្តកំពង់ត្រឡាច ។

**ទិន្នន័យសង្ខេប**

**ទីតាំង** ៖ មន្ទីរសន្តិសុខវត្តកំពង់ត្រឡាច ស្ថិតនៅក្នុងភូមិកំពង់ត្រឡាច ឃុំកែប ស្រុកកំពត ខេត្តកំពត ។

**ស្ថិតិ** ៖ បរិវេណខាងក្នុងវត្តកំពង់ត្រឡាច ជាមន្ទីរសន្តិសុខនៅសម័យខ្មែរក្រហម ។ ចំណែកបរិវេណខាងក្រៅជាទីតាំងសម្លាប់ ។

**ផេង ពង្សរ៉ាស៊ី**



មន្ទីរសន្តិសុខវត្តកំពង់ត្រឡាច ភូមិកំពង់ត្រឡាច ឃុំកែប ស្រុកកំពត ខេត្តកំពត

# ព្រាត់ស្លាប់

ជាមួយទឹកមុខមាំនិងក្លាហាន កាលីជីប បានឲ្យដឹងថា គាត់ជាប្រធាននារីភូមិ ទទួលខុសត្រូវការងារខាងស្ត្រីអ៊ីស្លាមនៅភូមិចាមលើ ឃុំព្រែកថ្មី ស្រុកកោះធំ ខេត្តកណ្តាល ដែលជាភូមិកំណើតរបស់គាត់ និងក៏ជាទីលំនៅបច្ចុប្បន្នរបស់គាត់ដែរ ។ កាលីជីប ត្រូវប្រជាជនជ្រើសរើសឲ្យធ្វើជាប្រធាននារីភូមិ តាំងពីការបោះឆ្នោតអាណត្តិទី១ ក្នុងឆ្នាំ១៩៩៣ ។ កាលីជីប អាចរក្សាតំណែងនេះបានរហូតមកដល់បច្ចុប្បន្នអាស្រ័យ ដោយប្រជាជនមានទំនុកចិត្តលើការងាររបស់គាត់ ។

កាលីជីប បានប្រាប់ខ្ញុំអំពីជីវិតតស៊ូរបស់គាត់ក្នុងនាមជាស្ត្រីមេម៉ាយម្នាក់តាំងពីឆ្នាំ១៩៧៥ ។ កាលីជីប ជាស្ត្រីរឹងប៉ឹង ប៉ុន្តែគាត់បែរជាមិនអាចទប់ទឹកភ្នែកបាននៅពេលរំឭកដល់រឿងរ៉ាវនៃរបបខ្មែរក្រហម គាត់បាននិយាយរៀបរាប់ថា ៖

«ពេលខ្ញុំផ្លាស់ទៅរស់នៅភូមិចាមលើខ្ញុំមានកូនពីរនាក់ហើយ ប្តីខ្ញុំជាទាហានខាងសម្តេច សីហនុ ។ គាត់ត្រូវទៅបំពេញបេសកកម្មនៅស្រុកស្វាយទង ខេត្តស្វាយរៀង ។ គាត់ក៏បានយកខ្ញុំនិងកូនទៅរស់នៅជាមួយគាត់ដែរ ។ កាលណោះកងពលរបស់គាត់ប្រយុទ្ធគ្នាជាមួយកងទ័ពខ្មែរក្រហម ប៉ុន្តែដោយសារចាញ់សង្គ្រាមជាមួយកងទ័ពខ្មែរក្រហម គាត់ត្រូវបញ្ជូនឲ្យមកនៅមន្ទីរវត្តមហាមន្ត្រីទីក្រុងភ្នំពេញ ។ ខ្ញុំរស់នៅទីក្រុងភ្នំពេញបានរយៈពេលមួយឆ្នាំ ប្តីខ្ញុំក៏ធ្លាក់ខ្លួនឈឺ ។ ខ្ញុំដើរលក់បន្លែដើម្បីយកប្រាក់មកព្យាបាលជំងឺគាត់និងផ្គត់ផ្គង់ជីវភាព ។ ក្រោយមកជំងឺគាត់ក៏បានធូរស្រាលឡើងវិញ ។ ពេលនោះខ្ញុំមានផ្ទៃពោះ ហើយសម្រាលបានកូនស្រីម្នាក់ទៀតឈ្មោះ សាឡេះ ពៅ នៅមន្ទីរពេទ្យជ័យជម្នះទីក្រុងភ្នំពេញ ។ ខ្ញុំចេញពីមន្ទីរពេទ្យបានបីថ្ងៃ ស្រាប់តែមានភាពចលាចលនៅទីក្រុងភ្នំពេញ ។ កងទ័ពខ្មែរក្រហមកាន់អាវុធគ្រប់ដៃបានប្រាប់ឲ្យយើងចេញពីទីក្រុង ។ ខ្ញុំក៏ចាកចេញពីផ្ទះទាំងសរសៃខ្ចី ។ សំណាងល្អ ប្តីខ្ញុំចេះជំនាញពេទ្យខ្លះដែរ គាត់បានទិញថ្នាំពេទ្យតាមផ្លូវមកចាក់ឲ្យខ្ញុំ ។

ខ្ញុំធ្វើដំណើរដោយថ្មើរជើងអស់រយៈប្រហែលមួយខែ ទើបទៅដល់ផ្ទះនៅឯស្រុកកោះធំ ។ ខ្ញុំទៅដល់ផ្ទះម៉ោងប្រហែល១០ព្រឹក ម៉ោង៣រសៀលខ្មែរក្រហមដេញប្រជាជនពីភូមិចាមលើទៅភូមិចាមក្រោមទាំងអស់ ។ ខ្ញុំមិនដឹងពីមូលហេតុដែលខ្មែរក្រហមជម្លៀសជនជាតិចាមទៅរស់នៅភូមិចាមក្រោមទេ ។

ក្នុងឆ្នាំ១៩៧៥ ឈ្លបខ្មែរក្រហមបានមកដល់ផ្ទះខ្ញុំ ហើយប្រាប់ប្តីខ្ញុំថា អង្គការស្នើឲ្យគាត់ទៅរៀនសូត្រ ។ ខ្ញុំស្មានថា អង្គការយកគាត់ទៅរៀនសូត្រមែន ប៉ុន្តែប្តីខ្ញុំវិញ គាត់ហាក់ដូចជាដឹងថាអង្គការចង់បោសសម្អាតអតីតទាហាន ឬអ្នកធ្វើការរបបមុន គាត់បានសុំខមាទោសពីខ្ញុំ និងផ្តាំផ្ញើខ្ញុំជាច្រើន មុនពេលគាត់ចាកចេញទៅ ។

ខ្ញុំចាំបាត់ៗក៏សង្ស័យថា ប្រហែលជាអង្គការសម្លាប់គាត់ហើយ ។ ខ្ញុំមិនដឹងគិតយ៉ាងណាទេ ព្រោះខ្ញុំមានតែម្នាក់ឯង ម្យ៉ាងទៀត



កាលីជីប នៅភូមិចាមលើ ឃុំព្រែកថ្មី ស្រុកកោះធំ ខេត្តកណ្តាល

កូនច្រើនទៀត ។ ខ្ញុំនិងកូនរស់នៅភូមិចាមក្រោមបានប្រហែល៥ខែ ត្រូវខ្មែរក្រហមជម្លៀសទៅខេត្តពោធិសាត់ ។ ខ្មែរក្រហមប្រកាសប្រាប់អ្នកភូមិទាំងអស់ថា ខេត្តពោធិសាត់ សម្បូររបស់របរហូបចុកណាស់ ។ ទោះបីជាយ៉ាងណាក៏យើងមិនអាចប្រកែកនឹងខ្មែរក្រហមបានដែរ ព្រោះនេះគ្រាន់តែជាលេសរបស់ខ្មែរក្រហមប៉ុណ្ណោះ ។ នៅពេលទៅដល់ភូមិចន្ទ្រា ខ្មែរក្រហមឲ្យខ្ញុំចូលក្នុងកងវែកដីដោយម្នាក់ៗត្រូវវែកដីឲ្យបាន៥០ម៉ែត្រនិងកំពស់៦តឹកក្នុងមួយថ្ងៃ ។ ខ្ញុំក្រោកពីដំណេកតាំងពីម៉ោង២ទៀបភ្លឺដើម្បីទៅវែកដីឲ្យទាន់ផែនការ ។ សំពត់របស់ខ្ញុំពណ៌ស ស្លៀកយូរៗទៅទើចហើយស្អើងទៀត ។ ពេលយប់ខ្ញុំស្លៀកក្រមាដើម្បីយកសំពត់ទៅជ្រលក់ភក់ឲ្យខ្មៅកុំឲ្យឃើញស្អើងពេក ព្រឹកឡើងទើបខ្ញុំស្លៀកសំពត់នោះទៅធ្វើការវិញ ។ ខោអាវដែលយកមកពីភូមិទាំងប៉ុន្មានខ្ញុំយកទៅជ្រលក់ពណ៌ខ្មៅទាំងអស់ ។ ខ្ញុំលួចសំពះយ៉ាំងបានច្រើនដងដែរ ប៉ុន្តែក្រោយមកដោយសារមានការហាមប្រាមមិនឲ្យមានសាសនាខ្ញុំក៏ផ្អាកមួយរយៈ ។ សម្លៀកបំពាក់ថ្វាយបង្គំ (ម៉ាខ្នាល)របស់ខ្ញុំ ត្រូវខ្មែរក្រហមបញ្ជាឲ្យយកទៅជ្រលក់ពណ៌ខ្មៅនិងកាត់ជាបំណែកធ្វើក្រមាប្រើប្រាស់វិញ ។ ខ្ញុំអត់មានសម្លៀកបំពាក់ថ្វាយបង្គំទេ ពេលខ្ញុំមានឱកាសថ្វាយបង្គំ ខ្ញុំពាក់អាវដៃវែងនិងសារុងជំនួស ។ ខ្មែរក្រហមមិនត្រឹមតែមិនចែកសម្លៀកបំពាក់ឲ្យខ្ញុំប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានស្នើសុំ ហូលសារុង និងសំពត់ហូរបស់ខ្ញុំទៀត ។ មាសខ្ញុំកាលណោះច្រើនណាស់ ប៉ុន្តែអង្គការដកហូតយកទាំងអស់ ។ ខ្ញុំឆ្អែតចិត្តណាស់នៅពេលរំឭកដល់រឿងនេះ ។ ចំពោះអាហារហូបចុកវិញ យើងហូបតែបបររាវៗមួយកំប៉ុងគ្នា៤០នាក់ ។ ខ្ញុំយកទឹកបបរមកដាំលាយជាមួយដើមច្រាច់ដើម្បីឲ្យឃើញច្រើនទើបនាំគ្នាហូប ។ កាលណោះសូម្បីតែទឹកក៏ខ្វះខាតដែរ ។ ខ្ញុំទៅដួសទឹកតាមថ្លុកជើងគោយកមកទុកឲ្យរងសម្រាប់ទុកឲ្យកូនផឹក ។

ក្រោយមកទៀត ខ្មែរក្រហមដាក់ផែនការឲ្យជនជាតិចាមទៅរាយមងនៅបឹង ។ ខ្ញុំខ្លាចឈ្លើងណាស់ ។ ខោខ្ញុំរហែកពីមុខរហែកពីក្រោយ ឈ្លើងតោងពេញចង្កេះពេញខ្លួនខ្ញុំ ។ ខ្ញុំមិនដឹងធ្វើម៉េច ក៏នោមដាក់ខោដើម្បីឲ្យឈ្លើងជ្រុះ ។ ខ្ញុំរកត្រីបានច្រើនណាស់ ។ ថ្ងៃមួយខ្ញុំសុំច្បាប់ប្រធានកងមិនទៅរកត្រី ព្រោះខ្ញុំឈឺក្បាលហើយខ្លាចឈ្លើងផង ប៉ុន្តែគេថាបើមិនទៅយប់ហ្នឹងទេ គេនឹងយកខ្ញុំទៅវាយចោល ។ គ្រាន់តែឮថាវាយចោលខ្ញុំក៏សុខចិត្តទៅរាយមងបន្តទៀត ។ ខ្ញុំបានទុកកូនតូចខ្ញុំចោលមួយយប់ទល់ភ្លឺ ពេលខ្ញុំមកពីរាយមងវិញ ឃើញវាស្រែកយំឡើងស្វាយមុខ ។ ខ្ញុំអាណិតកូន ខ្ញុំបានសុំមេកងឈប់ទៅរាយមងមួយរយៈ ដើម្បីអាចមើលថែកូនដោយសុំទៅបេះបន្លែជំនួសវិញ ។ មេកងក៏អនុញ្ញាត ។ ពីរថ្ងៃក្រោយមកអង្គការបានបំបែកខ្ញុំពីកូនទៅធ្វើការនៅកងវែកដីវិញ ។ កូនស្រីធំៗរបស់ខ្ញុំពីរនាក់ក្តៅខ្លួនខ្លាំង ខ្ញុំសុំមេកងទៅមើលកូនឈឺ មេកងមិនឲ្យខ្ញុំទៅទេព្រោះខ្ញុំមិនមែនពេទ្យ ។ ក្រោយមកកូនៗរបស់ខ្ញុំក៏ស្លាប់ ។ ដោយសារការអត់ឃ្លាននិងបាក់កម្លាំងធ្វើឲ្យមនុស្សស្លាប់ច្រើនណាស់ទាំងខ្មែរ ទាំងចាម ។ មនុស្សនៅសល់តែជាង១០នាក់នៅក្នុងសហករណ៍ពេងបាយរបស់ខ្ញុំ ។ អ្នកជិតខាងខ្ញុំម្នាក់ឈ្មោះ ជីណុប ឃ្លានពេក ខ្ញុំក៏ទៅលួចបាយក្តាំងគាត់ហូប ។ ហូបគ្រាន់មានកម្លាំងបន្តិច ជីណុប បានប្រាប់ខ្ញុំថាចង់ហូបពងទាកូន ។ ខ្ញុំក៏យកថ្នាំជក់បន្តិចទៅដូរជាមួយចុងភៅបានពងទាពីរគ្រាប់មកឲ្យគាត់ហូបទៀត ។ ហូបបានប្រហែលមួយម៉ោង ជីណុប ក៏ដាច់ខ្យល់ស្លាប់ ។ ខ្ញុំបានជួយរៀបចំបុណ្យសពគាត់តាមសាសនាជនជាតិចាម ។ ខ្ញុំយកសាកសពទៅជូតទឹក(ចំអាសទឹក) ហើយសូត្រធម៌តាមអ៊ីស្លាម ប៉ុន្តែ មិនបានថ្វាយបង្គំឲ្យសពទេព្រោះខ្ញុំជាស្រី ។ ការជូតទឹកក៏មិនសូវស្អាតដែរ ព្រោះទឹកមានតិចតួច ។ បន្ទាប់ពីជូតទឹកហើយ ខ្ញុំត្រូវរុំសពនឹងក្រណាត់រួចយកទៅកប់ ។ កាលនោះមាន សំរូប ដែលជនជាតិចាម និងជាអ្នកភូមិជាមួយខ្ញុំជាអ្នកជួយសែងសពយកទៅកប់ ។

រឿងដែលធ្វើឲ្យខ្ញុំខ្លាចខ្លាំងនោះគឺខ្ញុំឃើញខ្មែរក្រហមដឹកយកមនុស្សទៅសម្លាប់ ។ ព្រោះផ្ទះខ្ញុំនៅជាប់ផ្លូវ ។ យប់ឡើងឈ្លបខ្មែរក្រហមបរទេះកាត់មុខផ្ទះ ខ្ញុំនឹកស្មានថាដឹកមនុស្សយកទៅដាក់ភូមិនេះ ភូមិនោះ ប៉ុន្តែពេលរទេះបរត្រឡប់មកវិញឃើញតែខោអាវ ។ ឆ្នាំ១៩៧៨ ខ្ញុំគ្រាន់តែដឹងថា មានប្រជាជនមកពីស្វាយរៀងច្រើនណាស់ដែលត្រូវខ្មែរក្រហមសម្លាប់ ។

មានម្តងនោះពេលខ្ញុំកំពុងឱនរូកុ ថ្វាយបង្គំម៉ោងពាកនូះល្ងាចបាន២រ៉ាកាអាត់ ស្រាប់តែឈ្លបមកទាន់ ខ្ញុំក៏ធ្វើជាចុកពោះ

ហើយស្រែកតិចៗថា «ឈឺពោះណាស់» ។ ថៃដន្យថ្ងៃនោះខ្ញុំគ្រុនពោះវៀន ឈ្លបពិនិត្យឃើញថាខ្ញុំឈឺពិតមែន ហើយឲ្យពេទ្យផ្សំថ្នាំឲ្យខ្ញុំ ។ ពេលនោះប្រសិនបើខ្ញុំឈឺពុតច្បាស់ជាខ្មែរក្រហមធ្វើបាបខ្ញុំ ឬក៏យកទៅសម្លាប់ក៏មិនដឹង ព្រោះសូម្បីអ្នកអត់ទៅធ្វើការក៏ខ្មែរក្រហមយកទៅសម្លាប់ដែរ ដូចជា ម៉ាស់ ជាដើម ។ មេកងប្រាប់ខ្ញុំឲ្យហៅ ម៉ាស់ ទៅស្ទូងស្រូវនៅពេលយប់ជាមួយស្ត្រី១២នាក់ទៀត ។ ប៉ុន្តែ ម៉ាស់ ស្តីឲ្យខ្ញុំថា «ដីបឯងទ្រីស្តីបានតែគ្នាឯង» ។ ម៉ាស់ មិនព្រមទៅធ្វើការទេ គិតតែពីយកមាសពេជ្រដែលជាកេររបស់ម្តាយទៅដូរយកអាហារនិងរបស់របរប្រើប្រាស់ ។ ក្រោយមកខ្មែរក្រហមក៏នាំ ម៉ាស់ ទៅវាយចោលនៅមុខខ្ញុំ ។ កាលណោះ ម្តាយរបស់ ម៉ាស់ មុននឹងស្លាប់ គាត់បានផ្ញើមាសពេជ្រនិងសម្លៀកបំពាក់នឹងខ្ញុំដើម្បីទុកឲ្យកូនគាត់ ឈ្មោះ ម៉ាស់ ។ ទីបំផុត ខ្ញុំមិននឹកស្មានថា ម៉ាស់ ស្លាប់ដោយសារមាសពេជ្រនិងលាក់កម្លាំងពលកម្មទេ ។

ខ្មែរក្រហមកាន់តែរឹតបន្តឹងការរស់នៅនិងការប្រណិប័តន៍សាសនា ។ ប្រធានកងរបស់ខ្ញុំតាមដានខ្ញុំពីរឿងថ្វាយបង្គំខ្លាំងណាស់ ។ ខ្ញុំយកទឹកថ្វាយបង្គំ ហើយក៏អង្គុយនៅមួយកន្លែងសម្ងំសូត្រធម៌ដូចភាវនាធម៌ ប៉ុន្តែមិនបានឱនងើបៗតាមស៊ូរ៉ាត់(គោលការណ៍សំពះយ៉ាំង) ទេ ។ ពេលសំពះយ៉ាំងម្តងៗ ខ្ញុំភ័យអរៗខ្លាចក្រែងឈ្លបមកទាន់ ប៉ុន្តែនៅតែចៀសមិនផុត ពេលខ្ញុំចាប់ផ្តើមថ្វាយបង្គំស្រាប់តែឈ្លបមកទាន់ ហើយមកសួរថា«ធ្វើអីហ្នឹង?» ខ្ញុំឆ្លើយថា«ខ្ញុំរងាចុកពោះណែនដើមទ្រូង» ឈ្លបក៏មិនសួរនាំទៀតដែរ ។ ខ្ញុំក៏បន្តសំពះយ៉ាំងទៀត ។

នៅចុងឆ្នាំ១៩៧៨ មានពាក្យចចាមអារ៉ាមជាច្រើន លេចឮពីអ្នកធ្វើការជាមួយខ្មែរក្រហមដូចជានិរសារឬមេកងថា ស្រុកទេសនឹងប្រែប្រួល ។ ខ្ញុំមានកូនធម៌ម្នាក់ឈ្មោះ រស់ កុសល ជានិរសារខ្មែរក្រហមបានប្រាប់ខ្ញុំឲ្យឆាប់រត់ចេញពីភូមិ ព្រោះបន្តិចទៀតនឹងមានយន្តហោះទម្លាក់គ្រាប់បែក ហើយខ្មែរក្រហមនឹងបញ្ជាឲ្យប្រជាជនចុះក្នុងរណ្តៅដែលបង្កប់មីនរួចជាស្រេច បន្ទាប់មកគេនឹងចុចមីននោះឲ្យផ្ទុះឡើងស្លាប់ទាំងអស់គ្នា ។ កូនប្រុសខ្ញុំឈ្មោះ ម៉ាលី ក៏បានទទួលដំណឹងខ្លះដែរ វាប្រាប់ខ្ញុំថា ជិតមានគេមកជួយរំដោះហើយ ឲ្យខ្ញុំនិយាយប្រយ័ត្នប្រយែង ។ ខ្ញុំយកដំណឹងនេះទៅខ្សឹបប្រាប់អ្នកជិតខាងដែលខ្ញុំទុកចិត្ត ។ យប់ឡើងយើងនាំគ្នាលួចថ្វាយបង្គំសុំពីអាល់ឡោះដើម្បីឲ្យមានអ្នកមកជួយសង្គ្រោះយើងឆាប់ៗ ។

ខ្មែរក្រហមបានកៀរប្រជាជនជាច្រើនឡើងភ្នំ ដោយបំភ័យប្រជាជនថា «ប្រយ័ត្នយួនកាត់ក្បាលដាំតែអុង» ។ ពួកខ្ញុំសំណាងល្អដែរ ដែលកងទ័ពវៀតណាមមកជួយទាន់ពេលវេលា ។ ខ្ញុំអាណិតកូនស្រីពៅរបស់ខ្ញុំណាស់ វាឈឺតាមផ្លូវ ខ្ញុំបម្រុងទុកវាចោលនៅតាមផ្លូវដែរ ប៉ុន្តែបានទ័ពវៀតណាមឲ្យថ្នាំលេបក៏បានរស់មកដល់សព្វថ្ងៃ ។

ពេលខ្ញុំត្រឡប់មកដល់ភូមិវិញ ខ្ញុំទាស់សរសៃនៅសល់តែស្បែកដណ្តប់ឆ្អឹង ។ បងប្អូនខ្ញុំមើលខ្ញុំមិនស្គាល់ ចំណែកបងខ្ញុំម្នាក់ទៀតគ្រាន់តែឃើញរូបរាងខ្ញុំភ្លាមក៏សន្លប់បាត់ស្មារតី ។

ខ្ញុំបានស៊ើបសួរដំណឹងប្តីរបស់ខ្ញុំក្រែងគាត់នៅរស់ ប៉ុន្តែ ហ៊ុម ដែលជាអ្នកជិតខាងរបស់ខ្ញុំប្រាប់ថា ប្តីខ្ញុំស្លាប់នៅគុកពោធិ៍ទន្លេ ។ អ្នកដែលខ្មែរក្រហមចាប់ទៅជាមួយប្តីខ្ញុំ ខ្លះអាចរត់រួចខ្លួនមកវិញដូចជា ទីនយ៉េត ។ ចំណែកប្តីខ្ញុំជាប់ខ្នោះដៃជង់ខ្នោះជើងផង ដែលធ្វើឲ្យគាត់មិនអាចរត់រួច ។ ខ្មែរក្រហមបានវាយគាត់និងអ្នកទោស៦នាក់ទៀតទម្លាក់ចូលទៅក្នុងរណ្តៅនៅពោធិ៍ទន្លេ ។ បងបង្កើតខ្ញុំម្នាក់ទៀតក៏ត្រូវឈ្លបខ្មែរក្រហមវាយសម្លាប់នៅក្នុងរណ្តៅគ្នា៣នាក់ដែរ ។ ក្រោយមកខ្ញុំក៏បានទៅគុកពោធិ៍ទន្លេដើម្បីគាស់យកឆ្អឹងមកធ្វើបុណ្យតាមសាសនាអ៊ីស្លាម ។

ដោយសារតែមានកំហឹងឈឺចាប់ កូនប្រុសទាំងពីររបស់ខ្ញុំស្ម័គ្រចិត្តចូលបម្រើកងទ័ពរដ្ឋកម្ពុជាដើម្បីការពារប្រទេស ។

មកដល់ឆ្នាំ១៩៩៣ ប្រជាជនក្នុងភូមិបានបោះឆ្នោតឲ្យខ្ញុំធ្វើជាប្រធាននារីភូមិ ។ ដើម្បីបម្រើផលប្រយោជន៍ដល់ស្ត្រីក្នុងភូមិ ខ្ញុំក៏សម្រេចចិត្តធ្វើ ។ ការងារនេះមានច្រើនមុខដូចជា ការងារសុខភាពសម្រាប់ស្ត្រីភេទ ការអប់រំផ្សេងៗ និងមានការប្រជុំជាញឹកញាប់ ។ រយៈពេលជាង៣០ឆ្នាំកន្លងមកហើយ ទោះបីខ្ញុំមុងម៉ាត់នឹងការងារនិងរឹងប៉ុងក្នុងការរស់នៅក៏ខ្ញុំមិនដែលភ្លេចពីរបបខ្មែរក្រហមដែរ ។ ខ្ញុំចងចាំអស់មួយជីវិត ។

**សូ ហ្សារីណា**

# ចំណាចឧក្រិដ្ឋកម្ម
# មន្ទីរសន្តិសុខភូមិភាគនិរតី
# ការកកើត ប្រតិបត្តិការ និង ធំនាក់ធំនង

**(តចប់)**

**មន្ទីរសន្តិសុខភូមិភាគនិរតី**

មន្ទីរសន្តិសុខភូមិភាគនិរតី "គុកភ្នំសន្ទុង" មានទីតាំងនៅភ្នំសន្ទុង ដែលមានបរិវេណដីទំហំ៨គីឡូម៉ែត្របួនជ្រុង ។ មន្ទីរសន្តិសុខនេះស្ថិតក្នុងឃុំសន្ទុង ស្រុកទ្រាំង ខេត្តតាកែវ និងចាប់ផ្តើមដំណើរការពីដើមឆ្នាំ១៩៧៦រហូតដល់ឆ្នាំ១៩៧៩ ក្រោមការគ្រប់គ្រងរបស់លេខាភូមិភាគនិរតីឈ្មោះសមមិត្ត ម៉ុក និងប្រធាន ដឹកនាំផ្ទាល់ពីររូប គឺសមមិត្ត សេង និងសមមិត្ត សឿន ។

អ្នកទោសមន្ទីរសន្តិសុខភូមិភាគនិរតី ភាគច្រើនជាអតីតកងទ័ពកម្មាភិបាលរបបកម្ពុជាប្រជាធិបតេយ្យ ប្រពន្ធ កូន និងសាច់ញាតិត្រូវចោទប្រកាន់ថាក្បត់នឹងអង្គការ ។ អ្នកទោសត្រូវបែងចែកឲ្យធ្វើការនិងរស់នៅដាច់ដោយឡែកពីគ្នា ។ អ្នកទោសស្ត្រីរស់នៅក្នុងភូមិដីប្រាបប៉ែកខាងលិចភ្នំ ចំណែកអ្នកទោសបុរសរស់នៅក្នុងភូមិលោកប៉ែកខាងជើងភ្នំ ភូមិស្រះតាកួនប៉ែកខាងលិចភ្នំ និងភូមិក្រោមប៉ែកខាងត្បូងភ្នំ។ អគារឃុំឃាំងមួយត្រូវបានសង់ឡើងនៅក្នុងចម្ការស្វាយក្នុងភូមិដីប្រាប ដើម្បីឃុំឃាំងអ្នកទោសដែលបានប្រព្រឹត្តកំហុសលួចរបស់របរសមូហភាព ធ្វើការមិនពេញដៃពេញជើងនិងប៉ុនប៉ងរត់គេចខ្លួន ។ ទីតាំងសម្លាប់អ្នកទោសមានពីរគឺ នៅក្នុងចម្ការស្វាយនិងនៅភ្នំតូច ។

ម៉ន ធ្លាប់ចេញចូលភ្នំសន្ទុងបានឲ្យដឹងថា ចុងឆ្នាំ១៩៧៥ ប្រជាជនដែលរស់ជុំវិញភ្នំសន្ទុង ត្រូវបានជម្លៀសចេញឲ្យទៅរស់នៅឆ្ងាយពីភូមិ បន្ទាប់មកប្រែក្លាយភូមិនិងភ្នំសន្ទុងឲ្យទៅជាមន្ទីរឃុំឃាំងតាំងពីពេលនោះរហូតដល់ដើមឆ្នាំ១៩៧៩ ។ ខ្មែរក្រហមបានដឹកប្រជាជនទាំងឡានៗមកទម្លាក់នៅជុំវិញភ្នំមិនយូរប៉ុន្មាន សភាពស្ងាត់ជ្រងំនៃភ្នំសន្ទុង បានក្លាយជាអ៊ូអរ អឹងអាប់និងពេញទៅដោយអ្នកទោស ។

នៅដើមឆ្នាំ១៩៧៦ សៀន ត្រូវចាប់ខ្លួនបញ្ជូនទៅឃុំឃាំងនិងលត់ដំនៅភ្នំសន្ទុង ។ កំហុសរបស់គាត់គ្មានអ្វីធំដុំទេ គឺដោយសារគាត់ជាប្អូនប្រុសបង្កើតឈ្មោះ ស៊ុន ជាអតីតទាហាន លន់ នល់ ។ សៀន មានដើមកំណើតនៅភូមិព្រះសុខ ឃុំសន្ទុង ស្រុកទ្រាំង ខេត្តតាកែវ ។ ក្រោយឆ្នាំ១៩៧៥ សៀន ត្រូវបានជម្លៀសនិងធ្វើការក្នុងស្រុកអង្គរបូរី ។ នៅឆ្នាំ១៩៧៦ សៀន និងយុវជនចំនួន៣០០នាក់ផ្សេងទៀតត្រូវបានចាប់និងបញ្ជូនខ្លួនពីស្រុកអង្គបូរីមកភ្នំសន្ទុង ។ នៅពេលឮថា ពួកគាត់ត្រូវបញ្ជូនទៅមន្ទីរសន្តិសុខភូមិភាគនៅភ្នំសន្ទុង សៀន មានអារម្មណ៍ធូរស្បើយក្នុងចិត្ត ដោយសារគាត់គិតថា គាត់នឹងបានវិលត្រឡប់មករស់នៅធ្វើការ និងបានឃើញវាលស្រែនៅភូមិកំណើតរបស់ខ្លួនវិញ ។ ផ្ទុយស្រឡះពីអ្វីដែល សៀន បានរំពឹងទុក ការងារ ទារុណកម្ម និងជីវិតរស់នៅក្នុងភ្នំសន្ទុងធ្វើឲ្យគាត់នឹកខ្លាចលែងចង់ឮឈ្មោះភ្នំសន្ទុងទៀត ។ សៀន បញ្ជាក់ថា ប្រវត្តិជូរចត់ភ្នំសន្ទុងធ្វើឲ្យគាត់ចងចាំនិងមិនអាចបំភ្លេចបានរហូតដល់សព្វថ្ងៃ ។ "សែនលំបាកនិងវេទនាណាស់ ។ ធ្វើការនិងហូបចុកដូចសត្វធាតុ ។ ទោះជាចង់បំភ្លេចក៏បំភ្លេចមិនបាន ក្បាលខ្ញុំស្នាម២កាំបិត ដៃខ្ញុំស្នាមខ្សែចង ហើយខ្លួនប្រាណខ្ញុំឈឺចាប់និងធ្វើទុក្ខមិនទាន់បាត់នៅឡើយ" ។

ឈឿន ត្រូវបានចាប់ខ្លួន ដោយសារគាត់ជាប្អូនស្រីរបស់ ញិន ទាហានស័ក្តិពីរ លន់ នល់ ។ ស្នាកស្នាមដំបៅ ភាពទុរ្ភិក្សខ្ទេចខ្ទាំ ធ្វើឲ្យ ឈឿន បំភ្លេចមិនបាន ។ "អ្នកទោសជាប់នៅភ្នំសន្ទុង សែនពិបាកខ្លាំងណាស់ទាំងការងារ ការហូបចុក និងការវាយធ្វើបាប ។ មកដល់ឥឡូវសុខភាពខ្ញុំទ្រុឌទ្រោម ការចងចាំក៏មិនសូវល្អដែរ ពីព្រោះខ្ញុំស្លុតអារម្មណ៍បាក់ស្បាត ។ ឈឿន ត្រូវប្រធានកងឈ្មោះ ណេម ចាប់ចងបាញ់កាំភ្លើងសម្លុតគំរាមកំហែង ដោយចោទថា គាត់បានដើរបំផុសបំផុលឲ្យអ្នកទោសលួចរត់ចេញពី

មន្ទីរឃុំឃាំង ។ ឈឿន បដិសេធការចោទប្រកាន់របស់ ណេម "ខ្ញុំឯណាហ៊ានដល់ថ្នាក់ទៅបំផុសបំផុលគេឲ្យរត់ បើខ្លួនឯងរកតែពុំទាន់ផង" ។

ការងាររបស់អ្នកទោសនៅភ្នំសន្ទុងតែងតែប្រែប្រួលនិងផ្លាស់ប្តូរពីកន្លែងមួយទៅកន្លែងមួយតាមការចាត់តាំងនិងរដូវកាល ។ ការងាររបស់អ្នកទោសមានជីកស្រះ ជីកប្រឡាយ សែងទឹកលើកទំនប់ ដាំដំណាំ គាស់ថ្ម និង វាយថ្ម ។ អ្នកទោសចាប់ផ្តើមធ្វើការងារតាំងពីព្រលឹមរហូតដល់យប់អធ្រាត្រ ។ ហើយទទួលបានត្រឹមតែបបររាវលាយជាមួយត្រកៀត គល់ចេក និងត្រកួនពេលថ្ងៃត្រង់ និងពេលយប់ប៉ុណ្ណោះ ។ ការងាររបស់ ប្រុញ នៅភ្នំសន្ទុងផ្លាស់ប្តូរពីការដ្ឋានមួយទៅការដ្ឋានមួយ ។ ដំបូងជីកប្រឡាយលើកទំនប់នៅខាងកើតភ្នំ បន្ទាប់មកទៅសែងទឹកពីបុស្សស្រុកមកភ្នំសន្ទុង និងក្រោយមកផ្លាស់ទៅខាងគាស់ថ្ម ។ មុនពេលត្រូវផ្លាស់ទៅគាស់និងវាយថ្មជាមួយ ប្រុញ, ទូន ជាអ្នកធ្វើកញ្ច្រែងល្អី ។ ក្នុងកងយុវនារី ឈឿន មានភារកិច្ចស្ទូងដកនិងបង្កបង្កើនផល ។ ឈឿន ធ្វើការតាំងពីព្រលឹមទល់ព្រលប់ ប៉ុន្តែរបបអាហារមានតែបបរទឹករាវកក្កូកពីរពេលប៉ុណ្ណោះក្នុងមួយថ្ងៃ ។ ប្រុញ បញ្ជាក់ថា "ការហេវហត់ ធ្វើឲ្យអ្នកទោសមិនថាស្រី មិនថាប្រុស លែងមានការខ្មាសអៀន ដើរលែងជៀសគ្នា ឲ្យតែក្រឡេកឃើញផ្លែអ្វី ឬសត្វអ្វីដែលអាចហូបបាន គឺសម្រុកដណ្តើមតែម្តង សូម្បីតែស្លឹកអំពិលជូរ និងកណ្តុរក៏ដណ្តើមគ្នាដែរ" ។

ស្ថានភាពការងារនិងរបបអាហាររបស់អ្នកទោសពីមួយថ្ងៃទៅមួយថ្ងៃ ធ្វើឲ្យអ្នកទោសកាន់តែទន់ខ្សោយនិងបាក់កម្លាំង ។ ដើម្បីរស់និងគេចឲ្យផុតពីការដាក់ទណ្ឌកម្ម អ្នកទោសត្រូវតែតស៊ូទាំងឈឺ ទៅធ្វើការតាមផែនការដែលបក្សបានដាក់ចុះ ។ អ្នកទោសមួយចំនួនដួលសន្លប់និងស្លាប់នៅនឹងកន្លែង ។ ក្នុងឆ្នាំ១៩៧៦ ម៉ោងប្រហែល៩ព្រឹក នៅពេលកំពុងភ្ជួរស្រែនៅខាងជើងភ្នំ សៀន បានឃើញនារីម្នាក់កំពុងធាក់រហាត់ទឹក ស្រាប់តែធ្លាក់មកដីដើបលែងរួច ។ ពេលនោះឈ្លបដែលឈរយាមអ្នក-ទោសបានដើរសំដៅទៅរកនារីម្នាក់នោះ ហើយប្រើចំពុះទុងបុកសម្លាប់នារីម្នាក់នោះចោលតែម្តង ។ យុវជនម្នាក់ដែលនៅក្នុងកងជាមួយ ប្រុញ ដោយសារហេវហត់ខ្លាំងពេក យុវជននោះបានឈប់សម្រាកក្នុងពេលដែលសមាជិកឯទៀត កំពុងដេញកណ្តុរក្នុងស្រែ ។ ពេលនោះសមមិត្ត សឿន ដែលជាអនុប្រធានមន្ទីរសន្តិសុខបានបាញ់សម្លាប់យុវជននោះចោលភ្លាម ។ យុវជនដែលមានរូបកាយស្គមកំព្រឹងម្នាក់ទៀតមកពីតានី ស្រុកទូកមាស ខេត្តកំពត បានដួលស្លាប់ក្នុងពេលកំពុងគាស់ថ្មនៅខាងលិចភ្នំ ។

ការធ្វើដំណើរ ការនិយាយស្តីរបស់អ្នកទោសត្រូវបានហាមឃាត់យ៉ាងតឹងរ៉ឹងបំផុត ។ អំពើខាងលើត្រូវបានចាត់ទុកជាអំពើប្រឆាំងនឹងអង្គការមានបំណងមិនល្អ ចង់រត់គេចខ្លួននិងចង់ធ្វើការបះបោរ ។ ទោសខាងលើនេះគឺ ត្រូវចាប់បញ្ជូនទៅឃុំឃាំងធ្វើទារុណកម្ម សួរចម្លើយនិងប្រហារជីវិត ។ ក្នុងឆ្នាំ១៩៧៦ សៀន ត្រូវប្រធានកងយុវជនឈ្មោះ ពុង បញ្ជូនខ្លួនទៅដាក់ឃុំឃាំងនិងសួរចម្លើយអស់រយៈពេល៧ថ្ងៃ ដោយសារត្រូវបានចោទប្រកាន់ថា បានបំផុសបំផុលអ្នក-ទោសឲ្យរត់ ។ ពេលសួរចម្លើយ ពុង បានប្រើខ្សែគោចងដៃរបស់ សៀន យ៉ាងតឹងរហូតចេញឈាម និងយកកាំបិតកាប់ក្បាលរបស់គាត់ពីរកាំបិត បន្សល់ស្លាកស្នាមរហូតដល់សព្វថ្ងៃ ។ សៀន មានជីវិតរស់នៅដោយសារខ្មែរក្រហមត្រូវបានផ្តួលរំលំក្នុងឆ្នាំ១៩៧៩ ។



ប្រុញ មានវាសនា មិនខុសពី សៀន ទេ ។ គាត់ត្រូវបញ្ជូនខ្លួនទៅឃុំឃាំងនិងធ្វើទារុណកម្មយ៉ាងខ្លាំងរហូតដល់មិនសង្ឃឹមថាបានរស់ឡើយ ។

អ្នកទោសដែលប្រព្រឹត្តកំហុសជាក់ស្តែង ដូចជាលួចនិងរត់គេចខ្លួន ហើយត្រូវឈ្លបឃើញ ឬតាមចាប់បាន គឺត្រូវសម្លាប់ចោលភ្លាម ។ ការសម្លាប់នោះគឺធ្វើឡើងនៅក្នុងអង្គមីទ្ទីងនៅចំពោះមុខសមាជិកក្រុមឬកងតែម្តង ។ សៀន, ប្រុញ និងញ្ជូវ ចាំបានថា ក្នុងឆ្នាំ១៩៧៧ ការសម្លាប់ជាលក្ខណៈមីទ្ទីងមានចំនួនពីរដង ។ បុរសម្នាក់ត្រូវចាប់ខ្លួនដោយសារបានលួចស្ករនៅក្នុងរោងបាយ ។ ស្រ្តីម្នាក់ត្រូវបានចាប់ខ្លួនដោយសារលួចរត់ចេញពីមន្ទីរសន្តិសុខ ។ អ្នកទោសទាំងពីរនេះត្រូវបានសម្លាប់តាមវិធីតែមួយ គឺវះពោះយកថ្លើម រួចរុញទម្លាក់ទៅក្នុងរណ្តៅ ។ ប្រុញ នៅចាំបានថា យុវជនម្នាក់ទៀតឈ្មោះ យក្ស បានរត់គេចខ្លួន ហើយឡើងទៅពួននៅលើចុងត្នោត ។ ឈ្លបក្នុងមន្ទីរសន្តិសុខបានតាមចាប់គាត់ ហើយលួងលោមគាត់ឲ្យចុះពីលើចុងត្នោតមកវិញ ប៉ុន្តែគាត់មិនព្រមចុះ ។ ទីបំផុត យក្ស បានសម្រេចចិត្តលោតចុះពីចុងត្នោតធ្វើអត្តឃាតតែម្តង ។ ប្រុញ បញ្ជាក់ថា «យក្ស វាដឹង ទោះជាចុះមកវិញក៏មិនរស់ដែរ ទើបវាធ្វើអ៊ីចឹង» ។

ឈឿន អះអាងថា អ្នកទោសដែលត្រូវបានសម្លាប់នៅភ្នំសន្ទុងមានចំនួនច្រើន ។ «នៅពេលយប់ អ្នកទោសមួយចំនួនត្រូវបញ្ជូនឡើងឡានដឹកចេញជាបន្តបន្ទាប់ ។ ចំនួនអ្នកទោសថយចុះពីមួយថ្ងៃទៅមួយថ្ងៃ ពីមួយខែទៅមួយខែ» ។ សៀន បញ្ជាក់ថា អ្នកទោសដែលស្លាប់ភាគច្រើនជាអតីតទាហាន ប៉ូលិស ក្នុងរបបលន់ នល់ ។ គាត់ដឹងពីល្បិចកលរបស់ប្រធានគ្រប់គ្រងមន្ទីរសន្តិសុខសមមិត្ត សេង និង សឿន ក្នុងការសម្លាប់អ្នកទោសថា ក្នុងឆ្នាំ១៩៧៦ សេង និង សឿន បានប្រកាសរកអ្នកចេះអក្សរជ្រៅជ្រះ ដើម្បីឲ្យជួយធ្វើការងារនៅក្នុងការិយាល័យ ។ អ្នក-ទោសជាច្រើននាំគ្នាចុះឈ្មោះ រៀបរាប់ពីកម្រិតវប្បធម៌របស់ខ្លួនដើម្បីបានប្តូរពីការងារក្រោមកំដៅថ្ងៃ គាស់ថ្ម និងវាយថ្ម ទៅធ្វើការងារក្នុងការិយាល័យ ។ ទីបំផុតអ្នកទោសទាំងនោះ ត្រូវដឹកតាមរថយន្តឆ្ពោះទៅភ្នំតូច ហើយសម្លាប់ចោលនៅទីនោះ ។ ប្រុញ អះអាងថា គាត់បានឮឈ្លបនិយាយគ្នាអំពីការងារប្រជុំរវាងអនុប្រធានមន្ទីរសន្តិសុខឈ្មោះ សឿន និង តាម៉ុក អំពីអ្នកទោសក្នុងមន្ទីរសន្តិសុខភូមិភាគ ។ តាមផែនការរបស់ តាម៉ុក គឺទីតាំងភ្នំសន្ទុងត្រូវដាក់អ្នកទោសឲ្យបានគ្រប់១៥០០០នាក់ ។ ប្រុញ ឮឈ្លបនោះនិយាយថា «ឥឡូវមានតែ១២០០០នាក់ នៅខ្វះ៣០០០នាក់ទៀត ទើបគ្រប់តាមផែនការ តា(ម៉ុក) ដាក់ឲ្យ» ។

អ្នកទោសជាប្រជាជនមូលដ្ឋាន និងប្រជាជនដែលធ្លាប់ចេញចូលមន្ទីរសន្តិសុខភូមិភាគ ធ្លាប់ឃើញ តាម៉ុក និរសាររបស់គាត់ និងអ្នកបើកបររថយន្តចេញចូលមន្ទីរសន្តិសុខភូមិភាគជាញឹកញាប់ ។ ប្រុញ រៀបរាប់ថា តាម៉ុក ធ្លាប់ចេញចូលភ្នំសន្ទុងក្នុងឆ្នាំ១៩៧៦ និង១៩៧៧ ។ ចំណែក ម៉ន និងប្រជាជនមូលដ្ឋាន ធ្លាប់ចូលទៅដឹកស្មៅនិងអំពៅក្នុងភ្នំសន្ទុងទៅចែកតាមសហករណ៍ ក៏ធ្លាប់ជួប តាម៉ុក និងអ្នកបើកបររបស់គាត់ដែរ ។ «តាម៉ុក ជិះរថយន្តហ្សីបជាមួយកូនក្មេងពីរនាក់ ម្នាក់ជានិរសារ និងម្នាក់ជាអ្នកបើករថយន្ត» ។ ក្មេងពីរនាក់ដែល ម៉ន រៀបរាប់ម្នាក់ គឺ សាវុធ មានវ័យ១៥ឆ្នាំ ជា អ្នកបើកបររថយន្តឲ្យ តាម៉ុក ។ សាវុធ ធ្លាប់ជូន តាម៉ុក ទៅភ្នំសន្ទុង ហើយគាត់ក៏បានឃើញអ្នកទោសដែលវាយថ្មនៅភ្នំសន្ទុងនេះដែរ ប៉ុន្តែ គាត់មិនបានដឹងថា តាម៉ុក ទៅភ្នំសន្ទុងធ្វើអ្វីឡើយ ។

## សន្និដ្ឋាន

ការយល់ឃើញរបស់មេដឹកនាំខ្មែរក្រហមអំពីខ្មាំងច្រើនសន្ធឹកសន្ធាប់នៅគ្រប់ទីកន្លែង ជាមូលហេតុបណ្តាលឲ្យមេដឹកនាំខ្មែរក្រហមបង្កើតឲ្យមានមន្ទីរសន្តិសុខគ្រប់ទីកន្លែង ។ ចេតនាក្នុងការបង្កើតមន្ទីរសន្តិសុខ គឺដើម្បីស្វែងរកចាប់ខ្លួនឃុំឃាំង សួរចម្លើយ និងប្រហារជីវិត ។ គ្រប់អង្គការភូមិភាគ ក្រសួងមន្ទីរត្រូវបានគណៈមជ្ឈិមបក្សប្រគល់សិទ្ធិឲ្យយ៉ាងពេញលេញក្នុងការបង្កើតមន្ទីរសន្តិសុខ រួមទាំងសិទ្ធិសម្រេចប្រហារជីវិតខ្មាំង ។

រដ្ឋធម្មនុញ្ញ លក្ខន្តិកៈបក្ស និងគណៈមជ្ឈិមបក្សនៃបក្សកុម្មុយនិស្តកម្ពុជា បានណែនាំនិងប្រគល់សិទ្ធិដល់គ្រប់អង្គការទូទាំងប្រទេសក្នុងការបង្កើតឲ្យមានមន្ទីរសន្តិសុខរួមទាំងសិទ្ធិប្រហារជីវិត ។ ក្រោមការគ្រប់គ្រងរបស់លេខាភូមិភាគនិរតី ឈិត ជឿន ហៅ ម៉ុក សាច់ញាតិ និងជនបដិវត្ត ក្រោមការគ្រប់គ្រងរបស់ ម៉ុក មន្ទីរសន្តិសុខត្រូវបានបង្កើតឡើងយ៉ាងព្រោងព្រាត ។

មន្ទីរឈ្លបឃុំ ជាមន្ទីរដំបូងបង្កើតឡើងដើម្បីចាប់ខ្លួន ធ្វើកំណត់ហេតុ និងឃុំខ្លួនបណ្តោះអាសន្នមុននឹងបញ្ជូនបន្តទៅមន្ទីរអប់រំស្រុក ។ មន្ទីរឈ្លបឃុំ គឺជាកន្លែងលត់ដំការងារធ្ងន់ធ្ងរ និងហូបចុកមិនគ្រប់គ្រាន់សម្រាប់អ្នកទោសដែលត្រូវបានចាប់ខ្លួនពីបទបានលួចបេះបោចដំណាំបន្លែបង្ការផ្សេងៗរបស់សមូហភាព ។ ប្រជាជនដែលជាប់ឃុំឃាំងនៅមន្ទីរឈ្លបឃុំភាគច្រើនជាប្រជាជនមូលដ្ឋាន គ្មានប្រវត្តិរូបពាក់ព័ន្ធនិន្នាការនយោបាយនិងវណ្ណៈ ។ ចំពោះប្រជាជនថ្មីឬប្រជាជន១៧/មេសា ដែលបានប្រព្រឹត្តកំហុសខាងលើត្រូវបានបញ្ជូនទៅមន្ទីរឃុំឃាំងអប់រំស្រុកតែម្តង ។ អ្នកទោសក្នុងមន្ទីរឈ្លបឃុំទទួលលទ្ធផលពីរ គឺបាត់បង់ជីវិតចំនួនតិចតួចនិងត្រូវបានដោះលែងចំនួនច្រើន ។ មូលហេតុនៃការដោះលែងឲ្យត្រឡប់ទៅតាមកងនិងសហករណ៍វិញ ដោយសារអ្នកទោសឆ្លងកាត់ការលត់ដំ ហើយត្រូវមើលឃើញថា មានការវិវត្តកែប្រែខ្លួនបានល្អ ។

មន្ទីរអប់រំស្រុកបង្កើតឡើងក្នុងបំណងបម្រើឲ្យការងារសន្តិសុខនិងប្រើប្រាស់ជាមន្ទីរឃុំឃាំងសួរចម្លើយនិងកន្លែងប្រហារជីវិត ។ អ្នកទោសក្នុងមន្ទីរអប់រំស្រុកភាគច្រើន ជាប្រជាជនដែលត្រូវកម្មាភិបាលមូលដ្ឋានចោទប្រកាន់ថាជាខ្មាំងរបស់អង្គការ មានជាប់និន្នាការនយោបាយ វណ្ណៈ និងលួចរបស់របរសមូហភាព ។ បន្ទាប់ពីឆ្លងកាត់ការអប់រំ អ្នកទោសភាគច្រើនត្រូវស្លាប់បាត់បង់ជីវិតក្នុងមន្ទីរអប់រំស្រុក ។ អ្នកទោសមួយចំនួនត្រូវបានបញ្ជូនទៅថ្នាក់លើបន្តបន្ទាប់ រួមមានមន្ទីរសន្តិសុខតំបន់និងមន្ទីរស-២១ នៅមជ្ឈិម ។

ដំណើរការនិងចេតនារបស់មន្ទីរសន្តិសុខតំបន់ ក៏មិនខុសពីដំណើរការនិងចេតនារបស់មន្ទីរអប់រំស្រុកដែរ ។ មន្ទីរសន្តិសុខតំបន់ គឺជាមន្ទីរឃុំឃាំងប្រជាជន ហើយភាគច្រើនជាកម្មាភិបាលកងទ័ពរបស់ខ្មែរក្រហមដែលបម្រើការងារនៅថ្នាក់តំបន់ និងមួយចំនួនជាប្រជាជនដែលត្រូវបានចោទប្រកាន់ថាជាខ្មាំងរបស់អង្គការដោយសារមូលហេតុនិន្នាការនយោបាយនិងវណ្ណៈ ។ អ្នកទោសមន្ទីរសន្តិសុខតំបន់ត្រូវប្រឈមមុខនឹងជោគវាសនាបី ទី១) ត្រូវប្រហារជីវិត ទី២) ត្រូវបញ្ជូនទៅមន្ទីរលត់ដំ និង ទី៣) ត្រូវបញ្ជូនទៅមន្ទីរស-២១ ។

មន្ទីរសន្តិសុខភូមិភាគនិរតីខុសប្លែកអំពីដំណើរការរបស់មន្ទីរអប់រំស្រុកនិងមន្ទីរសន្តិសុខតំបន់ ដោយសារមន្ទីរសន្តិសុខភូមិភាគនិរតីមានលក្ខណៈជាមន្ទីរលត់ដំឲ្យធ្វើការងារធ្ងន់ធ្ងរ និងផ្តល់អាហារមិនគ្រប់គ្រាន់ជាជាងចេតនាសួរចម្លើយនិងប្រហារជីវិត ។ ប្រជាជនដែលជាប់ឃុំឃាំងក្នុងមន្ទីរសន្តិសុខភូមិភាគនិរតី ភាគច្រើនជាកូនប្រពន្ធ និងសាច់ញាតិខ្មាំងដែលត្រូវអង្គការចាប់ខ្លួននិងប្រហារជីវិត ។ ចំនួនអ្នកទោសជាប់ឃុំឃាំងក្នុងមន្ទីរសន្តិសុខភូមិភាគមានចំនួនរាប់ពាន់នាក់ ហើយត្រូវបានបង្ខំឲ្យជីកប្រឡាយ ធ្វើស្រែចម្ការ ប៉ុន្តែបើប្រៀបធៀបអត្រាប្រហារជីវិត មន្ទីរសន្តិសុខភូមិភាគមានអត្រាទាបជាងមន្ទីរអប់រំស្រុក និងមន្ទីរសន្តិសុខតំបន់ ។

មន្ទីរសន្តិសុខគ្រប់ថ្នាក់ទាំងអស់មានទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធក្នុងដំណើរការចាប់ខ្លួន ឃុំឃាំង និងប្រហារជីវិតខ្មាំង ។ ការរាយការណ៍បញ្ជូនខ្លួនពីមន្ទីរសន្តិសុខទោសកម្រិតស្រាលទៅមន្ទីរសន្តិសុខទោសកម្រិតធ្ងន់ ទីបំផុតអ្នកទោសចំនួនតិចបំផុតដែលមានវាសនាគេចផុតពីការប្រហារជីវិតរបស់អង្គការ ។

ករណីអ្នកទោសឈ្មោះ ប្រាហ៊ីម ជាឧទាហរណ៍បង្ហាញពីទំនាក់ទំនងតាំងពីថ្នាក់ ឃុំ ស្រុក តំបន់ មន្ទីរស-២១ និងគណៈមជ្ឈិមបក្សក្នុងដំណើរការបញ្ជូនអ្នកទោសមកមន្ទីរស-២១ និងប្រហារជីវិត ។ ប្រាហ៊ីម (អតីតទាហានស័ក្តិ៤កន្ទះ) ឆ្លងកាត់ពេលវេលានិងដំណាក់កាលជាច្រើន មុនពេលក្លាយជាអ្នកទោសមន្ទីរស-២១ ។ ប្រាហ៊ីម ត្រូវប្រធានភូមិកុហកឲ្យទៅតាមគាត់ដើម្បីរៀបចំខ្លួនត្រឡប់ទៅធ្វើការនៅកន្លែងចាស់តាមជំនាញដែលគាត់មាន ។ ផ្ទុយស្រឡះពីអ្វីដែលប្រធានភូមិចាមលើបានប្រាប់ ប្រាហ៊ីម ត្រូវបញ្ជូនទៅមន្ទីរឈ្លបនៅកំពង់កុង ។ បន្ទាប់ពីជាប់ឃុំឃាំងក្នុងមន្ទីរកំពង់កុងអស់រយៈពេល៣ខែ ឪពុកប្រាហ៊ីម ក៏ត្រូវបានចាប់ខ្លួនបញ្ជូនទៅមន្ទីរកំពង់កុងដែរ ។ ក្រោយមក ប្រាហ៊ីម និងឪពុកត្រូវបានបញ្ជូនទៅមន្ទីរអប់រំស្រុកកោះធំនៅលើកោះពោធិ៍ទន្លេ ។ អតីតឈ្លបមន្ទីរអប់រំស្រុកកោះធំរៀបរាប់ថា «ខ្ញុំឃើញ ប្រាហ៊ីម ចូលទៅមន្ទីរអប់រំជាមួយអ្នកទោស៣នាក់ផ្សេងទៀតដោយដៃជាប់ចំណងស្វាបសេក ។ ខ្ញុំឃើញគាត់ត្រូវបានបណ្តើរយកទៅសួរចម្លើយម្តងទៀត ។ ឈ្លបសួរឈ្មោះគាត់ ។ គាត់ឆ្លើយថាឈ្មោះ ប្រាហ៊ីម ។ ស៊ីប្រាក់ខែប៉ុន្មាន? គាត់

ឆ្លើយថាមួយខែបាន១៣ម៉ឺន ។ ពេលនោះខ្ញុំឮឈ្លបនិយាយថា ឆ្លើយឲ្យត្រង់ស្រួលអង្គការឲ្យហ្អែងវិលទៅធ្វើការកន្លែងដើមវិញ» ។ បីថ្ងៃក្រោយពីសួរចម្លើយរួច ប្រាហ៊ឹម ត្រូវចងស្លាបសេក ហើយបណ្តើរចុះទូកទៅមន្ទីរសន្តិសុខតំបន់២៥នៅលើកោះថ្មី បន្តទៀត ។ ដូចក្នុងមន្ទីរឈ្លបឃុំនិងមន្ទីរអប់រំស្រុកដែរ អ្នក-ទោសមានឋានៈខ្ពស់ៗក្នុងរបប លន់ នល់ ដូច ប្រាហ៊ឹម ត្រូវប្រធានមន្ទីរសន្តិសុខតំបន់សម្រេចបញ្ជូនបន្តនិងបានមកដល់មន្ទីរ ស-២១ នៅថ្ងៃទី២៨ ខែមករា ឆ្នាំ១៩៧៦ ។ ប្រាហ៊ឹម ត្រូវគណៈមជ្ឈិមបក្សសម្រេចឲ្យកម្ទេចនៅថ្ងៃទី២៦ ខែឧសភា ឆ្នាំ ១៩៧៦ ដោយបន្សល់ទុកនូវឯកសារចម្លើយសារភាពចំនួន ២០០សន្លឹក ។

ឧទាហរណ៍ដែលបានបង្ហាញពីទំនាក់ទំនងពីគណៈមជ្ឈិមបក្សទៅអង្គការភូមិភាគក្នុងដំណើរការចាប់ខ្មាំង បញ្ជូនទៅមន្ទីរស-២១ និងប្រហារជីវិត សូមមើលឧទាហរណ៍ករណីអ្នកទោសឈ្មោះ សោម ជា ។

សោម ជា ហៅ ស្តើង អតីតលេខាតំបន់២៥ ភូមិភាគនិរតី ត្រូវចាប់ខ្លួននៅថ្ងៃទី១៥ ខែមីនា ឆ្នាំ១៩៧៨ ។ សោម ជា ត្រូវបានសួរចម្លើយចប់នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៨ ។ ឌុច ទទួលបានចម្លើយសារភាពរបស់ សោម ជា នៅថ្ងៃទី១ ខែមេសា ឆ្នាំ ១៩៧៨ គឺមួយថ្ងៃ បន្ទាប់ពីសួរចម្លើយចប់ ។ បន្ទាប់ពីអានចម្លើយសារភាពរបស់អ្នកទោសចប់ ឌុច សង្ខេបចម្លើយសារភាព ហើយផ្ញើជូនអនុលេខាបក្ស នួន ជា ។ ឌុច សរសេរថា «បងជាទីគោរព ។ ឯកសារនេះច្បាស់ត្រឹមតែប្រវត្តិវាជាសេ.អ៊ី.អា (ទាំងការចូលទាំងការចាត់តាំងឲ្យទៅនៅក្រោមការគ្រប់គ្រងពីម្នាក់ទៅម្នាក់រហូតអាដ័យ) ដោយគោរព ឌុច» ។ នៅក្នុងចម្លើយសារភាពរបស់ សោម ជា មានរាយឈ្មោះអ្នកពាក់ព័ន្ធជាច្រើន ក្រៅពីឈ្មោះ នៃ សារ៉ាន ហៅ យ៉ា ។ ហ៊ូ នឹម និង ឈូក ត្រូវអង្គការចាប់ខ្លួនរួចហើយ នៅមានឈ្មោះជាច្រើនទៀតដែលសព្វថ្ងៃរស់នៅក្នុងតំបន់២៥ ភូមិភាគនិរតី ។ តាម៉ុក ទទួលភារកិច្ចតាមចាប់ខ្លួនបក្ខពួករបស់ សោម ជា ដែលនៅសេសសល់ក្នុងចម្លើយសារភាពរបស់ សោម ជា ។ តាម៉ុក បានទទួលការចាត់តាំងរបស់បក្សតាមចំណារលើឯកសារ «សមមិត្ត ម៉ុក អានហើយប្រគល់មកវិញថ្ងៃទី១៨ ខែមេសា ឆ្នាំ១៩៧៨» ។ បក្ខពួករបស់ សោម ជា ត្រូវបានតាមចាប់ខ្លួននិងបញ្ជូនមកមន្ទីរស-២១ជាបន្តបន្ទាប់ ។ ទឹម សេន ហៅ ស៊ិត និង វៀល លិញ ដែលមានឈ្មោះក្នុងចម្លើយសារភាពរបស់ សោម ជា ត្រូវបានចាប់ខ្លួននិងបញ្ជូនទៅមន្ទីរស-២១ ។

សាវ៉ុធ អតីតនិរសារនិងជាអ្នកបើកបររថយន្តរបស់ តាម៉ុក បានឲ្យដឹងថា តាម៉ុក តែងប្រើប្រាស់រថយន្តហ្ស៊ីបធ្វើដំណើរជុំវិញភូមិភាគនិរតីនិងភ្នំពេញ ។ តាម៉ុក តែងអង្គុយនៅខាងឆ្វេងដៃអ្នកបើករថយន្ត ហើយនិរសារម្នាក់អង្គុយនៅខាងក្រោយ ។ សាវ៉ុធ ធ្លាប់បើករថយន្តជូន តា ម៉ុក ទៅភ្នំពេញជាច្រើនលើកក្នុងអំឡុងឆ្នាំ១៩៧៦ និងឆ្នាំ១៩៧៧ ។ «ពេលជូនគាត់ទៅភ្នំពេញ ខ្ញុំមិនដឹងថា គាត់ទៅជួបនរណានិងធ្វើការងារអ្វីឡើយ» ។ សាវ៉ុធ បញ្ជាក់ថា ថ្ងៃមួយនៅចុងឆ្នាំ១៩៧៦ បន្ទាប់ពីវិលត្រឡប់មកពីភ្នំពេញវិញ តាម៉ុក បានហៅគណៈភូមិភាគនិរតីម្នាក់ឈ្មោះ អាចារ្យកង មកផ្ទះរបស់គាត់ ។ គាត់ទាំងពីរអង្គុយនិយាយគ្នាមួយសន្ទុះបន្ទាប់មក តាម៉ុក បានបញ្ជាកងទ័ពរបស់គាត់ឲ្យចាប់អាចារ្យកង ដាក់ខ្នោះ ហើយបណ្តើរឡើងឡានតែម្តង ។ តាមចម្លើយសារភាពរបស់ អាចារ្យកង នៅមន្ទីរស-២១បញ្ជាក់ថា គាត់ត្រូវចាប់ខ្លួននិងបញ្ជូនមកសួរចម្លើយនៅមន្ទីរស-២១នៅថ្ងៃទី២ ខែតុលា ឆ្នាំ១៩៧៦ ។ អាចារ្យកង ឆ្លើយសារភាពអំពីកំហុសដែលនាំឲ្យមានការចាប់ខ្លួនគាត់ថា គាត់ជាខ្សែសង្វាក់ក្បត់អង្គការជាមួយនឹង ច័ន្ទ ចក្រី និងលេខាតំបន់២៥ ឈ្មោះ ជ័យ សួន ។ អាចារ្យកង បន្តថា គាត់បានចូលរួមប្រជុំជាមួយ ជ័យ សួន និង ច័ន្ទ ចក្រី ចំនួនពីរលើកគឺនៅឆ្នាំ១៩៧៤និងឆ្នាំ១៩៧៦ ហើយគាត់ត្រូវអង្គការចាប់ខ្លួន បន្ទាប់ពីពិធីប្រជុំធ្វើការបែងចែកភារកិច្ច និងទិសការងារនៅផ្ទះរបស់គាត់ នៅថ្ងៃទី១៣ ខែមេសា ឆ្នាំ១៩៧៦ ។ នៅលើចម្លើយសារភាពរបស់ អាចារ្យកង សមមិត្ត ឌុច គណៈមន្ទីរស-២១ ចារថា «១) រាយការណ៍ទាំងស្រុងជូនបង៦២ជាព័ត៌មាន ។ ២) កាត់ខាងចុងចោលមួយឃ្លាជូនអង្គការ ។ រាយការណ៍នៅថ្ងៃទី២ ខែកញ្ញា ឆ្នាំ១៩៧៦» ។ បន្ទាប់ពីការចាប់ខ្លួនអាចារ្យកង សមមិត្ត សុន សេន បានបញ្ជាសមមិត្ត មុត ប្រធានកងពល១៦៤ តាមរកនិងចាប់ខ្លួនប្រពន្ធ អាចារ្យកង ។

*នៅថ្ងៃទី១៩ ខែតុលា (ឆ្នាំ១៩៧៦) បន្ទាប់ពីស្វែងរកនិងតាមដានមួយរយៈពេលសមមិត្ត មុត បានរាយការណ៍ជូនសមមិត្ត សុន សេន អំពីករណីប្រពន្ធអាចារ្យកង ថា "ប្រពន្ធអាចារ្យកង មកដេកពេទ្យកងពល១៦៤ នៅចុងខែ សីហា ឆ្នាំ១៩៧៦ បាន៤-៥ថ្ងៃ មានម្នាក់ឈ្មោះ ឆេង មកដឹកយកទៅវិញ ។ ក្នុងការមកដេកពេទ្យនេះ តាមមតិម្នាក់ឈ្មោះ បន នៅជាមួយសមមិត្ត គ្រិន នាំមកដេកពេទ្យ និងពិនិត្យជំងឺដោយថា កូនវាបេះតែឈឺ ខ្លួនក៏មិនសូវជាទៀត ឆ្លៀតឱកាសមកលេងមិត្តភក្តិធ្លាប់ស្គាល់ នៅដែនេះក៏សុំមកពិនិត្យជំងឺនិងព្យាបាលផងទៅ ។ ដូច្នេះ ពេលថ្មីៗនេះមិនឃើញមកទៀតទេ ។ ថ្ងៃទី១៩ ខែតុលា "(សមមិត្ត) មុត" ។ មួយថ្ងៃបន្ទាប់ពីទទួលបានរបាយការណ៍ពី មុត សមមិត្ត សុន សេន រាយការណ៍បន្តជូនសមមិត្ត នួន ជា អំពីករណីប្រពន្ធអាចារ្យកង នៅថ្ងៃទី២០ ខែតុលា (ឆ្នាំ១៩៧៦) "ជូនបងនួន ១) ឥឡូវប្រពន្ធអាចារ្យកង ចេញពីពេទ្យកងពលហើយ ។ ២) ស្នើរាវរកឈ្មោះ ឆេង និង បន ដែលមានការទាក់ទងនឹងរឿងនេះ ថ្ងៃទី២០ ខែតុលា (ឆ្នាំ១៩៧៦) ខៀវ" ។*

## ឧបសម្ព័ន្ធ

ខាងក្រោមនេះ គឺជាអត្ថន័យសំបុត្ររបស់អ្នកទោសស្ត្រីក្រមុំម្នាក់សរសេររៀបរាប់អំពីជីវិតរបស់ខ្លួនប្រាប់ប្រធានមន្ទីរសន្តិសុខ ។ សំបុត្រនេះ ការពិតកើតឡើងដោយសារប្រធានមន្ទីរសន្តិសុខ បានយកក្រដាសនិងប៊ិចប្រគល់ឲ្យអ្នកទោសស្ត្រីនោះសរសេរចម្លើយសារភាពអំពីទោសកំហុសរបស់ខ្លួនជូនអង្គការ ។ អ្នកទោសស្ត្រីនោះពុំបានដឹងអំពីទោសកំហុសរបស់គាត់ដែលត្រូវអង្គការចាប់ខ្លួនទេ ដូច្នេះនាងគ្មានអ្វីត្រូវសរសេរក្រៅអំពីជីវិតលំបាករបស់នាងក្នុងមន្ទីរសន្តិសុខ ។ "ខ្ញុំពុំយល់ ពុំដឹងអំពីរូបខ្ញុំដែលមានឈ្មោះថា អ្នកទោសនេះឡើយ ។ តើទោសពៃរ៍របស់នាងខ្ញុំស្ថិតនៅកន្លែងណា?" ។

នៅក្នុងសំបុត្រនេះ អ្នកទោសស្ត្រីបានរៀបរាប់ពីការលំបាកការឈឺចាប់របស់នាងប្រាប់ប្រធានមន្ទីរសន្តិសុខដោយក្តីអស់សង្ឃឹម ។ ចុងបញ្ចប់ក្នុងសំបុត្ររបស់ខ្លួនអ្នកទោសស្ត្រីរូបនោះបញ្ជាក់ប្រាប់ ប្រធានមន្ទីរសន្តិសុខអំពីគោលបំណងចុងក្រោយរបស់នាង ។ *"ខ្ញុំសុំឲ្យពូយកខ្ញុំទៅបាញ់ចោល ឬយកដុំថ្មមួយដុំធំចងផ្អោបនឹងខ្លួនរបស់ខ្ញុំ ហើយប្រានទម្លាក់ទឹកទន្លេចុះ ព្រោះខ្ញុំពុំចង់បានជីវិត ដូចសព្វថ្ងៃនេះទេ វាជាជីវិតលើកទីមួយ ហើយជាជីវិតខ្លាសអស់ធម្មជាតិ និងខ្លាសខ្លួនឯងពេកណាស់"* ។

អ្នកទោសស្ត្រីនោះត្រូវបានលួងលោម ភូតភរ និងចាប់បញ្ជូនខ្លួនទៅដាក់ឃុំឃាំងនៅមន្ទីរសន្តិសុខ នៅថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ១៩៧៥ បន្ទាប់ពីត្រូវជម្លៀសចេញពីទីក្រុងភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ទៅរស់នៅឯកោម្នាក់ឯងឆ្ងាយពីក្រុមគ្រួសារ ក្នុងស្រុកស្អាង ខេត្តកណ្តាល ។

តាមរយៈស្នាមគូសបន្ទាត់ពីក្រោមអត្ថន័យសំខាន់ៗក្នុងសំបុត្ររបស់អ្នកទោសស្ត្រីរូបនេះ ខ្ញុំសន្មតថា កម្មាភិបាលដឹកនាំក្នុងមន្ទីរសន្តិសុខបានអានសេចក្តីសំបុត្ររបស់នាង ហើយក៏ទំនងជាបានជួយបំពេញតាមសំណូមពរចុងក្រោយរបស់នាង ដោយបញ្ជូននាងទៅកាន់ភពថ្មីដែរ ។

*ថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ១៩៧៥*

### ពីនាងខ្ញុំចំពោះពូដែលក្តោបក្តាប់កន្លែងនេះ!

*◆តើថ្ងៃណាទើបខ្ញុំមានសេរីភាពវិញ?*

*◆តើអាចឲ្យនាងខ្ញុំសរសេររៀបរាប់អំពីមុខរបររបស់នាងខ្ញុំនៅឯកោះខែលដែរឬទេ?*

*◆នៅពេលខ្ញុំសរសេរពីជីវប្រវត្តិដ៏ល្អិតល្អន់តាមសំណួរនៃក្រដាសដែលពូឲ្យខ្ញុំរួច តើខ្ញុំបានទៅផ្ទះវិញឬទេ? ខ្ញុំគ្មានសង្ឃឹមសោះរឿងនេះ ព្រោះខ្ញុំលែងទុកចិត្តអង្គការហើយ ។ កាលខ្ញុំមកពីកោះខែល ខ្ញុំមិននឹកស្មានថាមកនៅកន្លែងនេះសោះ ។ ដំបូងពេលព្រលប់ៗមានពូ២នាក់ជិះកង់ទៅហៅខ្ញុំពីមូលដ្ឋានដោយប្រាប់ថា ម្ចាស់ផ្ទះហៅខ្ញុំទៅជួប ។ ខ្ញុំក៏ជិះកង់មកតាមគាត់ ។ ទៅដល់ផ្ទះគណៈភូមិ ឬឃុំ ឬស្រុកគាត់ក៏ថា អង្គការព្រមទទួលខ្ញុំហើយ នៅតែអង្គការនារីទេ ។ ពេលនោះគាត់ឲ្យខ្ញុំទៅកន្លែងអង្គការនារីជាមួយអ៊ំស្រីម្នាក់ និងមិត្តយើងអ្នកបើកម៉ូតូ ។ ទៅដល់មន្ទីរព្រែកអំបិលមួយសន្ទុះមិត្តនារីម្នាក់ប្រាប់ខ្ញុំឲ្យទៅជាមួយគាត់ ។ ខ្ញុំចូលក្នុងបន្ទប់ជាមួយគាត់ ហើយគាត់ឆែកឆេរខ្ញុំ ដោយពាក្យថា "សុំទោស" ។ បន្ទាប់មក ស្រាប់តែមិត្ត២នាក់ចូលទៅហើយសួរទីកំណើតរបស់ខ្ញុំ ហើយប្រាប់ខ្ញុំថា មានបងប្អូន២នាក់មកពីបាត់ដំបងចង់ជួបឲ្យទៅឥឡូវនៅជិតតាខ្មៅ ។ ខ្ញុំក៏ព្រមដោយ*

មិននឹកព្រួយ ព្រោះមានបងប្អូនជីដូនមួយខាងឪពុករបស់ខ្ញុំចូលក្រហមដែរ ។ ស្រាប់តែមកដល់កន្លែងនេះ ហើយប្រទះស្ថានការណ៍បែបនេះទៅវិញ! ។

នៅពេលខ្ញុំសួរពូថា តើខ្ញុំអ្នកទោស? ពូថាពុំមែនទេ! ពុំមែនឯណាបើជើងជាប់ច្រវាក់ ជាប់សោ ទាំងទ្វារបន្ទប់ទៀត ។ នៅពេលខ្ញុំចង់ចូលបង្គន់ គឺត្រូវទ្រាំអត់កន្លះម៉ោងទៅមួយម៉ោង ចុះបើសិនជាក្មេងទ្រាំមិនបាន? ... ហើយបន្ទប់បង្គន់មានទាំងបើកទឹកមិនចេញអត់ភ្លើងទៀត ។ ខ្ញុំពុំចង់បានភាពសង្ហារទេ ។ សូវពូឲ្យខ្ញុំកាន់ចបជីក ជីកដុះដុំល់ដី យួរទឹកធុងផ្ទាល់ដៃខ្លួនឯងវិញ វាប្រសើរជាងឲ្យខ្ញុំចូលបន្ទប់ទឹកដែលមានប្រដាប់ប្រដាសព្វគ្រប់ ។ ខ្ញុំក៏ធ្លាប់បានស្គាល់បន្ទប់ទឹកដែលសង្ហាជាងនេះឆ្ងាយណាស់ដែរ ។ ខ្ញុំពុំចង់បានបាយទឹកស្រាប់ដែលគេយកមកឲ្យក្នុងន័យមាក់ងាយឡើយ ខ្ញុំស៊ូទ្រាំអត់ ទ្រាំឃ្លានដូចពេលជម្លៀសមក ៦-៧ខែវិញ ព្រោះគ្មានសេរីភាព ។

ខ្ញុំពុំយល់ ពុំដឹងអំពីរូបខ្ញុំដែលមានឈ្មោះថា អ្នកទោសនេះឡើយ ។ តើទោសពៃរ៍របស់នាងខ្ញុំស្ថិតនៅកន្លែងណា? ខ្ញុំយល់ថា អង្គការបដិវត្តន៍ពុំមែនជាអង្គការពាក់មុខទេ ។

ខ្ញុំសុំឲ្យពូយកខ្ញុំទៅបាញ់ចោល ឬយកដុំថ្មមួយដុំធំចងផ្អោបនឹងខ្លួនរបស់ខ្ញុំ ហើយប្រានទម្លាក់ទឹកទន្លេចុះ ព្រោះខ្ញុំពុំចង់បានជីវិតដូចសព្វថ្ងៃនេះទេ វាជាជីវិតលើកទីមួយ ហើយជាជីវិតខ្មាសអស់ធម្មជាតិនិងខ្មាសខ្លួនឯងពេកណាស់ ។ ខ្ញុំសុខចិត្តស្លាប់ដោយឥតស្តាយទេ ថ្វីបើខ្ញុំពុំទាន់បានស្គាល់នូវឆាកជីវិតដែលមានគ្រួសារ ។

ទាំងនេះក៏ពុំខុសពីជីវិតរបស់ទស្សនវិទូម្នាក់ឈ្មោះសូក្រាតគ្រា៤-៥សតវត្សរ៍មុនព្រះយេស៊ូកើតដែរ ។ គាត់ស្លាប់ដោយសារថ្នាំបំពុលស៊ិនគុយ គាត់ជឹកក្នុងតុលាការទីក្រុងអាថែន ដោយសារគាត់ត្រូវបានចោទប្រកាន់ថាបានបំបះបោរនិស្សិតក្នុងទីក្រុងនេះ ។ ពេលជិតដាច់ខ្យល់ស្លាប់ គាត់គ្មានតក់ស្លុតឡើយ ហើយគាត់បានទារថ្នាំបំពុលនោះលេបទៀតដោយពុំចាំបាច់គេបង្ខំ ។ គាត់បានស្រែកថា “ច្បាប់តុលាការទីក្រុងអាថែន (Athen) អ្នកល្អប្រពៃណាស់ យុត្តិធម៌ណាស់ គឺមានតែអ្នកប្រព្រឹត្តច្បាប់តុលាការនេះទេ ដែលអាក្រក់ហើយអយុត្តិធម៌” ។

នេះក៏ប្រហែលជាពុំខុសពីជីវិតរបស់ខ្ញុំដែរ កំព្រាឯកា អនាថាក្បាលមួយមកនៅស្រុកគេ បែកអស់គ្រួសារគឺលំបាកណាស់ ទាំងផ្លូវកាយនិងចិត្ត ។ តើឲ្យរស់ធ្វើអ្វីទៀត បើដល់ថ្នាក់វាគ្មានប្រយោជន៍ដល់អង្គការបដិវត្ត ផ្ទុយទៅវិញ មានតែធ្វើឲ្យអង្គការបដិវត្តខូលខ្ជាយរំខានខាតប្រយោជន៍យ៉ាងធំរបស់អង្គការបដិវត្ត ។

សូមអង្គការយកជីវិតខ្ញុំទៅសម្លាប់ភ្លាមចុះ! កុំចាំបាច់អង្គការមកសម្លាប់ខ្ញុំម្តងបន្តិចៗ ធ្វើឲ្យទឹកភ្នែកហូរពុំឈប់ ឈឺក្រុនរាល់ថ្ងៃបែបនេះ ។ គួរពុំគួរសុំអង្គការធ្វើតាមសំណូមពរខ្ញុំចុះ ។

**អៀ ម៉េងទ្រី**

## ស្តាប់រឿងរ៉ាវប្រវត្តិសាស្ត្រតាមវិទ្យុ

មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតឲ្យមានកម្មវិធីអានអត្ថបទទស្សនាវដ្តីស្វែងរកការពិតនិងសៀវភៅផ្សេងទៀត ដែលបោះពុម្ពដោយមជ្ឈមណ្ឌលឯកសារកម្ពុជាផ្សាយតាមវិទ្យុមួយចំនួនដូចតទៅ ÷

- វិទ្យុFM១០២MHz របស់មណ្ឌលព័ត៌មានស្ត្រីកម្ពុជារៀងរាល់ថ្ងៃពុធនិងព្រហស្បតិ៍ វេលាម៉ោង៧:៣០-៧:៤៥ល្ងាច ។
- វិទ្យុFM៩៣.២៥MHz ខេត្តកំពត រៀងរាល់ថ្ងៃនៅម៉ោង៧-៧:៣០ព្រឹក និងម៉ោង៧:០០-៧:៣០ល្ងាច ។
- វិទ្យុFM៩៩MHz ខេត្តព្រះវិហារ រៀងរាល់ថ្ងៃនៅម៉ោង៧:០០-៧:៣០ព្រឹក និងម៉ោង៦:៣០-៧:០០ល្ងាច ។
- វិទ្យុFM១០៣.២៥MHz ខេត្តបាត់ដំបងរៀងរាល់ថ្ងៃនៅម៉ោង៩:០០-៩:៣០ព្រឹក និងម៉ោង៣:០០-៣:៣០រសៀល ។

នៅក្នុងពេលដ៏ខ្លីខាងមុខនេះមជ្ឈមណ្ឌលយើងនឹងពង្រីកការផ្សព្វផ្សាយនៅវិទ្យុខេត្តសៀមរាបទៀត ។

យើងខ្ញុំសង្ឃឹមថា កម្មវិធីនេះនឹងចូលរួមចំណែកក្នុងការផ្តល់ឱកាសឲ្យប្រជាជនកម្ពុជាស្វែងយល់អំពីប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហមបានកាន់តែប្រសើរឡើង និងទប់ស្កាត់ការកើតមានឡើងវិញនៃរបបនេះ ។

**ឡាត់ សោភ័ណ និង ឡេង រតនៈ**

# ខាសនាកូនស្រីខ្ញុំ

កែវ ជា ជនរងគ្រោះម្នាក់ក្នុងចំណោមជនរងគ្រោះកម្ពុជារាប់លាននាក់ ដែលបានបាត់បង់កូនបីនាក់ក្នុងចំណោមកូន៦នាក់នៅក្នុងរបបខ្មែរក្រហម សព្វថ្ងៃគាត់រស់នៅក្នុងស្រុកព្រៃវែង ខេត្តព្រៃវែង ។ ក្នុងវ័យ៨១ឆ្នាំ លោកតា កែវ ជា នៅតែចងចាំអំពីព្រឹត្តិការណ៍ដែលគាត់និងគ្រួសារគាត់ដែលបានឆ្លងកាត់ ។

នៅឆ្នាំ១៩៥៥ កែវ ជា និងប្រពន្ធឈ្មោះ ងិន សឹម បាននាំកូនចាកចេញពីភូមិកំណើតនៅភូមិព្រៃឆ្កង ឃុំពានរោង ស្រុកព្រៃវែង មករស់នៅក្នុងទីរួមខេត្តដើម្បីកសាងជីវភាពនិងដើម្បីងាយស្រួលឲ្យកូនបានសិក្សារៀនសូត្រ ។ ក៏ប៉ុន្តែនៅឆ្នាំ១៩៦៩ ដោយសារសភាពការណ៍ស្រុកទេសច្របូកច្របល់ ក្រុមគ្រួសាររបស់ កែវ ជា បានផ្លាស់ទៅរស់នៅភូមិកំណើតវិញ ដែលជាហេតុធ្វើឲ្យកូនៗរបស់គាត់ត្រូវបោះបង់ចោលការសិក្សាទាំងអស់ ។

កូនស្រីច្បងរបស់ កែវ ជា ម្នាក់ឈ្មោះ ជុំ នាង ហៅ ជុំ កញ្ញា បានឈប់រៀនត្រឹមថ្នាក់ទី៧ នៅវិទ្យាល័យទីរួមខេត្តព្រៃវែងដើម្បីជួយធ្វើការឪពុកម្តាយ ក៏ប៉ុន្តែមិនបានមួយខែផង ម្តាយមីងឈ្មោះ ណេង បានមកយក កញ្ញា ទៅរស់នៅជាមួយគាត់នៅទីរួមខេត្តព្រៃវែងវិញ ។ ប្តីរបស់ ណេង ឈ្មោះ ឌុល ជាទាហានលន់ នល់ ប្រចាំខេត្តព្រៃវែង ហើយបានបញ្ចូល កញ្ញា ឲ្យធ្វើជាទាហាននៅពេលនោះដែរ ។

កងទ័ពរំដោះខ្មែរក្រហមបង្កើនការវាយប្រហារពីមួយថ្ងៃទៅមួយថ្ងៃដើម្បីដណ្តើមកាន់កាប់ទីរួមខេត្តព្រៃវែង ។ ដូច្នេះ កញ្ញា ក៏ត្រូវផ្លាស់ទៅរស់ជាមួយម្តាយមីងនៅច្បារអំពៅជាយទីក្រុងភ្នំពេញវិញ ។

បន្ទាប់ពីរដ្ឋប្រហារទម្លាក់សម្តេចព្រះនរោត្តម សីហនុ នៅឆ្នាំ១៩៧០ ប្រជាជនភាគច្រើនដែលស្មោះស្ម័គ្រនឹងសម្តេចបានស្ម័គ្រចិត្តចូលបដិវត្តន៍តស៊ូប្រយុទ្ធប្រឆាំងជាមួយនឹងទាហាន លន់ នល់ ដើម្បីដណ្តើមអំណាចថ្វាយព្រះអង្គវិញ ។ កូនប្រុសរបស់ កែវ ជា ពីរនាក់ក៏បានស្ម័គ្រចិត្តចូលធ្វើកងទ័ពដែរ កូនប្រុសច្បងឈ្មោះ ជា សុផន បានចូលធ្វើកងទ័ពរំដោះនៅឆ្នាំ១៩៧០ ហើយបានស្លាប់នៅសមរភូមិ ។ ចំណែកកូនប្រុសពៅឈ្មោះ ជា ពៅ បានបាត់ខ្លួនតាំងពីចាកចេញពីផ្ទះទៅធ្វើកងទ័ពរំដោះ ។

នៅថ្ងៃទី១៧មេសា ឆ្នាំ១៩៧៥ កងទ័ពខ្មែរក្រហមបានចូលកាន់កាប់ទីក្រុងភ្នំពេញទាំងស្រុង និងជម្លៀសប្រជាជនទៅកាន់ទីជនបទ ។ ប្រជាជនទូទាំងប្រទេសត្រូវអង្គការរៀបចំឲ្យបង្កបង្កើនផលជាសហករណ៍ ហូបរួម ដេករួម ហើយទ្រព្យសម្បត្តិផ្ទាល់ខ្លួនក៏ត្រូវដាក់រួមដែរ ។ កែវ ជា ត្រូវបានចាត់តាំងឲ្យដើរសង់ផ្ទះឲ្យប្រជាជនថ្មី (ប្រជាជនជម្លៀសឬប្រជាជន១៧មេសា) សង់រោងបាយសហករណ៍ ឃ្វាលក្របីនិងស្ទូងស្រូវ ។ ចំណែកប្រពន្ធរបស់គាត់អង្គការចាត់តាំងឲ្យមើលក្មេងៗតូច និងកូនៗដែលមិនបានទៅបម្រើបដិវត្តន៍ត្រូវទៅធ្វើការក្នុងកងចល័ត ។

ចុងឆ្នាំ១៩៧៦ កែវ ជា បានទទួលសំបុត្រមួយច្បាប់ដែល កញ្ញា ផ្ញើតាមមិត្តភក្តិមកឲ្យក្រុមគ្រួសារនៅក្នុងភូមិព្រៃឆ្កងដើម្បីសួរសុខទុក្ខឪពុកម្តាយនិងប្រាប់អំពីការងាររបស់ខ្លួនដែលធ្វើជាពេទ្យក្នុងរោងចក្រត-២នៅឫស្សីកែវ ។ តាំងពីពេលនោះមក កែវ ជា មិនដែលបានទទួលដំណឹងអ្វីពី កញ្ញា ទៀតឡើយ ។

នៅឆ្នាំ១៩៧៧ ក្រុមគ្រួសាររបស់ កែវ ជា បានសុំការអនុញ្ញាតទៅរស់នៅនៅភូមិព្រៃជ្រាំងដើម្បីបានជួបជុំសាច់ញាតិនិងកូនស្រីម្នាក់ទៀតឈ្មោះ ជា យាង ដែលជាបុគ្គលិកពេទ្យឃុំនៅភូមិនោះផង ។

នៅឆ្នាំ១៩៧៨ អង្គការបានចោទថា កម្មាភិបាលថ្នាក់ដឹកនាំខ្មែរក្រហមនៅភូមិភាគបូព៌ាក្បត់ ព្រោះមានការទាក់ទងជាមួយវៀតណាម ។ អង្គការបានជម្លៀសប្រជាជននៅភូមិភាគបូព៌ាទៅកាន់តំបន់ផ្សេងៗដែលនៅឆ្ងាយពីព្រំប្រទល់វៀតណាម ដោយប្រាប់ថាកន្លែងទាំងនោះជាដីខ្លាញ់ (ដីមានជីជាតិ) ងាយស្រួលបង្កបង្កើនផល ។ ក្រុមគ្រួសាររបស់ កែវ ជា បានធ្វើដំណើរដោយថ្មើរជើងពីភូមិកំណើតឆ្លងកាត់អ្នកលឿងនិងមកឈប់សម្រាកនៅភ្នំពេញដើម្បីរង់ចាំជិះរថភ្លើងបន្តឆ្ពោះទៅខេត្តបាត់ដំបង ។ ក្នុងអំឡុងពេលរង់ចាំ កែវ ជា តាមស៊ើបសួរដំណឹងកូនស្រីនៅរោង

ចក្រត-២នៅឫស្សីកែវដែរ ប៉ុន្តែមិនបានទទួលដំណឹងអ្វីទេ ព្រោះពេលវេលាខ្លីពេក ។

ក្រុមគ្រួសារ កែវ ជា ត្រូវជម្លៀសទៅដល់ស្រុកមោងឫស្សី នៅខេត្តបាត់ដំបង ។ កែវ ជា ទទួលការចាត់តាំងឲ្យជួយធ្វើស្រែ ប្រជាជនមូលដ្ឋាននៅក្នុងសហករណ៍ភូមិអូរគ្រាត ឃុំគារ ។ ប្រជាជនមូលដ្ឋានម្នាក់ឈ្មោះ ខាន់ បានខ្សឹបប្រាប់ កែវ ជា ថាប្រជាជនបូព៌ារស់នៅកន្លែងនេះត្រូវអង្គការបង្ខំឲ្យធ្វើការងារធ្ងន់និងស្ថិតក្រោមការតាមដានយ៉ាងម៉ឺងម៉ាត់ថែមទៀត ព្រោះអ្នកទាំងនោះ ត្រូវបានចាត់ទុកថាជាសមាសភាពមិនល្អ ហើយអ្នកដែលមកពីភូមិភាគបូព៌ាមានក្រមាខៀវ-សជាសញ្ញាសម្គាល់ ។ កែវ ជា ក៏យល់ពីហេតុផលដែលអង្គការបានចែកក្រមានេះនិងប្រេងកូឡាមួយប្រអប់ដល់ប្រជាជនបូព៌ានៅពេលឡើងជិះរថភ្លើងចេញពីទីក្រុងភ្នំពេញ ។ ចាប់តាំងពីពេលនោះក្រុមគ្រួសាររបស់ កែវ ជា ប្រុងប្រយ័ត្នគ្រប់សកម្មភាពនិងខំធ្វើការទ្រាំទ្រដើម្បីចៀសវាងផុតពីការយកទៅសម្លាប់ ។

រស់នៅបានមួយរយៈពេលខ្លី កែវ ជា ឮដំណឹងថាកងទ័ពរណសិរ្សបានមកបង្កប់ខ្លួននៅក្បែរទន្លេសាបនិងរំដោះប្រជាជនក្នុងព្រៃនៅភូមិដូនទ្រី ។ ក្រុមគ្រួសាររបស់ កែវ ជា បានទាក់ទងជាសម្ងាត់ជាមួយប្រជាជននៅទីនោះ ព្រមទាំងបានលួចបញ្ជូនស្រូវដោយលួចលាក់ទៅផ្គត់ផ្គង់ទ័ពរណសិរ្សផង ពីព្រោះ កែវ ជា ធ្វើការនៅកន្លែងលានបោកស្រូវដែលមិនសូវមានការយាមកាមតឹងរ៉ឹង ។

ប្រហែល២សប្តាហ៍ក្រោយមក កងទ័ពវៀតណាមវាយរំដោះបានទីក្រុងភ្នំពេញនិងបន្តមកដល់ខេត្តពោធិ៍សាត់ ។ ខ្មែរក្រហមបានបើកអង្គប្រជុំជាច្រើនលើកដើម្បីពង្រឹងស្មារតីប្រជាជនកុំឲ្យភ័យរត់ចូលព្រៃឬបាត់បង់ភាពម្ចាស់ការ ។ ប៉ុន្តែនៅពេលកងទ័ពវៀតណាមវាយចូលដល់ស្រុកមោងឫស្សី ខ្មែរក្រហមក៏កៀរប្រជាជនរត់ឡើងភ្នំ និងឃោសនាថាបើកងទ័ពវៀតណាមតាមទាន់នឹងវះពោះប្រកស្មៅ ។ កែវ ជា មិនព្រមរត់ឡើងភ្នំតាមខ្មែរក្រហមទេ ពីព្រោះកូនប្រុសរបស់គាត់ឈ្មោះ ជា សុផាត បានស្តាប់វិទ្យុឮថាកងទ័ពវៀតណាមវាយរំដោះប្រជាជនកម្ពុជាដល់ស្រុកមោងឫស្សីហើយ ។ កែវ ជា បាននាំក្រុមគ្រួសាររត់ចូលព្រៃ រួចបន្តដំណើរតាមទូកឆ្លងកាត់បឹងទន្លេសាបឆ្ពោះមកខេត្តសៀមរាប ។ កែវ ជានិងក្រុមគ្រួសារបានត្រឡប់មកដល់ភូមិកំណើតវិញនៅក្នុងឆ្នាំ១៩៧៩ ។

សព្វថ្ងៃ កែវ ជា នៅតែទន្ទឹងរង់ចាំដំណឹងពីកូនស្រីឈ្មោះ កញ្ញា ពីព្រោះក្នុងចំណោមកូនរបស់គាត់បីនាក់ដែលចូលធ្វើបដិវត្តន៍មុនឆ្នាំ១៩៧៥ មានតែ កញ្ញា ម្នាក់គត់ដែលគាត់បានទទួលដំណឹងកាលពីឆ្នាំ១៩៧៦ ។ នៅរដូវបុណ្យទានម្តងៗ កែវ ជា តែងបន់ស្រន់ដើម្បីឲ្យកូនឆាប់រកផ្លូវឃើញត្រឡប់មកផ្ទះវិញ ហើយសង្ឃឹមថា កញ្ញា នឹងវិលមករកក្រុមគ្រួសារវិញនៅថ្ងៃណាមួយជាមិនខាន ។

ភាពស្រពេចស្រពិលរបស់ កែវ ជា ទាំងប៉ុន្មានបានដឹងច្បាស់នៅពេលដែលក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាយកប្រវត្តិរូបដែលមានភ្ជាប់រូបថតរបស់ កញ្ញា ទៅបង្ហាញគាត់ ។ ក្រោយពេល កែវ ជា បានអានប្រវត្តិរូបនោះមក គាត់មានការសោកស្តាយចំពោះការបាត់បង់កូនស្រីរបស់គាត់ជាខ្លាំងនិងធ្វើឲ្យគាត់អស់មន្ទិលក្នុងការទន្ទឹងរង់ចាំផ្លូវកូនតទៅទៀតដែរ ។ “ខ្ញុំហាក់ដូចជាមានអារម្មណ៍ធូរស្បើយក្នុងចិត្តព្រោះបានដឹងច្បាស់ធ្វើឲ្យខ្ញុំអស់សង្ស័យ ទោះបីជាដឹងថាកូនខ្ញុំជាប់គុកទួលស្លែងក៏ដោយ” ។ កែវ ជា សង្ឃឹមថា រូបគាត់និងប្រជាជនដទៃទៀតដែលធ្លាប់បានឆ្លងកាត់របបខ្មែរក្រហមនឹងបានធូរស្រាលក្នុងចិត្តបន្ទាប់ពីតុលាការខ្មែរក្រហមផ្តល់យុត្តិធម៌មួយពិតប្រាកដ ។

នៅក្នុងប្រវត្តិរូបដែលធ្វើឡើងនៅក្នុងជំនាន់ខ្មែរក្រហម កញ្ញា ជាយុទ្ធនារីនៅក្នុងកង២២៩ ក្រោយមកត្រូវបានអង្គការចាប់ខ្លួនពីរោងចក្រត-២នៅឫស្សីកែវ រួចបញ្ជូនមកកាន់មន្ទីរឃុំឃាំងស-២១ (គុកទួលស្លែង) នៅថ្ងៃទី១៩ ខែ១០ ឆ្នាំ១៩៧៦ ។

**ណាយ សុផារី**

## ពាក្យស្លោកខ្មែរក្រហម

- **ជនកុម្មុយនិស្តល្អបទក្រែ ឥតសំចៃ ហ៊ានបូជា ជនជីវ៉ា ដើម្បីជាតិ។**

*(សៀវភៅកំណត់ហេតុលេខ១០ ៧/៧)*

# ការចូលរួមរបស់ជនរងគ្រោះ : ដំណើរទស្សនកិច្ចលើកទី១០ទៅកាន់អគារអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ដំណើរទស្សនកិច្ចអគារអង្គជំនុំជម្រះវិសាមញ្ញលើកចុងក្រោយសម្រាប់ឆ្នាំ២០០៦នេះបានប្រព្រឹត្តទៅនៅថ្ងៃទី២០ និង ២១ ខែវិច្ឆិកា ។ រាប់ចាប់តាំងពីដំណើរទស្សនកិច្ចលើកទី១មកដល់លើកទី១០នេះ មជ្ឈមណ្ឌលបានអញ្ជើញប្រជាជនកម្ពុជាពីតំបន់ផ្សេងៗនៅក្នុងប្រទេសសរុបទាំងអស់ជាង៥ពាន់នាក់ទៅទស្សនាបូជនីយដ្ឋានប្រល័យពូជសាសន៍សំខាន់ៗ និងចូលរួមប្រជុំជាមួយវាគ្មិនសំខាន់ៗទាក់ទិនទៅនឹងសាលាក្តីខ្មែរក្រហម ។ ចាប់តាំងពីដំណើរទស្សនកិច្ចនេះចាប់ផ្តើម តុលាការបានបង្កើតការផ្សព្វផ្សាយជាសាធារណៈ ដោយសង្កត់ធ្ងន់ទៅលើបញ្ហាជនដៃដល់និងជនជាប់ចោទនៃរបបប្រល័យពូជសាសន៍ ។ យ៉ាងណាមិញ មជ្ឈមណ្ឌលឯកសារកម្ពុជា តែងតែឲ្យតម្លៃដល់មតិជនរងគ្រោះនិងចាត់ទុកជាភស្តុតាងមួយចេញពីការផ្សារសម្ភាសន៍និងការប្រមែប្រមូលឯកសារពីជនរងគ្រោះនៃអំពើប្រល័យពូជសាសន៍ទាំងអស់នេះ ។ ទន្ទឹមនឹងការរំភើបត្រេកអរចំពោះដំណើរវិវឌ្ឍនៃតុលាការ មជ្ឈមណ្ឌលឯកសារកម្ពុជាប្តេជ្ញាយ៉ាងមោះមុតក្នុងការផ្សារភ្ជាប់តួនាទីរបស់ជនរងគ្រោះទៅនឹងដំណើរការផ្សព្វផ្សាយយុត្តិធម៌ ។ ដំណើរទស្សនកិច្ចអគារអង្គជំនុំជម្រះវិសាមញ្ញមិនត្រឹមតែឆ្លុះបញ្ចាំងពីតួនាទីរបស់ជនរងគ្រោះនៅក្នុងតុលាការប៉ុណ្ណោះទេ ជាក់ស្តែង ការនាំប្រជាជនមកធ្វើទស្សនកិច្ចបែបនេះគឺជាការលើកកម្ពស់ទំនាក់ទំនង និងការយល់ដឹងពីប្រជាជនកម្ពុជាផ្ទាល់ ចំពោះអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា ។


ប្រជាជនដើរទស្សនាអគារគុកនៅមន្ទីរស-២១

កម្មវិធីដំណើរទស្សនកិច្ចលើកចុងក្រោយនេះមិនខុសពីដំណើរទស្សកិច្ចលើកមុនឡើយ ។ ដំបូងជនរងគ្រោះដើរទស្សនាសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង ចូលរួមប្រជុំទទួលព័ត៌មានពីអ្នកបង្កើតច្បាប់មកពីរដ្ឋសភាជាតិ ទស្សនាខ្សែភាពយន្តឯកសារ និងបន្តទៅទស្សនាបូជនីយដ្ឋានវាលពិឃាតជើងឯក ។ នៅថ្ងៃទី២នៃដំណើរទស្សនកិច្ចនេះមានកម្មវិធីសំណួរចម្លើយជាមួយមន្ត្រីអង្គជំនុំជម្រះវិសាមញ្ញ ។ មិនត្រឹមតែប៉ុណ្ណោះ កម្មវិធីមួយត្រូវបានបន្ថែមនៅក្នុងគម្រោងនេះ គឺការបកស្រាយបង្ហាញដោយសាស្ត្រាចារ្យជំនាញវិទ្យាសាស្ត្រនយោបាយពីររូប មកពីសកលវិទ្យាល័យ អ៊ីលីណយខាងកើត បកស្រាយពីប្រធានបទស្តីអំពីតុលាការឧក្រិដ្ឋកម្មអន្តរជាតិ និងអង្គជំនុំជម្រះវិសាមញ្ញ ។ ដោយផ្តោតការយកចិត្តទុកចេញពីប្រវត្តិសាស្ត្រកម្ពុជានិងច្បាប់នានានៅក្នុងស្រុក ដើម្បីធ្វើការប្រៀបធៀបដ៏ទូលាយមួយរវាងសាលាក្តីសំខាន់ៗនៅលើពិភពលោក ។ ដំណើរទស្សនកិច្ចអគារអង្គជំនុំជម្រះវិសាមញ្ញមានមុខងារយ៉ាងសំខាន់ក្នុងការចូលរួមលើកកម្ពស់តួនាទីរបស់ជនរងគ្រោះ ។

ដំណើរទស្សនកិច្ចលើកទី១០មានប្រជាជនចូលរួមចំនួន ៤០២នាក់ មកពី១១ខេត្តក្រុង ។ ក្រៅពីក្រុងព្រះសីហនុ មានប្រជាជនមកពី % ខេត្តបន្ទាយមានជ័យ២៩នាក់, ខេត្តកំពង់ចាម ១៣នាក់, ខេត្តព្រៃវែង៥៦នាក់, ខេត្តស្វាយរៀង៣៣នាក់, ខេត្តកំពត១៩នាក់, ខេត្តតាកែវ១៣នាក់, ខេត្តកណ្តាល១៩នាក់, ខេត្ត

កំពង់ស្ពឺ១០នាក់, ខេត្តពោធិសាត់៣២នាក់, ខេត្តកំពង់ឆ្នាំង៥៧នាក់ និងខេត្តក្រចេះ៤៥នាក់ ។ បន្ថែមពីលើនេះ មានដូនជីចំនួន១០នាក់ ។ ក្នុងចំណោមប្រជាជន៤០២នាក់ មានស្ត្រីចូលរួមចំនួន១២០នាក់ ។

មិនខុសពីដំណើរទស្សនកិច្ចលើកមុនៗទេ លើកចុងក្រោយនេះ ក៏មានប្រព័ន្ធផ្សព្វផ្សាយក្នុងនិងក្រៅប្រទេសចូលរួមថតរូបនិងសម្ភាសប្រជាជនយ៉ាងច្រើន ។ អ្នកថតរូបឯករាជ្យ រ៉ែន ក្លាក់មេន និង អាល់រិច ឡេដូន័ររបស់ *Die Zeit* មានវត្តមានទាំងពីរថ្ងៃក្នុងដំណើរទស្សនកិច្ច ។ ជាងនេះទៅទៀត ហ្សាប៉ែល រ៉ដូរ សាស្ត្រាចារ្យខាងសារព័ត៌មានប្រចាំផ្នែកទំនាក់ទំនងនិងផ្សព្វផ្សាយនៃវិទ្យាស្ថានទំនាក់ទំនងកម្ពុជា បាននាំនិស្សិតឆ្នាំទីបីមកចូលរួមដំណើរទស្សនកិច្ចនេះផងដែរ ។ ឆ្លៀតឱកាសនេះ និស្សិតទាំងឡាយបានអនុវត្តជាក់ស្តែងនូវអ្វីដែលខ្លួនបានសិក្សានៅក្នុងថ្នាក់រៀនកន្លងមក ។ ជាមួយនឹងការជួយណែនាំពីបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា និស្សិតបានជួបសម្ភាសន៍ប្រជាជនមួយចំនួនដែលបានរកឃើញរូបថតបងប្អូនមិត្តភក្តិរបស់ខ្លួននៅសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ។ លើសពីនេះ និស្សិតក៏បានប្រើម៉ាស៊ីនថតវីដេអូថតមួយចំនួននៃដំណើរទស្សនកិច្ចនេះដែរ ។

សារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង ជាកន្លែងដែលទាក់ទាញចំណាប់អារម្មណ៍ប្រជាជនខ្លាំងជាងគេ ។ ការនិយាយប្រាប់តៗគ្នាពីមាត់មួយទៅមាត់មួយធ្វើឲ្យសារមន្ទីរទួលស្លែង កាន់តែល្បីល្បាញទូទាំងប្រទេស ។ សារមន្ទីរប្រល័យពូជសាសន៍ទួលស្លែងជាកន្លែងតម្កល់ភ័ស្តុតាងនៃរបបកម្ពុជាប្រជាធិបតេយ្យ ហើយប្រជាជនមកទីនេះក្នុងបំណងស្វែងរករូបថតសាច់ញាតិ ដែលបាត់ខ្លួននៅក្នុងសម័យខ្មែរក្រហម ។ ដំណើរទស្សនកិច្ចលើកនេះធ្វើឲ្យក្តីសង្ឃឹមក្លាយជាការពិតដោយប្រជាជនរកឃើញរូបថតដែលខ្លួនស្គាល់ ។ នៅពេលឃើញរូបថតសាច់ញាតិមិត្តភក្តិ ប្រជាជនខ្លះ ភ្ញាក់ផ្អើលរន្ធត់ ខ្លះឈរទ្រឹង ខ្លះស្ងៀមស្ងាត់ ខ្លះខិតខំពិនិត្យមើលមុខមាត់មនុស្សនៅក្នុងរូបថតសខ្មៅឲ្យបានច្បាស់ថា ពិតជារូបថតរបស់សាច់ញាតិដែលបែកគ្នាអស់ច្រើនទសវត្សរ៍មែនឬមិនមែន ។ ប្រជាជនមានការរំជួលចិត្តនិងប្រញាប់ប្រញាល់ស្វែងរកបុគ្គលិកមជ្ឈ-មណ្ឌលដើម្បីសុំរូបថត ។ នៅក្នុងដំណើរទស្សនកិច្ចលើកនេះ ប្រជាជនរកឃើញរូបថតសាច់ញាតិដែលបានបាត់ខ្លួនចំនួនពីរករណី ។

ករណីទី១ ស្ត្រីម្នាក់ឈ្មោះ វន ស៊ាន បានរកឃើញរូបថតឪពុកនិងបងប្រុសរបស់គាត់នៅក្នុងមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ។ ពេលដែលឪពុករបស់គាត់បាត់ខ្លួន វន ស៊ាន មានអាយុ២០ឆ្នាំ រហូតមកដល់បច្ចុប្បន្ននេះ វន ស៊ា មានអាយុ៤៩ឆ្នាំ ហើយទើបបានឃើញមុខមាត់ឪពុករបស់គាត់ម្តងទៀតនៅសារមន្ទីរទួលស្លែង ។ កាលពីពីរបីឆ្នាំមុន មីងត្រូវបានសម្ភាសដោយក្រុមការងារជំរុញឲ្យមានការទទួលខុសត្រូវរបស់មជ្ឈ-មណ្ឌលឯកសារកម្ពុជា និងបានទទួលនូវប្រវត្តិរូបរបស់ឪពុកដែលមានភ្ជាប់នូវរូបថតមានទំហំតូចនិងមិនសូវច្បាស់ពីមន្ទីរស-២១ ។ នៅពេលសម្លឹងមើលរូបថតទំហំធំជាងមុនដែលមានលេខសម្គាល់“២០” មីងស៊ាន មិនទាន់ច្បាស់ក្នុងចិត្តថាជារូបថតរបស់ឪពុកគាត់នៅឡើយទេ ។ មីងស៊ាន ពិនិត្យមើលធ្មេញបាក់នៅជួរខាងមុខ(ក្នុងរូបថត) បន្ទាប់មកទើបប្រាកដក្នុងចិត្តថា នេះគឺពិតជាឪពុកគាត់មែនហើយ ។ ជាមួយនឹងកែវភ្នែកដ៏មុតបន្តុប់ដោយភាពតក់ស្លុត និងកាយវិការភ្ញាក់ផ្អើល រូបថតរបស់ ឈឿម វុន បញ្ជាក់នូវអារម្មណ៍របស់អ្នកទោសផ្សេងទៀតដែលត្រូវបានបញ្ជូនមកមន្ទីរស-២១ ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ(១៩៧៥-១៩៧៩) ។ ការប្រព្រឹត្តនូវអ្វីដែលអង្គការចាត់ទុកថាជាបទល្មើសគឺជាការងាយស្រួលដូចជាការដកដង្ហើមអ៊ីចឹង ។ ស៊ាន នៅមិនទាន់ដឹងពីមូលហេតុនៃការចាប់ខ្លួនឪពុកគាត់មកកាន់មន្ទីរស-២១នៅឡើយ គាត់គ្រាន់តែដឹងថាឪពុករបស់គាត់ត្រូវបានបញ្ជូនតាមឡានចេញទៅយប់មួយតែប៉ុណ្ណោះ ។ ស៊ាន បានឲ្យដឹងថា ឪពុករបស់គាត់បានមកលេងគាត់ចុងក្រោយនៅឆ្នាំ១៩៧៦ ។ កាលណោះ ស៊ាន នៅលីវនៅឡើយ ហើយមានអ្នកតាមចែចូវគាត់ជាច្រើន ប៉ុន្តែឪពុករបស់គាត់មិនទាន់ឲ្យរៀបការទេ ដោយហេតុផលថាប្រទេសនឹងត្រូវរំដោះក្នុងពេលឆាប់ៗ ។ ស៊ាន ក៏លែងឃើញឪពុកតាំងពីឆ្នាំ១៩៧៦រហូតមក ។ នៅក្នុងបន្ទប់ផ្សេងទៀតក៏មានព្យួររូបថតអ្នកទោសផ្តិតទំហំធំជាងមុនដែរ ។ ក្នុងចំណោមរូបថតនោះ ស៊ាន បានរកឃើញរូបថត “បងប្រុស”ម្នាក់ទៀត ។ ស៊ាន ក៏មិនដឹងពីមូលហេតុនៃការចាប់ខ្លួនបងប្រុសដែរ ។ បុគ្គលិកមជ្ឈ-មណ្ឌលឯកសារកម្ពុជាបានថតនិងផ្តិតរូបថតនៅមន្ទីរស-២១

ទាំងពីរសន្និកនិងប្រគល់ឲ្យ ស៊ាន នៅថ្ងៃបន្ទាប់ ។ នៅពេលយើងសួរគាត់ថា តើគាត់ចង់ឲ្យមានតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមដែរឬអត់ ស៊ាន ឆ្លើយថា «ខ្ញុំចង់មានតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមដើម្បីឲ្យក្មេងជំនាន់ក្រោយបានដឹង និងកុំឲ្យមានការកាប់សម្លាប់គ្នាម្តងទៀត» ។

អ្នកភូមិម្នាក់ទៀតឈ្មោះ មុត លាងគ្រី ក៏មានសាច់រឿងគួរឲ្យចាប់អារម្មណ៍ដែរ ។ លាងគ្រី បានរកឃើញរូបថតអ្នកជិតខាងរបស់គាត់ម្នាក់ដែលអតីតជាអ្នកយាមនៅមន្ទីរស-២១ និងនៅមានជីវិតរស់មកដល់សព្វថ្ងៃ ។ លាងគ្រី និយាយថា គាត់នៅចាំយ៉ាងច្បាស់នូវមុខមាត់របស់មិត្តភក្តិពីកុមារភាពនិងញាតិក្នុងភូមិរបស់គាត់ឈ្មោះ ទ្រី លាងម៉ៃ ដែលមានស្រុកកំណើតនៅស្រុកកោះធំ ។ មុនពេលមកធ្វើជាអ្នកយាមនៅមន្ទីរស-២១ លាងម៉ៃ ជាយុទ្ធនារីរបស់ខ្មែរក្រហម ។ បន្ទាប់មក លាងម៉ៃ ត្រូវអង្គការចាប់ខ្លួននិងក្លាយជាអ្នកទោសនៅកន្លែងដែលគាត់ធ្លាប់យាម ។ យោងតាមអ្នកជិតខាងរបស់គាត់ លាងម៉ៃ សព្វថ្ងៃរស់នៅទីក្រុងភ្នំពេញនិងធ្វើការនៅក្នុងរោងចក្រកាត់ដេរ ។ បុគ្គលិកផ្នែកផលិតកុនរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា កញ្ញា ប៉ាង ពីវ៉ន កំពុងតែទាក់ទងរកវិធីដើម្បីជួបជាមួយអតីតអ្នកយាមមន្ទីរស-២១ ឈ្មោះ លាងម៉ៃ ដើម្បីធ្វើសម្ភាសន៍ ។

អ្នកភូមិចំណាយពេលជិត១ម៉ោងកន្លះក្នុងការដើរទស្សនាសារមន្ទីរទួលស្លែងនេះ ។ នៅម៉ោង៩ព្រឹក អ្នកភូមិបានបន្តដំណើរទៅចូលរួមស្តាប់ការស្រាយបំភ្លឺរបស់វាគ្មិនពីររូបនៅមហាវិទ្យាល័យសង្គមសាស្ត្រនិងមនុស្សសាស្ត្រ ។ ឯកឧត្តម ម៉ោញ សាផាន គឺជាអនុប្រធានគណៈកម្មការនីតិកម្មនៃរដ្ឋសភាជាតិ ឯកឧត្តមបានដើរតួនាទីយ៉ាងសំខាន់ក្នុងដំណើរការពិភាក្សា និងអនុម័តច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ឯកឧត្តម បានបកស្រាយពីច្បាប់និងនីតិវិធីដែលត្រូវប្រើនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញ ។ ក្រៅពីបទអន្តរាគមន៍របស់ឯកឧត្តម ម៉ោញ សាផាន នៅមានការចូលរួមរបស់សាស្ត្រាចារ្យសញ្ជាតិអាមេរិកពីររូបទៀតដែលបានផ្តល់បទខទ្ទេសនាមក្រោមប្រធានបទ «ប្រៀបធៀបអង្គជំនុំជម្រះវិសាមញ្ញជាមួយនឹងតុលាការការអន្តរជាតិដទៃទៀត គិតចាប់តាំងពីតុលាការអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី» ។ លោកស្រីបណ្ឌិត លីលាន អេ.បារៀ និងបណ្ឌិត ស៊ីវិន ឌី.រ៉ូភ័រ គឺជាសាស្ត្រាចារ្យផ្នែកវិទ្យាសាស្ត្រនយោបាយមកពីសាកលវិទ្យាល័យអ៊ីលីណយខាងកើត សាស្ត្រាចារ្យទាំងពីររូបនេះបានរួមគ្នានិពន្ធសៀវភៅមួយ «ការរៀបចំតុលាការឧក្រិដ្ឋកម្ម ៖ អធិបតេយ្យភាព និងការយកចិត្តទុកដាក់របស់អន្តរជាតិក្នុងការការពារសិទ្ធិមនុស្ស» ។

បន្ទាប់ពីផ្តល់បទខទ្ទេសនាមរួច ប្រជាជនបានទទួលឱកាសមួយដើម្បីចោទជាសំណួរ ។ សំណួរដែលសួរនៅក្នុងលើកនេះក៏ដូចគ្នានឹងសំណួរដែលបានសួរនៅក្នុងដំណើរទស្សនកិច្ចលើកមុនដែរ ហើយសំណួរភាគច្រើនសង្កត់ធ្ងន់ទៅលើបុគ្គលដែលត្រូវយកមកកាត់ទោស ការដាក់ទោស តើរដ្ឋាភិបាលអន្តរជាតិត្រូវយកមកកាត់ទោសដែរឬទេ និងតើហេតុអ្វីបានជាមិនមានការបញ្ឈប់អំពើប្រល័យពូជសាសន៍ ។ វាគ្មិនទាំងបីរូបមានភាពអត់ធ្មត់និងរួសរាយក្នុងការឆ្លើយនូវសំណួរពិបាកទាំងនោះ ។

បន្ទាប់ពីទទួលទានអាហារពេលថ្ងៃ មានការបញ្ចាំងខ្សែភាពយន្តឯកសារមួយដែលនិពន្ធដោយ ប៉ាន់ ឫទ្ធី ក្រោមចំណងជើងថា «មន្ទីរស-២១ ៖ ម៉ាស៊ីនសម្លាប់មនុស្សរបស់ខ្មែរក្រហម» ។ ខ្សែភាពយន្តនេះក៏មានបញ្ចាំងនៅមហាវិទ្យាល័យសង្គមសាស្ត្រមនុស្សសាស្ត្រដែរ ។ ភាពយន្តឯកសារនេះឆ្លុះបញ្ចាំងពីបទពិសោធន៍នៃការធ្វើជាអ្នកទោសនៅគុកសម្ងាត់របស់ខ្មែរក្រហមហៅថា ស-២១ ។ នៅក្នុងគុកនិងមន្ទីរសួរចម្លើយ ចម្លើយសារភាព ត្រូវបានធ្វើឡើងដោយទារុណកម្ម ដោយសេរី និងការសម្លាប់ ដែលហាក់ដូចជាបានគ្រោងទុកមុនជាស្រេច ។ អ្នកដែលត្រូវបញ្ជូនខ្លួនមកមន្ទីរស-២១សុទ្ធតែមានកំហុស ហើយអ្នកទោសទាំងនោះកម្រត្រូវបានដោះលែងណាស់ ។ ភាពយន្តនេះបានធ្វើឲ្យអ្នកទស្សនាមួយចំនួនមានការរំជួលចិត្ត ហើយអ្នកភូមិខ្លះបានដើរចេញពីបន្ទប់ធំក្នុងពេលកំពុងបញ្ចាំង ។ មីងម្នាក់មានយោបល់ថា ពេលទស្សនាខ្សែភាពយន្តនេះបានធ្វើឲ្យគាត់នឹកឃើញពីបទពិសោធន៍ដ៏ជូរចត់ដែលគាត់បានលាក់ទុកនៅក្នុងខ្លួនអស់រយៈពេលជាយូរមកហើយ ។ មីងបានដើរចេញពីបន្ទប់បញ្ចាំងកុនទាំងទឹកភ្នែក ហើយនៅសម្ងំនៅខាងក្រៅបន្ទប់ ដើម្បីសម្រួលអារម្មណ៍ ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ គាត់បានថ្លែងអំណរគុណដល់មជ្ឈមណ្ឌលឯកសារ

កម្ពុជាដែលអញ្ជើញគាត់ឲ្យចូលរួមក្នុងដំណើរទស្សនកិច្ចនេះ ។

នៅពេលរសៀល អ្នកភូមិធ្វើដំណើរបន្តទៅទស្សនាវាលពិឃាតបឹងជើងឯក ។ សំណង់ដែលទាក់ទាញអារម្មណ៍ជាងគេពេលធ្វើដំណើរទៅដល់ទីតាំងនោះគឺ ប្ញូជនីយដ្ឋានខ្ពស់ជន្រ្ទាងមួយដែលស្ថិតនៅជិតច្រកចូល ។ ប្ញូជនីយដ្ឋាននេះមានតម្កល់លលាដ៍ក្បាលជនរងគ្រោះដែលត្រូវបានសម្លាប់នៅវាលពិឃាតបឹងជើងឯក ហើយសាកសពភាគច្រើនគឺជាអ្នកទោសដែលបញ្ជូនចេញពីមន្ទីរស-២១ ។ រណ្តៅសាកសពរួមស្ទើតែចំណាំមិនបាន ព្រោះត្រូវហ៊ុមព័ទ្ធដោយស្មៅដែលដុះនៅជុំវិញនោះ ។ ទោះជាយ៉ាងណា ក៏មានផ្លាកសញ្ញាទាំងជាភាសាខ្មែរនិងអង់គ្លេសសម្រាប់បញ្ជាក់ពីទីតាំងនិងវិធីធ្វើទារុណកម្មនិងសម្លាប់មនុស្សនៅទីនោះដែរ ។ បទសម្ភាសន៍មួយចំនួនត្រូវបានធ្វើឡើងដោយបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា នៅក្នុងទីតាំងនេះ ។ ទោះបីជាដំណើរទស្សនកិច្ចពេញមួយថ្ងៃនេះបង្ហាញយ៉ាងច្បាស់នូវអំពើសាហាវឃោរឃៅដែលកើតឡើងនៅក្នុងរបបខ្មែរក្រហមនិងរំលឹកនូវអតីតកាលឈឺចាប់ដែលមិនអាចបំភ្លេចបានក៏ដោយ ក៏អ្នកផ្តល់បទសម្ភាសន៍បានសម្តែងនូវចំណាប់អារម្មណ៍ថា ពួកគាត់សប្បាយចិត្តពេលឃើញមានទីតាំងរំឭកវិញ្ញាណក្ខន្ធមួយសម្រាប់ជាភស្តុតាងប្រវត្តិសាស្ត្រសម្រាប់ក្មេងៗជំនាន់ក្រោយ ។ អ្នកភូមិថែមទាំងសន្យាថានឹងចែករំលែកនូវអ្វីដែលគាត់បានឃើញនិងបានដឹងដល់គ្រួសារនិងញាតិជិតខាងទៀតផង ។

ថ្ងៃទីពីរនៃដំណើរទស្សនកិច្ច បានចាប់ផ្តើមតាំងពីព្រលឹមនៅក្នុងបន្ទប់សវនាការរបស់អង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា នៅខាងក្រោយទីតាំងនៃអគ្គបញ្ជាការកងទ័ពជាតិ នៅតាមបណ្តោយផ្លូវជាតិលេខ៤ ។ នៅក្នុងបន្ទប់សវនាការ អ្នកភូមិត្រូវបានទទួលស្វាគមន៍យ៉ាងរាក់ទាក់ពីមន្ត្រីកិច្ចការសាធារណៈ លោក រាជ សម្បត្តិ និងជំនួយការជាន់ខ្ពស់នៃ ការិយាល័យសហព្រះរាជអាជ្ញា លោកស្រី ផាមេឡា រ៉េអស ។ សំណួរជាច្រើនត្រូវបានឆ្លើយដោយលោក រាជ សម្បត្តិ និងលោកស្រី ផាមេឡា រ៉េអស ។ លោក រាជ សម្បត្តិ ធ្វើឲ្យប្រជាជនពេញចិត្តនឹងការសួរសំណួរជាច្រើនដោយការប្រើប្រាស់ទេពកោសល្យពីធម្មជាតិរបស់លោកក្នុងការសម្រួលខ្លឹមសារដ៏សាំញ៉ាំមកជាចំណុចងាយយល់និងស្តាប់បាន ។

នៅក្នុងដំណើរទស្សនកិច្ចលើកទី១០នេះ អ្នកភូមិបានចូលរួមយ៉ាងសកម្ម(ជាងដំណើរទស្សនកិច្ចមុនៗ)ក្នុងការចោទជាសំណួរផ្សេងៗ ។ សំណួរមួយចំនួនស្រដៀងគ្នានឹងសំណួរដែលបានចោទសួរលើកមុនៗ ប៉ុន្តែសំណួរមួយចំនួនទៀតនៅមិនទាន់បានចោទសួរនៅឡើយ ។ សំណួរទាំងនោះរួមមាន ÷ ១) តើអ្នកណាខ្លះនឹងត្រូវចោទប្រកាន់? ២) ហេតុអ្វីក៏មានតែមេដឹកនាំកំពូលៗត្រូវនាំខ្លួនយកទៅកាត់ទោស ហើយហេតុអ្វីមិនយកអ្នកដឹកនាំថ្នាក់តំបន់ថ្នាក់ភូមិភាគ ថ្នាក់ស្រុក និងសហករណ៍ផង? ៣) តើនឹងមានអ្វីកើតឡើងចំពោះអ្នកដែលត្រូវចោទប្រកាន់ប៉ុន្តែនៅក្រៅឃុំ? ៤) តើមានមនុស្សស្លាប់ប៉ុន្មាននាក់នៅក្នុងរបបប្រល័យពូជសាសន៍ (៣លាននាក់ ឬ២លាននាក់ ឬ១,៧លាននាក់)?៥) តើតាម៉ុកនឹងត្រូវកាត់ទោសដែរឬទេ? ៦) ហេតុអ្វីក៏មានតុលាការដល់ទៅពីរថ្នាក់ដើម្បីកាត់ទោសមេដឹកនាំខ្មែរក្រហម? ៧) តើមេដឹកនាំខ្មែរក្រហមរូបណាត្រូវនាំយកមកកាត់ទោស? ៨) ហេតុអ្វីក៏ចំណាយពេលយូរម្ល៉េះក្នុងការបង្កើតតុលាការខ្មែរក្រហម? ៩) តើប្រទេសណាខ្លះគាំទ្រខ្មែរក្រហមនៅពេលនោះ? ១០) ឧទាហរណ៍ថាប្រជាជន៣លាននាក់បានស្លាប់ និងទ្រព្យសម្បត្តិច្រើនរាប់មិនអស់ត្រូវបានបំផ្លាញ តើជនរងគ្រោះដែលនៅរស់នឹងទទួលបានសំណងជំងឺចិត្តដែរឬទេ? ១១) តើមេដឹកនាំខ្មែរក្រហមណាខ្លះដែលរស់នៅឯបរទេសសព្វថ្ងៃនេះ? ១២) តើកម្មាភិបាលថ្នាក់ក្រោមដែលបានប្រព្រឹត្តអំពើធ្វើទារុណកម្មនិងការសម្លាប់ត្រូវយកមកកាត់ទោសដែរឬទេ? ១៣) តើការចោទប្រកាន់នឹងត្រូវធ្វើឡើងយ៉ាងដូចម្តេចប្រសិនបើជនរងគ្រោះមិនបានចោទប្រកាន់ជនដៃដល់នោះ? ហើយតើជនដៃដល់នោះនឹងត្រូវកាត់ទោសនៅក្នុងតុលាការដែរឬទេ? ១៤) តើអ្នកដែលត្រូវបានរកឃើញថា មានកំហុសនឹងត្រូវអនុគ្រោះទោសដោយតុលាការ ឬក៏ការដាក់ទោសពិតជាមានមែន? ១៥) តើអ្នកណាជាខ្មែរក្រហមពិតប្រាកដ ហើយរបបនេះកើតឡើងដោយរបៀបណា? ១៦) តើមានសាក្សីប៉ុន្មាននាក់និងតើភស្តុតាងអ្វីខ្លះដែលត្រូវការដើម្បីការកាត់ទោស?

ទោះបីជាយើងមិនអាចប៉ាន់ស្មាននូវលទ្ធផលនៃដំណើរទស្សនកិច្ចដោយមិនបានធ្វើការស្ទាបស្ទង់មតិចំពោះអ្នកភូមិដែលធ្លាប់ចូលរួមក៏ដោយ សំណួរដែលចោទឡើងនៅវគ្គចុងក្រោយអាចធ្វើ

ជាក់ស្តែងបានថាគម្រោងការងារនេះពិតជាមានឥទ្ធិពលទៅលើប្រជាជនមែន ។សំណួរដែលចោទសួរនៅក្នុងដំណើរទស្សនកិច្ចលើកនេះមានចំនួនច្រើនជាងការចោទសួរនៅក្នុងដំណើរទស្សនកិច្ចលើកមុនៗ ។ សំណួរទាំង នោះមានភាពច្បាស់លាស់ ទូលំទូលាយ និងទាក់ទងទៅនឹងចំណុចសំខាន់ៗ និងព័ត៌មានដែលមាននៅក្នុងឯកសារទាំងបួនប្រភេទដែលប្រគល់ជូនអ្នកភូមិក្នុងដំណើរទស្សនកិច្ចនីមួយៗ ។ ឯកសារទាំងបួនប្រភេទគឺ កូនសៀវភៅស្តីពីតុលាការ ខ្មែរក្រហមនិងតួនាទីរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា កូនសៀវភៅស្តីពីច្បាប់នៃការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ និងច្បាប់អនុម័តលើកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជា ទស្សនាវដ្តី«ស្វែងរកការពិត»លេខពិសេសរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា និងកូនសៀវភៅស្តីពីការណែនាំបំភ្លឺអំពីការជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហម(ផ្តល់ជូនដោយអង្គជំនុំជម្រះវិសាមញ្ញ) ។ ឯកសារទាំងនោះមិនត្រឹមតែអប់រំអ្នកភូមិដែលបានចូលរួមក្នុងដំណើរទស្សនកិច្ចនេះទេ ថែមទាំងអប់រំប្រជាជនផ្សេងទៀតដែលបានអានឯកសារទាំងនេះដែរ ។ រហូតមកទល់ពេលនេះ ការអប់រំក្នុងប្រព័ន្ធ និងអត្ថបទជាភាសា ខ្មែរនិយាយពីប្រវត្តិសាស្ត្រខ្មែរក្រហមនៅមិនទាន់មានដល់ដៃប្រជាជននៅឡើយ ។ សំណួរដែលចោទសួរឡើងនៅក្នុងដំណើរទស្សនកិច្ចនេះបានបង្ហាញថា ប្រជាជនពិតជាកំពុងតាមដានពីដំណើរការតុលាការយុត្តាធិការ និងពីអ្វីដែលតុលាការនឹងផ្តល់ជូនពួកគាត់ដោយគិតទាំងព័ត៌មាននិងយុត្តិធម៌ផង ។ យោងតាមយោបល់និងមតិក្រៅផ្លូវការរបស់ប្រជាជននៅក្នុងដំណើរទស្សនកិច្ចនេះបង្ហាញថា ការចាប់អារម្មណ៍របស់ប្រជាជននិងចំណេះដឹងពីតុលាការពិតជាបានកើនឡើងក្នុងស្រទាប់ប្រជាជន ។ បើនិយាយពីជំនួបរវាងអ្នកចូលរួមនិងមន្ត្រីអង្គជំនុំជម្រះក្នុងវគ្គសំណួរចម្លើយ អ្នកភូមិនិយាយទាំងទឹកចិត្តមោះមុត ដោយពេលខ្លះអាននូវសំណួរដែលបានព្រាងទុក និងពេលខ្លះនិយាយទាំងសំឡេងញ័រ ដែលផុសចេញពីបេះដូងរបស់ពួកគាត់ផ្ទាល់ ។

នៅក្នុងចំណោមប្រជាជនដែលបានអញ្ជើញចំនួន៤២៨នាក់ មានប្រជាជន៤០២នាក់(ស្មើនឹង៩៤ភាគរយ)បានចូលរួមក្នុងដំណើរទស្សនកិច្ចនេះ ។ រូបថតដែលថតចេញពីរូបថតនៅមន្ទីរស-២១ចំនួន៧សន្លឹកត្រូវបានបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាប្រគល់ជូនអ្នកភូមិ ។ អ្នកដឹកនាំសហគមន៍ចាម(អ៊ីម៉ាំខេត្ត) ឈ្មោះ សាន់ ឡាទីន ក៏បានទូរស័ព្ទថ្លែងអំណរគុណមជ្ឈមណ្ឌលឯកសារកម្ពុជាចំពោះការរៀបចំដំណើរទស្សនកិច្ចនេះ ។ ឡាទីនមិនបានចូលរួមក្នុងដំណើរទស្សនកិច្ចលើកនេះទេ ប៉ុន្តែប្រជាជនជាច្រើនមកពីសហគមន៍របស់គាត់ដែលមាន២០ភូមិនៅក្នុងខេត្តក្រចេះបានចូលរួមក្នុងដំណើរទស្សនកិច្ចចុងក្រោយនេះ ។

ជាមួយនឹងការលើកទឹកចិត្ត(ការសហការ)ពីអង្គជំនុំជម្រះវិសាមញ្ញ ពួកយើង(មជ្ឈមណ្ឌលឯកសារកម្ពុជា)កំពុងរៀបចំផែនការសម្រាប់ដំណើរទស្សនកិច្ចក្នុងឆ្នាំ២០០៧ទៀត ទោះបីជាគម្រោងការនេះមិនទាន់ត្រូវបានសម្រេចក៏ដោយ ។ ដំណើរទស្សនកិច្ចក្នុងឆ្នាំ២០០៧ នឹងពិតជាមានសារសំខាន់ចំពោះប្រជាជននិងអង្គជំនុំជម្រះវិសាមញ្ញផ្ទាល់ ព្រោះថាឆ្នាំនោះ គឺជាពេលសម្រាប់ចាប់ផ្តើមសវនាការ ។ គោលដៅក្នុងការស្វែងរកយុត្តិធម៌សម្រាប់ជនរងគ្រោះនៃអំពើប្រល័យពូជសាសន៍នៅកម្ពុជាឥឡូវកំពុងតែខិតជិតមកដល់ ហើយដំណើរទស្សនកិច្ចនេះនឹងបម្រើគោលបំណងឲ្យប្រជាជនកម្ពុជាយល់ដឹងអំពីអង្គជំនុំជម្រះ និងឲ្យអង្គជំនុំជម្រះស្វែងយល់ពីប្រជាជនវិញ ។ យើងសង្ឃឹមថានឹងបន្តផ្តើមគម្រោងនេះទៀតក្នុងឆ្នាំ២០០៧ខាងមុខ ។

**កែវ ដាស៊ីល**

# រឿងរ៉ាវពិតដើម្បីប្រវត្តិសាស្ត្រ

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា ប្រជាជនកម្ពុជាគ្រប់រូបដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហមបាន និងកំពុងសរសេរអត្ថបទឬសៀវភៅអំពីរឿងរ៉ាវពិតផ្ទាល់ខ្លួន ហើយនឹងផ្ញើមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមអាសយដ្ឋានខាងក្រោម ៖

ប្រអប់សំបុត្រលេខ ១១១០ ភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទលេខៈ (៨៥៥) (២៣) ២១១ ៨៧៥
ទូរសារលេខៈ (៨៥៥) (២៣) ២១០ ៣៥៨
*Email: dccam@online.com.kh*
*Home page: www.dccam.org*

# ឧក្រិដ្ឋកម្មដែលវិនិច្ឆ័យដោយអង្គជំនុំជម្រះវិសាមញ្ញ

**(តចប់)**

## ឧក្រិដ្ឋកម្មបំផ្លិចបំផ្លាញសម្បត្តិវប្បធម៌

មាត្រា៧នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានផ្តល់អង្គជំនុំជម្រះវិសាមញ្ញនូវសិទ្ធិអំណាចក្នុងការកាត់សេចក្តីឧក្រិដ្ឋកម្មបំផ្លិចបំផ្លាញសម្បត្តិវប្បធម៌ ដោយសំអាងទៅលើអនុសញ្ញាទីក្រុងឡាអេឆ្នាំ១៩៥៤ស្តីអំពីការការពារសម្បត្តិវប្បធម៌នៅក្នុងព្រឹត្តិការណ៍នៃជម្លោះប្រដាប់អាវុធដែលហៅកាត់ថា អនុសញ្ញាស្តីអំពីសម្បត្តិវប្បធម៌ជាប្រភពនៃច្បាប់សម្រាប់កាត់សេចក្តីឧក្រិដ្ឋកម្មបំផ្លិចបំផ្លាញសម្បត្តិវប្បធម៌ ។ ក៏ប៉ុន្តែ មានបញ្ហាសំខាន់មួយទាក់ទិននឹងការសំអាងទៅលើអនុសញ្ញានេះជាប្រភពច្បាប់នៃឧក្រិដ្ឋកម្មបំផ្លិចបំផ្លាញសម្បត្តិវប្បធម៌ ដោយសារតែអនុសញ្ញានេះមិនមានចែងនូវបទឧក្រិដ្ឋកម្មនិងមិនបានបង្កើតការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មជាបុគ្គលចំពោះការរំលោភបំពានច្បាប់នៃអនុសញ្ញានេះ ។

អនុសញ្ញាស្តីអំពីការបំផ្លិចបំផ្លាញសម្បត្តិវប្បធម៌ គឺជាសន្ធិសញ្ញាអន្តរជាតិដែលត្រូវបានអនុវត្តជាយូរមកហើយ ហើយដែលត្រូវបានចុះហត្ថលេខាមុនពេលដែលគោលការណ៍នៃការទទួលខុសត្រូវជាបុគ្គលបានក្លាយទៅជាផ្នែកមួយដ៏សំខាន់នៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ។ ដូចនេះ មានតែរដ្ឋអធិបតេយ្យប៉ុណ្ណោះដែលប្រើប្រាស់អនុសញ្ញានេះ ហើយអនុសញ្ញានេះមិនមានចែងការទទួលខុសត្រូវចំពោះបទឧក្រិដ្ឋជាបុគ្គលថែមទៀត ។ ដំណោះស្រាយលើការរំលោភបំពានលើអនុសញ្ញា ជាទូទៅគឺទុកឲ្យប្រទេសមួយផ្ញើពាក្យបណ្តឹងទៅប្រទេសមួយទៀត ឬសម្រាប់ការដោះស្រាយផ្នែកហិរញ្ញវត្ថុ ឬការផ្លាស់ប្តូរនៅក្នុងការប្រព្រឹត្តទាំងក្នុងតុលាការជាតិឬតុលាការយុត្តិធម៌អន្តរជាតិដែលមានទីតាំងនៅទីក្រុងឡាអេ និងជំនុំជម្រះក្តីរវាងប្រទេសនិងប្រទេស រវាងអង្គការអន្តរជាតិនិងអង្គការអន្តរជាតិ ឬរវាងប្រទេសនិងអង្គការអន្តរជាតិ ក៏ប៉ុន្តែមិនមែនរវាងបុគ្គលនិងបុគ្គលនោះទេ ។ សាលាជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហមអាចមានការស្មុគស្មាញក្នុងការវិនិច្ឆ័យបទឧក្រិដ្ឋកម្មដោយយោងទៅតាមអនុសញ្ញាដែលមិនមានចែងបទឧក្រិដ្ឋកម្ម ឬការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មជាបុគ្គល ។ ទោះបីជាយ៉ាងណាក៏ដោយ ក៏មានប្រភពច្បាប់ផ្សេងៗទៀតសម្រាប់ការជំនុំជម្រះឧក្រិដ្ឋកម្មបែបនេះ ដែលមានចែងនៅក្នុងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដូចជា ច្បាប់ទំនៀមទម្លាប់និងអនុសញ្ញាទីក្រុងហ្សឺណែវដែលបានចាត់ទុកការបំផ្លិចបំផ្លាញនិងការរឹបអូសទ្រព្យសម្បត្តិក្នុងពេលមានជម្លោះប្រដាប់អាវុធថាជាអំពើឧក្រិដ្ឋកម្ម ។ ដោយត្រូវបានចោទប្រកាន់ថាជាបទឧក្រិដ្ឋកម្មសង្គ្រាម ព្រះរាជអាជ្ញាការពារក្តីត្រូវបង្ហាញធាតុមូលដ្ឋានទាំងបួននេះដែលចាំបាច់សម្រាប់ការចោទប្រកាន់ឧក្រិដ្ឋកម្មសង្គ្រាមខាងលើនេះ ។

## ឧក្រិដ្ឋកម្មប្រឆាំងនឹងបុគ្គលដែលទទួលបានការការពារជាអន្តរជាតិ

មាត្រា៨នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានផ្តល់អង្គជំនុំជម្រះវិសាមញ្ញនូវសិទ្ធិអំណាចក្នុងការជំនុំជម្រះឧក្រិដ្ឋកម្មប្រឆាំងនឹងអ្នកដែលទទួលបានការការពារជាអន្តរជាតិ ដោយសំអាងទៅលើអនុសញ្ញាទីក្រុងវីយែន ឆ្នាំ១៩៦១ ស្តីអំពីទំនាក់ទំនងការទូត (អនុសញ្ញាទីក្រុងវីយែន) ។ ឧក្រិដ្ឋកម្មនេះ មានចែងនៅក្នុងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានអង្គហេតុដូចគ្នានឹងឧក្រិដ្ឋកម្មបំផ្លិចបំផ្លាញសម្បត្តិវប្បធម៌ដែរ ។ អនុសញ្ញាទីក្រុងវីយែនមិនមានចែងបទឧក្រិដ្ឋកម្មនិងការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មជាបុគ្គលទេ ។ ជាការពិតណាស់ អនុសញ្ញានេះសំដៅយកសកម្មភាពដែលប្រព្រឹត្តឡើងដោយរដ្ឋ ប៉ុន្តែមិនមែនសំដៅយកសកម្មភាពរបស់បុគ្គលម្នាក់ៗនោះទេ ។ ដូចគ្នានឹងការពិភាក្សាទៅលើអនុ-សញ្ញាស្តីពីការបំផ្លិចបំផ្លាញសម្បត្តិវប្បធម៌ ពុំមានអំពើឧក្រិដ្ឋកម្មណាមួយត្រូវបានបញ្ចូលទៅក្នុងអនុសញ្ញាទីក្រុងវីយែន ហើយចៅក្រមនឹងទំនងជាមិនអាចវិនិច្ឆ័យទោសឧក្រិដ្ឋកម្មមួយ ដែលមិនមានចែងក្នុងច្បាប់ ។

ជាការពិតណាស់ ឧក្រិដ្ឋកម្មប្រឆាំងនឹងជនដែលទទួលបាន

ការការពារជាអន្តរជាតិ មានចែងនៅក្នុងអនុសញ្ញាស្តីអំពីការបង្ការនិងផ្តន្ទាទោសខក្រិដ្ឋកម្មប្រឆាំងនឹងអ្នកដែលទទួលបានការការពារជាអន្តរជាតិដោយរាប់បញ្ចូលទាំងភ្នាក់ងារការទូត ។ អនុសញ្ញានេះក៏មានចែងនូវការផ្តន្ទាទោសចំពោះបុគ្គលដែលប្រព្រឹត្តអំពើឧក្រិដ្ឋកម្មប្រឆាំងនឹងអ្នកដែលទទួលការការពារជាអន្តរជាតិដែរ ។ ក៏ប៉ុន្តែ អនុសញ្ញានេះមិនមានចែងនៅក្នុងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាទេ ពីព្រោះប្រទេសកម្ពុជាមិនមែនជាសមាជិកនៃអនុសញ្ញានេះ ។ ប្រការនេះជាឧបសគ្គសំខាន់បន្ថែមមួយក្នុងការធានានូវការចោទប្រកាន់របស់ចៅក្រមចំពោះបទឧក្រិដ្ឋនេះ ។ ប្រសិនបើមានការអះអាងយ៉ាងច្បាស់លាស់ថា ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជារាប់បញ្ចូលទាំងបទឧក្រិដ្ឋបែបនេះ ចៅក្រមនឹងមានការលំបាកក្នុងការសម្រេចចិត្តពិនិត្យមើលអនុសញ្ញាមួយដែលមិនមាននៅក្នុងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬដែលភាគីកម្ពុជាមិនបានផ្តល់សច្ចាប័ន ។

ចៅក្រមបានអះអាងថា ច្បាប់ទំនៀមទម្លាប់អន្តរជាតិពិតជាបានហាមប្រាមនូវបទល្មើសឧក្រិដ្ឋដែលមានចែងក្នុងអនុសញ្ញានេះ ។ តាមការពិត ទង្វើករណ៍នោះហាក់ដូចជាចាប់យកតែខ្លឹមសារនៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាក្នុងការផ្តល់នូវដែនយុត្តាធិការពិនិត្យទៅលើឧក្រិដ្ឋកម្មបែបនេះ ។ ប្រការនេះបង្ហាញពីភាពយឺតយ៉ាវក្នុងការផ្តល់សិទ្ធិអំណាចដល់ចៅក្រម ។ ក៏ប៉ុន្តែ ទង្វើករណ៍នេះជួយពិនិត្យការវាយប្រហារទៅលើមន្ត្រីទូតដោយអំពើចោរកម្មនិងទាសភាពដែលជាឧក្រិដ្ឋកម្មមួយក្នុងចំណោមឧក្រិដ្ឋកម្មអន្តរជាតិ“ធំ”ចំនួនបី ។ នៅដើមឆ្នាំ ១៨២៦ នៅក្នុងរឿងក្តីដ៏សំខាន់មួយរវាងសហរដ្ឋអាមេរិក និងប្រធានាធិបតី នីហ្គារ៉ាហ្គា អ័រតេហ្គា តុលាការកំពូលសហរដ្ឋអាមេរិកក៏បានឈានទៅដល់ការវិនិច្ឆ័យទោសត្រង់ចំណុចនេះ ។

## ការចោទប្រកាន់ផ្សេងៗទៀត ៖ ការប្រើប្រាស់ជាយុទ្ធសាស្ត្រអំពីឧក្រិដ្ឋកម្មក្រោមច្បាប់ជាតិ

មាត្រា៣នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាអនុញ្ញាតឲ្យអង្គជំនុំជម្រះវិសាមញ្ញកាត់សេចក្តីឧក្រិដ្ឋកម្មក្រោមច្បាប់ជាតិ ដូចជា ការធ្វើមនុស្សឃាត អំពើទារុណកម្ម និងការធ្វើទុក្ខបុកម្នេញខាងសាសនា ។ ឧក្រិដ្ឋកម្មទាំងបីនេះត្រូវបានដកចេញពីច្បាប់ព្រហ្មទណ្ឌឆ្នាំ១៩៥៦ ។ ដោយសារតែប្រទេសកម្ពុជាមានអង្គការយុត្តិសាស្ត្រព្រហ្មទណ្ឌដែលមិនទាន់ពេញលេញនៅឡើយ កម្ពុជាពុំទាន់កំណត់ច្បាស់លាស់នូវធាតុឧក្រិដ្ឋកម្មទាំងបីនេះនៅឡើយទេ ។ ចៅក្រមនៃសាលាជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហមមានសិទ្ធិសម្រេចបង្កើតធាតុឧក្រិដ្ឋកម្ម និងវាយតម្លៃការវិនិច្ឆ័យទោសរបស់អង្គជំនុំជម្រះ ។ នេះជាឱកាសដ៏ល្អមួយសម្រាប់ប្រទេសកម្ពុជាក្នុងការអភិវឌ្ឍន៍យុត្តិកម្មរបស់ខ្លួនដែលទាក់ទិននឹងឧក្រិដ្ឋកម្មទាំងបីនេះនៅក្នុងដំណើរការកាត់សេចក្តីមេដឹកនាំខ្មែរក្រហម ។

សារសំខាន់នៃសាលាជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហមស្ថិតនៅលើឧក្រិដ្ឋកម្មផ្ទាល់ ហើយសារសំខាន់នេះមិនគួរត្រូវបានមើលរំលងនោះទេ ។ ទោះបីជាយ៉ាងណាក៏ដោយ ឧក្រិដ្ឋកម្មជាតិក៏មានសារសំខាន់ដែរ ពីព្រោះឧក្រិដ្ឋកម្មនេះជួយបង្កើននូវប្រសិទ្ធភាពនៃ“ការចោទប្រកាន់ផ្សេងៗទៀត” មានន័យថា ព្រះរាជអាជ្ញាអាចចោទប្រកាន់ជនជាប់ចោទចំពោះបទឧក្រិដ្ឋផ្សេងៗជាច្រើន ។ បទឧក្រិដ្ឋផ្សេងៗនេះជា“សំណាញ់សុវត្ថិភាព” យ៉ាងមាំក្នុងការរកឲ្យឃើញនូវបទល្មើសដែលមិនឆ្លើយតបទៅនឹងធាតុចាំបាច់មួយឬច្រើននៃឧក្រិដ្ឋកម្មអន្តរជាតិទាំង៥ដែលមានចែងនៅក្នុងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ជាឧទាហរណ៍ ប្រសិនបើព្រះរាជអាជ្ញាមិនអាចចោទប្រកាន់ជនជាប់ចោទពីបទអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ឬឧក្រិដ្ឋកម្មសង្គ្រាម ផ្ទុយទៅវិញ ព្រះរាជអាជ្ញាអាចធានាបាននូវការចោទប្រកាន់របស់ខ្លួនចំពោះអំពើមនុស្សឃាតអំពើទារុណកម្ម ឬការធ្វើទុក្ខបុកម្នេញខាងសាសនាដោយអនុលោមតាមច្បាប់ព្រហ្មទណ្ឌឆ្នាំ១៩៥៦ ។ ការចោទប្រកាន់បែបនេះពុំបន្សល់ទុកនូវស្លាកស្នាមដ៏អាក្រក់ទៅដល់ជនជាប់ចោទជាងការចោទប្រកាន់ឧក្រិដ្ឋកម្មមួយក្នុងចំណោមឧក្រិដ្ឋកម្មអន្តរជាតិធំៗចំនួនប្រាំ ។ ក៏ប៉ុន្តែ ការចោទប្រកាន់ជាច្រើនករណី (ឧទាហរណ៍ការសម្លាប់១០០ករណី ឬការធ្វើទារុណកម្មជាច្រើនករណី) នឹងផ្តន្ទាទោសយ៉ាងធ្ងន់ធ្ងរទៅលើឧក្រិដ្ឋកម្ម ដូចជាការជាប់គុកដែលមានរយៈពេលយូរជាដើម ។ ការរាប់បញ្ចូលទាំងឧក្រិដ្ឋកម្មជាតិ

នេះ មិនទាន់ដឹងច្បាស់នៅឡើយថា បុគ្គលដែលមានទោសពីបទរំលោភបំពានយ៉ាងធ្ងន់ធ្ងរនឹងត្រូវបានផ្តន្ទាទោស ដោយសារការប្រព្រឹត្តរបស់អ្នកទាំងនេះមិនត្រូវបានចាត់ចូលក្នុងប្រភេទនៃឧក្រិដ្ឋកម្មអន្តរជាតិដែលមានចែងនៅក្នុងច្បាប់អន្តរជាតិ ។

## សិទ្ធិការពារខ្លួនមុនការជំនុំជម្រះក្តី

ជនជាប់ចោទមានសិទ្ធិជំទាស់ចំពោះការចោទប្រកាន់មកលើខ្លួននៅក្នុងពេលជំនុំជម្រះក្តី ។ ជាទូទៅ ទាំងនីតិព្រហ្មទណ្ឌជាតិនិងអន្តរជាតិអនុញ្ញាតឲ្យជនជាប់ចោទមានសិទ្ធិលើកឡើងនូវសិទ្ធិការពារខ្លួនមួយឬច្រើន ។ ទោះបីជាច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមិនមានចែងយ៉ាងច្បាស់ស្តីអំពីបញ្ហានេះក៏ដោយ ក៏វាច្បាស់ថាជនជាប់ចោទមានសិទ្ធិលើកឡើងនូវសិទ្ធិការពារខ្លួនមួយចំនួនផងដែរ ។ ជាទូទៅ មានសិទ្ធិការពារខ្លួនចំនួនបី សម្រាប់ជនជាប់ចោទជំទាស់ទៅនឹងការចោទប្រកាន់ ។ ទីមួយ ជនជាប់ចោទមានសិទ្ធិការពារខ្លួនជាយុត្តិសាស្ត្រ ដោយអះអាងថា តុលាការនៅខ្វះសិទ្ធិអំណាចក្នុងការវិនិច្ឆ័យទោស ។ ទីពីរ ជនជាប់ចោទមានសិទ្ធិជំទាស់ការចោទប្រកាន់ ដោយបង្ហាញថាព្រះរាជអាជ្ញាមិនបានឆ្លើយតបទៅនឹងបន្ទុកនៃភស្តុតាងរបស់ខ្លួន ។ ទីបី ចុងចោទអាចលើកឡើងនូវ "សិទ្ធិការពារខ្លួនជាវិជ្ជមាន" ដោយបង្ហាញថាការប្រព្រឹត្តបទឧក្រិដ្ឋមានភាពត្រឹមត្រូវឬអាចលើកលែងទោសបាន ។ ផ្នែកខាងក្រោមនេះនឹងពិនិត្យឡើងវិញនូវប្រភេទនីមួយៗនៃសិទ្ធិការពារខ្លួនរបស់ជនជាប់ចោទនៅពេលមានសាលាជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហម ។ ប្រសិនបើតុលាការទទួលស្គាល់នូវសិទ្ធិការពារខ្លួនរបស់ជនជាប់ចោទ ចៅក្រមនឹងមិនដាក់ទោសអតីតមេដឹកនាំខ្មែរក្រហមដែលព្រះរាជអាជ្ញាបានចោទប្រកាន់ទេ ។

## សិទ្ធិការពារខ្លួនជាយុត្តិសាស្ត្រ

ដូចបានកត់សម្គាល់ខាងលើ សាលាក្តីខ្មែរក្រហមបានកំណត់យកនូវដែនយុត្តាធិការមានកំណត់ដែនយុត្តាធិការលើជនល្មើសនិងយុត្តាធិការនៃបទល្មើស ។ ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាអនុញ្ញាតឲ្យតុលាការកាត់ទោសត្រឹមតែឧក្រិដ្ឋជនមួយចំនួនដែលបានប្រព្រឹត្តបទឧក្រិដ្ឋកម្មជាច្រើនដែលបានកើតឡើងនៅក្នុងរយៈកាលនោះ ។ ដូចនេះ ជនជាប់ចោទមានសិទ្ធិការការពារខ្លួនចំនួនបីក្នុងការជំទាស់ទៅនឹងការចោទប្រកាន់ ។ ទីមួយ ជនជាប់ចោទអាចលើកឡើងថា តុលាការនៅខ្វះដែនយុត្តាធិការមានកំណត់ ពីព្រោះឧក្រិដ្ឋកម្មត្រូវបានប្រព្រឹត្តឡើងមុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ឬក្រោយថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ។ ទម្រង់ទីពីរ ជនជាប់ចោទអាចអះអាងថា តុលាការខ្វះនូវយុត្តាធិការលើជនល្មើស ពីព្រោះចុងចោទមិនបានស្ថិតនៅក្នុងចំណាត់ប្រភេទនៃជនដែលត្រូវកាត់ទោស ។ ជាក់ស្តែង ជនជាប់ចោទអាចធ្វើបណ្តឹងតវ៉ាថា ខ្លួនមិនមែនជា"អតីតមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម" ឬ "ជនដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះអំពើឧក្រិដ្ឋកម្ម" ដែលបានកើតឡើងក្នុងរយៈកាលនោះទេ ។ ម្យ៉ាងវិញទៀត បុគ្គលដែលត្រូវបានផ្តល់ការលើកលែងចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យអាចអះអាងថា តុលាការពុំមានដែនយុត្តាធិការក្នុងការដាក់ទោសពួកគេទេ ។ អង្គជំនុំជម្រះវិសាមញ្ញជាអ្នកសម្រេចបញ្ហាដ៏ចម្រូងចម្រាសនេះ ដោយអនុលោមទៅតាមមាត្រា៤០នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ទម្រង់ទីបី ជនជាប់ចោទអាចលើកសំណើថា តុលាការខ្វះដែនយុត្តាធិការលើបទល្មើសដោយអះអាងថា ការចោទប្រកាន់បទឧក្រិដ្ឋមិនស្ថិតនៅក្រោមអំណាចរបស់តុលាការទេ ។ ទម្រង់ទីបីនេះអាចក្លាយជារឿងក្តីមួយ ប្រសិនបើជនជាប់ចោទត្រូវបានចោទប្រកាន់ថាជាជនក្បត់ជាតិ ។

## សិទ្ធិការពារខ្លួនពី«ការមិនបង្ហាញភស្តុតាង»

ប្រសិនបើតុលាការកំណត់ថាខ្លួនមានដែនយុត្តាធិការជំនុំជម្រះក្តី មេធាវីចុងចោទអាចប្រើប្រាស់សិទ្ធិការពារខ្លួនផ្សេងៗជាច្រើនទៀតរបស់ជនជាប់ចោទ ។ ក្នុងនោះ មានសិទ្ធិការពារខ្លួនដែលព្រះរាជអាជ្ញាមិនបានបង្ហាញនូវធាតុទាំងអស់នៃបទឧក្រិដ្ឋ ។ នៅក្នុងសំណុំរឿងក្តីកាត់ទោសអតីតមេដឹកនាំខ្មែរក្រហមដែលទាក់ទិននឹងបទឧក្រិដ្ឋផ្សេងៗទៀត ព្រះរាជអាជ្ញាជាអ្នកទទួលខុសត្រូវលើបន្ទុកនៃភស្តុតាង ។ ដូចនេះ ព្រះរាជអាជ្ញាត្រូវតែមានភស្តុតាងគ្រប់គ្រាន់ក្នុងការបង្ហាញធាតុនៃបទឧក្រិដ្ឋកម្ម មុនពេលដែលតុលាការចេញសាលាក្រមសម្រេចកាត់ទោសឧក្រិដ្ឋជន ។ បន្ទាប់ពីបានពិនិត្យឡើងវិញនូវភស្តុតាងទាំងអស់ ប្រសិនបើ

ចៅក្រមរកឃើញថាព្រះរាជអាជ្ញាមិនបានឆ្លើយតបទៅនឹងបន្ទុកនៃភស្តុតាងរបស់ខ្លួន ដែលទាក់ទងនឹងបទចោទប្រកាន់ជនជាប់ចោទនឹងត្រូវបានរួចទោសពីការចោទប្រកាន់នេះ ។ ដូចនេះ សិទ្ធិការពារខ្លួនពីការមិនបង្ហាញភស្តុតាង គ្របដណ្តប់ទៅលើការលើកឡើងនូវការមន្ទិលសង្ស័យចំពោះសំណុំរឿងក្តីរបស់ព្រះរាជអាជ្ញា ។ ជនជាប់ចោទអាចបង្ហាញថា ព្រះរាជអាជ្ញាមិនមានភស្តុតាងគ្រប់គ្រាន់ក្នុងការបង្ហាញនូវធាតុផ្សំសំខាន់មួយឬច្រើននៃបទល្មើសឧក្រិដ្ឋ ដោយការពិនិត្យនិងការមិនជឿទុកចិត្តសាក្សីរបស់ព្រះរាជអាជ្ញា ដោយការពិនិត្យភស្តុតាងឯកសារដែលស្នើឡើងដោយព្រះរាជអាជ្ញានិងដោយការកោះហៅសាក្សីរបស់ជនជាប់ចោទឬស្នើឲ្យពិនិត្យភស្តុតាងដែលផ្ទុយពីការចោទប្រកាន់របស់ព្រះរាជអាជ្ញា ។

ជនជាប់ចោទក៏អាចបង្ហាញពី "ការមិនបង្ហាញភស្តុតាង" តាមរយៈការការពារពាក្យដោះសា ឬការបង្ហាញដោយភ័ន្តច្រឡំ ។ ការការពារពាក្យដោះសា ជាទូទៅ ត្រូវបានលើកឡើងមុនពេលតុលាការព្រហ្មទណ្ឌជាតិឬអន្តរជាតិចាប់ផ្តើម ។ នៅពេលលើកឡើងនូវសិទ្ធិការពារខ្លួនបែបនេះ ជនជាប់ចោទអាចអះអាងថាខ្លួនស្ថិតនៅទីកន្លែងផ្សេងនៅពេលដែលមានការប្រព្រឹត្តឧក្រិដ្ឋកម្ម និងមិនបានប្រព្រឹត្តឧក្រិដ្ឋកម្មណាមួយ ។ ដោយអនុលោមទៅតាមវិធាននៃនីតិវិធីនិងវិធាននៃភស្តុតាងនៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីនិងប្រទេសរ៉្វាន់ដា ជនជាប់ចោទត្រូវតែបង្ហាញឲ្យបានច្បាស់លាស់នូវទីតាំងរបស់ខ្លួននៅពេលមានអំពើឧក្រិដ្ឋកម្ម ត្រូវផ្តល់ឈ្មោះនិងអាសយដ្ឋានរបស់សាក្សី និងត្រូវផ្តល់ព័ត៌មានដែលជាភស្តុតាងសំអាងបន្ថែមទៀត ។ ជាឧទាហរណ៍ ក្នុងរឿងក្តី វ៉ាស៊ីលជេស្វិ សៀវភៅកំណត់ហេតុមន្ទីរពេទ្យ គឺជាភស្តុតាងសំខាន់សម្រាប់ការចោទប្រកាន់ ។ នៅក្នុងរឿងក្តីកាត់ទោសមេដឹកនាំខ្មែរក្រហម រយៈពេលនិងកង្វះខាតនូវកំណត់ហេតុច្បាស់លាស់ អាចធ្វើឲ្យមេធាវីការពារក្តីមានការលំបាកក្នុងការការពារកូនក្តីរបស់ខ្លួនពីការចោទប្រកាន់ បើទោះបីជាមេធាវីទាំងនេះព្រមទទួលស្គាល់នូវការការពារបែបនេះក៏ដោយ ។

មេធាវីការការពារក្តីក៏អាចលើកឡើងថាសាក្សីបានបង្ហាញមិនត្រឹមត្រូវនូវជនដែលត្រូវព្រះរាជអាជ្ញាចោទប្រកាន់ ។ ក្នុងការវាយតម្លៃសិទ្ធិការពារខ្លួនពីការបង្ហាញមិនត្រឹមត្រូវនូវជនជាប់ចោទ តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីពិនិត្យភស្តុតាង ដោយរាប់បញ្ចូលទាំងកាលៈទេសៈដែលសាក្សីទាមទារឲ្យធ្វើការអង្កេតទៅលើជនជាប់ចោទ រយៈពេលនៃការធ្វើអង្កេត ភាពប្រហាក់ប្រហែលគ្នារបស់សាក្សីជាមួយនឹងជនជាប់ចោទមុនការកំណត់អត្តសញ្ញាណនិងចម្លើយដែលផ្តល់ដោយសាក្សីរបស់ជនជាប់ចោទ ។ ការការពារខ្លួនបែបនេះ អាចមានភាពខ្លាំងក្លាទៅបានប្រសិនបើជនជាប់ចោទបង្ហាញនូវជនដែលមានរូបរាងប្រហាក់ប្រហែល និងអ្នករួមគំនិតក្បត់ផ្សេងៗទៀត និងអ្នកដែលមានវត្តមាននៅទីកន្លែងដែលអំពើឧក្រិដ្ឋកម្មបានកើតឡើង ។

### សិទ្ធិការពារខ្លួនជាវិជ្ជមាន

ក្រៅពីការបណ្តឹងតវ៉ាដែលថាព្រះរាជអាជ្ញាមិនបានបង្ហាញធាតុផ្សំនៃឧក្រិដ្ឋកម្ម ជនជាប់ចោទអាចលើកឡើងនូវ"សិទ្ធិការពារខ្លួនជាវិជ្ជមាន"ចំនួនពីរ រួមមាន សិទ្ធិការពារខ្លួននៃយុត្តិកម្មនិងការលើកលែងទោស ។ សិទ្ធិការពារខ្លួននៃយុត្តិកម្មគ្របដណ្តប់ទៅលើទង្វើករណ៍នៅក្នុងកាលៈទេសៈពិសេសណាមួយដែលការប្រព្រឹត្តរបស់ជនជាប់ចោទត្រូវបានទទួលស្គាល់ខាងសីលធម៌និងសង្គម ហើយការប្រព្រឹត្តនេះមិនមានការទទួលខុសត្រូវចំពោះបទឧក្រិដ្ឋកម្មទេ ។ ការទាមទារធ្វើយុត្តិកម្មនូវអំពើដែលត្រូវបានហាមឃាត់ គឺជាសិទ្ធិការពារខ្លួន ។ សិទ្ធិការពារខ្លួននៃការលើកលែងទោសបង្ហាញថា ជនជាប់ចោទពុំទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មទេ បើទោះបីជាមានការប៉ះពាល់ដល់ជនដទៃទៀតក៏ដោយ ។ ជាឧទាហរណ៍ ករណីនេះជនជាប់ចោទបានទទួលរងនូវការប៉ះទង្គិចផ្លូវចិត្ត ឬបានប្រព្រឹត្តអំពើខុសច្បាប់ដោយការគំរាមកំហែង ។ កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជានិងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមិនបានកំណត់ឲ្យបានច្បាស់ស្តីពីសិទ្ធិការពារខ្លួនជាវិជ្ជមាន ទៅដល់ជនជាប់ចោទរបស់សាលាជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហមទេ ។ ក៏ប៉ុន្តែ ច្បាប់ព្រហ្មទណ្ឌឆ្នាំ១៩៥៦ មានចែងអំពីសិទ្ធិការពារខ្លួនជាទូទៅ ។ ម្យ៉ាងវិញទៀត នៅក្នុងអំឡុងពេលនៃដំណើរការកាត់

សេចក្តីរបស់អង្គជំនុំជម្រះវិសាមញ្ញ ចៅក្រមអាចស្វែងរកនូវជំនួយណែនាំក្នុងការការពារខ្លួននៅក្នុងតុលាការអន្តរជាតិផ្សេងៗទៀត និងដែលត្រូវបានប្រមូលចងក្រងជាច្បាប់នៅក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិ ។

### សិទ្ធិការពារផ្ទាល់ខ្លួន ឬសិទ្ធិការពារខ្លួនរបស់ជនដទៃទៀត

សិទ្ធិការពារខ្លួនជាវិជ្ជមានមួយក្នុងចំណោមសិទ្ធិការពារខ្លួនជាវិជ្ជមានដែលកើតមានមុនដំណើរការជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហម គឺជាទន្ធីករណ៍ដែលការសម្លាប់ឬអំពើខុសច្បាប់បានក្លាយជាការការពារផ្ទាល់ខ្លួន ។ នៅក្នុងកាលៈទេសៈមួយចំនួនការសម្លាប់ឬការធ្វើឲ្យរបួសលើរាងកាយទៅដល់បុគ្គលក្នុងការការពារខ្លួនឬទៅដល់ជនដែលមិនមែនជាភាគីក្នុងអំពើឧក្រិដ្ឋកម្មនោះទេ ។ ច្បាប់ព្រហ្មទណ្ឌឆ្នាំ១៩៥៦ អនុញ្ញាតឲ្យមានការការពារខ្លួនបែបនេះ ដែលទាក់ទិនទៅនឹងការវាយប្រហារដែលអាស្រ័យទៅលើភាពជាក់ស្តែង និងដែលមិនបានប្រើប្រាស់អ្វីដែលចាំបាច់ក្នុងការបដិសេធចំពោះការវាយប្រហារបែបនេះ ។ ច្បាប់ព្រហ្មទណ្ឌឆ្នាំ១៩៥៦ចែងថា ប្រសិនបើចម្លើយសារភាពរបស់ជនជាប់ចោទមានលក្ខណៈហួសហេតុពេក សិទ្ធិការពារផ្ទាល់ខ្លួន ឬសិទ្ធិការពារខ្លួនរបស់ជនដទៃទៀតអាចជួយបន្ថយការផ្តន្ទាទោស ។

ថ្មីនេះៗ តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីបានចេញសេចក្តីសម្រេចថាការអនុញ្ញាតឲ្យមានសិទ្ធិការពារខ្លួន គឺជាគោលការណ៍មួយនៃច្បាប់ទំនៀមទម្លាប់អន្តរ-ជាតិ ក៏ប៉ុន្តែសិទ្ធិការពារផ្ទាល់ខ្លួនចាំបាច់ត្រូវតែមានលក្ខខណ្ឌដែលប្រហាក់ប្រហែលគ្នាទៅនឹងលក្ខខណ្ឌដែលមានចែងនៅក្នុងច្បាប់កម្ពុជា ។ លក្ខខណ្ឌទីមួយ អំពើនេះពិតជាបាន“ប្រើប្រាស់នូវកងកម្លាំងដោយខុសច្បាប់” ប្រឆាំងនឹងការវាយប្រហារទៅលើបុគ្គលឬទ្រព្យសម្បត្តិ “ដែលទទួលបាននូវការការពារ” ។ លក្ខខណ្ឌទីពីរ សិទ្ធិការពារខ្លួនត្រូវ“សមាមាត្រទៅនឹងកម្រិតនៃគ្រោះថ្នាក់” ។ ក៏ប៉ុន្តែ នៅក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ការជំទាស់តវ៉ាចំពោះស្ថានភាពនៃសិទ្ធិការពារខ្លួនដោយកម្លាំងយោធា គឺមិនគ្រប់គ្រាន់ក្នុងការអះអាងបញ្ជាក់ថាជនជាប់ចោទពុំទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មបាននោះទេ ។ ច្បាប់តុលាការព្រហ្មទណ្ឌអន្តរជាតិក៏មានចែងអំពីសិទ្ធិការពារផ្ទាល់ខ្លួន ក៏ប៉ុន្តែបានកំណត់ថាបណ្តឹងតវ៉ាតាមទារនូវសិទ្ធិការពារខ្លួនដោយយោធាតែមួយគឺពុំគ្រប់គ្រាន់នោះទេ ។ គោលការណ៍នេះនឹងអនុវត្តទៅបាន លុះត្រាណាដែលជនជាប់ចោទមានបំណងធ្វើយុត្តិកម្មអំពើទាំងឡាយដែលទាក់ទិនទៅនឹងសកម្មភាពយោធានៃប្រទេសថៃ វៀតណាម ឬអាមេរិក ។

### សិទ្ធិការពារខ្លួនដោយពុទ្ធិវិបល្លាស

ការការពារខ្លួនដោយពុទ្ធិវិបល្លាស គឺជាបណ្តឹងតវ៉ាតាមទារទីពីរដែលអាចកើតមាននៅមុនការជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហម ។ មាត្រា៨៩ និង៩០ នៃច្បាប់ព្រហ្មទណ្ឌឆ្នាំ១៩៥៦ចែងថា ជន



បន្ទប់សម្រាប់ឃុំខ្លួនជនជាប់ចោទនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

គ្រប់រូបដែលតុលាការរកឃើញថាមានពុទ្ធិវិបល្លាសនៅពេលនៃការប្រព្រឹត្តបទល្មើស មិនទទួលខុសត្រូវចំពោះអំពើឧក្រិដ្ឋកម្មរបស់ខ្លួនទេ ។ គោលការណ៍នេះក៏ត្រូវបានទទួលស្គាល់ក្នុងកម្រិតជាអន្តរជាតិដែរ ។ ជាឧទាហរណ៍ មាត្រា៣១ នៃច្បាប់លក្ខន្តិកៈតុលាការព្រហ្មទណ្ឌអន្តរជាតិមិនផ្តន្ទាទោសទៅដល់បុគ្គលដែលមាន“ជំងឺប៉ះទង្គិចផ្លូវចិត្តឬដែលអសមត្ថភាពក្នុងការយល់ដឹងនូវភាពខុសច្បាប់ឬសារជាតិនៃការប្រព្រឹត្តរបស់ខ្លួន ឬអសមត្ថភាពក្នុងការគ្រប់គ្រងនូវការប្រព្រឹត្តរបស់ខ្លួនដោយអនុលោមតាមតម្រូវការចាំបាច់នៃច្បាប់” ។ ទោះបីជា តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីនិងប្រទេសរ៉្វាន់ដាអាចចោទ

ប្រកាន់ជនជាប់ចោទដោយសំអាងលើហេតុផលពុទ្ធិវិបល្លាសក៏ដោយ ។ នៅក្នុងសំណុំរឿងក្តី *ដេឡាលីក* តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី បានទទួលស្គាល់ការបាត់បង់សមត្ថភាពដែលជាហេតុផលមួយក្នុងការជួយបន្ធូរបន្ថយការផ្តន្ទាទោសជនជាប់ចោទ ។

## ស្ថានភាពចាំបាច់ ឬការបង្ខិតបង្ខំ

សិទ្ធិការពារខ្លួននៃស្ថានភាពចាំបាច់និងការបង្ខិតបង្ខំ ជាទង្ហឹករណ៍ស្តីពីការមិនដាក់ទោសបន្ថែមទៅដល់ជនជាប់ចោទ ។ សិទ្ធិការពារខ្លួននៃការបង្ខិតបង្ខំឲ្យប្រព្រឹត្តនៅពេលដែលបុគ្គលម្នាក់ប្រព្រឹត្តបទល្មើសក្នុងការបញ្ចៀសគ្រោះថ្នាក់ធំៗ និងធ្ងន់ធ្ងរដល់ខ្លួនឬក្រុមគ្រួសារពីបុគ្គលម្នាក់ផ្សេងទៀត ដូចជា ការគំរាមកំហែងដោយការភ្ជង់កាំភ្លើងជាដើម ។ សិទ្ធិការពារខ្លួននៃស្ថានភាពចាំបាច់ត្រូវបានប្រើប្រាស់នៅពេលដែលបុគ្គលម្នាក់បានប្រព្រឹត្តបទល្មើស ក្នុងការបញ្ចៀសនូវគ្រោះថ្នាក់ដោយកម្លាំងនៃធម្មជាតិ ។ ប្រព័ន្ធច្បាប់ជាច្រើន បានទទួលស្គាល់សិទ្ធិការពារខ្លួននៃស្ថានភាពចាំបាច់និងការបង្ខិតបង្ខំ ហើយសិទ្ធិទាំងនេះត្រូវបានអនុញ្ញាតឲ្យប្រើប្រាស់នៅក្នុងអង្គជំនុំជម្រះវិសាមញ្ញ ។



ច្បាប់ព្រហ្មទណ្ឌឆ្នាំ១៩៥៦ចែងថា ជនល្មើសមិនទទួលខុសត្រូវចំពោះបទឧក្រិដ្ឋ ប្រសិនបើជនល្មើសបានប្រព្រឹត្តសកម្មភាពដែលត្រូវបានហាមឃាត់ដោយ“ការបង្ខិតបង្ខំ” ។ ច្បាប់បានកំណត់ការបង្ខិតបង្ខំថា ជាស្ថានភាពចាំបាច់ទាំងស្រុងដែលជនជាប់ចោទប្រឈមមុខនឹងគ្រោះថ្នាក់ដែលខ្លួនមិនអាចបញ្ចៀសបានក្រៅពីការប្រព្រឹត្តបទឧក្រិដ្ឋ ។ ច្បាប់លក្ខន្តិកៈនៃតុលាការព្រហ្មទណ្ឌអន្តរជាតិក៏ទទួលស្គាល់ថា ការបង្ខិតបង្ខំជាសិទ្ធិការពារខ្លួនទៅតាមលក្ខខណ្ឌច្បាស់លាស់ នៅពេលដែលជនជាប់ចោទ ឬគតិយជនប្រឈមមុខនឹងការស្លាប់ ឬផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់រូបរាងកាយ ។ តុលាការព្រហ្មទណ្ឌអន្តរជាតិនឹងមិនដាក់ទោសជនជាប់ចោទនោះទេ ប្រសិនបើជនជាប់ចោទនោះបានប្រព្រឹត្តដោយចាំបាច់ និងដោយមានហេតុផលត្រឹមត្រូវដើម្បីការពារខ្លួនពីការគំរាមកំហែង ហើយប្រសិនបើការគំរាមកំហែងនោះធ្វើឡើងដោយជនដទៃផ្សេងៗទៀត ឬកាលៈទេសៈក្រោយពីការគ្រប់គ្រងរបស់ជនជាប់ចោទ ។

ទោះបីជាយ៉ាងណាក៏ដោយ មានការមិនយល់ស្របគ្នាមួយចំនួននៅក្នុងច្បាប់អន្តរជាតិស្តីពីការបង្ខិតបង្ខំឬស្ថានភាពចាំបាច់ក្នុងការការពារខ្លួនពីការសម្លាប់ ។ តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីត្រូវតែដោះស្រាយបញ្ហានេះ ដូចជាក្នុងរឿងក្តី *អេឌឺម៉ូវិក* ជាដើម ។ ក្នុងរឿងក្តីនេះ ជនជាប់ចោទជនជាតិស៊ែបបានឆ្លើយសារភាពថាខ្លួនបានសម្លាប់ពួកមូស្លីមនៅឯតំបន់ស្រេបប្រ៊ីនីកានៅក្នុងឆ្នាំ១៩៩៥ ក៏ប៉ុន្តែបានអះអាងថាប្រសិនបើគាត់បដិសេធមិនសម្លាប់ពួកមូស្លីម ពួកស៊ែបដែលជាសហជីវិនរបស់គាត់នឹងសម្លាប់គាត់ ។ សាលាឧទ្ធរណ៍នៃតុលាការព្រហ្មទណ្ឌអន្តរជាតិ សម្រាប់អតីតប្រទេសយូហ្គោស្លាវីបានចេញសេចក្តីសម្រេចថាការបង្ខិតបង្ខំមិនបានការពារទាំងស្រុងចំពោះបុគ្គលដែលជាប់ចោទពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ឬឧក្រិដ្ឋកម្មសង្គ្រាមដែលទាក់ទិននឹងការសម្លាប់ប្រជាជនស្លូតត្រង់នោះទេ ។ ក៏ប៉ុន្តែ តុលាការនេះអាចចាត់ទុកការបង្ខិតបង្ខំជាកត្តាដែលនាំឲ្យមានការបន្ធូរបន្ថយទៅដល់ការផ្តន្ទាទោស ។ ប្រព័ន្ធច្បាប់ជាតិនៅមានការខ្វែងយោបល់គ្នាអំពីបញ្ហានេះនៅឡើយ ។

## សិទ្ធិការពារខ្លួនបន្ថែម

ជនជាប់ចោទអាចមានសិទ្ធិការពារខ្លួនតាមរបៀបផ្សេងៗទៀត ។ អាយុអាចជាហេតុផលមួយក្នុងការមិនដាក់ទោសទៅដល់ជនជាប់ចោទ ។ ដោយយោងទៅតាមច្បាប់ព្រហ្មទណ្ឌឆ្នាំ១៩៥៦ ជនល្មើសដែលមានអាយុក្រោម១៨ឆ្នាំដែលបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ត្រូវតុលាការផ្តន្ទាទោសដរាបណាតុលាការចេញសេចក្តីសម្រេចថា ជនជាប់ចោទយល់ដឹងអំពើឧក្រិដ្ឋកម្មរបស់ខ្លួន នៅពេលដែលខ្លួនប្រព្រឹត្តអំពើឧក្រិដ្ឋកម្ម ។ ម្យ៉ាងវិញទៀត ជនជាប់

ចោទអាចត្រូវបានលើកលែងទោសដោយស្របច្បាប់ចំពោះអ្វីដែលមិនមែនជាអំពើឧក្រិដ្ឋកម្ម ។ ជាឧទាហរណ៍ ជនជាប់ចោទអាចប្តឹងតវ៉ាថាខ្លួនច្រឡំថា វត្ថុដែលខ្លួនបានបាញ់គឺជាអន្ទត់ឈើច្រើនជាងរូបមនុស្ស ។ ការយល់ខុសនៃច្បាប់មិនទំនងជាអាចសម្រេចបានដោយជោគជ័យជាងការការពារខ្លួនរបស់ជនជាប់ចោទទេ ហើយជាទូទៅជនជាប់ចោទមិនអាចគេចផុតពីទោសកំហុសរបស់ខ្លួន ដោយគ្រាន់តែអះអាងថា ខ្លួនមិនបានដឹងថាទង្វើដែលខ្លួនបានប្រព្រឹត្តនោះជាអំពើឧក្រិដ្ឋកម្ម ។ ច្បាប់លក្ខន្តិកៈរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិទទួលស្គាល់ចំពោះប្រភេទការពារខ្លួនទាំងពីរនេះ ក្នុងករណីដែលការយល់ច្រឡំនៃអង្គហេតុ ឬច្បាប់ដែលផ្ទុយទៅនឹងធាតុសតិបញ្ញានៃបទឧក្រិដ្ឋ ។

***សិទ្ធិការពារខ្លួនដែលមិនត្រូវបានទទួលស្គាល់នៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ***

ក្រៅពីការការពារខ្លួននៅក្នុងសាលាជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហម ជនជាប់ចោទមានសិទ្ធិការពារខ្លួនផ្សេងៗទៀតដែលមិនមាននៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ។ ដូចនេះ សិទ្ធិការពារខ្លួនបែបនេះកម្រនឹងត្រូវបានទទួលស្គាល់ណាស់ ។ ជាក់ស្តែង ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាពុំទទួលស្គាល់សិទ្ធិការពារខ្លួនទាំងពីរប្រភេទនេះឡើយ គឺទង្វើករណ៍ដែលផ្អែកទៅលើតួនាទីឬឋានៈរបស់ជនជាប់ចោទ និងសិទ្ធិការពារខ្លួននៃការបង្គាប់បញ្ជារបស់ថ្នាក់លើ ។

***ការលើកលែងទោសរបស់ព្រះរាជអាជ្ញាដោយផ្អែកទៅលើតួនាទី ឬឋានៈ***

មាត្រា២៩នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាចែងថាមន្ត្រីរដ្ឋាភិបាលនឹងពុំទទួលបាននូវការលើកលែងទោសពីព្រះរាជអាជ្ញា ដែល"តួនាទីឬឋានៈរបស់ជនសង្ស័យមិនអាចជួយជននេះឲ្យរួចផុតពីការទទួលខុសត្រូវចំពោះបទឧក្រិដ្ឋឬជួយបន្ធូរទណ្ឌកម្មដល់ជននេះបានឡើយ" ។ ដូចគ្នានេះដែរ ច្បាប់លក្ខន្តិកៈនៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីនិងប្រទេសរ៉្វាន់ដាពុំទទួលស្គាល់ការលើកលែងទោសរបស់ព្រះមហាក្សត្រថាជាការការពារខ្លួនដែលមានសុពលភាពសម្រាប់ជនជាប់ចោទ ដោយមិនគិតពីឋានៈចាប់ពីប្រមុខរដ្ឋរហូតដល់មន្ត្រីថ្នាក់ទាបនោះទេ ។ ច្បាប់លក្ខន្តិកៈនៃតុលាការព្រហ្មទណ្ឌអន្តរជាតិកំណត់យ៉ាងច្បាស់ថា តួនាទីរបស់ជនជាប់ចោទមិនអាចជួយបន្ធូយការដាក់ទណ្ឌកម្មដល់ជនសង្ស័យបានទេ ។ ជាងនេះទៅទៀត តុលាការព្រហ្មទណ្ឌអន្តរជាតិពុំបានទទួលស្គាល់នីតិវិធីជាតិ ឬអន្តរជាតិណាមួយដែលរារាំងទៅដល់តុលាការក្នុងការប្រើប្រាស់នូវដែនយុត្តាធិការរបស់ខ្លួនទៅលើមន្ត្រីដែលមានតួនាទីច្បាស់លាស់ ។

***សិទ្ធិការពារខ្លួននៃការបង្គាប់បញ្ជារបស់ថ្នាក់លើ***

ចាប់តាំងពីមានសវនាការនៅទីក្រុងនូរ៉ឹមប៊ឺក ប្រការដែលអ្នកនៅក្រោមបង្គាប់អនុវត្តតាមការបញ្ជារបស់អ្នកថ្នាក់លើ មិនមែនជាការការពារខ្លួនចំពោះអំពើឧក្រិដ្ឋកម្មអន្តរជាតិទេ ។ ដូចនេះជនគ្រប់រូបត្រូវទទួលស្គាល់ភាពមិនស្របច្បាប់នៃការចេញបញ្ជាដោយសារតែការចេញបញ្ជាឲ្យប្រព្រឹត្តឧក្រិដ្ឋកម្ម ដូចជាអំពើប្រល័យពូជសាសន៍ឬឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ គឺមានលក្ខណៈខុសច្បាប់យ៉ាងពិតប្រាកដ ។ នៅក្នុងព្រឹត្តិការណ៍នៃការចេញបញ្ជាដោយខុសច្បាប់របស់ថ្នាក់លើ ច្បាប់ព្រហ្មទណ្ឌឆ្នាំ១៩៥៦ ផ្តល់សិទ្ធិអំណាចឲ្យតុលាការកំណត់កម្រិតពិរុទ្ធភាពរបស់ជនជាប់ចោទ ។ ផ្ទុយទៅវិញ មាត្រា២៩នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាចែងថា "ប្រការដែលថា ជនសង្ស័យបានប្រព្រឹត្តអំពើឧក្រិដ្ឋតាមការបញ្ជារបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ឬរបស់ថ្នាក់លើណាមួយ មិនអាចជួយជនសង្ស័យនេះឲ្យរួចផុតពីការទទួលខុសត្រូវចំពោះបទឧក្រិដ្ឋនេះបានឡើយ ។ ច្បាប់លក្ខន្តិកៈនៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីនិងសម្រាប់ប្រទេសរ៉្វាន់ដា មានចែងបទប្បញ្ញត្តិដែលមានលក្ខណៈស្រដៀងគ្នាទៅនឹងមាត្រា២៩នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ មាត្រា៣៣នៃច្បាប់តុលាការព្រហ្មទណ្ឌអន្តរជាតិអនុញ្ញាតឲ្យមានការការពារបែបនេះនៅក្នុងរឿងក្តីមួយចំនួន ក៏ប៉ុន្តែ មិនមែននៅក្នុងករណីការចេញបញ្ជា"ខុសច្បាប់"នោះទេ ។ ជាក់ស្តែង ច្បាប់នេះបានចាត់ទុកអំពើប្រល័យពូជសាសន៍និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិជាគំរូនៃការប្រព្រឹត្តដោយខុសច្បាប់យ៉ាងពិតប្រាកដ ។ ការមិនបានការការពារខ្លួនបែបនេះ គឺ

មានសារសំខាន់ខ្លាំងណាស់នៅក្នុងសាលាក្តីជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហម ក្នុងការផ្តល់សម្បទានដល់ជនជាប់ចោទក្នុងការធ្វើពាក្យបណ្តឹងតវ៉ាថាខ្លួនបានធ្វើទៅតាមការបញ្ជារបស់ថ្នាក់លើ ។

## សន្និដ្ឋាន

ដូចដែលជំពូកនេះបានបង្ហាញខាងលើ បញ្ហាសំខាន់មួយចំនួនស្តីអំពីច្បាប់សារវ័ន្តមាននឹងមានប៉ះពាល់ទៅដល់ដំណើរការរបស់តុលាការនៅពេលជំនុំជម្រះក្តី ។ ការចេញសេចក្តីសម្រេច និងសាលក្រមរបស់អង្គជំនុំជម្រះវិសាមញ្ញទៅលើការមន្ទិលសង្ស័យទាំងនេះនឹងមានសារសំខាន់សម្រាប់ភាគីជម្លោះនិងសម្រាប់តុលាការដែលនឹងលើកឡើងនូវបញ្ហាទាំងនេះថាជាបញ្ហាដែលកើតមានពីមុនៗ ។ បញ្ហាមួយដែលចៅក្រមនឹងត្រូវប្រឈមមុខដោះ-ស្រាយនោះ គឺសេចក្តីត្រូវការជាចាំបាច់ក្នុងការកំណត់ថា គោលការណ៍នៃការទទួលខុសត្រូវរបស់ថ្នាក់លើបានអនុវត្តក្រោបរិបទជម្លោះប្រដាប់អាវុធអន្តរជាតិនៅក្នុងឆ្នាំ១៩៧៥ ។ សេចក្តីសម្រេចចិត្តនោះមានសារសំខាន់សម្រាប់ការជំនុំជម្រះក្តីអតីតមេដឹកនាំខ្មែរក្រហម ។

បញ្ហាប្រភេទទីពីរទាក់ទិននឹងអំពើឧក្រិដ្ឋកម្មចំនួនពីរដែលស្ថិតនៅក្រោមដែនយុត្តាធិការរបស់តុលាការ គឺឧក្រិដ្ឋកម្មបំផ្លិចបំផ្លាញសម្បត្តិវប្បធម៌និងឧក្រិដ្ឋកម្មប្រឆាំងនឹងជនដែលទទួលបាននូវការការពារជាអន្តរជាតិដែលសំដៅចំពោះប្រភពច្បាប់ដែលមិនបានបង្កើតនូវអំពើឧក្រិដ្ឋកម្ម និងមិនបានចែងអំពីការទទួលខុសត្រូវជាបុគ្គល ។ ចៅក្រមអាចប្រើប្រាស់អនុសញ្ញាទីក្រុងហ្សឺណែវជាមូលដ្ឋានសម្រាប់ការជំនុំជម្រះក្តីឧក្រិដ្ឋកម្មបំផ្លិចបំផ្លាញសម្បត្តិវប្បធម៌ ហើយចៅក្រមក៏អាចប្រើប្រាស់ច្បាប់ទំនៀមទម្លាប់អន្តរជាតិ បំពេញបំណងរបស់អ្នកធ្វើសេចក្តីព្រាងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងបញ្ចូលឧក្រិដ្ឋកម្មប្រឆាំងនឹងជនដែលទទួលបាននូវការការពារជាអន្តរជាតិទៅក្នុងដែនយុត្តាធិការរបស់តុលាការ ។ ជាការពិត មានបញ្ហាពីមុនរួចមកហើយស្តីអំពីបទឧក្រិដ្ឋអន្តរជាតិនេះនៅក្នុងប្រព័ន្ធយុត្តិធម៌ក្នុងស្រុកដទៃទៀត ។

និយមន័យឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៅក្នុងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា លើកឡើងនូវសំណួរសំខាន់ៗដោយយោងទៅតាមក្រុមដែលទទួលបាននូវការការពារ ដែលតុលាការអាចចាត់ទុកជាផ្នែកមួយនៃធាតុផ្សំរូបរាងកាយឬសតិបញ្ញានៃបទឧក្រិដ្ឋ ។ ការចេញសេចក្តីសម្រេចរបស់ចៅក្រមស្តីអំពីនីតិវិធីក្នុងការបកស្រាយច្បាប់នេះថាតើត្រូវអនុវត្តទៅតាមតុលាការព្រហ្មទណ្ឌអន្តរជាតិ តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា ឬទៅតាមការសម្រេចនៃច្បាប់មុនៗដែលតម្រូវជាចាំបាច់នូវការរីកញែកដ៏មានសារសំខាន់សម្រាប់ដំណើរការជំនុំជម្រះក្តីនេះ ។ សេចក្តីសម្រេចរបស់តុលាការទៅលើអង្គហេតុនឹងទំនងជាប៉ះពាល់ទៅដល់លទ្ធផលក្រោយការជំនុំជម្រះក្តី ។ សេចក្តីសម្រេចនេះក៏នឹងប៉ះពាល់ទៅដល់ការវាយតម្លៃរបស់ចៅក្រមនូវធាតុនៃបទឧក្រិដ្ឋដែលត្រូវបានបង្ហាញយ៉ាងច្បាស់លាស់ដែលជះឥទ្ធិពលទៅដល់សេចក្តីសម្រេចរបស់តុលាការ ។

ជំពូកនេះក៏បង្ហាញអំពីបញ្ហាសំខាន់ៗដែលព្រះរាជអាជ្ញានឹងត្រូវប្រឈមមុខដោះស្រាយ ។ សម្រាប់បទឧក្រិដ្ឋកម្មអន្តរជាតិ "សំខាន់ៗ"ចំនួនបី គឺអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម ការបង្ហាញគ្រប់ធាតុទាំងអស់នៃបទឧក្រិដ្ឋនឹងជួបការលំបាកនៅពេលសវនាការ ។ ដើម្បីធានាការចោទប្រកាន់ចំពោះអំពើប្រល័យពូជសាសន៍ ព្រះរាជអាជ្ញាចាំបាច់ត្រូវបង្ហាញក្រុមដែលទទួលបាននូវការការពារ និងអំពើដែលត្រូវបានហាមឃាត់ដែលត្រូវបានប្រព្រឹត្តឡើង "ដោយចេតនាបំផ្លិចបំផ្លាញទាំងស្រុងឬមួយផ្នែក"នៃក្រុមនោះ ។ ដោយសារតែការលំបាកក្នុងការបង្ហាញនូវធាតុសតិបញ្ញានៃអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍នឹងទំនងជាមិនគ្របដណ្តប់ទាំងស្រុងទៅលើការសម្លាប់ដែលបានកើតឡើងនៅក្នុងប្រទេសកម្ពុជាចន្លោះឆ្នាំ១៩៧៥-៧៩ទេ ។ ផ្ទុយទៅវិញ ធាតុផ្សំនៃអំពើប្រល័យពូជសាសន៍អាចជួយធានាទៅដល់ការចោទប្រកាន់ចំពោះបទឧក្រិដ្ឋកម្មដែលប្រឆាំងនឹងក្រុមបែបនេះ ដូចជាជនជាតិខ្មែរអ៊ីស្លាម ជនជាតិភាគតិចវៀតណាម ចិន ជនបរទេស កុលសម្ព័ន្ធព្រៃភ្នំ និងព្រះសង្ឃ ។

និយមន័យឧក្រិដ្ឋកម្មសង្គ្រាមនៃច្បាប់ស្តីពីការបង្កើតអង្គ

ជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ក៏នៅពុំទាន់ផ្តល់ចម្លើយ ឆ្លើយតបទៅនឹងសំណួរសំខាន់ៗនេះនៅឡើយដែរ ។ ប្រសិនបើ តុលាការសម្រេចមិនកាត់សេចក្តីឧក្រិដ្ឋកម្មសង្គ្រាមដែលបាន កើតឡើងនៅពេលមានជម្លោះប្រដាប់អាវុធជាអន្តរជាតិ និង បានកំណត់ថាជម្លោះក្នុងស្រុកបានកើតឡើងស្ទើរតែពេញមួយ របបកម្ពុជាប្រជាធិបតេយ្យ ព្រះរាជអាជ្ញាអាចចោទប្រកាន់ ជនជាប់ចោទពីបទឧក្រិដ្ឋកម្មសង្គ្រាម ។ ក៏ប៉ុន្តែ ប្រសិនបើចៅក្រម សម្រេចកាត់សេចក្តីសម្ព័ន្ធភាពជម្លោះប្រដាប់អាវុធជាអន្តរជាតិ ព្រះរាជអាជ្ញានឹងប្រឈមមុខក្នុងការមិនបង្ហាញថា ជនជាប់ចោទ បានប្រព្រឹត្តឧក្រិដ្ឋកម្មសង្គ្រាម ។ ការចោទប្រកាន់ផ្តោតជាសំខាន់ ទៅលើប៉ុន្មានខែដំបូងនៃរបបកម្ពុជាប្រជាធិបតេយ្យ ហើយ ព្រះរាជអាជ្ញាអាចអះអាងថា ការបោសសម្អាតក្រុមអ្នកគាំទ្រ រដ្ឋាភិបាល លន់ នល់ បានកើតឡើងនៅក្នុងអំឡុងពេលនៃសង្គ្រាម ស៊ីវិលឆ្នាំ១៩៧០-៧៥ និងនៅក្នុងអំឡុងនៃសង្គ្រាមឥណ្ឌូចិន លើកទីពីរដែលរបប លន់ នល់ និងក្រុមសម្ព័ន្ធមិត្តអាមេរិក ប្រយុទ្ធ ប្រឆាំងនឹងកងទ័ពខ្មែរក្រហមនិងប្រទេសដែលនៅពីក្រោយដែល គាំទ្រខ្មែរក្រហម ដូចជាប្រទេសវៀតណាម ចិន និងបណ្តា ប្រទេសកុម្មុយនិស្តផ្សេងៗទៀត ។ ប្រសិនបើតុលាការពុំទទួល ស្គាល់ទស្សនៈនេះទេ ទំនងជាពុំមានការចោទប្រកាន់ឧក្រិដ្ឋកម្ម សង្គ្រាមមុនរបបកម្ពុជាប្រជាធិបតេយ្យឡើយ ។

ព្រះរាជអាជ្ញាក៏អាចអះអាងថា ជម្លោះប្រដាប់អាវុធបាន កើតឡើងរវាងប្រទេសកម្ពុជានិងវៀតណាម ស្ទើរតែពេញមួយ រយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យ និងជាពិសេសនៅក្នុង ឆ្នាំ១៩៧៧និងឆ្នាំ១៩៧៨ នៅពេលដែលការប៉ះទង្គិចគ្នានៅ តាមព្រំដែនរវាងប្រទេសកម្ពុជានិងវៀតណាមបាននាំប្រទេស ទាំងពីរនេះឆ្ពោះរកការធ្វើសង្គ្រាមរវាងគ្នានឹងគ្នា ។ ប្រសិនបើអង្គ ជំនុំជម្រះវិសាមញ្ញទទួលស្គាល់នូវទស្សនៈនេះ ទំនងជាមានការ ពិភាក្សាស្តីពីការចោទប្រកាន់ឧក្រិដ្ឋកម្មសង្គ្រាម ។ ប្រសិនបើ តុលាការកំណត់ថា ជម្លោះនៅតាមព្រំដែនជាមួយវៀតណាម (និងមួយចំនួនតូចជាមួយនឹងប្រទេសថៃ) មិនមែនជាជម្លោះ ប្រដាប់អាវុធជាអន្តរជាតិ មេធាវីការពារក្តីនឹងទំនងជាធានាបាន នូវការរួចទោសពីការចោទប្រកាន់របស់តុលាការពីបទឧក្រិដ្ឋកម្ម សង្គ្រាម ។

ឧក្រិដ្ឋកម្មជាតិ ការធ្វើមនុស្សឃាត អំពើទារុណកម្ម និងការ ធ្វើទុក្ខបុកម្នេញសាសនា ដែលដកស្រង់ចេញពីច្បាប់ព្រហ្មទណ្ឌឆ្នាំ ១៩៥៦ ទំនងជាពុំបង្កនូវភាពស្មុគស្មាញទៅដល់ចៅក្រម ព្រះរាជ អាជ្ញា និងមេធាវីការពារក្តីទេ ។ ក្នុងការចោទប្រកាន់អំពើឧក្រិដ្ឋ កម្មជាតិ ព្រះរាជអាជ្ញាពុំចាំបាច់បង្ហាញធាតុចេតនាបំផ្លិចបំផ្លាញ "ទាំងស្រុងឬមួយផ្នែក" នៃក្រុមដែលទទួលបាននូវការការពារ ដូចគ្នានឹងអំពើប្រល័យពូជសាសន៍ ឬបង្ហាញការវាយប្រហារ "ទ្រង់ទ្រាយធំឬជាខ្សែសង្វាក់" មានលក្ខណៈដូចគ្នាទៅនឹងឧក្រិដ្ឋ កម្មប្រឆាំងនឹងមនុស្សជាតិ ឬបង្ហាញអំពើឧក្រិដ្ឋកម្មដែលបាន កើតឡើងនៅពេលមានជម្លោះប្រដាប់អាវុធមានលក្ខណៈដូចគ្នា នឹងឧក្រិដ្ឋកម្មសង្គ្រាម ។ ព្រះរាជអាជ្ញាមានលំបាកក្នុងការបង្ហាញ ធាតុទាំងនេះ ពីព្រោះធាតុទាំងនេះតម្រូវជាចាំបាច់ឲ្យមានភស្តុតាង ជាច្រើននិងការយល់ដឹងឲ្យបានច្បាស់លាស់នូវសតិបញ្ញារបស់ ជនជាប់ចោទ ។

វាមានសារសំខាន់ខ្លាំងណាស់ក្នុងការបញ្ជាក់ថា អង្គហេតុជា សារវន្តដែលត្រូវបានលើកឡើងខាងលើនេះពុំត្រូវបានដាក់ឲ្យ ដាច់ចេញពីច្បាប់នោះឡើយ ពីព្រោះបញ្ហាទាំងនេះមានទំនាក់ ទំនងទៅនឹងបញ្ហានយោបាយដែលងាយនឹងប្រេះស្រាំ និងដែល បានដាក់សម្ពាធទៅលើចៅក្រមក្នុងការសម្រេចចិត្តលើបញ្ហាច្បាប់ សារវិជ្ជមាន ។ សម្រាប់សាលាជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហម វិញ ការដាក់សម្ពាធទៅលើការចេញសាលក្រមដែលទាក់ទិននឹង បទឧក្រិដ្ឋ "ធំៗ" ដូចជាអំពើប្រល័យពូជសាសន៍និងឧក្រិដ្ឋកម្ម ប្រឆាំងនឹងមនុស្សជាតិ មិនប៉ះពាល់ទៅដល់ការចេញសេចក្តី សម្រេចនូវច្បាប់សារវិជ្ជមានដែលរំលោភសិទ្ធិរបស់ជនជាប់ចោទ នោះទេ ។ ប្រសិនបើសាលាជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហម អាច ដោះស្រាយនូវការសម្រេចចិត្តត្រឹមត្រូវដែលអាចជឿទុកចិត្ត បានស្តីអំពីនិយមន័យនៃឧក្រិដ្ឋកម្មដែលពិភាក្សាក្នុងជំពូកនេះ សាលាជំនុំជម្រះក្តីនេះនឹងចូលរួមក្នុងការធ្វើយុត្តិកម្មលើច្បាប់ ព្រហ្មទណ្ឌអន្តរជាតិដែលកំពុងតែរីកចម្រើន ។

**អូប្រី អារដម៉ា**

# ប្រវត្តិសាលាក្តីកាត់ទោសមេដឹកនាំខ្មែរក្រហម កំណរកំណើត ការចរចា និងការបង្កើត

**(តចប់)**

### ការចរចាបង្កើតសាលាក្តី-ការកំណត់ចំណុចបង្គោល

តាំងពីដើមមក ភាគីទាំងពីរមានគំនិតផ្សេងគ្នាអំពីថាតើសាលាក្តីនេះនឹងត្រូវបង្កើតឡើងដោយរបៀបណា ។ ភាពខុសគ្នានេះ មានស្ទើរតែគ្រប់ផ្នែកទាំងអស់នៃការបង្កើតសាលាក្តី ។ ក្រុមការងាររាជរដ្ឋាភិបាលបានស្នើថា សាលាក្តីនេះត្រូវស្ថិតនៅក្នុងប្រព័ន្ធតុលាការក្នុងស្រុកដែលមានស្រាប់ ។ ផ្ទុយទៅវិញ ភាគីអង្គការសហប្រជាជាតិចង់ឲ្យបង្កើតតុលាការពិសេសមួយ ។ ជាងនេះទៅទៀត ទាំងអង្គការសហប្រជាជាតិ ទាំងរាជរដ្ឋាភិបាលកម្ពុជាបានទាមទារថា ចៅក្រមមកពីភាគីទាំងពីរគួរតែមានចំនួនភាគច្រើន ។

ប្រធានបទមួយដែលត្រូវបានចរចាយូរគឺ ដំណើរការនៃការតែងតាំងចៅក្រមនិងព្រះរាជអាជ្ញា ។ ក្រុមការងារខាងរាជរដ្ឋា-ភិបាលបានស្នើថា ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមដែលជាអង្គការទទួលខុសត្រូវក្នុងការតែងតាំងអង្គចៅក្រមនិងអយ្យការនឹងតែងតាំងចៅក្រមកម្ពុជា ហើយអគ្គលេខាធិការអង្គការសហប្រជាជាតិនឹងតែងតាំងចៅក្រមបរទេសបន្ទាប់ពីមានការពិគ្រោះយោបល់ជាមួយរាជរដ្ឋាភិបាលកម្ពុជា ។ ទោះជាយ៉ាងនេះក្តី ការិយាល័យកិច្ចការច្បាប់របស់អង្គការសហប្រជាជាតិមើលឃើញថា ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមខ្វះឯករាជ្យភាព ។ ក្រុមប្រឹក្សានេះគ្រាន់តែជាឧបករណ៍នយោបាយថ្នាក់ខ្ពស់ ហើយភាគីអង្គការសហប្រជាជាតិយល់ឃើញថា វាជាការសំខាន់ណាស់ដែលហានិភ័យ(ព្រឹត្តិការណ៍ជាយថាហេតុ) ទាក់ទងទៅនឹងសម្ពាធនយោបាយដោយផ្ទាល់ឬដោយប្រយោលគួរតែត្រូវបានលុបបំបាត់ ។ ជាងនេះទៅទៀត អ្នកជំនាញការច្បាប់មានការព្រួយបារម្ភថា ការបង្កើតឲ្យមានយន្តការតែងតាំងផ្សេងគ្នានឹងនាំឲ្យមានការបែងចែករវាងចៅក្រមកម្ពុជានិងចៅក្រមអន្តរជាតិ ។ ភាគីមួយនឹងទទួលបានការគាំទ្រពីសហគមន៍អន្តរជាតិ ហើយភាគីមួយទៀតមិនទទួលបានការគាំទ្រ ។ អ្នកច្បាប់របស់អង្គការសហប្រជាជាតិបានឲ្យយោបល់ថា វិធីដែលល្អបំផុតដើម្បីធានាឲ្យបានភាពមិនលម្អៀងនិងឯករាជ្យភាព គឺតម្រូវឲ្យការតែងតាំងចៅក្រមនិងព្រះរាជអាជ្ញាទាំងអស់ត្រូវតែឆ្លងកាត់យន្តការតែងតាំងរបស់អន្តរជាតិ ។

ឧបសគ្គមួយទៀតទាក់ទងនឹងដែនយុត្តាធិការរបស់តុលាការ ។ ភាគីទាំងពីរបានយល់ស្របថា វាមិនប្រាកដប្រជាទេ ប្រសិនបើតុលាការធ្វើការកាត់ទោសកម្មាភិបាលពីគ្រប់ឋានន្តរក្រមទាំងអស់នៃរបបខ្មែរក្រហម ប៉ុន្តែគួរផ្តោតទៅលើចំនួនកំណត់មួយវិញ ។ ក្រុមមន្ត្រីអង្គការសហប្រជាជាតិបានទាមទារថា ការកាត់ទោសគួរតែធ្វើឡើងទៅលើមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម និងអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម ។ ចំនួនដែលស្នើនៅក្នុងរបាយការណ៍របស់អ្នកជំនាញការក្នុងឆ្នាំ១៩៩៩ គឺមានពី២០ ទៅ៣០នាក់ ជាចំនួនដែលសម្តេច ហ៊ុន សែន ប្រឆាំងជំទាស់ជាដាច់ខាត ។ គំនិតរបស់គាត់គឺថា ការកាត់ទោសគួរតែជ្រើសរើសអ្នកខ្ពស់បំផុត ដែលកំណត់យកតែមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមតែ៤ទៅ៥នាក់ប៉ុណ្ណោះ ។ សម្តេច ហ៊ុន សែន បានអះអាងថា ការកាត់ទោសលើសពីនេះនឹងនាំឲ្យមានប្រតិកម្មហិង្សាពីកម្លាំងខ្មែរក្រហមដែលសេសសល់ ហើយថាស្ថិរភាពនយោបាយ សន្តិសុខសង្គមនិងការអភិវឌ្ឍន៍សេដ្ឋកិច្ច គឺជាអាទិភាពចំពោះមុខរបស់រាជរដ្ឋាភិបាល ។ ក្រុមអ្នករិះគន់បានអះអាងថា សម្តេច ហ៊ុន សែន កំណត់ចំនួនចុងចោទដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួន ។ មុនពេលរត់ទៅវៀតណាមនៅឆ្នាំ១៩៧៧ ហ៊ុន សែន ធ្វើជាកម្មា-ភិបាលយោធារបស់ខ្មែរក្រហម ។ វាមិនមែនថា មិនអាចយល់បាននោះទេ ដែលថាសំណាញ់ដ៏ធំរបស់ព្រះរាជអាជ្ញាអាចក្រសោបយកទាំងអតីតកម្មាភិបាលដែលមានឋានៈប្រហាក់ប្រហែលគាត់នោះ ។ ជាងនេះទៅទៀត លោក ហ៊ុន សែន ប្រឈមមុខទៅនឹងសម្ពាធរបស់សមាជិកគណៈអចិន្ត្រៃយ៍បក្សប្រជាជនកម្ពុជា

ដែលធ្លាប់ចូលរួមក្នុងរបបខ្មែរក្រហម ។

ប្រធានបទស្តីអំពីដែនយុត្តាធិការរបស់តុលាការ ក៏បានផ្តើមឲ្យមានការពិភាក្សាពីបញ្ហាពាក់ព័ន្ធមួយផ្សេងទៀត គឺការលើកលែងទោសឲ្យ អៀង សារី ។ គោលជំហររបស់អង្គការសហប្រជាជាតិគឺច្បាស់លាស់ ។ លទ្ធភាពនៃការលើកលែងទោសក្នុងករណីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិគឺមិនអាចទទួលយកបាន ។ ទោះជាយ៉ាងនេះក្តី រាជរដ្ឋាភិបាលកម្ពុជាមានការស្ទាក់ស្ទើរក្នុងការបដិសេធទៅនឹងសិទ្ធិរបស់ព្រះមហាក្សត្រដែលធានាដោយរដ្ឋធម្មនុញ្ញ ។ សម្តេច ហ៊ុន សែន បានប្រឆាំងជាលក្ខណៈបុគ្គលទៅនឹងជំហររបស់អង្គការសហប្រជាជាតិ ដោយប្រកាន់យកនូវគោលនយោបាយយូរអង្វែងរបស់គាត់ ដែលធានាមិនឲ្យមានការកាត់ទោសចំពោះក្រុមខ្មែរក្រហមផ្តាច់ខ្លួនដែលបានប្រកាសស្មោះស្ម័គ្រជាមួយនឹងបក្សរបស់គាត់ ។ តំណាងរបស់អាមេរិកបានចូលខ្លួនជួយដោះស្រាយចំពោះការខ្វែងគំនិតគ្នាទាំងនេះ ។ ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកសម្រាប់ឧក្រិដ្ឋកម្មសង្គ្រាម លោក ដេវីដ សែវហ្វ័រ និងឯកអគ្គរដ្ឋទូតអាមេរិកប្រចាំទីក្រុងភ្នំពេញ លោក ឃេន វាយដឺមែន បានដឹកនាំកិច្ចខិតខំប្រឹងប្រែងក្នុងការសម្របសម្រួលជាមួយរាជរដ្ឋាភិបាលកម្ពុជា ។ អ្នកទាំងនេះចាប់ផ្តើមការងារដោយធ្វើការពិភាក្សាពីប្រធានបទទាក់ទងនឹងរចនាសម្ព័ន្ធតុលាការ ។ ការពិភាក្សាផ្តោតសំខាន់ទៅលើថាតើការកាត់ទោសគួរតែបំបែកចេញ ឬដាក់បញ្ចូលទៅក្នុងប្រព័ន្ធតុលាការកម្ពុជាដែលមានស្រាប់ ។ អ្វីដែលទទួលបានគឺការផ្តល់សម្បទានទៅវិញទៅមករវាងភាគីទាំងពីរ ។ តុលាការពិសេសមួយនឹងត្រូវបានបង្កើតឡើងក្នុងប្រព័ន្ធតុលាការកម្ពុជា ដែលរួមមានសាលាដំបូង សាលាឧទ្ធរណ៍ និងតុលាការកំពូល ។

អ្នកតំណាងរបស់អាមេរិកក៏បានព្យាយាមបំបែកភាពទាល់ច្រករវាងការិយាល័យកិច្ចការច្បាប់របស់អង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាទាន់ទិននឹងបញ្ហាថាតើភាគីណាមួយនឹងមានចំនួនចៅក្រមច្រើនជាង ។ ឯកអគ្គរដ្ឋទូតសហអាមេរិក វាយដឺមែន បានស្នើឲ្យមានការបោះឆ្នោតដោយសំឡេងភាគច្រើនដាច់ខាត មានន័យថាចៅក្រមកម្ពុជានឹងមានចំនួនច្រើនជាង ប៉ុន្តែត្រូវមានការគាំទ្រពីចៅក្រមអន្តរជាតិម្នាក់យ៉ាងតិចដើម្បីឲ្យការធ្វើសេចក្តីសម្រេចចិត្តមានសុពលភាព ។ លោកបានឲ្យយោបល់ថា ធ្វើបែបនេះនឹងធានាបានថា ចៅក្រមអន្តរជាតិនឹងមានសំឡេងនៅក្នុងដំណើរការកាត់ក្តីនេះ ។ ដើម្បីទទួលបានការគាំទ្រពីសហគមន៍អន្តរជាតិ ក៏មានការស្នើសុំឲ្យមានសហព្រះរាជអាជ្ញានិងសហចៅក្រមស៊ើបអង្កេតដែលមានតួនាទីស្រាប់នៅក្នុងប្រព័ន្ធច្បាប់កម្ពុជា ។

សេចក្តីព្រាងច្បាប់ត្រូវបានបញ្ចប់ ហើយត្រូវបានដាក់ជូនរដ្ឋសភាជាតិកម្ពុជានៅខែមករា ឆ្នាំ២០០០ ហើយមួយច្បាប់ទៀតត្រូវបានបញ្ជូនទៅឲ្យអគ្គលេខាធិការអង្គការសហប្រជាជាតិ ។ បញ្ហាមួយចំនួនបានកើតឡើងជាថ្មីម្តងទៀត ។ ចំនួនភាគច្រើននៃចៅក្រមកម្ពុជាស្ថិតនៅដដែល ។ បញ្ហាស្តីពីការលើកលែងទោសឲ្យ អៀង សារី មិនត្រូវបានដោះស្រាយ ហើយបញ្ហាថ្មីៗផ្សេងទៀតក៏បានលេចឡើង ។ រាជរដ្ឋាភិបាលកម្ពុជាបានស្នើឡើងថារដ្ឋាភិបាលបរទេសនិងអាជ្ញាធរកម្ពុជាអាចជ្រើសរើសចៅក្រមពីក្នុងប្រទេសរបស់ខ្លួន ។ វាក៏មានភាពមិនច្បាស់លាស់ចំពោះបញ្ហាដែលថា តើសហព្រះរាជអាជ្ញាទាំងពីរត្រូវតែចុះហត្ថលេខាលើដីកាចោទប្រកាន់រួមគ្នា ។ ប្រសិនបើដូច្នេះភាគីម្ខាងនឹងអាចប្រឆាំងទៅនឹងដីកាចោទប្រកាន់ដែលមានភាពចម្រូងចម្រាសមួយចំនួន ។

លោកអគ្គលេខាធិការអង្គការសហប្រជាជាតិ កូហ្វី អាណាន់ បានបង្ហាញពីការព្រួយបារម្ភតាមរយៈសំបុត្រមួយច្បាប់ផ្ញើជូនសម្តេច ហ៊ុន សែន នៅខែកុម្ភៈឆ្នាំ២០០០ ដោយគូសបញ្ជាក់នូវបញ្ហាបួន ដែលត្រូវយកចិត្តទុកដាក់ជាបន្ទាន់ ។ បញ្ហាទីមួយគឺ ការធានាឲ្យបានថា ជនដែលត្រូវបានចោទប្រកាន់នឹងត្រូវចាប់ខ្លួន ។ ទីពីរ នឹងមិនមានការលើកលែងទោស ។ ទីបី ព្រះរាជអាជ្ញាត្រូវជាអន្តរជាតិដើម្បីធានាភាពមិនលម្អៀង ។ ចុងក្រោយ ចៅក្រមអន្តរជាតិត្រូវតែមានចំនួនភាគច្រើន ហើយត្រូវតែងតាំងដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

ទោះជាក្រុមអ្នកច្បាប់ព្យាយាមដោះស្រាយភាពផ្ទុយគ្នាអស់ជាច្រើនខែមក ព្រឹទ្ធសមាជិកអាមេរិកលោក ចន ឃើរី ដោយមានការពិភាក្សាជាមួយលេខាធិការដ្ឋានអង្គការសហប្រជាជាតិ បានស្នើឲ្យមានដំណោះស្រាយក្រៅផ្លូវការមួយប្រកបដោយ

ដោគជ័យ ដើម្បីដោះស្រាយជម្លោះរវាងសហព្រះរាជអាជ្ញានិង សហចៅក្រមស៊ើបអង្កេត ។ លោកស្នើឲ្យមានការបង្កើតអង្គ ចៅក្រម៥រូបដាច់ដោយឡែក ដែលនឹងអនុវត្តតាមរូបមន្តភាគ ច្រើនដាច់ខាត ដើម្បីកាត់សេចក្តីលើសុពលភាពនៃដីកាចោទ ប្រកាន់ ។ អ្នកសង្កេតការណ៍ជាច្រើនបានចាត់ទុករឿងនេះថាជា ការធ្វើសម្បទានដ៏ធំមួយរបស់រាជរដ្ឋាភិបាលកម្ពុជា ។

ជាមួយនឹងសភាពការណ៍វិវឌ្ឍន៍បែបនេះ ក្រុមអ្នកច្បាប់ របស់អង្គការសហប្រជាជាតិបានវិលត្រឡប់មកទីក្រុងភ្នំពេញ វិញ ។ ទោះជាយ៉ាងនេះក្តី ភាសាប្រើប្រាស់បានផ្លាស់ប្តូរ ។ លោក ហែន កូវែល បានពណ៌នាសាលាក្តីនេះថាជា«តុលាការកម្ពុជា



ជនរងគ្រោះនៅក្នុងបន្ទប់សវនការនៃអង្គជំនុំជម្រះវិសាមញ្ញ

ដោយមានការចូលរួមពីចៅក្រមនិងព្រះរាជអាជ្ញាអន្តរជាតិ» ។ ចំណុចមួយត្រូវបានបង្កើតឡើង ។ នៅពេលនេះអង្គការសហ ប្រជាជាតបានចាត់ទុកដំណើរការនេះថាជារបស់កម្ពុជាដោយ មានជំនួយពីខាងក្រៅ ។ ក្រុមអ្នកច្បាប់បានបង្ហាញជូនរាជរដ្ឋា ភិបាលកម្ពុជានូវសេចក្តីព្រាងច្បាប់ស្តីអំពីកិច្ចសហប្រត្តិការរវាង ភាគីទាំងពីរពាក់ព័ន្ធបញ្ហាតុលាការនេះ ។ អង្គការសហប្រជាជាតិ បានបញ្ជាក់ថា រាល់ការផ្លាស់ប្តូរទៅលើច្បាប់ដែលបានអនុម័តរួច នឹងមិនខុសគ្នាពីចំណុចព្រមព្រៀងនៅក្នុងមាត្រាទាំងនេះឡើយ ។ ជាក់ស្តែង មាត្រាទាំងនេះបានលុបចោលបទប្បញ្ញត្តិទាំងឡាយ ដែលអនុញ្ញាតឲ្យបរទេសនិងរាជរដ្ឋាភិបាលកម្ពុជាតែងតាំងអង្គ ចៅក្រមអន្តរជាតិ ។ ដូចគ្នាដែរ មាត្រាថ្មីទាំងនេះបានបញ្ជាក់ថា អង្គការសហប្រជាជាតិនឹងតែងតាំងព្រះរាជអាជ្ញាអន្តរជាតិ ហើយ តំណែងថ្មីពីរ(ព្រះរាជអាជ្ញារងអន្តរជាតិនិងអនុប្រធានរដ្ឋបាល) នឹងត្រូវបង្កើតឡើង ។ ចំពោះតំណែងសហព្រះរាជអាជ្ញាអន្តរជាតិ អង្គការសហប្រជាជាតិនឹងជ្រើសរើសបេក្ខជនថ្មីសម្រាប់តំណែង នេះ ។

ការចរចាអស់រយៈពេលយ៉ាងយូរស្តីអំពីកិច្ចព្រមព្រៀងនេះ មានផលប៉ះពាល់តិចតួចណាស់ ទៅលើជំហររបស់រាជរដ្ឋាភិបាល កម្ពុជា ។ រដ្ឋសភាកម្ពុជាបានអនុម័តច្បាប់ស្តីពីការបង្កើតអង្គ ជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានៅខែមករាឆ្នាំ២ ០ ០ ១ ហើយបន្ទាប់ពីទោសប្រហារជីវិតត្រូវបានដកចេញតាមសំណើ របស់ក្រុមប្រឹក្សាធម្មនុញ្ញ ព្រះមហាក្សត្របានឡាយព្រះហស្ត-លេខាប្រកាសឲ្យប្រើច្បាប់នេះនៅខែសីហា ឆ្នាំ២ ០ ០ ១ ។ ទោះ ជាយ៉ាងនេះក្តី ច្បាប់នេះមានចំណុចខ្វះខាតជាច្រើន ដែលអង្គការ សហប្រជាជាតិបានគូសបញ្ជាក់នៅក្នុងកិច្ចព្រមព្រៀង ។ ចំពោះ ជំនួយអន្តរជាតិសម្រាប់សាលាក្តី អ្នកជំនាញការច្បាប់អន្តរជាតិ បានទទូចឲ្យមានការចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះ ប៉ុន្តែ រាជរដ្ឋាភិបាលកម្ពុជាបានលើកឡើងថា កិច្ចព្រមព្រៀងបែបនេះ នឹងរំលោភទៅលើអធិបតេយ្យភាពជាតិ ។

ជំហរដាច់អហង្ការរបស់រាជរដ្ឋាភិបាលកម្ពុជាបាននាំទៅដល់

ការប្រកាសដកខ្លួនចេញពីការចរចារបស់អង្គការសហប្រជាជាតិ នៅខែកុម្ភៈ ឆ្នាំ២០០២ ។ អង្គការសិទ្ធិមនុស្សសំខាន់ៗជាច្រើន គាំទ្រសេចក្តីសម្រេចចិត្តនេះដោយអះអាងថា ភាពមិនច្បាស់លាស់ចំពោះបញ្ហាបច្ចេកទេសនិងបញ្ហានយោបាយរបស់សាលាក្តី នឹងធ្វើឲ្យអាក់ខានដល់ការទទួលបាននូវយុត្តិធម៌កម្រិតស្តង់ដាអន្តរជាតិ ។ ទោះជាយ៉ាងនេះក្តី មជ្ឈដ្ឋានមួយចំនួនផ្សេងទៀតបានរិះគន់ចំពោះការដកខ្លួនចេញនេះ ។ អ្នកទាំងនោះរួមមានៈ តំណាងពិសេសរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិសម្រាប់សិទ្ធិមនុស្ស ភិតធ័រ ឡឺព្រិច សហរដ្ឋអាមេរិក ជប៉ុន បារាំង ឥណ្ឌា រុស្ស៊ី និងប្រទេសអាស៊ីអាគ្នេយ៍មួយចំនួន ។ ក្រុមអ្នករិះគន់បានអះអាងថា ការដកខ្លួនចេញរបស់អង្គការសហប្រជាជាតិនឹងធ្វើឲ្យក្រុមអ្នកជំនាញការច្បាប់អន្តរជាតិមិនអាចសម្រេចបានក្នុងការនាំយកមេដឹកនាំខ្មែរក្រហមដែលចាស់ជរាទៅហើយនោះមកកាត់ទោសបាន ។ អ្នកទាំងនេះបាននិយាយថា ការបញ្ចប់ការចរចាគឺមានន័យស្មើនឹងការជំរុញឲ្យមាននិទ្ទណ្ឌភាព ។

### ការចូលរួមសាជាថ្មីរបស់អង្គការសហប្រជាជាតិ

នៅក្នុងសេចក្តីសម្រេចដែលគាំទ្រដោយជប៉ុននិងបារាំងនៅខែធ្នូ ឆ្នាំ២០០២ មហាសន្និបាតអង្គការសហប្រជាជាតិបានផ្តល់សិទ្ធិឲ្យអគ្គលេខាធិការអង្គការសហប្រជាជាតិ ផ្តើមការចរចាក្នុងការបង្កើតសាលាក្តីជាថ្មីម្តងទៀត ។ សេចក្តីសម្រេចនេះក៏បានជំរុញឲ្យក្រុមអ្នកជំនាញការច្បាប់វិលត្រឡប់មកទីក្រុងភ្នំពេញ ដើម្បីបញ្ចប់ការចរចាទៅលើបញ្ហាទាំងឡាយដែលទាមទារដោយភាគីកម្ពុជា ។ រដ្ឋជាសមាជិកអង្គការសហប្រជាជាតិបានស្វាគមន៍ច្បាប់ឆ្នាំ២០០១ ដែលពីមុនត្រូវបានចាត់ទុកថាមិនច្បាស់លាស់ ហើយបានជំរុញឲ្យការិយាល័យកិច្ចការច្បាប់របស់អង្គការសហប្រជាជាតិដោះស្រាយឲ្យបានឆាប់រហ័សនូវបញ្ហាសំខាន់ៗទាំងឡាយ ហើយឈានដល់ការព្រមព្រៀងចុងក្រោយទៅលើរចនាសម្ព័ន្ធ និងប្រត្តិបត្តិការរបស់តុលាការ ។

ក្រុមអ្នកច្បាប់ទាំងពីរបានជួបប្រជុំគ្នា៦ដងនៅក្នុងអំឡុងខែមករា ឆ្នាំ២០០៣ ប៉ុន្តែមិនបានឈានដល់កិច្ចព្រមព្រៀងអ្វីឡើយ ។ អង្គការសហប្រជាជាតិបានទាមទារម្តងទៀតឲ្យមានចំនួនចៅក្រមអន្តរជាតិភាគច្រើន និងមានព្រះរាជអាជ្ញាឯករាជ្យមួយ ដែលតែងតាំងដោយអង្គការសហប្រជាជាតិ ។ រាជរដ្ឋាភិបាលបានទទូចឲ្យប្រកាន់យកបទប្បញ្ញត្តិដែលមានចែងនៅក្នុងច្បាប់ឆ្នាំ២០០១ ។ ដោយមានការអំពាវនាវយ៉ាងខ្លាំងពីប្រទេសអូស្ត្រាលី ជប៉ុន សហរដ្ឋអាមេរិក បារាំង ឥណ្ឌា និងហ្វីលីពីន និងដើម្បីឈានដល់កិច្ចព្រមព្រៀងក្រុមអ្នកច្បាប់បានវិលត្រឡប់មកចរចាជាលើកចុងក្រោយជាមួយក្រុមការងាររបស់រាជរដ្ឋាភិបាលកម្ពុជា ។ នៅថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០០៣ អង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងបង្កើតតុលាការដែលនឹងដំណើរការនៅក្នុងវង្វង់ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាឆ្នាំ២០០១ ប៉ុន្តែមានការបន្ថែមមួយចំនួនដូចជា ការដកចេញមិនឲ្យមានការលើកលែងទោសចំពោះបទឧក្រិដ្ឋ ដែលស្ថិតក្នុងដែនតុលាការ និងការកែសម្រួលរចនាសម្ព័ន្ធតុលាការពីបីថ្នាក់មកនៅត្រឹមពីរថ្នាក់ ។ វិសោធនកម្មទៅលើច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាឆ្នាំ២០០១ត្រូវបានព្រាងឡើងផ្អែកលើបទប្បញ្ញត្តិដែលបានព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជា ។

បន្ទាប់ពីការបោះឆ្នោតជាតិឆ្នាំ២០០៣ កម្ពុជាបានជួបប្រទះនូវការជាប់គាំងនយោបាយរយៈពេល១១ខែ ដែលបានបន្តរហូតដល់ខែកក្កដាឆ្នាំ២០០៤ ។ សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានអះអាងថា នៅពេលភាពទ័លច្រកត្រូវបានបញ្ចប់ ការអនុម័តលើកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជានិងវិសោធនកម្មលើច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាឆ្នាំ២០០១ គឺជាអាទិភាពមុនគេបង្អស់របស់រាជរដ្ឋាភិបាល ។ សម្តេចនាយករដ្ឋមន្ត្រីបានគោរពពាក្យសន្យា ដោយបានបញ្ជូនសេចក្តីព្រាងច្បាប់ទាំងពីរទៅរដ្ឋសភាជាតិដើម្បីអនុម័តច្បាប់ទាំងពីរនេះ ។ រដ្ឋសភាបានអនុម័តច្បាប់ទាំងពីរនេះនៅខែតុលា ពីរខែក្រោយការបង្កើតរដ្ឋាភិបាល ។ ជាងនេះទៅទៀត ក្រុមអ្នកចរចារបស់អង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាបានព្រមព្រៀងគ្នាទាំងស្រុងទៅលើចំនួនថវិកាដែលត្រូវផ្តល់ឲ្យតុលាការដោយភាគីទាំងពីរក្នុងរយៈពេលប្រមាណបីឆ្នាំ ។ ភាគីអង្គការសហ

ប្រជាជាតិនឹងផ្តល់ថវិកាចំនួន ៤៣លានដុល្លារអាមេរិក ហើយរាជរដ្ឋាភិបាលកម្ពុជានឹងរួមចំណែកថវិកាចំនួន ១៣លានដុល្លារអាមេរិក ។ នៅចុងឆ្នាំ២០០៤ រាជរដ្ឋាភិបាលកម្ពុជាហាក់ដូចជាបង្ហាញការតាំងចិត្តរបស់ខ្លួនក្នុងការស្វែងរកយុត្តិធម៌ពីឧក្រិដ្ឋកម្មក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។

មន្ត្រីអង្គការសហប្រជាជាតិបានផ្តល់ដំណឹងនៅខែមេសា ឆ្នាំ២០០៥ថា ខ្លួនបានប្រមូលថវិកាគ្រប់គ្រាន់ពីប្រទេសអ្នកផ្តល់ជំនួយសម្រាប់ចំណាយទៅលើផ្នែកអន្តរជាតិ ។ អង្គការសហ-ប្រជាជាតិក៏បានរៀបចំបញ្ជីឈ្មោះបេក្ខជនសម្រាប់តំណែងសហព្រះរាជអាជ្ញានិងចៅក្រមអន្តរជាតិ ហើយរាជរដ្ឋាភិបាលកម្ពុជាបានតែងតាំងលោកស្រី មីសែល លី ដែលត្រូវបានជ្រើសរើសដោយអង្គការសហប្រជាជាតិ ជាអនុប្រធានការិយាល័យរដ្ឋបាលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ការប្តេជ្ញារបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការបង្កើតតុលាការមានការរីកចម្រើនច្រើន ។ មន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជាបាននិយាយថារដ្ឋាភិបាលមិនមានលទ្ធភាពផ្តល់វិភាគទានទឹកប្រាក់១៣លានដុល្លារអាមេរិកទេ ហើយបានអំពាវនាវឲ្យសហគមន៍អន្តរជាតិជួយបំពេញខ្វះចំណាយដែលខ្លួនបានយល់ព្រម ។ ទោះជាយ៉ាងនេះក្តី រាជរដ្ឋាភិបាលកម្ពុជាបានរៀបចំទីតាំងរបស់តុលាការ និងបានបង្ហាញការវិវឌ្ឍន៍ទៅមុខចំពោះបញ្ហាផ្ទាល់ខ្លួនមួយចំនួន ។ រាជរដ្ឋាភិបាលបានតែងតាំងលោក ស៊ាន វិសុទ្ធ ជាប្រធានការិយា-ល័យរដ្ឋបាលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានៅខែវិច្ឆិកា ឆ្នាំ២០០៥ បង្ហាញបញ្ជីឈ្មោះបេក្ខជនចៅក្រមនៅខែធ្នូ ហើយបានតែងតាំងមន្ត្រីខ្មែរ១៧រូបនិងបរទេស១៣ឲ្យបម្រើការនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានៅខែឧសភា ឆ្នាំ២០០៦ ។ រហូតមកទល់នឹងបច្ចុប្បន្ននេះ សាលាក្តីមានធនធានបុគ្គលិក និងថវិកាគ្រប់គ្រាន់ដើម្បីដំណើរការកាត់ក្តី ។

## លទ្ធផលនៃការចរចា

ការចរចាអស់រយៈពេលជាច្រើនឆ្នាំបានធ្វើឲ្យអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជា ផ្តល់សម្បទានឲ្យគ្នាទៅវិញទៅមកលើបញ្ហាសំខាន់ៗជាច្រើន ទាក់ទងនឹងការបង្កើតសាលាក្តីកាត់ទោសខ្មែរក្រហម ។ ទោះបីជាភាគីទាំងពីរបានធ្វើសម្បទានយ៉ាងល្អយ៉ាងណាក៏ដោយ លទ្ធផលនៃការចរចាជាទូទៅឈានទៅរកការចង់បាននឹងផលប្រយោជន៍របស់រាជរដ្ឋាភិបាលកម្ពុជា ។ មន្ត្រីអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាបានឈានដល់ការព្រមព្រៀងប្រកបដោយការយោគយល់គ្នាទៅលើនិយមន័យច្បាប់នៃឧក្រិដ្ឋកម្មដែលត្រូវកាត់ទោស ក៏ដូចជាការព្រមព្រៀងគ្នាជាទូទៅទៅលើវិធាននៃភស្តុតាងនិងបញ្ហាសំខាន់ៗជាច្រើនទៀត ។ ទោះជាយ៉ាងនេះក្តី ចំពោះបញ្ហានយោបាយដ៏ចម្រូងចម្រាសភាគច្រើនជុំវិញដែនយុត្តាធិការរបនាសម្ព័ន្ធនិងមន្ត្រីបម្រើការក្នុងតុលាការ ភាគីរាជរដ្ឋាភិបាលកម្ពុជាទទួលបានច្រើននូវអ្វីដែលខ្លួនចង់បាន ។

## ការធ្វើសម្បទានទៅលើដែនយុត្តាធិការ

ដូចដែលបានកត់សម្គាល់ពីខាងដើម រាជរដ្ឋាភិបាលកម្ពុជាផ្តោតជាចម្បងទៅលើការកាកំណត់ដែនយុត្តាធិការរបស់តុលាការដោយអនុញ្ញាតឲ្យធ្វើការកាត់ទោសតែមេដឹកនាំជាន់ខ្ពស់បំផុត ឬចុងចោទខ្មែរក្រហមដែលមានឥទ្ធិពលខ្លាំងបំផុតប៉ុណ្ណោះ ។ លទ្ធផលនៃការចរចានាំទៅដល់ការគូសបញ្ជាក់ថា ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អនុញ្ញាតឲ្យអង្គជំនុំជម្រះវិសាមញ្ញធ្វើការកាត់ទោសតែទៅលើមេដឹកនាំជាន់ខ្ពស់នៃរបបខ្មែរក្រហមនិងជនទាំងឡាយណាដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះការរំលោភយ៉ាងធ្ងន់ធ្ងរលើច្បាប់កម្ពុជា និងច្បាប់អន្តរ-ជាតិដែលបានប្រព្រឹត្តក្នុងអំឡុងពេលពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ។ ទោះជាមិនមានការកំណត់ចំនួនច្បាស់លាស់ក៏ដោយ ក៏អ្នកចរចាកម្ពុជាបានធ្វើឲ្យអ្នកសង្កេតការណ៍រំពឹងទុកថា មានមនុស្សប្រហែលពី៤ទៅ៥នាក់ប៉ុណ្ណោះដែលនឹងត្រូវនាំយកមកកាត់ទោស ។ ចំនួននេះតិចជាងឆ្ងាយណាស់ពីចំនួនដែលអ្នកជំនាញការច្បាប់អន្តរជាតិបានលើកឡើងថា មានមនុស្សពី២០ទៅ៣០នាក់នឹងត្រូវនាំមកកាត់ទោស ហើយក៏ជាចំនួនដែលស្របទៅនឹងការចង់បានរបស់រាជរដ្ឋាភិបាលក្នុងការគ្រប់គ្រងឥទ្ធិពលនយោបាយរបស់តុលាការដែរ ។ ដោយជ្រើសរើសយកចំនួនចុងចោទតិចយ៉ាងប្រុងប្រយ័ត្នបែបនេះ រាជរដ្ឋាភិបាលកម្ពុជាអាចលុបបំបាត់ចោលនូវការធ្វើឲ្យអាក់ខានដល់ដំណើរការរបស់តុលាការ ។ ក្រុមអ្នករិះគន់រដ្ឋាភិបាល ដែល

ដឹកនាំដោយគណបក្សប្រជាជនកម្ពុជាបានអះអាងថា ការកំណត់ចំនួនជនសង្ស័យដ៏តូចនេះនឹងកាត់បន្ថយនូវគ្រោះថ្នាក់ដែលថា សម្តេច ហ៊ុន សែន និងមន្ត្រីជាន់ខ្ពស់ដទៃទៀតនឹងរងនូវភាពអាម៉ាស់ ដោយសារការចូលរួមរបស់ខ្លួនជាមួយខ្មែរក្រហមពីអតីតកាល ។

ទំហំនៃដែនយុត្តាធិការរបស់តុលាការមានភាពចម្រូងចម្រាសបន្តិចបន្តួច ហើយក៏មានការរិះគន់តិចតួចពីអ្នកសង្កេតការណ៍ទៅលើដំណើរការនេះដែរ ។ នៅក្រោមច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អង្គជំនុំជម្រះវិសាមញ្ញអាចកាត់ទោសជនសង្ស័យពីបទឧក្រិដ្ឋកម្មក្នុងស្រុកដូចជា មនុស្សឃាត ការធ្វើទារុណកម្ម និងការធ្វើទុក្ខបុកម្នេញលើសាសនា ក្រោមក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ ក៏ដូចជាឧក្រិដ្ឋកម្មអន្តរជាតិមួយចំនួនរួមមាន ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩ អនុសញ្ញាទីក្រុងឡាអេ ឆ្នាំ១៩៥៤ សម្រាប់កាត់ទោសការបំផ្លាញសម្បត្តិវប្បធម៌ក្នុងព្រឹត្តិការណ៍ជម្លោះប្រដាប់អាវុធ និងអនុសញ្ញាទីក្រុងវីយែន ឆ្នាំ១៩៦១ ស្តីពីទំនាក់ទំនងការទូត ។



ប្រជាជនរង់ចាំចូលក្នុងបន្ទប់សវនាការនៃអង្គជំនុំជម្រះវិសាមញ្ញ

### តុល្យភាពនៃឥទ្ធិពលទៅលើតុលាការ

លទ្ធផលនៃការចរចាបានបំពេញទៅតាមការចង់បានរបស់រាជរដ្ឋាភិបាលកម្ពុជា ដោយឲ្យមានចំនួនចៅក្រមជាតិច្រើនជាងនៅក្នុងតុលាការចម្រុះមួយនេះ ។ នឹងមានតុលាការពីរថ្នាក់នៅក្នុងប្រព័ន្ធតុលាការកម្ពុជាដែលមានស្រាប់ ៖ សាលាដំបូងនិងសាលាឧទ្ធរណ៍ ។ សាលាដំបូងរួមមានចៅក្រមកម្ពុជាបីរូបនិងចៅក្រមបរទេសពីររូប ហើយសាលាឧទ្ធរណ៍មានចៅក្រមកម្ពុជា៤រូបនិងចៅក្រមបរទេស៣រូប ។ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមនឹងធ្វើការតែងតាំងចៅក្រមកម្ពុជានិងចៅក្រមអន្តរជាតិទាំងអស់ដែលផ្តល់ឲ្យដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ ។ តុលាការទាំងពីរថ្នាក់នេះនឹងធ្វើសេចក្តីសម្រេចដោយផ្អែកលើមតិភាគច្រើនដាច់ខាត ហើយតម្រូវឲ្យមានការបោះឆ្នោតយល់ព្រមពីចៅក្រម៤រូបយ៉ាងតិចនៅក្នុងសាលាដំបូង និង៥រូបយ៉ាងតិចនៅក្នុងសាលាឧទ្ធរណ៍ ។ បទប្បញ្ញត្តិមតិភាគច្រើនដាច់ខាតធានាបញ្ចៀសការគ្រប់គ្រងរបស់ភាគីអន្តរជាតិទៅលើការកាត់សេចក្តី ប៉ុន្តែវាក៏បានធានាផងដែរថា ការសហការគ្នារវាងចៅក្រមអន្តរជាតិនិងចៅក្រមកម្ពុជារួមគ្នាតែមួយមិនអាចសម្រេចទៅលើដីកាណាមួយបានឡើយ ។ អំណាចរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការតែងតាំងចៅក្រមអន្តរជាតិ បានបន្ថែមសមត្ថភាពរបស់រាជរដ្ឋាភិបាលក្នុងការជះឥទ្ធិពលទៅលើបុគ្គលពាក់ព័ន្ធ ។

រាជរដ្ឋាភិបាលកម្ពុជាក៏បានគ្រប់គ្រងអង្គភាពមួយចំនួននៅក្នុងអង្គជំនុំជម្រះវិសាមញ្ញ ។ អង្គបុរេជំនុំជម្រះរួមមានចៅក្រមខ្មែរ៣រូប តែងតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដែលក្នុងនោះ មួយរូបធ្វើជាប្រធាននិងចៅក្រមអន្តរជាតិ២រូប តែងតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម បន្ទាប់ពីមានការចាត់តាំងពីអគ្គលេខាធិការអង្គការសហប្រជាជាតិ ។ អង្គបុរេជំនុំជម្រះមានភារកិច្ចដោះស្រាយរាល់ជម្លោះទាំងឡាយដែលកើតមានរវាងសហព្រះរាជអាជ្ញានិងសហចៅក្រមស៊ើបអង្កេត ។ ប្រធានការិយាល័យរដ្ឋបាលគឺជាជនជាតិខ្មែរតែងតាំងដោយរាជរដ្ឋាភិបាលកម្ពុជាដែលជាអ្នកមានតួនាទីគ្រប់គ្រងកិច្ចការទូទៅលើការិយាល័យនេះ ។ ការិយាល័យរដ្ឋបាលរួមមានអនុប្រធានម្នាក់តែងតាំងដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ ។ អនុប្រធានការិយាល័យរដ្ឋបាលមានតួនាទីជ្រើសរើសបុគ្គលិកផ្នែកអន្តរជាតិនិងកិច្ចការរដ្ឋបាលទាំងអស់នៃផ្នែកអន្តរជាតិនៃសាលាក្តីខ្មែរក្រហមនេះ ។ ភារកិច្ចនៃការ

ចោទប្រកាន់នឹងត្រូវបានដាក់ដោយឡែកនៅក្នុងការិយាល័យអយ្យការដែលរួមមាន សហព្រះរាជអាជ្ញា២រូប (អន្តរជាតិមួយរូបនិងកម្ពុជាមួយរូប) ។ អគ្គលេខាធិការអង្គការសហប្រជាជាតិបានចាត់តាំងបុគ្គលពីររូប ហើយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមបានតែងតាំងសហចៅក្រមស៊ើបអង្កេតអន្តរជាតិមួយរូបនិងសហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុងមួយរូបទៀត ។ រាជរដ្ឋាភិបាលកម្ពុជាក៏បានធ្វើការតែងតាំងសហព្រះរាជអាជ្ញាកម្ពុជាផងដែរ ។ សហព្រះរាជអាជ្ញានឹងជួយក្នុងការស៊ើបអង្កេត និងរៀបចំដីកាចោទប្រកាន់ប្រឆាំងនឹងជនទាំងឡាយណាដែលត្រូវបានសង្ស័យថា បានប្រព្រឹត្តបទឧក្រិដ្ឋដែលមានចែងនៅក្នុងច្បាប់ ។ ចៅក្រមស៊ើបអង្កេតជាតិនិងអន្តរជាតិក៏នឹងធ្វើការនៅក្នុងតុលាការនេះដែរ ។ អគ្គលេខាធិការអង្គការសហប្រជាជាតិបានចាត់តាំងបុគ្គលពីររូបសម្រាប់តំណែងសហព្រះរាជអាជ្ញាអន្តរជាតិ ។ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមបានតែងតាំងសហព្រះរាជអាជ្ញាអន្តរជាតិមួយរូបនិងសហព្រះរាជអាជ្ញាអន្តរជាតិបម្រុងមួយរូប ។

នៅក្នុងហេតុការណ៍ដែលសហព្រះរាជអាជ្ញានិងសហចៅក្រមស៊ើបអង្កេត មិនអាចឈានដល់កិច្ចព្រមព្រៀង ថាតើត្រូវបន្តការស៊ើបអង្កេតឬការកាត់សេចក្តី អង្គបុរេជំនុំជម្រះអាចដោះស្រាយវិវាទទាំងនេះ ដោយតម្រូវឲ្យមានការបោះឆ្នោតយល់ព្រមដោយមតិភាគច្រើនពីចៅក្រមយ៉ាងតិច៤រូប ។ សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះមិនអាចប្តឹងឧទ្ធរណ៍បានទេ ។ ការស៊ើបអង្កេតនិងការកាត់សេចក្តីនឹងបន្តដំណើរទៅមុខ ប្រសិនបើគ្មានការយល់ព្រមពីមតិភាគច្រើន ។ សេចក្តីលម្អិតស្តីអំពីសមាសភាពតុលាការនិងច្បាប់នីតិវិធីនឹងមានរៀបរាប់ក្នុងជំពូកទី៣ ។

## ស្វែងយល់ពីលទ្ធផលនៃការចរចា

ទោះបីជាភាគីអង្គការសហប្រជាជាតិមានឥទ្ធិពលខ្លាំងទៅលើការកាត់សេចក្តី ក៏រចនាសម្ព័ន្ធរបស់តុលាការលម្អៀងទៅខាងរាជរដ្ឋាភិបាលកម្ពុជា ។ ទោះបីជាអង្គការសហប្រជាជាតិបានទាមទារយ៉ាងខ្លាំងក្លាដើម្បីឲ្យតុលាការនេះអនុលោមទៅតាមបទដ្ឋានស្តង់ដារអន្តរជាតិក្នុងការសម្រេចឲ្យបាននូវការទទួលខុសត្រូវនិងការកាត់ទោសដោយយុត្តិធម៌យ៉ាងណាក៏ដោយ ក៏រាជរដ្ឋាភិបាលកម្ពុជានៅតែរក្សាជំហររបស់ខ្លួនមិនឲ្យអន្តរជាតិគ្រប់គ្រងភាគច្រើនទៅលើតុលាការនេះដែរ ។ យោងតាមក្រុមអ្នករិះគន់ ការស្នើសុំជំនួយជំហរពីអង្គការសហប្រជាជាតិរបស់សម្តេច ហ៊ុន សែន ដើម្បីកាត់ទោសការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរពីអតីតកាល គឺគ្រាន់តែជាយុទ្ធសាស្ត្រក្នុងការដាក់សម្ពាធទៅលើក្រុមខ្មែរក្រហមឲ្យចុះចាញ់និងចូលរួមជាមួយគណបក្សប្រជាជនកម្ពុជាប៉ុណ្ណោះ ។ នៅពេលគោលដៅនេះបានសម្រេច សម្តេចនាយករដ្ឋមន្ត្រីបានងាកមកគ្រប់គ្រងលើដំណើរការចរចាវិញ ។ យុទ្ធសាស្ត្រពន្យារពេលភាពមិនច្បាស់លាស់ និងការបញ្ចុះបញ្ចូលបានអនុញ្ញាតឲ្យភាគីកម្ពុជា គ្រប់គ្រងបានស្ទើរតែគ្រប់ចំណុចទាំងអស់នៃដំណើរការកាត់ក្តីរបស់តុលាការនេះ ។ ការរិះគន់ទៅលើតុល្យភាពនៃឥទ្ធិពលរបស់រាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិចំពោះតុលាការគឺទាក់ទងនឹងការដឹងឮទាំងក្នុងស្រុកនិងអន្តរជាតិអំពីជំហររបស់សម្តេច ហ៊ុន សែន និងរដ្ឋាភិបាលដែលគ្រប់គ្រងដោយគណបក្សប្រជាជនកម្ពុជា នៅទីក្រុងភ្នំពេញ ។ អ្នកសង្កេតការណ៍កម្ពុជានិងបរទេសភាគច្រើនគាំទ្រចំពោះការកាត់ទោសមេដឹកនាំខ្មែរក្រហមមួយចំនួន ប៉ុន្តែក្រុមអ្នកប្រឆាំងគណបក្សប្រជាជនកម្ពុជាមានការប្រយ័ត្នប្រយែងក្នុងការផ្តល់ឲ្យរាជរដ្ឋាភិបាលកម្ពុជានូវការគ្រប់គ្រងនូវផ្នែកជាច្រើន ឬឱកាសច្រើនដើម្បីទាញយកប្រយោជន៍នយោបាយ ។ និយាយម្យ៉ាងទៀត ភាពមិនច្បាស់លាស់របស់រាជរដ្ឋាភិបាលកម្ពុជានិងគោលគំនិតផ្ទុយគ្នាស្តីអំពីតុលាការចម្រុះបានធ្វើឲ្យអានុភាពនៃការចរចារបស់អង្គការសហប្រជាជាតិថយចុះ និងចេញជាលទ្ធផលមួយ ដែលរដ្ឋាភិបាលបរទេសជាច្រើនមិនសូវមានសុទិដ្ឋិនិយម ។ រដ្ឋាភិបាលទាំងឡាយ នៅអឺរ៉ុបខាងជើងមានការមិនពេញចិត្តយ៉ាងខ្លាំងចំពោះតុលាការដែលមានលក្ខណៈក្នុងស្រុកច្រើន ហើយរដ្ឋាភិបាលអឺរ៉ុបខាងលិចភាគច្រើនបានធ្វើអនុបវាទលើការបោះឆ្នោតរបស់មហាសន្និបាតអង្គការសហប្រជាជាតិដើម្បីអនុម័តលើកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជានៅចុងឆ្នាំ២០០២ ។ បារាំងនិងរុស្ស៊ី ក៏បានបង្ហាញជំហរមិនច្បាស់លាស់នៅក្នុងក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ។ ដោយបង្ហាញជំហរមិនច្បាស់លាស់របស់ខ្លួនចំពោះដំណើរការនេះ ប្រទេសមហាអំណាចបានលុបចោលលទ្ធភាពក្នុងការបង្កើតតុលាការនេះ ។ នៅក្នុងសហរដ្ឋអាមេរិក ទោះជាមាន

ការគាំទ្រច្រើនពីសាធារណៈមតិ ក៏សមាជិកសភាដែលមានឥទ្ធិពលជាច្រើនបានជំទាស់ទៅនឹងដំណើរការនេះដោយអះអាងថាសម្តេច ហ៊ុន សែន និងគណបក្សប្រជាជនកម្ពុជាហាក់ដូចជាទទួលរងការរិះគន់ច្រើនជាង"ក្រុមមេដឹកនាំខ្មែរក្រហមចាស់ជរាមួយក្តាប់តូច" ។ អាទិភាពនយោបាយក្រៅប្រទេសផ្សេងទៀតក៏បានធ្វើឲ្យមន្ត្រីជាន់ខ្ពស់ អាមេរិកជាច្រើនទៀតមានការខ្វល់ខ្វាយផងដែរ ហើយប្រធានបទស្តីអំពីសិទ្ធិមនុស្សមិនសូវជាលេចធ្លោទេនៅក្រោមរដ្ឋបាលប្រធានាធិបតី ហ្សកដាប់បែលយូ ប៊ូស ពោលគឺមិនដូចនៅក្រោមរដ្ឋបាល ប្រធានាធិបតី គ្លីនតុន ឡើយ ។ នៅពេលសហរដ្ឋអាមេរិកធ្វើអន្តរាគមន៍ សកម្មជនសិទ្ធិមនុស្សនិងអង្គការក្រៅរដ្ឋាភិបាលមួយចំនួនបានអះអាងថា អន្តរាគមន៍ជាឯកតោភាគីរបស់សហរដ្ឋអាមេរិកបានបំផ្លាញដល់កិច្ចខិតខំប្រឹងប្រែងរបស់ក្រុមអ្នកច្បាប់អង្គការសហប្រជាជាតិ ដោយធ្វើឲ្យមានការចាប់អារម្មណ៍ថាអង្គការសហប្រជាជាតិមិនមែនជាតំណាងអ្នកចរចាតែមួយគត់របស់ប្រទេសលោកខាងលិចដ៏មានឥទ្ធិពលទេ ។

សម្ពាធនយោបាយក្នុងតំបន់ក៏បានបន្ថយឥទ្ធិពលរបស់មន្ត្រីអង្គការសហប្រជាជាតិ ក្នុងការចរចាបង្កើតអង្គជំនុំជម្រះវិសាមញ្ញទៅតាមលក្ខខណ្ឌទាមទាររបស់ខ្លួន ។ ចិនមានការប្រយ័ត្នប្រយែងជាពិសេសចំពោះការបង្កើតសាលាក្តីខ្មែរក្រហម ដោយបានរាំងខ្ទប់ការចូលរួមរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិជាច្រើនលើក ។ រដ្ឋាភិបាលចិនបានប្រកាសជាសាធារណៈថាប្រធានបទខ្មែរក្រហម គឺជាបញ្ហាផ្ទៃក្នុងរបស់កម្ពុជា ដោយនិយាយថា ចិនមើលឃើញការបង្កើតតុលាការនេះថា ជាការជ្រៀតជ្រែករបស់លោកខាងលិចទៅក្នុងនយោបាយក្នុងស្រុករបស់កម្ពុជា ។ ក្រុមអ្នករិះគន់បានអះអាងថា ចិនមានហេតុផលជាក់លាក់ ដោយភ័យខ្លាចថាការកាត់ក្តីនឹងនាំដល់ការចាប់អារម្មណ៍ពីការគាំទ្ររបស់ចិនទៅលើរបបកម្ពុជាប្រជាធិបតេយ្យ ភាពប្រហាក់ប្រហែលគ្នារវាងមនោគមវិជ្ជាខ្មែរក្រហមនិងមនោគមវិជ្ជាម៉ៅ និងការអនុវត្តសិទ្ធិមនុស្សរបស់ចិន ។ ប្រទេសអាស៊ីអាគ្នេយ៍មួយចំនួនបានបង្ហាញទស្សនៈរបស់ខ្លួនថា ការកាត់សេចក្តីនេះគឺជាបញ្ហាក្នុងស្រុករបស់កម្ពុជា ហើយប្រទេសទាំងនេះផ្តល់អាទិភាពទៅលើទំនាក់ទំនងសេដ្ឋកិច្ចនិងសន្តិសុខនាពេលបច្ចុប្បន្នជាមួយរដ្ឋាភិបាលក្រុងភ្នំពេញជាង ។ បញ្ហានេះបានជួយពន្យល់អំពីមូលហេតុដែលវៀតណាម (សត្រូវដ៏ជូរចត់របស់ខ្មែរក្រហមនិងជាមិត្តជិតស្និទ្ធរបស់គណបក្សប្រជាជនកម្ពុជា) មានការស្ងៀមស្ងាត់ចំពោះបញ្ហានេះ ។

## សេចក្តីបញ្ចប់ ៖ ប្រតិកម្មពីក្រុមអ្នករិះគន់និងអ្នកគាំទ្រ

កម្លាំងនយោបាយអន្តរជាតិដែលបានរៀបរាប់ពីខាងដើមបានរាំងខ្ទប់អង្គការសហប្រជាជាតិ ឬប្រទេសមហាអំណាចមិនឲ្យមានលទ្ធភាពក្នុងការដាក់សម្ពាធឲ្យបានគ្រប់គ្រាន់ ដើម្បីធានាឲ្យបាននូវការគ្រប់គ្រងរឹងមាំពីអន្តរជាតិទៅលើដំណើរការកាត់សេចក្តីនៃសាលាក្តីខ្មែរក្រហមនេះ ។ លទ្ធផលគឺ តុលាការចម្រុះដែលអ្នកតស៊ូមតិផ្នែកសិទ្ធិមនុស្សជាច្រើនយល់ឃើញថា ជាបរាជ័យនៃយុត្តិធម៌កម្រិតស្តង់ដារអន្តរជាតិ ភាពត្រឹមត្រូវ និងបទដ្ឋានច្បាប់ ។ ឧទាហរណ៍ របាយការណ៍សង្ខេបរបស់អង្គការឃ្លាំមើលសិទ្ធិមនុស្ស បានចាត់ទុកតុលាការនេះថាមាន"គុណវិបត្តិខ្លាំង" ដោយសង្កត់ធ្ងន់ថា មន្ត្រីរាជរដ្ឋាភិបាលកម្ពុជាមានឥទ្ធិពលខ្លាំងក្នុងការជ្រៀតជ្រែកទៅលើកិច្ចការរបស់តុលាការ ។ ជាងនេះទៅទៀត តុលាការនេះមិនបានបញ្ជាក់ច្បាស់លាស់អំពីនីតិវិធីបទដ្ឋានជាច្រើនដែលមានចែងនៅក្នុងច្បាប់ ហើយសេចក្តីព្រាងច្បាប់មិនមានចែងបទប្បញ្ញត្តិស្តីអំពីសំណងចំពោះជនរងគ្រោះ ឬចំណាត់ការក្នុងការកសាងសមត្ថភាពដែរ ។

ក្នុងរយៈកាលនៃការចរចា អង្គការសហប្រជាជាតិមានការតាំងចិត្តក្នុងការរក្សាឲ្យបានថា តុលាការដែលនឹងត្រូវបង្កើតឡើងដើម្បីកាត់សេចក្តីមេដឹកនាំខ្មែរក្រហមនឹងត្រូវតែអនុលោមទៅតាមបទដ្ឋានច្បាប់កម្រិតខ្ពស់បំផុត ។ ទោះជាយ៉ាងនេះក្តីជម្លោះនៅកម្ពុជារក្សាបាននូវគោលដៅរបស់ខ្លួនស្ទើរតែគ្រប់ចំណុចរបត់ទាំងអស់ ។ យោងតាមអ្នកសង្កេតការណ៍មួយចំនួនថា សម្បទានរបស់សហគមន៍អន្តរជាតិបានធ្វើឲ្យលេចឡើងនូវតុលាការមួយ ដែលមិនច្បាស់លាស់ ។ ដោយបង្ហាញពីការមិនពេញចិត្តចំពោះទម្រង់របស់តុលាការ លោក កូហ្វី អាណាន់ អគ្គលេខាធិការអង្គការសហប្រជាជាតិបាននិយាយនៅក្នុងរបាយការណ៍ឆ្នាំ២០០៣ ទៅកាន់មហាសន្និបាតថា ៖ មានបញ្ហាជាបន្តបន្ទាប់ទាក់ទិនទៅនឹងនីតិវិធីច្បាប់និងការប្រព្រឹត្តរបស់តុលាការនៅកម្ពុជា ដែលជាលទ្ធផល

នៃការជ្រៀតជ្រែកពីសំណាក់អំណាចនីតិប្រតិបត្តិទៅលើឯករាជ្យភាពនៃអំណាចតុលាការ ។ ខ្ញុំចង់បានជាពិសេសថា សេចក្តីព្រាងកិច្ចព្រមព្រៀងសម្រាប់តុលាការទាំងពីរថ្នាក់នៃអង្គជំនុំជម្រះវិសាមញ្ញនឹងមានចៅក្រមអន្តរជាតិភាគច្រើន...។ វានៅតែមានមន្ទិលសង្ស័យនៅឡើយទៅលើបញ្ហាថា តើបទប្បញ្ញត្តិនៅក្នុងសេចក្តីព្រាងកិច្ចព្រមព្រៀងស្តីអំពីរចនាសម្ព័ន្ធនិងការចាត់តាំងរបស់អង្គជំនុំជម្រះវិសាមញ្ញនឹងធានាឲ្យបានពេញលេញនូវភាពដែលអាចជឿទុកចិត្តបានរបស់សាលាក្តីនេះ ដោយសារតែភាពមិនច្បាស់លាស់របស់អំណាចតុលាការនៅកម្ពុជា...។ រាល់ការផ្លាស់ប្តូរទាំងឡាយរបស់រាជរដ្ឋាភិបាលកម្ពុជាចំពោះកាតព្វកិច្ចរបស់ខ្លួនអាចនាំដល់ការដកខ្លួនចេញរបស់អង្គការសហប្រជាជាតិពីកិច្ចសហប្រតិបត្តិការនិងដកជំនួយទាំងអស់ចេញពីដំណើរការនេះ ។

ក្រុមអ្នករិះគន់បានចោទប្រកាន់ថា ប្រសិនបើតុលាការមិនធ្វើការផ្លាស់ប្តូររចនាសម្ព័ន្ធនិងបច្ចេកទេសជាមូលដ្ឋានទេនោះ តុលាការនេះនឹងស្ថិតនៅក្រោមបញ្ជារបស់សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ។ អ្នកទាំងនេះនិយាយថា តុលាការនឹងមានភាពលម្អៀង ហើយការធ្វើសេចក្តីសម្រេចចិត្តនឹងត្រូវធ្វើឡើងតាមការចង់បានរបស់អ្នកនយោបាយនាពេលបច្ចុប្បន្ន ។ អ្នកវិភាគភាគច្រើនជឿជាក់ថា អំណាចនីតិប្រតិបត្តិនៅតែបន្តគ្រប់គ្រងយ៉ាងខ្លាំងក្លាទៅលើប្រព័ន្ធតុលាការកម្ពុជា ។ ក្រុមអ្នករិះគន់រដ្ឋាភិបាលដែលដឹកនាំដោយគណបក្សប្រជាជនបានអះអាងថា ការតែងតាំងចៅក្រមកាត់ក្តីកម្ពុជាចំនួនភាគច្រើនទាំងនៅក្នុងសាលាដំបូងនិងសាលាឧទ្ធរណ៍នឹងធ្វើឲ្យគណបក្សប្រជាជនកម្ពុជាកាន់តែមានឱកាសនយោបាយច្រើនក្នុងការជះឥទ្ធិពលទៅលើការកាត់សេចក្តីនេះ ។ ក៏មានការខ្វល់ខ្វាយដូចគ្នាផងដែរចំពោះការតែងតាំងសហព្រះរាជអាជ្ញានិងសហចៅក្រមស៊ើបអង្កេតកម្ពុជា ។ លោក *Mike Jendrzejczyk* នាយកអង្គការឃ្លាំមើលសិទ្ធិមនុស្សប្រចាំទ្វីបអាស៊ីបានអះអាងថា "ដោយសារតុលាការនេះស្ថិតនៅក្នុងប្រព័ន្ធតុលាការកម្ពុជា កិច្ចព្រមព្រៀងបានបង្ហាញច្បាស់ថា នយោបាយមិនមែនច្បាប់ទេដែលគ្រប់គ្រងលើកិច្ចការរបស់តុលាការ" ។

អង្គការសង្គមស៊ីវិលនៅកម្ពុជា និងក្រុមគណបក្សប្រឆាំងតែងតែបានធ្វើសេចក្តីថ្លែងការណ៍ជាសាធារណៈនៅក្នុងអំឡុងពេលនៃការចរចាដោយអះអាងថា ខ្លួនគាំទ្រចំពោះការស្វែងរកយុត្តិធម៌ពីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ ប៉ុន្តែ ដោយសារការចូលរួមរបស់អន្តរជាតិក្នុងដំណើរការកាត់សេចក្តី ដើរតួនាទីតិចជាងអ្វីដែលអ្នកសង្កេតការណ៍ភាគច្រើនបានរំពឹងទុកពីខាងដើមថា ក្រុមគណបក្សប្រឆាំងទាំងនេះត្រូវតែបង្ខំចិត្តគាំទ្រដំណើរការមួយដែលមនុស្សជាច្រើនមើលឃើញថាជាលទ្ធផលប្រកបដោយគុណវិបត្តិនៃអំណាចនយោបាយ ។ តាមពិត ក្រុមអ្នករិះគន់ជាច្រើនជឿជាក់ថា ការខិតខំប្រឹងប្រែងរបស់សម្តេច ហ៊ុន សែន ក្នុងការបង្កើតសាលាក្តីនេះ គឺជាមហិច្ឆតារបស់គាត់ក្នុងការការពារថ្នាក់ដឹកនាំបក្សនិងដើម្បីក្លាយទៅជាជើងឯកដែលបានផ្តួលរំលំខ្មែរក្រហម ។

អ្នកគាំទ្រសាលាក្តីនេះទទួលស្គាល់ថា មានភាពទន់ខ្សោយ ប៉ុន្តែអះអាងថា ការលុបបំបាត់ការចូលរួមរបស់ភាគីកម្ពុជាក្នុងតុលាការនេះ គឺជាការបដិសេធនូវតួនាទីដ៏មានអត្ថន័យនៅក្នុងដំណើរការផ្សះផ្សាជាតិនៃប្រទេសរបស់ខ្លួន ។ ក្រុមអ្នកគាំទ្រតុលាការក៏ចង់ឲ្យមានការចូលរួមយ៉ាងសកម្មពីអង្គការសង្គមស៊ីវិលនិងពីប្រជាជនអាចជួយកាត់បន្ថយអំពើពុករលួយដែលអាចកើតមានបង្កើនសមត្ថភាពបុគ្គលិកតុលាការក្នុងស្រុក និងផ្តល់ការធានាថា ការកាត់ក្តីនឹងអនុលោមទៅតាមស្តង់ដាច្បាប់អន្តរជាតិ ។ ទោះជាយ៉ាងណាក្តី បរាជ័យក្នុងបង្កើតឲ្យមានការកាត់ក្តីនឹងបង្ហាញឲ្យឃើញថា ជនដែលទទួលខុសត្រូវចំពោះការរំលោភយ៉ាងធ្ងន់ធ្ងរលើច្បាប់មនុស្សធម៌អន្តរជាតិ នឹងរស់នៅដោយគ្មានការទទួលខុសត្រូវចំពោះអំពើដែលខ្លួនបានប្រព្រឹត្ត ហើយនេះគឺ ជាសោកនាដកម្មនៃច្បាប់អន្តរជាតិ កេរ្តិ៍ឈ្មោះរបស់អង្គការសហប្រជាជាតិ និងជាសោកនាដកម្មសម្រាប់កិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជាដើម្បីបិទទំព័រប្រវត្តិសាស្ត្ររបបខ្មែរក្រហម ។

**ខែលី ឌ៉ាយលី**

# ពាក្យស្លោកខ្មែរក្រហម

- **ត្រូវមានស្មារតីរក្សាការសម្ងាត់ខ្ពស់។**

*(សៀវភៅកំណត់ហេតុលេខ១០ ៧/៧)*

# ឪពុកម្តាយរបស់ខ្ញុំក្នុងរបបខ្មែរក្រហម

ឪពុករបស់ខ្ញុំជាអ្នកស្រុកគីរីវង្ស ខេត្តតាកែវ ។ គាត់គឺជាកូនច្បងនិងជាអ្នកដែលបានទទួលការរៀនសូត្រច្រើនជាងគេ ។ ក្នុងឆ្នាំ១៩៧០ ឪពុកខ្ញុំនិងគ្រួសារ បានចាកចេញពីភូមិកំណើតមករស់នៅទីក្រុងភ្នំពេញជាមួយឪពុកមាដើម្បីបន្តការសិក្សាវិជ្ជាជីវៈគ្រូពេទ្យ ។ ចំណែកម្តាយរបស់ខ្ញុំមានដើមកំណើតនៅសង្កាត់លេខ៥ (សព្វថ្ងៃសង្កាត់បឹងត្របែក) ទីក្រុងភ្នំពេញ ។ នៅក្នុងឆ្នាំ១៩៧៤ គាត់ទាំងពីរបានរៀបការនិងរស់នៅជួបជុំគ្នា ។ ហេតុការណ៍នេះ បានធ្វើឲ្យក្រុមគ្រួសារទាំងមូលមានសភាពកាន់តែសប្បាយរីករាយថែមទៀត ។ ទោះជាយ៉ាងនេះក្តី ភាពសប្បាយរីករាយនេះ ត្រូវរលត់បាត់ទៅវិញក្នុងរយៈពេលតែមួយប៉ព្រិចភ្នែក ដោយសាររបបខ្មែរក្រហម ។



ក្រុមគ្រួសាររបស់ ជុំ ចរិយា ក្នុងទសវត្សរ៍ឆ្នាំ១៩៩០

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ សមាជិកគ្រួសារខ្ញុំទាំងអស់ត្រូវបានខ្មែរក្រហមជម្លៀសចេញពីផ្ទះសម្បែងទៅកាន់ភូមិស្តុកខ្លា ឃុំរំលេច ស្រុកបាកាន ខេត្តពោធិសាត់ ។ ឪពុកម្តាយខ្ញុំ ត្រូវអង្គការដាក់ឲ្យនៅកន្លែងខុសគ្នានិងបង្ខំឲ្យធ្វើការងារធ្ងន់ៗ ដោយមិនមានអាហារបរិភោគគ្រប់គ្រាន់ ។ ពេលនោះម្តាយខ្ញុំត្រូវបានបញ្ចូលទៅក្នុងកងពិសេស ។ កងរបស់គាត់ត្រូវធ្វើការងារដូចជាលើកទំនប់ជីកប្រឡាយ និងធ្វើស្រែចម្ការ ។ ម្តាយខ្ញុំ និងមិត្តភក្តិប្រាំពីរនាក់ត្រូវអង្គការតម្រូវឲ្យស្ទូងស្រូវឲ្យបានមួយហិកតា ក្នុងមួយថ្ងៃ ។ ក្រុមរបស់គាត់ធ្វើការតាំងពីព្រឹករហូតដល់ល្ងាចដោយសម្រាកហូបបបរតែពេលថ្ងៃត្រង់មួយភ្លែតប៉ុណ្ណោះ ។ ម្តាយខ្ញុំត្រូវបានផ្លាស់ឲ្យទៅធ្វើការជាច្រើនកន្លែង ។ ដោយសារការនឿយហត់នឹងការងារនិងការស្រេកឃ្លានពេលខ្លះម្តាយខ្ញុំបានរើសគ្រាប់ពោតនៅតាមផ្លូវហូប ។ ជួនកាល គាត់ហែកខ្នើយដើម្បីយកគ្រាប់គមកលីងហូប ហើយជួនកាលគាត់បានផឹកទឹកតាមដានជើងក្របីទៀតផង ។

ចំណែកឪពុកខ្ញុំវិញនៅឯសមរភូមិក្រោយ ។ គាត់ត្រូវបានបង្ខំឲ្យធ្វើការធ្ងន់ដូចម្តាយរបស់ខ្ញុំដែរ ។ ជារៀងរាល់ថ្ងៃ ឪពុកខ្ញុំត្រូវទៅលើកទំនប់ ភ្ជួររាស់ និងស្ទូង ។ ឪពុកខ្ញុំខស្សប្រាហ៍ឈឺណាស់ ។ ទោះជាយ៉ាងនេះក្តី ខ្មែរក្រហមមិនអនុញ្ញាតឲ្យគាត់សម្រាក ឬឲ្យថ្នាំព្យាបាលទេ ។ ឈ្លបខ្មែរក្រហមតែងតែសួរនាំពីប្រវត្តិរូបនិងប្រវត្តិរៀនសូត្ររបស់ឪពុកខ្ញុំ ប៉ុន្តែគាត់តែងតែឆ្លើយថា គាត់ជាកម្មករធ្វើការឲ្យគេ ។ សំណាងល្អ ឪពុកខ្ញុំបានរួចផុតពីសេចក្តីស្លាប់ ព្រោះទាំងគាត់ទាំងម្តាយខ្ញុំបានឆ្លើយនូវចម្លើយដដែលថា គាត់ជាកម្មករធ្វើការឲ្យគេតែប៉ុណ្ណោះ ។

នៅក្នុងរបបខ្មែរក្រហម គ្រប់គ្រួសារទាំងអស់យ៉ាងហោចណាស់ក៏មានសមាជិកម្នាក់ស្លាប់ឬបាត់ខ្លួនដែរ ។ ក្រុមគ្រួសាររបស់ម្តាយខ្ញុំ នៅពេលជម្លៀសទៅមានគ្នា១១នាក់ ។ ប៉ុន្តែពេលត្រឡប់មកវិញ សមាជិកគ្រួសាររបស់គាត់នៅសល់តែ៤នាក់ប៉ុណ្ណោះ គឺឪពុកម្តាយខ្ញុំ ជីដូនខ្ញុំ និងពូរបស់ខ្ញុំ ។ ក្រៅពីនោះ បានស្លាប់ដោយការសម្លាប់និងការអត់ឃ្លាន ។ ខ្ញុំសង្ឃឹមជឿជាក់ថា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (សាលាជំនុំជម្រះក្តីខ្មែរក្រហម) នឹងនាំយកមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមមកកាត់ទោសប្រកបដោយយុត្តិធម៌និងតម្លាភាពដើម្បីព្យាបាលរបួសផ្លូវចិត្តរបស់ជនរងគ្រោះ ដែលមិនទាន់ទទួលបានការព្យាបាលអស់រយៈពេលជិត៣០ឆ្នាំមកហើយ ។

**ជុំ ចរិយា**

# សេចក្តីប្រកាសរកបងប្អូន៨នាក់

នាងខ្ញុំឈ្មោះ ផាច់ សាលី អាយុ៥៧ឆ្នាំ មានស្រុកកំណើតនៅសង្កាត់គីឡូម៉ែត្រលេខ៦ ភូមិស្ពានខ្ពស់ ខណ្ឌឫស្សីកែវ សព្វថ្ងៃរស់នៅទីក្រុងភ្នំពេញ ។ ឪពុកឈ្មោះ ផាច់ ឃៀច ជាអតីតទាហានសម័យសម្តេចឪ និងម្តាយឈ្មោះ លី ធីវ៉ាន់ ។ នាងខ្ញុំសូមស្វែររកបងប្អូន ប្រុសស្រីចំនួន៨នាក់ ដែលបែកគ្នាតាំងពីសម័យ ប៉ុល ពត ដែលមានឈ្មោះដូចជា ÷ ១) បងប្រុស ផាច់ មឿង ២) បងស្រី ផាច់ សារីម ៣) បងស្រី ផាច់ សារឿន ៤) ប្អូនប្រុស ផាច់ មារឌី ៥) ប្អូនប្រុស ផាច់ ឌ្រី ៦) ប្អូនប្រុស ផាច់ សុខា ៧) ប្អូនប្រុស ផាច់ សំអុល និង៨) ប្អូនប្រុស ផាច់ ពៅ ។

ប្រសិនបើបង-ប្អូនៗ បានឃើញប្រកាសនេះ ឬញាតិមិត្តណាបានស្គាល់ឈ្មោះខាងលើសូមទាក់ទងមក ឈ្មោះ លឹម ហុក ទូរស័ព្ទ លេខ ០១២ ៣០៩ ៩០៥ ឬតាមរយៈមជ្ឈមណ្ឌលឯកសារកម្ពុជាទូរស័ព្ទលេខ ៨៥៥ ០២៣ ២១១ ៨៧៥ ឬប្រអប់សំបុត្រ ១១១០ ភ្នំពេញ ។ សូមអរគុណ ។

# សេចក្តីប្រកាសរកឪពុកនិងប្អូនស្រី

នាងខ្ញុំឈ្មោះ កាន់ បូរីនីន សព្វថ្ងៃរស់នៅសហរដ្ឋអាមេរិកជាមួយម្តាយឈ្មោះ ឈុន បូរីន និងប្អូនស្រី៣នាក់ឈ្មោះ ១) កាន់ បូរីយ៉ាន ២) កាន់ ស្រីនូត និងទី៣) កាន់ ស្រីពៅ សូមស្វែររកឪពុក កាន់ បូ និងប្អូនស្រី កាន់ បុប្ផាគន្ធា ហៅ ស្រីអូន ដែលទើបមានអាយុ៦-៧ឆ្នាំ បានបែកគ្នានៅខេត្តបាត់ដំបងក្នុងឆ្នាំ១៩៧៩ ។ រយៈពេលពីរខែមុនពេលកងទ័ពវៀតណាមចូលទីក្រុងភ្នំពេញ អ្នកទាំងពីរត្រូវខ្មែរក្រហមជម្លៀសទៅភ្នំធិបតីក្នុងខេត្តបាត់ដំបង ។ ក្រោយមកឮដំណឹងថាលោកឪពុកមានជំងឺឫសដូងបាតរហូតដល់ធ្លាក់ឈាមមិនដឹងរស់ឬស្លាប់ ចំណែកប្អូនស្រី បុប្ផាគន្ធា គិតតែអង្គុយយំនិងរត់រកឲ្យអ្នកជិតខាងជួយ តាំងពីនោះមកខ្ញុំក៏លែងទទួលដំណឹងពីអ្នកទាំងពីរទៀត ។ បើប្អូនស្រី ឬបងប្អូនណាបានឮនិងស្គាល់ឈ្មោះទាំងពីរនេះ សូមជួយផ្តល់ដំណឹងឲ្យនាងខ្ញុំតាមរយៈមជ្ឈមណ្ឌលឯកសារកម្ពុជាប្រអប់សំបុត្រ ១១១០ ភ្នំពេញ ទូរស័ព្ទ លេខ ៨៥៥ ០២៣ ២១១ ៨៧៥ ។ សូមអរគុណ ។

# សេចក្តីប្រកាសរកឪពុកម្តាយនិងបងប្អូន៦នាក់

ខ្ញុំបាទឈ្មោះ ជា វណ្ណៈ ជាគ្រូបង្រៀននៅសាលាបឋមសិក្សារមូល ឃុំរអាង ស្រុកកំពង់សៀម ។ សព្វថ្ងៃខ្ញុំបាទរស់នៅភូមិអំពិល ឃុំអំពិល ស្រុកកំពង់សៀម ខេត្តកំពង់ចាម សូមស្វែររកឪពុកនិងបងប្អូន៦ នាក់ ទៀតដែលមានឈ្មោះដូចខាងក្រោមនេះ ÷

១) ឡាយ យូ អាយុប្រហែល៧៤ឆ្នាំ (ឪពុក) ២) ឡាយ ជី (ម្តាយ) ៣) ឡាយ យូវ៉ាន់ឌី ៤) ឡាយ សុរិប្រាសិទ្ធិ ៥) ឡាយ មុន្នីធីរិទ្ធិ ៦) ឡាយ សុគន្ធា ៧) ឡាយ សុជាតា និង៨) ឡាយ សុភាព ។

មុនឆ្នាំ១៩៧០ ក្រុមគ្រួសារខ្ញុំបាទរស់នៅទីក្រុងភ្នំពេញ ។ ឪពុកជាអតីតទាហានជំនាន់បារាំង ទាហានជំនាន់សម្តេច និងទាហានលន់នល់ ។ នៅឆ្នាំ១៩៧៥ ឪពុកម្តាយនិងបងប្អូនទាំង៦នាក់របស់ខ្ញុំបានធ្វើដំណើរទៅខេត្តតាកែវ ក្នុងគោលបំណងត្រឡប់ទៅស្រុកកំណើតនៅកម្ពុជាក្រោមវិញ ប៉ុន្តែតាំងពីពេលនោះមកក៏បាត់ដំណឹងមិនដឹងថាអ្នកទាំងអស់នៅរស់ឬស្លាប់ឡើយ ។

បើបងប្អូនណាស្គាល់ឬដឹងដំណឹងពីឈ្មោះខាងលើសូមមេត្តាជួយផ្តល់ដំណឹងតាមរយៈមជ្ឈមណ្ឌលឯកសារកម្ពុជាប្រអប់ សំបុត្រ ១១១០ ភ្នំពេញ ទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ដោយអនុគ្រោះ ។ សូមអរគុណ ។



បន្ទប់សម្រាប់ឃុំខ្លួនជនជាប់ចោទនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ឧបត្ថម្ភការបោះពុម្ពផ្សាយដោយរដ្ឋាភិបាល ដេនម៉ាក ន័រវេ ស៊ុីតដេន និងសហរដ្ឋអាមេរិក
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម/៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

**មជ្ឈមណ្ឌលឯកសារកម្ពុជា : ការិយាល័យព័ត៌មានសាធារណៈ**
ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ : (៨៥៥) ២៣ ២១០ ៣៥៨

DC-Cam/PIR : #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ Fax: (855) 23 210 358 ◆ dccam@online.com.kh ◆ www.dccam.org.
A magazine of the Documentation Center of Cambodia: Searching for the truth. ◆ Number 84, December 2006 ◆ Funded by Denmark, Norway, Sweden, and USA.
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.